# គិហិបដិបត្តិ

## ប្រស្នាត្រៃគុណសង្ខេប

មាឃបូជា - វិសាខបូជា

អាសាឡ្ហបូជា - អស្សយុជបូជា



វត្តខេមរង្សារាម

ទីក្រុងស៊ីដនីយ៍ ប្រទេសអូស្ត្រាលី

ព.ស ២៥៥៣ គ.ស. ២០០៩

ទំព័រដោយលោក ឃៀ ឃុនសុីវ៉ុនដល់កម្ពុជាខ្មែរ
ដើម្បីដាក់ក្នុង elibrary of Cambodia
កក្កដា 2015

# គិហិបដិបត្តិ

## ប្រស្នាត្រៃគុណសង្ខេប

**មាឃបូជា — វិសាខបូជា**

**អាសាឡ្ហបូជា — អស្សយុជបូជា**

ប្រមូលរៀបរៀងឡើងវិញដោយ


ភិក្ខុ វីរិយប្បិយោ ជួន ហ្វួត

ភិក្ខុ សុវណ្ណជោតោ ជា ពេជ្ជ



បោះពុម្ពចែកជាធម្មទាន ដោយពុទ្ធបរិស័ទ

**វត្តខេមរង្សារាម**

ទីក្រុងស៊ីដនីយ៍ ប្រទេសអូស្ត្រាលី

លើកទី ៣ ចំនួន ៣០០០ ក្បាល



**WATT KHEMARANGSARAM**
**68 TARLINGTON PARADE**
**BONNYRIGG N.S.W 2177**
**Tel: (02) 9823 6404**
**(AUSTRALIA)**



ព្រះគ្រូឥន្ទមេធោ ឡុង សាខន

ព្រះចៅអធិការ វត្តខេមរឧទ្យារាម

រដ្ឋញូវសោធវែល ទីក្រុងស៊ីដនីយ៍ ប្រទេសអូស្ត្រាលី

# អារម្ភកថា

យើងខ្ញុំបានរៀបរៀងអត្ថបទធម៌ផ្សេងៗ ដែលជាស្នាដៃរបស់លោកអ្នកប្រាជ្ញកវីនិពន្ធទាំងឡាយជំនាន់ដើម មានសម្ដេចព្រះមហាសុមេធាធិបតីព្រះសង្ឃរាជទី១ គណៈមហានិកាយ **(ជួន ណាត) ជោតញ្ញាណោ** ជាដើម យកមករៀបចំចងក្រង ឱ្យកើតជាសៀវភៅមួយឈ្មោះថា «**គិហិបដិបត្តិ**» ដើម្បីជាគុណប្រយោជន៍សំរាប់ពុទ្ធសាសនិកជនទូទៅ ក្នុងគោលបំណងជួយលើកស្ទួយព្រះពុទ្ធសាសនាឱ្យបានរុងរឿងចំរើន ជានិច្ចនិរន្តរ៍តរៀងទៅ ។

ជាពិសេសសៀវភៅនេះ នឹងអាចបោះពុម្ពផ្សព្វផ្សាយចែកជាធម្មទានទៅបាន គឺអាស្រ័យដោយមានការជួយឧបត្ថម្ភជ្រោមជ្រែងយ៉ាងខ្លាំងក្លា អំពីព្រះគ្រូធម្មមេធោ **ឡុង សាខន** ព្រះចៅអធិការ **វត្តខេមរង្សារាម** (BONNYRIGG) និងគណៈកម្មការអាចារ្យ ព្រមទាំងពុទ្ធបរិស័ទសប្បុរសជនខ្មែររដ្ឋញូវសោធវែល ទីក្រុងស៊ីដនីយ៍ ប្រទេសអូស្ត្រាលី ។

ក្នុងនាមយើងខ្ញុំ ជាអ្នករៀបរៀងចងក្រង ជាបែបបទសៀវភៅនេះ ឡើងកាន់កុំព្យូទ័រ សូមអភ័យទោសទុកជាមុន នូវរាល់កំហុសឆ្គងដោយអចេតនានូវអក្ខរាវិរុទ្ធ និងឃ្លាឃ្លោងក្នុងសៀវភៅនេះ ដូច្នេះយើងខ្ញុំសូមរង់ចាំជានិច្ចនូវរាល់ការរិះគន់ ដើម្បីស្ថាបនានឹងជួយកែលំអអំពីសំណាក់ពុទ្ធសាសនិកជនគ្រប់មជ្ឈដ្ឋាន ។

ដោយតេជានុភាពនៃការព្យាយាមចងក្រងសៀវភៅ «**គិហិបដិបត្តិ**» នេះ សូមឱ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឱ្យលោកទាំងមូលប្រកបដោយសន្តិភាព ។

គ្រូតពិនិត្យផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធ ផ្នែកភាសាបាលីនិងខេមរភាសា ដោយឧទ្ទេសាចារ្យ **ប្រាក់ ឃុន** គ្រូបង្ហាត់ភាសាបាលី ។

ឧទ្ទេសាចារ្យ **នេត ននៈ** គ្រូបង្ហាត់ភាសាបាលី នៅវត្តអារញ្ញិការាម កំពង់ឆ្នាំង ។

វត្តខេមរង្សារាម រដ្ឋញូវសោធវែល ទីក្រុងស៊ីដនីយ៍ ប្រទេសអូស្ត្រាលី
១៥ កើត ខែ ចេត្រ ព.ស. ២៥៥១
ត្រូវនឹងថ្ងៃចន្ទ ទី ២ ខែ មេសា គ.ស. ២០០៧

## សេចក្តីយល់ឃើញ

សៀវភៅដែលអស់លោកអ្នក កំពុងកាន់អាននេះ ដែលប្រមូលរៀបរៀងដោយៈ

ភិក្ខុ វីរិយប្បិយោ ជួន ហ្វួត

ភិក្ខុ សុវណ្ណជោតោ ខាំ ពេជ្ជ

មានគុណតម្លៃណាស់ គួរតែពុទ្ធសាសនិកជន ខំរករៀនអានឱ្យបានគ្រប់គ្នា ព្រោះជាស្នាដៃនិពន្ធ របស់លោកអ្នកប្រាជ្ញជំនាន់មុន ដែលមានព្រះកិត្តិនាមខ្ពង់ខ្ពស់បំផុត ដូចជាសម្តេចព្រះសង្ឃរាជ (ជួន ណាត) ជោតញ្ញាណោ ជាដើម ។

ខ្ញុំព្រះករុណាខ្ញុំ បានយកអស់កម្លាំងកាយចិត្ត ផ្ទៀងផ្ទាត់គ្រប់ឃ្លាបន្ទាត់ទាំងអស់គ្មានចន្លោះ ទាំងបាលីទាំងសម្រាយ រួចកែឱ្យត្រឹមត្រូវ ឱ្យមានភាពសុក្រឹតអស់ហើយ។

រាជធានីភ្នំពេញ, ថ្ងៃសុក្រ ៣រោច ខែស្រាពណ៍ ព.ស ២៥៥១

ត្រូវនឹងថ្ងៃទី ៣១ ខែសីហា គ.ស ២០០៧

ហត្ថលេខា

ឌិត ជន

សាស្ត្រាចារ្យបាលីសំស្ក្រឹតនៅពុទ្ធិកវិទ្យាល័យ

ព្រះសុរាម្រឹត និង ពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ

# មាតិកាធម៌

ឈ្មោះធម៌..........ទំព័រលេខ
អារម្ភកថា ..........ក
មាតិកាធម៌ ..........ខ

## ត្រៃប្រណាម

បទសរភញ្ញ វិសន្តតិលកា ..........២
សូមអញ្ជើញពពួកទេវតា ..........៣
រតនត្តបូជា (ឥមេហិ)..........៣
ពុទ្ធរតនប្បណាម ..........៤
ធម្មរតនប្បណាម ..........៨
សង្ឃរតនប្បណាម ..........១១
បណាមគាថា (យោ កប្បកោដីហិបិ) ..........១៥
រតនត្តយវន្ទនគាថា (ឥច្ចេវមច្ចន្ត) ..........១៦
ពុទ្ធបាទនមស្សការគាថា (វន្ទាមិ ពុទ្ធំ) ..........១៧
នមស្សការបូជនីយវត្ថុជាទីគោរព (វន្ទាមិ ចេតិយំ) ..........១៨
ត្រៃប្រណាម បែបសង្ខេប ..........១៩
ត្រៃប្រណាម ប្រែកាព្យ ..........២៥

## គិហិវិន័យសង្ខេប

បុព្វភាគប់ដិបត្តិ ..........២៩
ឧបាសកនិទ្ទេស ..........៣៤
វិធីសមាទាននិច្ចសីល ..........៣៩

វិធីសមាទានឧបោសថសីល ........................................................៤៤
ឯកជ្ឈសមាទាន ...................................................................៤៩
អង្គនៃនិច្ចសីល ..................................................................៥៣
អង្គនៃឧបោសថសីល ...........................................................៥៤
ឧបោសថកាលសង្ខេប ..........................................................៥៦
ភាវេតព្វកិច្ច ......................................................................៥៨
វិធីសមាទានសីល ១០ ........................................................៦២
អានិសង្សសីលសង្ខេប .........................................................៦៥
អធិប្បាយសង្ខេប ................................................................៦៦
របៀបអ្នករក្សាសីល ១០ .......................................................៦៨
អកុសលកម្មបថ ..................................................................៦៩
កុសលកម្មបថ ....................................................................៧២
អដ្ឋង្គិកមគ្គ ៨ ....................................................................៧៣
អដ្ឋង្គិកមគ្គ ៨ (ប្រែកាព្យពាក្យ ៧) .............................................៧៤

## ធម៌សូត្រផ្សេងៗ

តេជះខ្ញុំសាង ......................................................................៧៧
ពាក្យសូមប្រាថ្នា ...................................................................៧៨
បត្តិទានគាថា (យំ កិញ្ចិ) .......................................................៧៩
យំកិញ្ចិ (ប្រែ ជាពាក្យកាព្យ) ......................................................៨០
យំកិញ្ចិ (ប្រែ កាព្យមួយបែបទៀត) ...............................................៨១
បត្តិទានគាថា (យា ទេវតា) ......................................................៨២
បត្តិទានបត្តនគាថា (ឥមិនា) .....................................................៨៤
ខមាបនគាថា (យេ កេចិ) ..........................................................៨៥

សុខាភិយាចនគាថាសង្ខេប ....................................................................៨៦
ព័ទ្ធសីមា ....................................................................................................៨៧
ធម៌សម្រាប់សូធ្យផ្សាយមេត្តា (សូមសេចក្ដីសុខ) ........................................៨៧
ធម៌សម្រាប់សូធ្យផ្សាយមេត្តា ......................................................................៨៧
ធម៌សូធ្យផ្សាយមេត្តាទាំង ១០ ទិស ...............................................................៨៨
អានិសង្សរបស់អ្នកចម្រើនមេត្តាចិត្ត ១១ យ៉ាង ...........................................៩០
អនុមោទនារក្ខយាចនគាថា (អាកាសដ្ឋា) .......................................................៩២
សុភមង្គលកថា .............................................................................................៩៣
សូធ្យឱ្យពរជាពាក្យកាព្យ ...............................................................................៩៤
សូធ្យផ្សាយព្រះពុទ្ធសាសនា ........................................................................៩៤
មង្គលសូត្រ (ធម៌មង្គល ៣៨ប្រការ) ...............................................................៩៥
ពុទ្ធជយមង្គលគាថា (ធម៌ ពាហុំ) ..................................................................៩៩
មោរបរិត្ត (ធម៌ ឧទេតយញ្ចុ) ......................................................................១០៤
ជយបរិត្តគាថា (ធម៌ ជយន្តោ) .....................................................................១០៦
បារមីធម៌ ១០ យ៉ាង ....................................................................................១០៨
បារមីធម៌ ៣០ ប្រការ ...................................................................................១០៩
គារវៈ ៦ យ៉ាង ............................................................................................១១២
អនុស្សតិ ១០ យ៉ាង .....................................................................................១១២

## ពិធីក្នុងព្រះពុទ្ធសាសនា

បរិត្តភាសនាយាចនគាថា ............................................................................១១៥
ទេវតាបកាសនគាថា .....................................................................................១១៦
ពាក្យប្រកាសមុនអារាធនាធម៌ទេសនា ..........................................................១១៧
ធម្មទេសនាយាចនគាថា ...............................................................................១១៧
ពាក្យអារាធនាធម៌ទេសនា (មួយបែបទៀត) ...................................................១២០

ធម៌សុខោ ....................................................................................១២១
ថ្វាយខ្លួនចំពោះព្រះរតនត្រ័យ ...........................................................១២២
ថ្វាយខ្លួនចំពោះលោកគ្រូធម្មាចារ្យ .....................................................១២២
វិធីសូមកម្មដ្ឋាន ......................................................................................១២៣
អារក្ខកម្មដ្ឋាន ........................................................................................១២៣
ទង់ព្រះពុទ្ធសាសនា ...............................................................................១២៥
កំណាព្យពាក្យ ៧ សម្តេចព្រះសង្ឃរាជ (ជួន ណាត) ..............................១២៦
ពុទ្ធប្បវត្តិសង្ខេប (បទពាក្យ ៧) ............................................................១២៧
ពុទ្ធកិច្ច ៥ យ៉ាង (បទពាក្យ ៧) ...............................................................១២៨
បទ គោរពទង់ជ័យព្រះពុទ្ធសាសនា ....................................................១២៩
ឆព្វណ្ណរង្សី ............................................................................................១៣០
ពាក្យអារាធនាមុនពេលទេសនា .............................................................១៣១
ធម៌អន្លង់ ៤ ប្រការ (ពាក្យអារាធនាមុនពេលទេសនា) ..........................១៣២
ពាក្យសូធ្យសរសើរធម្មទេសនា ..............................................................១៣៣
រំលឹកគុណព្រះរតនត្រៃ ...........................................................................១៣៤

## ពិធីវេរភត្ត និង បច្ច័យផ្សេងៗ

ឯកត្តទាំង ១៩ នោះគឺ ...........................................................................១៣៧
បាលីវេរភត្តច្រើនបែប ............................................................................១៣៨
របៀបវេរមតកភត្ត ..................................................................................១៤៣
វេរផ្កាហិរញ្ញវត្ថុ ......................................................................................១៤៤
វេរចតុប្បច្ច័យជាសង្ឃទាន ....................................................................១៤៥
វេរចតុប្បច្ច័យដល់ភិក្ខុ ២ ឬ ៣ អង្គ .......................................................១៤៥
វេរចតុប្បច្ច័យដល់ភិក្ខុ ១ អង្គ ................................................................១៤៦
វេរកឋិនទានដល់ព្រះសង្ឃ .....................................................................១៤៦

វេរគ្រឿងបរិក្ខាជាបរិវារកឋិន ..........១៤៧
វេរកឋិនទាន (មួយបែបទៀត) ..........១៤៧
វេរត្រៃចីវរ ..........១៤៩
វេរសំពត់សម្រាប់ងូតទឹកភ្លៀង ..........១៥០
វេរសង្ឃទាន ..........១៥១
វេរគណទាន ..........១៥១
វេរបាដិបុគ្គលិកទាន ..........១៥២
វេរអង្ករដល់ព្រះសង្ឃ ..........១៥២
វេរផ្លែឈើផ្សេងៗ ..........១៥៣
វេរគ្រឿងសេនាសនៈ ..........១៥៣
វេរគរុភណ្ឌ ..........១៥៤
វិធីវេរគ្រឿងភេសជ្ជៈ ..........១៥៥
បាលីវេរដុំថ្មជានិមិត្តសីមា ..........១៥៦
បាលីវេរកោងឧបោសថ (គឺវិហារ) ..........១៥៦
បាលី-ប្រែ សម្រាប់សូត្រឧទ្ទិសផលបុណ្យ ..........១៥៧
បញ្ហាទាន១ ..........១៥៨
ធ្វើទានបុំច្ច័យ ៤ ចំពោះសង្ឃ ..........១៥៩
របៀបវេរបច្ច័យ ៤ ជាសង្ឃទាន ..........១៥៩
អំពីពាក្យថា សង្ឃ ..........១៦១

## ប្រស្នាត្រៃគុណសង្ខេប

ប្រស្នាពុទ្ធគុណ ..........១៦៥
ប្រស្នាធម្មគុណ ..........១៧៧
ប្រស្នាសង្ឃគុណ ..........១៨២

## របៀបមាឃបូជា

នមស្សការព្រះបរមសារីរិកធាតុ ........................................១៩១
វិធីប្រកាសមាឃបូជា ........................................១៩២
បាលីវេរគ្រឿងសក្ការៈមាឃបូជា ........................................១៩៥
បទថ្វាយផ្កា ........................................១៩៧
នមោ ៨ បទ ........................................១៩៨
គាថាប្រារព្ធមាឃបូជា ........................................២០០
សត្តមហាឋាន (ឋានធំ ៧ កន្លែង) ........................................២០៣
អដ្ឋមហាឋាន (ឋានធំ ៨ កន្លែង) ........................................២០៤
នមក្ការគាថា (គាថានមស្ការចំពោះព្រះមហានាគ) ........................................២០៦
អដ្ឋវីសសម្ពុទ្ធនមក្ការគាថា (គាថានមស្ការចំពោះព្រះសម្ពុទ្ធ ២៨ ព្រះអង្គ) ......២០៨
ចតុសំវេជនីយដ្ឋាន ........................................២១១
ពុទ្ធបាទ ៥ ឋាន ........................................២១២
ធាតុចេតិយនមក្ការគាថា ........................................២១៤
បទគាថា និយាយពីទ្រង់ដាស់តឿន ........................................២១៩
បទ នមស្សការ ........................................២២០
នមស្សការកាលទ្រង់ប្រជុំធ្វើឱវាទបាដិមោក្ខ ........................................២២២
នមស្សការកាលទ្រង់ដាក់ជន្មាយុសង្ខារ ........................................២២២
បទគាថា និយាយអំពីទ្រង់ដាក់ជន្មាយុសង្ខាររួចហើយ (ក) ........................................២២៣
បទគាថា និយាយអំពីទ្រង់ដាក់ជន្មាយុសង្ខាររួចហើយ (ខ) ........................................២២៣
ចតុរង្គសន្និបាតរបស់ព្រះបរមគ្រូនៃយើងមានអង្គ ៤ គឺ ........................................២២៤
ធម៌សរសើរគុណព្រះសម្មាសម្ពុទ្ធ ........................................២២៥

## របៀបធ្វើវិសាខបូជា


វិធីប្រកាសវិសាខបូជា ............................................................ ២២៩
បាលីវេរគ្រឿងសក្ការៈវិសាខបូជា ............................................... ២៣២
នមោ ៨ បទ .......................................................................... ២៣៤
នមោ ៣ បទ .......................................................................... ២៣៥
នមោ ៣ បទ រួបរួមជា ១ បទ ..................................................... ២៣៦
គាថាប្រារព្ធមាឃបូជា ............................................................ ២៣៧
សត្តមហាឋាន (ឋានធំ ៧ កន្លែង) ................................................ ២៣៩
អដ្ឋមហាឋាន (ឋានធំ ៨ កន្លែង) ................................................ ២៤០
នមក្ការគាថា (គាថានមស្ការចំពោះព្រះមហានាគ) ............................ ២៤២
អដ្ឋវីសសម្ពុទ្ធនមក្ការគាថា (គាថានមស្ការចំពោះព្រះសម្ពុទ្ធ ២៨ ព្រះអង្គ) ....... ២៤៤
ពុទ្ធបាទនមក្ការគាថា ............................................................ ២៤៧
បទគាថា សម្តែងអំពីកាលទ្រង់ប្រសូត ........................................... ២៤៩
ទ្រង់ស្តេច ៧ ជំហានបន្លឺសីហនាទ ............................................... ២៤៩
បទគាថា និយាយអំពីបុព្វនិមិត្ត ៥ប្រការ ក្នុងវេលាយប់ ១៤កើត ខែពិសាខ ....២៥០
បទគាថា និយាយអំពីនាងសុជាតាថ្វាយមធុបាយាសពីព្រលឹម ........................ ២៥១
បទគាថា និយាយពីពុទ្ធក្ខេត្ត និងស្វេតច្ឆត្រ ........................................ ២៥២
បទគាថា និយាយពីទ្រង់ផ្ចាញ់មារវេលាល្ងាច ថ្ងៃ ១៥កើត ខែពិសាខ (ក) ....២៥៣
បទគាថា និយាយពីទ្រង់ផ្ចាញ់មារវេលាល្ងាច ថ្ងៃ ១៥កើត ខែពិសាខ (ខ) ....២៥៣
បទគាថា និយាយពីពលមារថយក្រោយខ្ចាត់ខ្ចាយ ..................................... ២៥៤
បទគាថា និយាយពីក្រុងមារថ្វាយសាធុការពរ ....................................... ២៥៥
បទគាថា និយាយពីវេលាត្រាស់ដឹងសព្វញ្ញុតញ្ញាណ ................................. ២៥៦
លុះបច្ចូសម័យទ្រង់សម្តែង (ឧទានគាថា) ............................................ ២៥៧

ទ្រង់បរិនិព្វាន បទឥន្ទ្រជិត (មិនមានបាលីគាថា) ....................២៥៨
ព្រះអានន្ទយំស្រណោះ បទឥន្ទ្រជិត (មិនមានបាលីគាថា) ....................២៥៩
បច្ឆិមពុទ្ធវចនៈ (បទបណ្ឌកគតិ) ....................២៦០
វិសាខបូជា (ថ្ងៃ ៨ រោច) ....................២៦៣
បាលីវេរគ្រឿងសក្ការៈបូជា ....................២៦៣
គាថាប្រារព្ធវិសាខបូជា (ថ្ងៃ ៨ រោច) ....................២៦៤
បទគាថា និយាយពីសហម្បតីព្រហ្មពោលសំវេគ ....................២៦៦
បទគាថា និយាយពីព្រះឥន្ទ្រពោលសំវេគ ....................២៦៦
បទគាថា និយាយពីព្រះអនុរុទ្ធពោលសំវេគ ....................២៦៧
បទគាថា និយាយពីព្រះអានន្ទពោលសំវេគ ....................២៦៨
គោលពិសេស កំណត់ថ្ងៃ-ខែ-ឆ្នាំនៃមហាបុរស ....................២៦៩

## របៀបអាសាឡ្ហបូជា

ពិធីអាសាឡ្ហបូជា (មានបូក្ស ៤ យ៉ាង) ....................២៧៣
វេរគ្រឿងសក្ការៈបូជា ....................២៧៤
បទគាថា និយាយពីស្ដេចចុះកាន់គភ៌ ....................២៧៥
បទគាថា និយាយពីស្ដេចចេញបព្វជ្ជា ....................២៧៥
បទគាថា និយាយពីទ្រង់សំដែងធម្មចក្ក ....................២៧៦
បទគាថា និយាយពីទ្រង់ធ្វើយមកប្បាដិហារ្យ ....................២៧៧
បទគាថា និយាយអំពីកាលទ្រង់ស្ថិតនៅក្នុងផ្ទៃ ....................២៧៨
បទគាថា និយាយពីទ្រង់ក្រសាលក្នុងឧទ្យាន ....................២៧៨
បទគាថា និយាយពីមុននឹងស្ដេចចេញបព្វជ្ជា ....................២៧៩
បទគាថា និយាយពីដាស់ឆន្នាមាត្យ ....................២៨០
បទគាថា និយាយពីកាលទ្រង់ជួបនឹងឧបកាជីវក (ក) ....................២៨១

បទគាថា និយាយពីកាលទ្រង់ជួបនឹងឧបកាជីវក (ខ) ..........................២៨១
បទគាថា និយាយពីកាលស្តេចទៅកាន់ដែនពារាណសី ..........................២៨២
បទគាថា និយាយពីស្តេចធ្វើយមកបាដិហារ្យ ..........................២៨៤
បុព្វនិមិត្ត ៣២ ប្រការគឺ ..........................២៨៧

# របៀបអស្សយុជបូជា

អស្សយុជបូជា ..........................២៩១
វេរគ្រឿងសក្ការៈបូជា ..........................២៩១
រតនប្បណាម ..........................២៩៣
បទគាថា និយាយពីស្តេចទៅកាន់ទេវលោក ..........................២៩៥
បទគាថា និយាយពីស្តេចធ្វើយមកបាដិហារ្យរួចហើយ ..........................២៩៦
បទគាថា និយាយអំពីអានិសង្សស្តាប់ធម៌ ..........................២៩៧
បទគាថា និយាយពីបញ្ហាព្រះគន្ធរចនាចារ្យ ..........................២៩៨
បទគាថា និយាយពីស្តេចចុះចាកទេវលោក ..........................៣០០
បទគាថា និយាយពីស្តេចធ្វើបាដិហារ្យចុះចាកទេវលោក ..........................៣០៣
ឧទានរបស់ព្រះសារីបុត្ត ..........................៣០៤
បទគាថា និយាយពីទ្រង់សម្តែងធម៌ ៤ យ៉ាង ..........................៣០៥
គុណព្រះនិព្វាន ៨ យ៉ាង ..........................៣០៦
ពាក្យនមស្ការ ..........................៣០៧
មហាបុរិសលក្ខណៈ ៣២ ប្រការ ..........................៣០៨
អនុព្យញ្ជនៈ របស់ព្រះសម្មាសម្ពុទ្ធមាន ៨០ គឺ ..........................៣១១
អដ្ឋុត្តរសតមង្គលគាថា (បាលី) ..........................៣១៣
អដ្ឋុត្តរសតមង្គលគាថា (បាលី ប្រែ) ..........................៣១៤
សរសើរព្រះបាទ ..........................៣១៧

នមស្ការព្រះពុទ្ធ ១០ ព្រះអង្គ ត្រាស់ដឹងក្នុងអនាគតកាល ..........................៣២១
ភាសិតោវាទសង្ខេប ..........................................................................៣២៥
បរាភវសូត្រ .....................................................................................៣៣៣

# ត្រៃប្រណាម

# បទសរភញ្ញ វសន្តតិលកា

## សម្រាប់សូធ្យគោរពទង់សាសនា[១]

១- សូមថ្វាយបង្គំ ព្រះស-ម្ពុទ្ធ    ប្រសើរបំផុត ក្នុងលោ-កា
ជាគ្រូនៃមនុស្ស និងទេ-ព្តា    ទ្រង់ត្រាស់ទេសនា ប្រដៅ-សត្វ
ចង្អុលឱ្យដើរ ផ្លូវក-ណ្តាល    មាគ៌ាត្រកាល អាចក-ម្ចាត់
ទុក្ខភ័យចង្រៃ ឱ្យខ្ចាយ-បាត់    អាចកាត់សង្សា រៈទុក្ខ-បាន ។

២- សាស្តាព្រះអង្គ នៅសព្វ-ថ្ងៃ    សត្វមាននិស្ស័យ ពីបូ-រាណ
ប្រឹងរៀនប្រឹងស្តាប់ ចេះចាំ-បាន    កាន់តាមលំអាន បានក្តី-សុខ
ឥតមានសុខណា ស្មើក្តី-ស្ងប់    បញ្ចប់ត្រឹមសុខ ឃ្លាតចាក-ទុក្ខ
តាំងពីលោកនេះ តទៅ-មុខ    ក្តីសុខនឹងមាន ព្រោះធម៌-ស្ងប់ ។

៣- ខ្ញុំសូមបង្គំ ឆ្ពោះព្រះ-ធម៌    ព្រះសង្ឃបវរ ទាំងគ្រប់-សព្វ
រួមជាត្រៃរ័ត្ន គួរគោ-រព    ជាម្លប់ត្រជាក់ នៃលោ-កា
ព្រះរូបព្រះធាតុ នៃព្រះ-ពុទ្ធ    វិសុទ្ធតាងអង្គ ព្រះសា-ស្តា
សូមគុណត្រៃរ័ត្ន ជួយខេម-រា    ឱ្យបានសុខា តរៀង-ទៅ ។

៚

ចម្លងចេញពីសៀវភៅ គិហិបដិបត្តិ របស់
សម្តេចព្រះមហាសុមេធាធិបតី ជួន ណាត (ជោតញ្ញាណោ) ព្រះសង្ឃរាជគណៈមហានិកាយ
ថ្ងៃទី ១២ កុម្ភៈ ឆ្នាំ ១៩៦៥ ។

---

(១) ក្នុងពិធីបុណ្យ មាឃបូជា វិសាខបូជា ឬ បុណ្យផ្សេងៗ ក្នុងពុទ្ធសាសនា គួរចាត់សូធ្យបទសរភញ្ញនេះ ក្នុងពេលលើក-ដាក់ ទង់សាសនា ដើម្បីឱ្យស្របតាមបុណ្យមាឃបូជា និង វិសាខបូជា ។

## សូមអញ្ជើញពពួកទេវតា

សមន្តា ចក្កវាឡេសុ អត្រាគច្ឆន្តុ ទេវតា
សទ្ធម្មំ មុនិរាជស្ស សុណន្តុ សគ្គមោក្ខទំ ។

ទេវតាទាំងឡាយ ក្នុងចក្រវាឡទាំងឡាយ ដោយជុំវិញ សូមអញ្ជើញមកប្រជុំគ្នាក្នុងទីនេះ ចូរស្ដាប់នូវព្រះសទ្ធម្ម ជាធម៌អាចឱ្យនូវសួគ៌និងព្រះនិព្វាន (របស់ព្រះអនាវរណញ្ញាណ) ជាស្ដេចនៃអ្នកប្រាជ្ញ ។

## រតនត្តបូជា

ថ្វាយគ្រឿងសក្ការៈដល់ព្រះរតនត្រ័យ

ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ អភិបូជយាមិ មាតាបិតាទីនំ
គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ឥមេហិ ទីបធូបាទិសក្ការេហិ ធម្មំ អភិបូជយាមិ មាតាបិតាទីនំ
គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ឥមេហិ ទីបធូបាទិសក្ការេហិ សង្ឃំ អភិបូជយាមិ មាតាបិតាទីនំ
គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ[១] ។

ប្រែថា ខ្ញុំព្រះករុណា សូមបូជាចំពោះនូវ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយ មានទៀននិងធូបជាដើមនេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។

(១) សូធ្យយ៉ាងខ្លី រួមគ្នាទាំង ៣ មេ ជាមួយគ្នាថា «ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ» ដូច្នេះក៏បាន ។

# ពុទ្ធរតនប្បណាម

ថ្វាយបង្គំព្រះពុទ្ធរតនៈ

**នមោ តស្ស**

**ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៗ**

ប្រែថា វិកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

សូធ្យបាលី ៣ ចប់ សម្រាយតែ ១ ចប់ក៏បាន

**យោ សន្និសិន្នោ វរពោធិមូលេ**
**មារំ សសេនំ មហតី វិជេយ្យោ**[១]
**សម្ពោធិមាគច្ឆិ អនន្តញាណោ**
**លោកុត្តមោ តំ បណមាមិ ពុទ្ធំ ៗ**

ប្រែថា ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើននូវព្រះអានាបានស្សតិកម្មដ្ឋានលើរតនបល្ល័ង្ក ក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជ ព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវ ព្រះសម្មាសម្ពុទ្ធអង្គនោះដោយគោរព ។

( ក្រាបថ្វាយបង្គំម្តង )

---

(១) ដែលធ្លាប់សូធ្យមកថា «វិជ្ជយោ» តែពិនិត្យផ្ទៀងផ្ទាត់ទៅឃើញថា «វិជេយ្យោ» ទើបត្រឹមត្រូវ. ត្រូវប្រែដូច «វិជិត្វា» ឬ «វិជេត្វា» ។

នមស្ការព្រះសម្មាសម្ពុទ្ធ ដូចសេចក្តីខាងលើនេះ គឺនមស្ការដោយសង្ខេប មិនបាន ញែកកាលចេញជា ៣ ឡើយ, បើនមស្ការដោយពិស្តារវិញ ទើបញែកកាលចេញជា ៣ ដូចសេចក្តីខាងក្រោមនេះ ៖

យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា

បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា ។

ប្រែថា ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វាន កន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គណា ដែលនឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុង ភទ្ទកប្បនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវ ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ គ្រប់កាលទាំងពួង ។

( ក្រាបថ្វាយបង្គំម្តង )

រួចហើយ គប្បីតាំងចិត្តរឭកដល់ព្រះពុទ្ធគុណទាំង ១០ ព្រះនាម ដោយបង្អោនកាយវាចាថា :

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ

វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ

អនុត្តរោ បុរិសទម្មសារថិ សត្ថាទេវមនុស្សានំ

ពុទ្ធោ ភគវាតិ ។

ប្រែថា **ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាម ថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគ និងវចីបយោគ,

**សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ,

**វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥,

**សុគតោ** ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន,

**លោកវិទូ** ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក,

**អនុត្តរោ** ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរ ដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន,

**បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យ គួរនឹងទូន្មានបាន,

**សត្ថាទេវមនុស្សានំ** ទ្រង់ព្រះនាមថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ,

**ពុទ្ធោ** ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹង នូវចតុរារិយសច្ច ហើយញុំាងអ្នកដទៃ ឱ្យត្រាស់ដឹងផង,

**ភគវា** ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរ ទៅកាន់ត្រៃភពខ្ចាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

រឭកដល់ពុទ្ធគុណ ដូច្នេះរួចហើយ គប្បីប្រកាសប្តេជ្ញាខ្លួនដោយពាក្យសច្ចៈថា :

**នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

ប្រែថា នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរឭក នៃខ្ញុំព្រះករុណា មិនមានឡើយ,

ពុទ្ធោ មេ សរណំ វរំ មានតែព្រះពុទ្ធ ជាម្ចាស់ជាទីពឹងទីរឭក ដ៏ប្រសើរ របស់ខ្ញុំព្រះករុណា,

ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសិរីសួស្តីជ័យមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

បើ្តជាខ្លួនដូច្នេះហើយ គប្បីសូធ្យសូមខមាទោស នឹងព្រះពុទ្ធជាម្ចាស់ថា៖

ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេ

យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ ។

ប្រែថា ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ខ្ញុំព្រះករុណា សូមថ្វាយបង្គំ នូវល្អងធូលីព្រះបាទ នៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈដ៏ឧត្តមគឺត្បូង,

ពុទ្ធេ យោ ខលិតោ ទោសោ ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះពុទ្ធជាម្ចាស់,

ពុទ្ធោ ខមតុ តំ មមំ សូមព្រះពុទ្ធជាម្ចាស់ អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

( ក្រាបថ្វាយបង្គំម្តង )

# ធម្មរតនប្បណាម

ថ្វាយបង្គំព្រះធម្មរតនៈ

**អដ្ឋង្គិការិយបថោ[១] ជនានំ មោក្ខប្បវេសាយ**

**ឧជូ[២] ច មគ្គោ ធម្មោ អយំ សន្តិករោ**

**បណីតោ និយ្យានិកោ តំ បនមាមិ ធម្មំ ។**

ប្រែថា ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញុំាងជន ដែលប្រាថ្នានូវព្រះនិព្វានឱ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះជាធម៌ធ្វើឱ្យត្រជាក់រម្ងាប់បង់ នូវភ្លើងទុក្ខភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញុំាងសត្វ ឱ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវ ព្រះសទ្ធម្មនោះ ដោយគោរព ។

( ក្រាបថ្វាយបង្គំម្ដង )

នមស្ការព្រះសទ្ធម្ម ដូចសេចក្ដីខាងលើនេះ គឺនមស្ការដោយសង្ខេប មិនបានពែកកាលចេញជា ៣ ឡើយ, បើនមស្ការដោយពិស្ដារវិញ ទើបញែកកាលចេញជា ៣ ដូចសេចក្ដីខាងក្រោមនេះ ៖

១

**យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា**

**បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា ។**

ប្រែថា ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្ដី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ នឹងមាន

---

(១)- ដែលធ្លាប់សូធ្យមកថា «អដ្ឋង្គិកោ អរិយបថោ» តែបានផ្ទៀងផ្ទាត់ទៅឃើញថា «អដ្ឋង្គិការិយបថោ» ទើបត្រឹមត្រូវតាមឆន្ទរបស់គាថា «អដ្ឋង្គិកោ អរិយបថោ» ដូចដែល ។

(២)- ក្នុងសៀវភៅ បោះពុម្ពអក្សរសីហឡៈ (អក្សរអ្នកលង្កាទ្វីប) ថា «មោក្ខប្បវេសាយុជុកោ ច មគ្គោ» គង់មានសេចក្ដីត្រូវគ្នានឹងបាលីក្នុងទីនេះដែរ ។

មកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវ ព្រះធម៌ទាំងឡាយនោះ គ្រប់កាលទាំងពួង ។

( ក្រាបថ្វាយបង្គំម្តង )

រួចហើយ គប្បីតាំងចិត្តរឭកដល់ធម្មគុណ ដោយបង្អោនកាយវាចាថា :

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ**

**អកាលិកោ ឯហិបស្សិកោ ឱបនយិកោ**

**បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។**

ប្រែថា **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយល្អ ( ធម្មោ ព្រះនព្វលោកុត្តរធម៌ មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១ ),

**សន្ទិដ្ឋិកោ** ជាធម៌គឺព្រះអរិយបុគ្គលទាំងពួង ដឹងពិតឃើញពិត ដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ ដោយជឿបុគ្គលដទៃនោះទក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង, ១

**អកាលិកោ** ជាធម៌ឱ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ,

**ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃ ឱ្យចូលមកមើលបាន,

**ឱបនយិកោ** ជាធម៌គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា,

**បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

រឭកដល់ធម្មគុណ ដូច្នេះរួចហើយ គប្បីប្រកាសប្ដេជ្ញាខ្លួនដោយពាក្យសច្ចៈថា :

នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ
ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។

ប្រែថា នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរឭក នៃខ្ញុំព្រះករុណា មិនមានឡើយ,

ធម្មោ មេ សរណំ វរំ មានតែព្រះធម៌ជាម្ចាស់ជាទីពឹងទីរឭក ដ៏ប្រសើរ របស់ខ្ញុំព្រះករុណា,

ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសិរីសួស្ដីជ័យមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

ប្ដេជ្ញាខ្លួនដូច្នេះហើយ គប្បីសូត្រសូមខមាទោស និងព្រះធម៌ជាម្ចាស់ថា :

ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ(១) វរំ ធម្មេ
យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ ។

ប្រែថា ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវ ព្រះធម៌ដ៏ប្រសើរមានពីរប្រការ គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តមគឺត្បូង,

ធម្មេ យោ ខលិតោ ទោសោ ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះធម៌ជាម្ចាស់,

ធម្មោ ខមតុ តំ មមំ សូមព្រះធម៌ជាម្ចាស់ អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

( ក្រាបថ្វាយបង្គំម្ដង )

---

(១)- ក្នុងសៀវភៅបោះពុម្ពអក្សរសីហឡៈ (អក្សរអ្នកលង្កាទ្វីប) ថា «តិវិធំ» សំដៅសេចក្ដីចំពោះព្រះធម៌បីយ៉ាង គឺ ព្រះបរិយត្តិធម៌, បដិបត្តិធម៌ និង បដិវេធធម៌ ។

# សង្ឃរតនប្បណាម

ថ្វាយបង្គំព្រះសង្ឃរតន

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ**

**សន្តិន្ទ្រិយោ សព្វមលប្បហីនោ**

**គុណេហិនេកេហិ សមិទ្ធិបត្តោ**

**អនាសវោ តំ បណមាមិ សង្ឃំ ។**

ប្រែថា ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធិវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយ៍រម្ងាប់ហើយ មានមន្ទិលគឺរាគាទិក្កិលេស ទាំងពួងបន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយនូវកិរិយាសម្រេច ដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវៈធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះអរិយសង្ឃនោះដោយគោរព ។

( ក្រាបថ្វាយបង្គំម្តង )

នមស្ការព្រះអរិយសង្ឃ ដូចសេចក្តីខាងលើនេះ គឺនមស្ការដោយសង្ខេប មិនបានញែកកាលចេញជា ៣ ឡើយ. បើនមស្ការដោយពិស្តារវិញ ទើបញែកកាលចេញជា ៣ ដូចសេចក្តីខាងក្រោមនេះ ៖

**យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា**

**បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា ។**

ប្រែថា ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គនិងផលកន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃនឹងបានសម្រេចមគ្គនិងផលក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គនិងផលក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវ ព្រះសង្ឃទាំងឡាយនោះគ្រប់កាលទាំងពួង ។

( ក្រាបថ្វាយបង្គំម្តង )

រួចហើយ គប្បីតាំងចិត្តរឭកដល់សង្ឃគុណ ដោយបង្អោនកាយវាចាថា :

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ**

**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ**

**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ**

**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ**

**យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។**

ប្រែថា **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌,

**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមបដិបទា,

**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ថានក្សេមផុតចាកទុក្ខទាំងពួង,

**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់ សីល សមាធិ បញ្ញា,

**យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយ មាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេច នូវសោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ ១

សកទាគាមិមគ្គ និងសកទាគាមិផលជាគូ ១ អនាគាមិមគ្គ និងអនាគាមិផលជាគូ ១ អរហត្តមគ្គ និងអរហត្តផលជាគូ ១,

**អដ្ឋបុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១,

**ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនោះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ,

**អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា,

**បាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិនិងមិត្រ ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា,

**ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្មនិងផលនៃកម្ម ហើយបូជា,

**អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ,

**អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជគឺបុណ្យនៃសត្វលោករកខេត្តដទៃ ក្រៃលែងជាងគ្មាន ។

រឭកដល់សង្ឃគុណ ដូច្នេះរួចហើយ គប្បីប្រកាសប្តេជ្ញាខ្លួនដោយពាក្យសច្ចៈថា :

**នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

ប្រែថា **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭក នៃខ្ញុំព្រះករុណាមិនមានឡើយ,

**សង្ឃោ មេ សរណំ វរំ** មានតែព្រះសង្ឃជាម្ចាស់ជាទីពឹងទីរឭក ដ៏ប្រសើររបស់ខ្ញុំព្រះករុណា,

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

ប្តេជ្ញាខ្លួនដូច្នេះហើយ គប្បីសូធ្យសូមខមាទោស នឹងព្រះសង្ឃជាម្ចាស់ថា :

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ សង្ឃេ**
**យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ ៕**

ប្រែថា **ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវ ព្រះសង្ឃដ៏ប្រសើរមានពីរប្រការ គឺសម្មតិសង្ឃនិងអរិយសង្ឃ ដោយអវយវៈដ៏ឧត្តមគឺត្បូង,

**សង្ឃេ យោ ខលិតោ ទោសោ** ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះសង្ឃជាម្ចាស់,

**សង្ឃោ ខមតុ តំ មមំ** សូមព្រះសង្ឃជាម្ចាស់ អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

( ក្រាបថ្វាយបង្គំម្តង )

# បណាមគាថា

យោ កប្បកោដីហិបិ អប្បមេយ្យំ
កាលំ ករោន្តោ អតិទុក្ករានិ
ខេទំ គតោ លោកហិតាយ នាថោ
នមោ មហាការុណិកស្ស តស្ស ៗ

ប្រែថា ព្រះពុទ្ធជាទីពឹង ជាព់នឹងសព្វសត្តា ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ ។
រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ បានត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើភពឋាន។
ធ្វើកម្មជាកម្រ សត្តនិករគ្រាប់ពុំបាន តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ
ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់ ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល ។

អសម្ពុធំ ពុទ្ធនិសេវិតំ យំ ភវាភវំ
គច្ឆតិ ជីវលោកោ នមោ អវិជ្ជា-
កិលេសជាលំ វិទ្ធំសិនោ ធម្មវរស្ស តស្ស ៗ

សត្វតែងកើតស្លាប់បង់ ព្រោះចំណងកម្មជាគោល ឱ្យវិលវល់អន្ទោល ក្នុងភពតូចនិងភពធំ ។
ហេតុតែមិនដឹងធម៌ បរិសុទ្ធល្អស្អាតសុខុម គឺព្រះពុទ្ធសេពសម ចិត្តខ្ញុំសូមនមស្សការ ។
នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា កាត់បង់នូវអវិជ្ជា គឺបណ្ដាញកិលេសហើយ ។

គុណេហិ យោ សីលសមាធិបញ្ញា
វិមុត្តិញាណប្បភុតីហិ យុត្តោ
ខេត្តញ្ជនានំ កុសលត្ថិកានំ
តមរិយសង្ឃំ សិរសា នមាមិ ៗ

ព្រះសង្ឃអង្គសាវ័ក មានស្ដំវរៈដ៏ផូរផង់ កបដោយគុណសីលត្រង់ និងសមាធិបញ្ញា ។
និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល ។
ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល ជាបុត្តព្រះទសពល ជាមង្គលដល់សព្វសត្វ ។

# រតនត្តយវន្ទនគាថា

ឥច្ចេវមច្ចន្ត នមស្សនេយ្យំ
នមស្សមានោ រតនត្តយំ យំ
បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ
តស្សានុភាវេន ហតន្តរាយោ ៕

ប្រែថា ខ្ញុំសូមនស្សការ លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា ។
សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសាធំទូលាយ ។
សូមឱ្យកំចាត់បង់ អពមង្គលទាំងឡាយ
ឱ្យចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ។
ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ។
ដោយគុណនមស្សការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វានហោង ។

# ពុទ្ធបាទនមស្សការគាថា

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ តិលោកកេតុំ តិភវេកនាថំ យោ
លោកសេដ្ឋោ សកលំ កិលេសំ ឆេត្វាន ពោធេសិ ជនំ អនន្តំ ។

ប្រែថា ព្រះសម្មាសម្ពុទ្ធឯណា ព្រះអង្គប្រសើរក្នុងលោក ទ្រង់កាត់បង់នូវកិលេសទាំងអស់បានហើយ ញ៉ាំងជនជាអនន្តឱ្យត្រាស់ដឹងហើយ ខ្ញុំសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្លងផុត អំពីច្រាំងនៃភពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃលោក មានតែព្រះអង្គមួយ ជាទីពឹងនៃសព្វសត្វក្នុងត្រៃភព ។

យំ នម្មទាយ នទិយា បុលិនេ ច តីរេ
យំ សច្ចពន្ធគិរិកេ សុមនា ច លគ្គេ
យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ
តំ បាទលញ្ជនមហំ សិរសា នមាមិ ។

ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើផ្ទៃខ្សាច់ទៀបឆ្នេរនៃស្ទឹងឈ្មោះនម្មទា ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើភ្នំសច្ចពន្ធ និងលើភ្នំសុមនកូដ ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) ក្នុងយោនកបុរី ខ្ញុំសូមក្រាបថ្វាយបង្គំដោយត្បូង ចំពោះទៅព្រះបាទនិងស្នាមព្រះបាទទាំងនោះ នៃព្រះសាក្យមុនី ។

សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ
យោនកបុរេ នម្មទាយ នទិយា បញ្ចបាទវរំ
ឋានំ អហំ វន្ទាមិ ទូរតោ ។

ខ្ញុំសូមនមស្សការ អំពីចម្ងាយ នូវឋានដែលមានព្រះបាទដ៏ប្រសើរ ៥ កន្លែង គឺស្ថានលើភ្នំសុវណ្ណមាលិក ១ លើភ្នំសុវណ្ណបព៌ត ១ លើភ្នំសុមនកូដ ១ ក្នុងយោនកបុរី ១ ក្បែរស្ទឹងនម្មទា ១ ។

# នមស្សការបូជនីយវត្ថុជាទីគោរព

វន្ទាមិ ចេតិយំ សព្វំ  សព្វដ្ឋានេសុ បតិដ្ឋិតំ

សារីរិកធាតុ មហាពោធឹ  ពុទ្ធរូបំ សកលំ សទា ៗ

ខ្ញុំសូមថ្វាយបង្គំ  ឆ្ពោះព្រះបរមចេតិយ

ព្រមទាំងព្រះសារី-  រិកធាតុនៃព្រះពុទ្ធ ។

និងមហាពោធិព្រឹក្ស  ដែលគួរទឹកដោយលំអុត

លំឱនចិត្តបរិសុទ្ធ  លើកកំបង់អញ្ជលី ។

និងព្រះពុទ្ធរូប  តំណាងអង្គព្រះមុនី

ដែលឋិតនៅគ្រប់ទី  ឋាននានានោះទាំងអស់ ។

ដោយតេជះនៃគុណ  ព្រះមានបុណ្យប្រសើរខ្ពស់

ដែលតែងតែរំលស់  រំដោះទុក្ខភ័យអន្តរាយ ។

សូមឱ្យខ្ញុំបានសុខ  ឃ្លាតចាកទុក្ខផងទាំងឡាយ

សត្រូវទោះជិតឆ្ងាយ  សូមឱ្យក្លាយមកជាមិត្រ ។

សូមទន់ព្រះអរី(១)-  យមេត្រីយ៍ថ្លៃវិសិដ្ឋ

សូមភ្ញៀនឃើញធម៌ពិត  សមដូចចិត្តប្រាថ្នាហោង ។

ចប់

រតនប្បញ្ញោ ពិស្តារ តែប៉ុណ្ណេះ

(១)- អរ+ណ្យ+ត >អរិយ, រិ ប្រកបនិង ២ កន្លះមាត្រា អានថា រី បានដូចជា បរមត្រ នាមរូប ។

# ត្រៃប្រណាម បែបសង្ខេប

ព្រមទាំងបូជាគ្រឿងសក្ការៈ

នមោ តស្ស

ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ប្រែថា វីកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

សូធ្យបាលី ៣ ចប់ សម្រាយតែ ១ ចប់ក៏បាន

(ក្រាបថ្វាយបង្គំម្តង)

## ពុទ្ធវន្ទនប្បណាម

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថាទេវមនុស្សានំ ពុទ្ធោ ភគវាតិ តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ គន្ធេ ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។

ប្រែថា ឥតិបិ សោ ភគវា អរហំ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគ និងវចីបយោគ,

សម្មាសម្ពុទ្ធោ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យ-ធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ,

វិជ្ជាចរណសម្បន្នោ ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥,

**សុគតោ** ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន,

**លោកវិទូ** ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក,

**អនុត្តរោ** ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរ ដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន,

**បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យ គួរនឹងទូន្មានបាន,

**សត្ថាទេវមនុស្សានំ** ទ្រង់ព្រះនាមថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ,

**ពុទ្ធោ** ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹង នូវចតុរារិយសច្ច ហើយញុំាងអ្នកដទៃ ឱ្យត្រាស់ដឹងផង,

**ភគវា** ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរ ទៅកាន់ត្រៃភពខ្ទាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

**តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រកបព្រមហើយដោយគុណ មានគុណថាអរហំ ជាដើមនោះ ដោយសិរសាគឺត្បូង,

**តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវ ព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ ។

(ក្រាបថ្វាយបង្គំម្តង)

# ធម្មវន្ទនប្បណាម

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។

ប្រែថា **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយល្អ ( ធម្មោ ព្រះនព្វលោកុត្តរធម៌ មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១ ),

សន្ទិដ្ឋិកោ ជាធម៌គឺព្រះអរិយបុគ្គលទាំងពួង ដឹងពិតឃើញពិត ដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ ដោយជឿបុគ្គលដទៃនោះ១ក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង,

អកាលិកោ ជាធម៌ឱ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ,

ឯហិបស្សិកោ ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃ ឱ្យចូលមកមើលបាន,

ឱបនយិកោ ជាធម៌គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា,

បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវ ព្រះធម៌ជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណ មានគុណថា ស្វាក្ខាតោ ជាដើមនោះ ដោយសិរសាគឺត្បូង,

តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះធម៌ជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ ។

# សង្ឃរតនប្បណាម

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ**

**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ**

**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ**

**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ**

**យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ តំ សុបដិបន្នា-ទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

ប្រែថា **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌,

**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមបដិបទា,

**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ថានក្សេមផុតចាកទុក្ខទាំងពួង,

**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់ សីល សមាធិ បញ្ញា,

**យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយ

មាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេច នូវសោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ ១ សកទាគាមិមគ្គ និងសកទាគាមិផលជាគូ ១ អនាគាមិមគ្គ និង អនាគាមិផលជាគូ ១ អរហត្តមគ្គ និងអរហត្តផលជាគូ ១,

**អដ្ឋបុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺព្រះសង្ឃដែលបានសម្រេច នូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១,

**ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនោះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ,

**អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា,

**បាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិនិងមិត្រ ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា,

**ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្មនិងផលនៃកម្ម ហើយបូជា,

**អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ,

**អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជគឺបុណ្យនៃសត្វលោករកខេត្តដទៃ ក្រៃលែងជាងគ្មាន ។

**តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវ ព្រះសង្ឃជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណ មានគុណថាសុបដិបន្នោ ជាដើមនោះ ដោយសិរសាគឺត្បូង,

**តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសង្ឃជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ ។

(ក្រាបថ្វាយបង្គំម្តង)

# រតនត្តយវន្ទនគាថា

ឥច្ចេវមច្ចន្ត នមស្សនេយ្យំ
នមស្សមានោ រតនត្តយំ យំ
បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ
តស្សានុភាវេន ហតន្តរាយោ ។

ប្រែថា ខ្ញុំសូមនមស្ការ លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា ។
សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសាធំទូលាយ ។
សូមឱ្យកំចាត់បង់ អពមង្គលទាំងឡាយ
ឱ្យចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ។
ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ។
ដោយគុណនមស្ការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វានបោរាង ។

ចប់

ត្រៃប្រណាម សង្ខេប តែប៉ុណ្ណេះ

# ត្រៃប្រណាម ប្រែភាសា

## ពុទ្ធរតនប្បណាម

ថ្វាយបង្គំព្រះពុទ្ធរតនៈ

យោ សន្និសិន្នោ វរពោធិមូលេ
មារំ សសេនំ មហតី វិជេយ្យោ
សម្ពោធិមាគច្ឆិ អនន្តញាណោ
លោកុត្តមោ តំ បណមាមិ ពុទ្ធំ ។

វីរអង្គព្រះសម្ពុទ្ធ ប្រសើរផុតអង្គឯណា
គង់ក្រោមម្លប់រុក្ខា ពោធិព្រឹក្សជាមង្គល ។
ទ្រង់ផ្ចាញ់នូវមារា ឱ្យបរាជ័យទាំងពល
ហើយព្រះអង្គបានដល់ ពោធិញ្ញាណជាសាស្តា ។
មានព្រះបញ្ញាញាណ ដឹងពុំមានសល់ត្រង់ណា
ប្រសើរលើសលោកា ខ្ញុំវន្ទាព្រះអង្គនោះ ។

## ធម្មរតនប្បណាម

ថ្វាយបង្គំព្រះធម្មរតនៈ

អដ្ឋង្គិការិយបថោ ជនានំ មោក្ខប្បវេសាយ
ឧជូ ច មគ្គោ ធម្មោ អយំ សន្តិករោ
បណីតោ និយ្យានិកោ តំ បណមាមិ ធម្មំ ។

ព្រះធម៌ប្រកបអង្គ    ជាផ្លូវត្រង់មានប្រាំបី
គន្លងព្រះអរិយ    ដ៏ប្រសើរលើសផ្លូវផង ។
ជាធម៌ល្អវិសេស    ស្ងប់កិលេសគ្រឿងសៅហ្មង
ញុំាងសត្វឱ្យបានឆ្លង    ដល់និព្វានគ្មានទុក្ខា ។
ជាធម៌ស្រោចស្រង់សត្វ    ឱ្យកំចាត់រាគតណ្ហា
រួចចាកសំសារា    ខ្ញុំវន្ទាព្រះធម៌នោះ ។

## សង្ឃរតនប្បណាម

ថ្វាយបង្គំព្រះសង្ឃរតនៈ

សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ
សន្តិន្ទ្រិយោ សព្វមលប្បហីនោ
គុណេហិនេកេហិ សមិទ្ធិបត្តោ
អនាសវោ តំ បណមាមិ សង្ឃំ ។

ព្រះសង្ឃអង្គបរិសុទ្ធ    ប្រសើរផុតចិត្តសុខុម
ទក្ខិណេយ្យដ៏ឧត្តម    មានឥន្ទ្រិយ៍ស្ងប់រម្ងាប់ ។
លះបង់មលជាតិ    គ្រឿងមិនស្អាតមន្ទិលសព្វ
សម្រេចគុណគួររាប់    ជាអនេកច្រើនប្រការ ។
ជាព្រះខីណាស្រព    ប្រសើរគាប់គួរអស្ចារ្យ
ខ្ញុំសូមនមស្សការ    ថ្វាយបង្គំព្រះសង្ឃនោះ ។

# គិហិវិន័យសង្ខេប

# បុព្វភាគបដិបត្តិ

បុរសស្ត្រីដែលមានសទ្ធាជ្រះថ្លាក្នុងគុណព្រះរតនត្រ័យ គឺគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហើយបានប្រាថ្នានឹងប្ដេជ្ញាខ្លួនជាឧបាសក ឬជាឧបាសិកា ជាបុព្វភាគបដិបត្តិ គឺសេចក្ដីប្រតិបត្តិចំណែកខាងដើម ឱ្យបានពេញសិបជាអ្នកកាន់ព្រះពុទ្ធសាសនា ឬជាអ្នកតម្កល់នៅក្នុងព្រះពុទ្ធ-សាសនានោះ, ដំបូងបង្អស់ត្រូវបញ្ចេញវិចិកេទ សូមខមាទោសនឹងព្រះរតនត្រ័យ ក្នុងទីចំពោះព្រះភ័ក្ត្រព្រះពុទ្ធរូបក៏បាន ចំពោះព្រះស្ដូប ឬព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះសម្មា-សម្ពុទ្ធក៏បាន ចំពោះបុគ្គល គឺភិក្ខុ ១ រូបក៏បាន ចំពោះមុខគណៈ គឺភិក្ខុ ២ រូប ឬ ៣ រូបក៏បាន ចំពោះព្រះសង្ឃ គឺភិក្ខុទាំងឡាយ តាំងពី ៤ រូបឡើងទៅក៏បាន លុះសូមខមាទោសរួចហើយ ត្រូវបញ្ចេញវិចិកេទពោលប្រកាសប្ដេជ្ញាខ្លួន ឱ្យជាអ្នកដល់នូវព្រះត្រៃសរណគមន៍ ជាឧបាសក ឬជាឧបាសិកា ក្នុងព្រះពុទ្ធសាសនាជាខាងក្រោយ រួចហើយត្រូវសមាទាននិច្ចសីលរក្សាឱ្យខ្ជាប់តទៅ, បើមានសទ្ធាជ្រះថ្លា ក៏គប្បីរក្សាឧបោសថសីល តាមកាលកំណត់ដែលត្រូវរក្សាម្ដងៗនោះផង នឹងមានផលានិសង្សច្រើន ដោយលំដាប់ៗឡើង ។

ឯពាក្យសូមខមាទោសនឹងព្រះរតនត្រ័យនោះ បើបុរសតែម្នាក់ ឬ ស្ត្រីតែម្នាក់ ត្រូវសូធ្យថា :

**អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ /១យោហំ / យាហំ ភន្តេ កាយេន វា វាចាយ វា មនសា វា ភគវតោ / ពុទ្ធស្ស វា / ធម្មស្ស វា / សង្ឃស្ស វា អគារវំ អកាសិ / តស្ស / តស្សា / មេ ភន្តេ ភគវា / អយ្យោ / អយ្យា / សង្ឃោ / អច្ចយំ អច្ចយតោ / បដិគ្គណ្ហតុ / បដិគ្គណ្ហន្តុ / អាយតឹ សំវរាយ ៗ**

(ប្រែថា) បពិត្រព្រះដ៏មានព្រះភាគ / ព្រះករុណា / ព្រះករុណាទាំងឡាយព្រះសង្ឃដ៏ចម្រើន ទោសកំហុសដែលប្រព្រឹត្តកន្លង គ្របសង្កត់ហើយនូវខ្ញុំព្រះករុណា តាមដោយខ្ញុំព្រះករុណា ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះដ៏មានព្រះភាគ / ព្រះករុណា / ព្រះករុណាទាំងឡាយ / ព្រះសង្ឃដ៏ចម្រើន ក្រែងខ្ញុំព្រះករុណា

បានធ្វើ ហើយនូវសេចក្ដីល្មើស មិនគោរពដល់ព្រះដ៏មានព្រះភាគ / ព្រះពុទ្ធជាម្ចាស់ក្ដី ដល់ព្រះធម៌ក្ដី ដល់ព្រះសង្ឃក្ដី / ដោយកាយក្ដី ដោយវាចាក្ដី ដោយចិត្តក្ដី បពិត្រព្រះដ៏មានព្រះភាគ / ព្រះករុណា / ព្រះករុណាទាំងឡាយ ព្រះសង្ឃដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ / ព្រះករុណា / ព្រះករុណាទាំងឡាយ / ព្រះសង្ឃ / អត់នូវទោសកំហុសនោះ ដល់ខ្ញុំព្រះករុណា ព្រោះអំពើនៃទោសនោះ ជាសេចក្ដីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្តឱ្យល្អទៅក្នុងខាងមុខនោះហោង ។

រួចជាបុគ្គល ឬគណៈ ឬសង្ឃ ដែលនៅជាប្រធាននៅទីនោះ ត្រូវទទួលថា សាធុ (ប៊ែរ៉ុចា) ប្រពៃហើយ ។

បើបុរសត្រូវសូធ្យថា យោហំ ថា តស្ស មេ, បើស្ត្រីត្រូវសូធ្យថា យាហំ ថា តស្សា មេ, តាមគួរដល់បាលីភាសា ដែលត្រូវផ្លាស់តាមបុរស-ស្ត្រី, ទោះបុរសក្ដី ស្ត្រីក្ដី បើសូមខមាទោស ក្នុងទីចំពោះមុខព្រះភក្ត្រព្រះពុទ្ធរូប ឬចំពោះព្រះស្តូប ឬព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះសម្មាសម្ពុទ្ធនោះ ត្រូវសូធ្យថា ភគវតោ វា ថា ភន្តេ ភគវា ថា បដិគ្គណ្ហតុ, បើចំពោះនឹងភិក្ខុ ១ រូប ត្រូវសូធ្យថា ពុទ្ធស្ស វា ថា ភន្តេ អយ្យោ ថា បដិគ្គណ្ហតុ, បើចំពោះគណៈ គឺភិក្ខុ ២រូប ឬ ៣រូប ត្រូវសូធ្យថា ពុទ្ធស្ស វា ថា ភន្តេ អយ្យា ថា បដិគ្គណ្ហន្តុ, បើចំពោះព្រះសង្ឃ ត្រូវសូធ្យថា ពុទ្ធស្ស វា ថា ភន្តេ សង្ឃោ ថា បដិគ្គណ្ហតុ, គ្រង់សេចក្ដីប្រែក៏មានរបៀបតាមផ្លូវបាលី ដែលខណ្ឌដោយកំនូសទ្រេត ( / ) នោះដែរ ។

បើសុទ្ធតែបុរស ឬសុទ្ធតែស្ត្រីច្រើននាក់ ឬបុរសនិងស្ត្រីច្រើននាក់លាយគ្នា តាំងពីពីរនាក់ឡើងទៅ ហើយសូធ្យសូមខមាទោសព្រមគ្នានោះ ត្រូវសូធ្យថា :

**អច្ចយោ នោ ភន្តេ អច្ចគមា / យថាពាលេ / យថាពាលា / យថាមូឡ្ហេ / យថាមូឡ្ហា / យថាអកុសលេ / យថាអកុសលា / យេ / យា មយំ ភន្តេ កាយេន វា វាចាយ វា មនសា វា ភគវតោ / ពុទ្ធស្ស វា / ធម្មស្ស វា / សង្ឃស្ស វា អគារវំ អករិម្ហា /**

**តេសំ / តាសំ / នោ ភន្តេ / ភគវា / អយ្យោ / អយ្យា / សង្ឃោ / អច្ចយំ អច្ចយតោ / បដិគ្គណ្ហាតុ / បដិគ្គណ្ហន្តុ / អាយតឹ សំវរាយ ។**

(សេចក្ដីប្រែដូចគ្នានឹងបែបមុន ប្លែកគ្នាតែត្រង់ពាក្យថា "ខ្ញុំព្រះករុណា" នោះ ក្នុងទីនេះត្រឡប់ប្រែថា "ខ្ញុំព្រះករុណាទាំងឡាយ" ដូច្នេះវិញ, ក្រៅពីនោះ នៅដូចគ្នាទាំងអស់) ។

បើបុរសត្រូវថា **យថាពាលេ យថាមូឡ្ហេ យថាអកុសលេ, យេ មយំ** ថា **តេសំ នោ** បើស្ត្រីត្រូវថា **យថាពាលា យថាមូឡ្ហា យថាអកុសលា, យា មយំ** ថា **តាសំ នោ** បើទុកជាគ្នាច្រើន មានបុរសមានស្ត្រីលាយគ្នា ហើយសូធ្យសូមខមាទោសព្រមគ្នានោះ ក៏ត្រូវតែសូធ្យខុសគ្នាត្រង់បទដែលខ័ណ្ឌដោយគំនូសទ្រេតនោះផងដែរ វៀរលែងតែត្រង់បទ ៣ អន្លើ គឺត្រង់បទថា **ភគវតោ វា ពុទ្ធស្ស វា, ភគវា** 'អយ្យោ អយ្យា សង្ឃោ, បដិគ្គណ្ហាតុ បដិគ្គណ្ហន្តុ នេះត្រូវសូធ្យដូចគ្នាទាំងបុរសទាំងស្ត្រី·' តែបើគ្នាច្រើន ហើយសូធ្យសូមខមាទោសព្រមគ្នាទាំងអស់នោះ បើមិនបាច់សូធ្យដោយពាក្យពហុវចនៈ តាមបែបខាងក្រោមនេះ នឹងសូធ្យដោយពាក្យឯកវចនៈតាមបែបមុននោះក៏បាន ព្រោះសូធ្យសូមខមាទោសព្រមទាំងអស់គ្នា ។

លុះបានសូមខមាទោស នឹងព្រះរតនត្រ័យដូច្នេះរួចហើយ គប្បីបញ្ចេញវិធីភេទប្ដេជ្ញាខ្លួនជាអ្នកដល់ត្រៃសរណគមន៍ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭក ដើម្បីនឹងឱ្យឡើងនាមបញ្ញត្តិជាឧបាសក ឬជាឧបាសិកា ក្នុងព្រះពុទ្ធសាសនាតទៅ, ឯការប្ដេជ្ញាខ្លួននោះនឹងប្ដេជ្ញាក្នុងទីចំពោះព្រះភ័ក្ត្រព្រះពុទ្ធរូបក៏បាន ចំពោះព្រះស្តូប ឬព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះសម្មាសម្ពុទ្ធក៏បាន ចំពោះបុគ្គល ឬគណៈ ឬសង្ឃក៏បាន ។

បើបុរសតែម្នាក់ ឬស្ត្រីតែម្នាក់ សូធ្យប្ដេជ្ញាខ្លួនចំពោះមុខបុគ្គល ឬគណៈ ឬសង្ឃនោះត្រូវប្ដេជ្ញាដោយពាក្យថា :

**ឯសាហំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច / ឧបាសកំ / ឧបាសិកំ / មំ អយ្យោ / អយ្យា / សង្ឃោ / ធារេតុ / ធារេន្តុ / អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។**

(ប្រែថា) បពិត្រ / ព្រះករុណា / ព្រះករុណាទាំងឡាយ / ព្រះសង្ឃ / ដ៏ចម្រើន ខ្ញុំព្រះករុណា សូមដល់នូវព្រះដ៏មានព្រះភាគ ដែលទ្រង់បរិនិព្វានទៅអស់កាលយូរអង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឮក សូម / ព្រះករុណា / ព្រះករុណាទាំងឡាយ / ព្រះសង្ឃ / ជ្រាបនូវខ្ញុំព្រះករុណាថាជា / ឧបាសក / ឧបាសិកា បានដល់ហើយនូវព្រះរតនត្រ័យជាទីពឹងទីរឮកស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

រួចបុគ្គល ឬគណៈ ឬសង្ឃ ត្រូវទទួលថា សាធុ (ប្រែដូចមុន) ។

បើបុរសត្រូវថា **ឧបាសកំ,** បើស្ត្រីត្រូវថា **ឧបាសិកំ,** ត្រង់ពាក្យថា **អយ្យោ ធារេតុ, អយ្យា ធារេន្តុ, សង្ឃោ ធារេតុ** នេះ មានសេចក្តីអធិប្បាយដូចក្នុងវិធីសូមខមាទោសខាងដើម ។

បើគ្នាច្រើនតាំងពីពីរនាក់ឡើងទៅ ទោះសុទ្ធតែបុរសក្តី សុទ្ធតែស្ត្រីក្តី បុរសនិងស្ត្រីលាយគ្នាក្តី ត្រូវសូធ្យថា :

**ឯតេ មយំ / ឯតា មយំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច / ឧបាសកេ / ឧបាសិកាយោ / នោ អយ្យោ / អយ្យា / សង្ឃោ / ធារេតុ / ធារេន្តុ / អជ្ជតគ្គេ បាណុបេតេ សរណំ គតេ / បាណុបេតា សរណំ គតា ។**

(សេចក្តីប្រែដូចគ្នានឹងបែបមុន ប្លែកគ្នាតែត្រង់ពាក្យ មុនថា "ខ្ញុំព្រះករុណា" នោះ ក្នុងទីនេះថា "ខ្ញុំព្រះករុណាទាំងឡាយ" ដូច្នេះវិញ, ក្រៅពីនោះ នៅដូចគ្នាទាំងអស់) ។

បើបុរសតែម្នាក់ ឬស្ត្រីតែម្នាក់ ហើយសូធ្យប្តេជ្ញាខ្លួនចំពោះព្រះពុទ្ធរូប ឬព្រះស្តូប ឬព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះសម្មាសម្ពុទ្ធនោះ ត្រូវពោលប្តេជ្ញាដោយពាក្យថា:

**ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច / ឧបាសកំ / ឧបាសិកំ / មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។**

(ប្រែថា) បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណា សូមដល់នូវព្រះដ៏មានព្រះភាគផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក, សូមព្រះដ៏មានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះករុណាថាជា / ឧបាសក / ឧបាសិកា បានដល់ហើយនូវ ព្រះរតនត្រ័យជាទីពឹងទីរឭកស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

បើគ្នាច្រើន ក៏ត្រូវសូធ្យដូចន័យមុន ខុសគ្នាតែត្រង់ពាក្យថា **ភគវន្តំ** ថា **ភគវា** ប៉ុណ្ណោះ, បើគ្នាច្រើន ហើយនឹងសូធ្យប្ដេជ្ញាខ្លួន ព្រមគ្នាដោយពាក្យជាឯកវចនៈក៏បាន ព្រោះសូធ្យព្រមទាំងអស់គ្នា ។

បុរស ឬស្ត្រី កាលបើបានពោលពាក្យប្ដេជ្ញាខ្លួន ជាអ្នកបានដល់នូវព្រះត្រៃសរណគមន៍ជាទីពឹងទីរឭក ដូច្នេះរួចហើយ ក៏បាននាមបញ្ញត្តិថា «ឧបាសក» ឬ «ឧបាសិកា» ក្នុងខណៈ នោះឯង ។

វិធីសូមខមាទោសក្ដី វិធីប្ដេជ្ញាខ្លួនជាឧបាសក ឧបាសិកាក្ដី បើអ្នកដែលមិនចេះសូធ្យជាបាលី នឹងសូធ្យជាសេចក្ដីសម្រាយតាមភាសារបស់ខ្លួននោះក៏បាន, បើចេះសូធ្យទាំងបាលីទាំងសេចក្ដីប្រែសម្រាយផង ដូចបានពោលមកហើយនោះជាការប្រពៃពិត តែកុំសូធ្យតែបាលីទទេ ដោយមិនដឹងថាអ្វីនោះឡើយ ព្រោះកិច្ចដែលសូធ្យខមាទោស នឹងប្ដេជ្ញាខ្លួននោះ ត្រូវយកសទ្ធា គឺសេចក្ដីជឿជាក់ និងបញ្ញាជាសម្មាទិដ្ឋិដែលដឹងពិត យល់ត្រូវពិតជាប្រមាណ ។

ចប់បុព្វភាគបដិបត្តិតែប៉ុណ្ណោះ

# ឧបាសកនិទ្ទេស

## សម្តែងអំពីនាមថាឧបាសក

## និងធម៌របស់ឧបាសកផ្សេងៗ មានសីលជាដើម

ជនដែលមាននាមបញ្ញត្តិថា «**ឧបាសក**» នោះ ដោយហេតុដែលបានចូលទៅអង្គុយជិត ព្រះរតនត្រ័យដែលជាទីពឹងទីរឭក ដូចពុទ្ធភាសិតដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងចំពោះ មហានាមសក្យរាជថា «ម្នាលមហានាម គ្រហស្ថឯណាមួយ បានដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭក គ្រហស្ថនោះឯង បានឈ្មោះថា **ឧបាសក** (បើស្ត្រីហៅថា **ឧបាសិកា**)» ។

ម្យ៉ាងទៀត បាលីថា **រតនត្តយំ ឧបាសតីតិ ឧបាសកោ** ជនឯណាចូលទៅអង្គុយជិតព្រះរតនត្រ័យ ជននោះឈ្មោះថា ឧបាសក ។

អធិប្បាយថា ជនដែលចូលទៅអង្គុយជិតព្រះរតនត្រ័យនោះ គឺមិនមែនជាចូលទៅអង្គុយជិតព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជានិច្ចដោយរូបកាយនោះទេ គឺលោកសង្គ្រោះយកនាមកាយជាប្រមាណ, សូម្បីជននោះស្ថិតនៅក្នុងទីឆ្ងាយប៉ុន្មាន តែមានសន្តានចិត្តប្រព្រឹត្តជាប់នៅក្នុងគុណព្រះរតនត្រ័យជានិច្ច, ចិត្តនោះឱនទៅតោងយកគុណព្រះរតនត្រ័យជាទីពឹងទីរឭកជានិច្ចហើយ ជននោះឈ្មោះថា បានចូលទៅអង្គុយជិតព្រះរតនត្រ័យជានិច្ច, បើគ្រាន់តែចូលទៅអង្គុយជិតព្រះពុទ្ធដោយរូបកាយ តែសន្តានចិត្តនោះស្ថិតនៅក្នុងទីឆ្ងាយអំពីគុណព្រះរតនត្រ័យ មិនបង្អោនចិត្តទៅក្នុងគុណព្រះរតនត្រ័យទេ ជននោះឈ្មោះថាស្ថិតនៅឆ្ងាយអំពីគុណព្រះរតនត្រ័យ មិនមែនជា «ឧបាសក, ឧបាសិកា» ឡើយ ។

## សីលនៃឧបាសក

បញ្ចវិរតិចេតនា គឺចេតនាដែលវៀរចាកវេរាទាំង ៥ ឈ្មោះថាជា «សីលនៃឧបាសក» ដូចពុទ្ធភាសិតដែលព្រះបរមគ្រូជាម្ចាស់ ទ្រង់ត្រាស់សម្តែងចំពោះមហានាមសក្យរាជថា "ម្នាលមហានាម ឧបាសកឯណា បានវៀរចាកបាណាតិបាត គឺមិនសម្លាប់សត្វ ១ វៀរចាកអទិន្នាទាន

គឺមិនលួចទ្រព្យអ្នកដទៃ ១ វៀរចាកកាមេសុមិច្ឆាចារ គឺមិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ វៀរចាកមុសាវាទ គឺមិននិយាយកុហក ១ វៀរចាកសុរាមេរយៈ គឺមិនផឹកនូវទឹកសុរានិងមេរ័យ ១ ឧបាសកនោះ ឈ្មោះថា ឧបាសកមានសីល ។

## អាជីវៈនៃឧបាសក

កិរិយាលះបង់នូវជំនួញ ៥ ប្រការ ហើយប្រកបកិច្ចការចិញ្ចឹមជីវិតដោយត្រឹមត្រូវតាមធម៌ ឈ្មោះថា "អាជីវៈនៃឧបាសក" ដូចមានពុទ្ធប្បញ្ញត្តិ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ហាមចំពោះភិក្ខុទាំងឡាយថា **បញ្ចិមា ភិក្ខវេ វណិជ្ជា ឧបាសកេន អករណីយា** ម្នាលភិក្ខុទាំងឡាយ ជំនួញខុសទាំងឡាយ ៥ ប្រការ ឧបាសកមិនគប្បីធ្វើឡើយ ។

ជំនួញខុស ៥ ប្រការ នោះគឺ :

១- **សត្ថវណិជ្ជា** ជួញគ្រឿងអាវុធសម្រាប់ប្រហារ គឺធ្វើគ្រឿងសស្ត្រាវុធនោះដោយខ្លួនឯង ឬឱ្យអ្នកដទៃគេធ្វើឱ្យ ឬបានមកដោយហេតុណាមួយ ហើយលក់នូវគ្រឿងសស្ត្រាវុធនោះ ។

២- **សត្តវណិជ្ជា** ជួញមនុស្ស ។

៣- **មំសវណិជ្ជា** ជួញសាច់ គឺចិញ្ចឹមនូវសត្វទាំងឡាយ មានគោជាដើម លុះដល់សត្វទាំងឡាយនោះចម្រើនធំឡើង ក៏សម្លាប់យកសាច់លក់ ។

៤- **មជ្ជវណិជ្ជា** ជួញទឹកស្រវឹង គឺផ្សំគ្រឿងស្រវឹងឯណាមួយ ឱ្យកើតឡើងជាទឹកស្រវឹងដោយខ្លួនឯង ឬទិញគេយកមក ហើយលក់ដូរនូវទឹកស្រវឹងនោះ ។

៥- **វិសវណិជ្ជា** ជួញថ្នាំពិស គឺចាត់ចែងផ្សំថ្នាំពិសឱ្យកើតឡើងដោយខ្លួនឯង ឬឱ្យគេផ្សំឱ្យ ឬបានមកដោយហេតុណាមួយ ហើយលក់នូវថ្នាំពិសនោះ ។

ឧបាសក កាលបើវៀរចាកជំនួញខុសទាំង ៥ ប្រការនេះ ហើយបានប្រតិបត្តិការចិញ្ចឹមជីវិតដោយធម៌ ឈ្មោះថាមានអាជីវធម៌ដោយប្រពៃ ។

## វិបត្តិនៃឧបាសក

ធម្មជាតិដែលញ៉ាំងសីល និង អាជីវធម៌នៃឧបាសកឱ្យវិនាស ឈ្មោះថា "វិបត្តិ" ។ វិបត្តិនោះមាន ៥ យ៉ាងគឺ :

១- អស្សទ្ធោ ហោតិ ឧបាសកមិនជឿគុណព្រះរតនត្រ័យ ។

២- ទុស្សីលោ ហោតិ ឧបាសកទ្រុស្តសីល (គឺមិនមានសីល) ។

៣- កោតូហលមង្គលិកោ ហោតិ ឧបាសកប្រកបដោយមង្គលភ្ញាក់ផ្អើល ។

៤- មង្គលំ បច្ចេតិ នោ កម្មំ ឧបាសកប្រកាន់ជឿថា មង្គលមានឫក្សពារវេលាជាដើមឱ្យផល មិនប្រកាន់ជឿកម្មជាកុសល និងអកុសលឱ្យផលឡើយ ។

៥- ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ តត្ថ ច បុព្វការំ ករោតិ ឧបាសកស្វែងរកតែទក្ខិណេយ្យបុគ្គល គឺបដិគ្គាហកៈអ្នកទទួលទានខាងក្រៅព្រះពុទ្ធសាសនា ហើយធ្វើនូវទានដល់ទក្ខិណេយ្យបុគ្គល ខាងក្រៅព្រះពុទ្ធសាសនានោះ ។

ឧបាសកឯណា ប្រកបដោយវិបត្តិ ៥ យ៉ាងនេះ ត្រង់វិបត្តិណាមួយហើយ, ឧបាសកនោះឈ្មោះថា "ឧបាសកចណ្ឌាល" គឺឧបាសកដូចជាមនុស្សចណ្ឌាលផង ឈ្មោះថា "ឧបាសកមលៈ" ឧបាសកមានធម៌ជាមន្ទិលសៅហ្មងផង ឈ្មោះថា "ឧបាសកបដិកិដ្ឋៈ" គឺឧបាសកដែលអ្នកប្រាជ្ញទាំងឡាយលោកតិះដៀលផង ។

## សម្បត្តិនៃឧបាសក

ធម្មជាតិដែលញ៉ាំងសីល និងអាជីវធម៌នៃឧបាសកឱ្យបរិបូណ៌ ឱ្យបរិសុទ្ធប្រពៃ ឈ្មោះថា "សម្បត្តិ" ។ សម្បត្តិនោះមាន ៥ យ៉ាងគឺ :

១- សទ្ធោ ហោតិ ឧបាសកមានសេចក្ដីជឿជាក់ច្បាស់ក្នុងគុណព្រះរតនត្រ័យ ។

២- សីលវា ហោតិ ឧបាសកមានសីល ។

៣- ន កោតុហលមង្គលិកោ ហោតិ ឧបាសកមិនប្រកបដោយមង្គលភ្ញាក់ផ្អើល។

៤- កម្មំ បច្ចេតិ នោ មង្គលំ ឧបាសកប្រកាន់ជឿថាកម្មជាកុសល និងអកុសលឱ្យផល មិនប្រកាន់ជឿថាមង្គលមានឫក្សពារវេលាជាដើមឱ្យផលឡើយ ។

៥- ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ ឧបាសកមិនស្វែងរកទក្ខិណេយ្យបុគ្គល គឺបដិគ្គាហកៈ អ្នកទទួលទានខាងក្រៅព្រះពុទ្ធសាសនាឡើយ ហើយធ្វើទានតែក្នុងទក្ខិណេយ្យបុគ្គល ក្នុងព្រះពុទ្ធសាសនានេះ ។

ឧបាសកឯណា ប្រកបដោយសម្បត្តិ ៥ យ៉ាងនេះហើយ, ឧបាសកនោះ ឈ្មោះថា "ឧបាសករតនៈ" គឺឧបាសកដូចជារតនវត្ថុមានកែវជាដើមផង ឈ្មោះថា "ឧបាសកបទុមៈ" គឺឧបាសកដូចជាផ្កាឈូកពណ៌ក្រហមផង ឈ្មោះថា "ឧបាសកបុណ្ឌរីកៈ" គឺឧបាសកដូចជាផ្កាឈូកមានពណ៌សផង ។

## គុណនៃឧបាសក

ធម៌សម្រាប់ឧបាសក ឧបាសិកាប្រតិបត្តិគ្រប់រូប ដើម្បីនឹងឱ្យកើតឱ្យចំរើននូវសម្បត្តិទាំងពួង ឈ្មោះថា គុណ ។ គុណនេះជារបស់ឧបាសក ឧបាសិកា ហៅថា "ឧបាសកគុណ" មាន ១០ យ៉ាងគឺ :

១- សង្ឃេន សទ្ធឹ សមានសុខទុក្ខោ ហោតិ ឧបាសកអ្នករួមសេចក្ដីសុខទុក្ខមួយអន្លើដោយភិក្ខុសង្ឃ គឺថាបើភិក្ខុសង្ឃមានសេចក្ដីសុខក៏ត្រេកអរ បើភិក្ខុសង្ឃមានសេចក្ដីទុក្ខព្រួយ ក៏ព្រួយជាមួយផង ។

២- កាយិកវាចសិកញ្ច សុរក្ខិតំ ហោតិ ឧបាសកមានកាយកម្ម និងវចីកម្មរក្សាហើយដោយប្រពៃ

៣- ធម្មា អធិបតេយ្យោ ហោតិ ឧបាសកមានធម៌ជាអធិបតី គឺថាបើប្រព្រឹត្តធ្វើអ្វីៗរមែងកាន់យកធម៌ជាធំ ជាទីតាំងជាទីអាងមាំមិនឱ្យខុស មិនឱ្យឃ្លៀងឃ្លាតអំពីធម៌ឡើយ ។

៤- យថាថាមេន សំវិភាគរតោ ច ហោតិ ឧបាសកជាអ្នកត្រេកអរក្នុងការបរិច្ចាគទាន តាមសមគួរដល់កម្លាំងនៃខ្លួន គឺធ្វើទានតាមសមគួរដល់ទ្រព្យតិចនិងច្រើន បើមានតិចក៏ធ្វើតិច បើមានច្រើនក៏ធ្វើច្រើន មិនមានមច្ឆរិយធម៌គ្របសង្កត់សន្ដានចិត្តឡើយ ។

៥- ជិនសាសនំ ជានិតុញ្ច ឧាយមតិ ឧបាសកឧស្សាហ៍ព្យាយាម ដើម្បីនឹងឱ្យដឹងច្បាស់នូវសាសនៈ គឺពាក្យប្រៀនប្រដៅពាក្យបណ្ដាំនៃព្រះជិនស្រី ។

៦- សម្មាទិដ្ឋិកោ ច ហោតិ ឧបាសកជាសម្មាទិដ្ឋិ គឺមានប្រាជ្ញាឃើញត្រូវតាមសេចក្ដីពិត ។

៧- អបគតោ កោតូហលមង្គលិកោ ច ហោតិ ឧបាសកប្រាសចាកមង្គលភ្ញាក់ផ្អើល ហើយជាអ្នកមិនប្រកាន់ជឿថា មង្គលមានឫក្សពារវេលាជាដើមឱ្យផលឡើយ ប្រកាន់ជឿតែកម្មជាកុសល និងអកុសលថាឱ្យផល ។

៨- ជីវិតហេតុបិ អញ្ញំ សត្ថារំ ន ឧទ្ទិសតិ ឧបាសកបើទុកជាមានហេតុគួរដល់នូវសេចក្ដីវិនាសជីវិតក្ដី ក៏មិនលះបង់ព្រះរតនត្រ័យ ហើយត្រឡប់ទៅកាន់យកមនុស្សដទៃជាគ្រូអាចារ្យ ជាទីពឹងរបស់ខ្លួន ថាប្រសើរជាងព្រះរតនត្រ័យនោះឡើយ ។

៩- សមគ្គារាមោ ច ហោតិ ឧបាសកមានសេចក្ដីត្រេកអរក្នុងសាមគ្គីធម៌ គឺសេចក្ដីព្រមព្រៀងគ្នា ។

១០- សាសនេ ចរតិ ឧបាសកប្រព្រឹត្តល្អក្នុងព្រះពុទ្ធសាសនា គឺប្រព្រឹត្តតាមតែធម៌វិន័យជាពុទ្ធសាសនា ។

ឧបាសកគុណទាំង ១០ យ៉ាងនេះ ឧបាសក, ឧបាសិកា គប្បីប្រព្រឹត្តតាមកុំឱ្យឃ្លៀងឃ្លាតឡើយ ព្រោះជាធម៌អាចនឹងធ្វើចិត្តឧបាសក ឧបាសិកា អ្នកប្រព្រឹត្តឱ្យសុចរិតផូរផង់ក្នុងព្រះពុទ្ធសាសនា ហើយឱ្យបានជាបច្ច័យនៃទិព្វនិសម្បត្តិផង ។

ឧបាសកនិទ្ទេស

ចប់តែប៉ុណ្ណោះ

# វិធីសមាទាននិច្ចសីល

ពុទ្ធសាសនិកជនដែលបានដល់ព្រះត្រៃសរណគមន៍ បានឡើងនាមបញ្ញត្តិជាឧបាសក ឬ ឧបាសិកាហើយ កាលបើនឹងសមាទាននូវនិច្ចសីល គឺសីល ៥ ជាបច្ចេកសមាទានអំពីបុគ្គលដទៃ គឺភិក្ខុ ឬសាមណេរនោះ គប្បីសូធ្យនមស្សការថ្វាយបង្គំ រឮកដល់គុណព្រះរតនត្រ័យ ដោយសង្ខេបជាមុន រួចហើយត្រូវសូមនូវនិច្ចសីល ព្រមទាំងព្រះត្រៃសរណគមន៍ចំពោះនិងភិក្ខុ ឬសាមណេរ ដែលខ្លួននឹងសមាទាននោះថា :

ឱកាស, / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាមិ / យាចាម;

ទុតិយម្បិ / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាមិ / យាចាម;

តតិយម្បិ / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាមិ / យាចាម ៗ

ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា,

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង ។

ឬនឹងសូមថា ឱកាស, / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាមិ / យាចាម;

ទុតិយម្បិ / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាមិ / យាចាម;

តតិយម្បិ / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាមិ / យាចាម អនុគ្គហំ កត្វា សីលំ ទេថ / មេ / នោ / ភន្តេ ៗ

ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេង១គ្នា, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឱ្យនូវសីល ដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ,

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវនិច្ចសីលប្រកបដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេង១គ្នា ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឱ្យនូវសីល ដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ ។

( សូមដូច្នេះក៏បាន តាមសេចក្តីពេញចិត្តរបស់អ្នកសូម )

១ បើអ្នកសមាទានមានតែម្នាក់ ត្រូវថា អហំ ថា យាចាមិ ត្រង់ប្រែត្រូវថា "ខ្ញុំព្រះករុណា" សូម ថា មេ ត្រង់ប្រែត្រូវថា "ដល់ខ្ញុំព្រះករុណា" បើគ្នាច្រើនតាំងពីពីរនាក់ឡើងទៅ នឹងសូមតែម្នាក់ថា មយំ ថា យាចាម ក៏បាន ត្រង់ប្រែត្រូវថា "ខ្ញុំព្រះករុណាទាំងឡាយ" សូម ថា នោ ត្រង់ប្រែត្រូវថា "ដល់ខ្ញុំព្រះករុណាទាំងឡាយ", តែថាបើគ្នាច្រើន ហើយសូមសូធ្យព្រមគ្នានោះ នឹងសូធ្យសូម ថា អហំ ថា យាចាមិ ថា មេ ក៏បាន ព្រោះសូធ្យសូមទាំងអស់គ្នា, លុះសូមដូច្នេះរួចហើយ លោកអ្នកឱ្យសីលលោកសូធ្យ នមោ ៣ ចប់ ហើយលោកឱ្យនូវព្រះត្រៃសរណគមន៍និងនិច្ចសីល, អ្នកសមាទានត្រូវទទួលថាតាមលោក ដោយបញ្ចេញវចីភេទឱ្យច្បាស់លាស់, កុំទទួលខ្សឹបៗ ។

លោកសូធ្យថាៈ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។ ( សូធ្យ ៣ ដង )

ប្រែថា វិកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ។

ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ។

សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ។

ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

តតិយម្បិ ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

ហើយលោកថា តិសរណគ្គហណំ បរិបុណ្ណំ (ប្រែថា) កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍បរិបូណ៌តែប៉ុណ្ណេះ ។

អ្នកសមាទានត្រូវទទួលថា **អាម ភន្តេ** (ប្រែថា) ករុណាលោកម្ចាស់ ។ ហើយលោកឱ្យនិច្ចសីលជាបច្ចេកសមាទានថា :

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា កាន់យកនូវវត្ថុដែលគេមិនបានឱ្យ ដោយកាយ ឬ ដោយវាចា ។

**កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

**មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ពោលនូវពាក្យកុហក ។

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។

៙

រួចហើយលោកអ្នកឱ្យសីល លោកពោលដាស់តឿនក្រើនរំឭកថា

**ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ ។**

(ប្រែថា) អ្នក / អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៥ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អអស់កាលជានិច្ច ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

បើអ្នកសមាទានមានតែម្នាក់ត្រូវថា "អ្នក", បើគ្នាច្រើនត្រូវថា "អ្នកទាំងឡាយ" ។

អ្នកសមាទានត្រូវទទួលថា **អាម ភន្តេ** (ប្រែដូចមុន) ហើយលោកសម្តែងអានិសង្ស សីលឱ្យស្តាប់តទៅទៀតថា :

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**

**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។**

ប្រែថា សត្វទាំងឡាយទៅកាន់ឋានសួគ៌បានក៏ព្រោះសីល សត្វទាំងឡាយបានបរិបូណ៌ ដោយភោគៈក៏ព្រោះសីល សត្វទាំងឡាយទៅកាន់ទីរលត់ទុក្ខ គឺព្រះនិព្វានបានក៏ព្រោះសីល ព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជម្រះនូវសីលឱ្យបរិសុទ្ធ កុំឱ្យសៅហ្មងឡើយ ។

អ្នកសមាទានត្រូវទទួលថា **សាធុ** (ប្រែថា) ប្រពៃហើយ ។

វិធីសមាទាននិច្ចសីលជាបច្ចេកសមាទាន

ចប់តែប៉ុណ្ណេះ

# វិធីសមាទានឧបោសថសីល

ឧបាសក ឧបាសិកាជាអ្នករក្សានូវឧបោសថសីល កាលបើដល់ថ្ងៃជិតនឹងរក្សានូវឧបោសថសីល គឺថ្ងៃមុន ១ ថ្ងៃ ដែលកំណត់ថាព្រឹកឡើង នឹងរក្សានូវឧបោសថនោះ គប្បីចាត់ចែងការងារដែលគួរនឹងចាត់ចែង មានវិធីចាត់ចែងនូវអាហារជាដើម ដែលជាការងារគឺខ្លួននឹងត្រូវធ្វើ ឬនឹងត្រូវប្រើឱ្យគេធ្វើក្នុងថ្ងៃស្អែក គឺក្នុងថ្ងៃឧបោសថកាល ឱ្យហើយក្នុងថ្ងៃនោះមុន តែកុំចាត់ចែងការងារ ដែលមិនប្រកបដោយធម៌ ដែលជាការងារគឺខ្លួនជាឧបាសក ឧបាសិកាមិនគួរនឹងចាត់ចែងនោះឡើយ, លុះដល់ព្រឹកឡើងជាថ្ងៃឧបោសថកាល ត្រូវរក្សានូវឧបោសថសីល គប្បីភ្ញាក់ឡើងអំពីព្រលឹម ហើយខ្ពុរមាត់ជម្រះធ្មេញឱ្យស្អាត រួចហើយបើបានសមាទាននូវឧបោសថសីលក្នុងវេលានោះ ក៏ជាការប្រពៃ បើឃើញថានឹងសមាទានពីព្រលឹមនោះមិនទាន់ទេ ក៏គប្បីកំណត់នូវឧបោសថកាល គឺកាលជាទីរក្សានូវឧបោសថសីលក្នុង ១ ថ្ងៃ ១ យប់នោះ ដោយបញ្ចេញវាចាអធិដ្ឋានថា :

**អជ្ជ ឧបោសថោ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ ឧបោសថិកោ / ឧបោសថិកា / ភវិស្សាមិ ។**

វ៉ែប្រថា ថ្ងៃនេះជាថ្ងៃត្រូវរក្សានូវឧបោសថសីល, ខ្លួនអញនឹងជាអ្នករក្សានូវឧបោសថសីលអស់ថ្ងៃនេះ និងយប់នេះ ។

បើឧបាសក *ត្រូវថា* **ឧបោសថិកោ**, បើឧបាសិកា *ត្រូវថា* **ឧបោសថិកា** ។

បើមិនចេះបាលី នឹងអធិដ្ឋានតាមភាសារបស់ខ្លួនៗ ក៏គួរដោយពិត, លុះអធិដ្ឋានកំណត់កាលដូច្នេះហើយ ត្រូវតាំងវិរតិចេតនាវៀរចាកសីលភេទ គឺហេតុដែលជាទីទម្លាយនូវសីលនោះៗ ឱ្យគ្រប់សិក្ខាបទទាំង ៨, កាលបើបានអធិដ្ឋានដូច្នេះរួចហើយ តអំពីពេលនោះមក ក៏គប្បីសមាទាននូវឧបោសថសីល អំពីបុគ្គលដទៃមានភិក្ខុជាដើម តាមកាលដ៏គួរចុះ បើទុកជាដល់ពេលព្រះអាទិត្យរះខ្ពស់ឡើងប្រមាណពេញពន្លឺធំ ទើបបានសមាទានក្តី ក៏ឈ្មោះថាបានសមាទានដោយប្រពៃ ឈ្មោះថាបានរក្សានូវឧបោសថសីល ពេញកាលកំណត់ ១ ថ្ងៃ ១ យប់ ដោយបរិបូណ៌ ព្រោះអ្នកសមាទានបានធ្វើនូវឧបោសថកាល មិនឱ្យខ្វះខាតទាំងវិរតិចេតនាសោត ក៏កើតចាស់ក្លាបរិបូណ៌ក្នុងសន្តាន នឹងបានផលានិសង្សច្រើន ។

កាលបើ ឧបាសក ឧបាសិកា នឹងសមាទាននូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ ជាបច្ចេកសមាទាន អំពីបុគ្គលដទៃគឺភិក្ខុ ឬសាមណេរនោះ គប្បីសូត្រនមស្ការថ្វាយបង្គំរឭកដល់គុណព្រះរតនត្រ័យដោយសង្ខេបជាមុន រួចហើយត្រូវសូមនូវឧបោសថសីល ព្រមទាំងព្រះ-ត្រៃសរណគមន៍ ចំពោះភិក្ខុ ឬសាមណេរ ដែលខ្លួននឹងសមាទាននោះថា :

**ឱកាស, / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខណត្ថាយ តិសរណេន សហ អដ្ឋ សីលានិ / យាចាមិ / យាចាម;**

**ទុតិយម្បិ / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខណត្ថាយ តិសរណេន សហ អដ្ឋ សីលានិ / យាចាមិ / យាចាម;**

**តតិយម្បិ / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខណត្ថាយ តិសរណេន សហ អដ្ឋ សីលានិ / យាចាមិ / យាចាម ៗ**

ប្រែដូចក្នុងវិធីសូមនិច្ចសីលខាងដើម ប្លែកគ្នាតែត្រង់ពាក្យថា **អដ្ឋ សីលានិ** (ប្រែថា) នូវសីលទាំងឡាយ ៨ ។

ឬនឹងសូមថា **ឱកាស, / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខណត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ / យាចាម;**

**ទុតិយម្បិ / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខណត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ / យាចាម;**

**តតិយម្បិ / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខណត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ / យាចាម អនុគ្គហំ កត្វា សីលំ ទេថ / មេ / នោ / ភន្តេ ៗ**

ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បី

ប្រយោជន៍នឹងរក្សាផ្សេងៗគ្នា, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា, ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ ។

សូមដូច្នេះក៏បាន តាមសេចក្តីពេញចិត្តរបស់អ្នកសូម ។ សេចក្តីអធិប្បាយអំពីអ្នកសូមតែម្នាក់ និងច្រើនអ្នកនោះ ដូចគ្នានឹងវិធីសូមនិច្ចសីលខាងដើម ។

រួចហើយលោកអ្នកឱ្យសីល លោកតាំង នមោ ៣ ចប់ ហើយឱ្យព្រះត្រៃសរណគមន៍, អ្នកសមាទានត្រូវទទួលតាមលោក ដូចវិធីសមាទាននិច្ចសីលខាងដើម, រួចហើយលោកឱ្យនូវឧបោសថសីល ជាបច្ចេកសមាទានថា :

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា កាន់យកនូវវត្ថុដែលគេមិនបានឱ្យ ដោយកាយ ឬដោយវាចា ។

**អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម។

**មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ពោលនូវពាក្យកុហក ។

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។

**វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា បរិភោគនូវភោជនាហារក្នុងកាលខុស ។

**នច្ចគីតវាទិតវិសូកទស្សន មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា រាំនិងច្រៀងនិងប្រគំនិងមើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ និងកិរិយាទ្រទ្រង់និងប្រដាប់តាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។

**ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកទីសេនាសនៈ ដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។

រួចហើយអ្នកសមាទាន សូត្យកំណត់ឧបោសថកាលថា :

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ៗ**

ប្រែថា ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ដ៏ប្រកបដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់បញ្ញត្តទុកហើយនេះ ដើម្បីនឹងរក្សាឱ្យបរិបូណ៌ប្រពៃ អស់កាលកំណត់ថ្ងៃនេះ និងយប់នេះ សូមកុសលចូលជាឧបនិស្ស័យធ្វើឱ្យច្បាស់នូវព្រះនិព្វាន ក្នុងអនាគតទៅឯមុខនោះហោង ។

បាលីនេះគ្រាន់តែជាពាក្យសម្រាប់ពោលកំណត់ឱ្យដឹងថា ឧបោសថសីលទាំង ៨ សិក្ខាបទនេះ អ្នកសមាទានត្រូវរក្សាតែត្រឹម ១ ថ្ងៃ ១ យប់នោះ ប៉ុណ្ណោះ, ហេតុនោះ បើអ្នកសមាទានបានចេះដឹងច្បាស់ប្រាកដក្នុងឧបោសថកាលហើយ មិនបាច់សូត្យក៏បាន, តែបើទុកជា

ចេះដឹងច្បាស់ប្រាកដហើយ នឹងសូធ្យបាលីនេះ ព្រមទាំងសេចក្តីប្រែនោះ ក៏ជាការប្រពៃណាស់ ជាហេតុនាំឱ្យរឹតតែចេះស្ទាត់ប្រាកដទាំងអស់គ្នាឡើង ។

រួចហើយលោកអ្នកឱ្យសីល លោកពោលដាស់តឿនក្រើនរំឭកថា :

**ឥមានិ អដ្ឋ សិក្ខាបទានិ ឧបោសថសីលវសេន តុម្ហេ រត្តឹ តុម្ហេ ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ ។**

រ៉ែប្រថា អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៨ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អ ដោយអំណាចនៃឧបោសថសីល អស់កាលកំណត់ត្រឹម ១ ថ្ងៃ ១ យប់នេះ ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

បើអ្នកសមាទានមានតែម្នាក់ត្រូវថា "អ្នក", បើគ្នាច្រើនត្រូវថា "អ្នកទាំងឡាយ" ។

អ្នកសមាទានត្រូវទទូលថា **អាម ភន្តេ** (រ៉ែប្រដូចមុន) ។ ហើយលោកសំម្តែងអានិសង្សសីលឱ្យស្តាប់តទៅទៀតថា :

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**
**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។**

រ៉ែប្រថា សត្វទាំងឡាយទៅកាន់ឋានសួគ៌បានក៏ព្រោះសីល សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈក៏ព្រោះសីល សត្វទាំងឡាយទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វានបានក៏ព្រោះសីល ព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជម្រះនូវសីលឱ្យបរិសុទ្ធ កុំឱ្យសៅហ្មងឡើយ ។

អ្នកសមាទានត្រូវទទូលថា **សាធុ** (រ៉ែប្រថា) ប្រពៃហើយ ។

វិធីសមាទានឧបោសថសីលជាបច្ចេកសមាទាន
ចប់តែប៉ុណ្ណេះ

# ឯកជ្ឈសមាទាន

បើឧបាសក ឧបាសិកា នឹងសមាទាននិច្ចសីល ជាឯកជ្ឈសមាទាន ព្រមទាំងព្រះត្រៃសរណគមន៍ផងនោះ ត្រូវសូមដូច្នេះ :

**ឱកាស, / អហំ / ភន្តេ / មយំ / ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា បញ្ចង្គសមន្នាគតំ និច្ចសីលំ / យាចាមិ / យាចាម;**

**ទុតិយម្បិ / អហំ / មយំ / ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា បញ្ចង្គសមន្នាគតំ និច្ចសីលំ / យាចាមិ / យាចាម;**

**តតិយម្បិ / អហំ / មយំ / ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា បញ្ចង្គសមន្នាគតំ និច្ចសីលំ / យាចាមិ / យាចាម អនុគ្គហំ កត្វា សីលំ ទេថ / មេ / នោ / ភន្តេ ។**

ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ ធ្វើឱ្យឯកជ្ឈៈ គឺសមាទានរួមតែម្ដង មួយអន្លើដោយព្រះត្រៃសរណគមន៍ បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្ដីអនុគ្រោះឱ្យនូវសីលដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ,

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ ធ្វើឱ្យឯកជ្ឈៈ គឺសមាទានរួមតែម្ដង មួយអន្លើដោយព្រះត្រៃសរណគមន៍ ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្ដីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ ។

រួចហើយលោកអ្នកឱ្យសីល លោកតាំង នមោ ៣ ចប់ ហើយឱ្យព្រះត្រៃសរណគមន៍, អ្នកសមាទានត្រូវទទួលតាមលោក ដូចវិធីសមាទាននិច្ចសីលខាងដើម, រួចហើយលោកឱ្យនូវឱវាទថសីលជាឯកជ្ឈសមាទានថា :

**បញ្ចង្គសមន្នាគតំ និច្ចសីលំ សមាទិយាមិ** (ប្រែថា) ខ្ញុំព្រះករុណា សូមសមាទាននូវនិច្ចសីល ប្រកបព្រមដោយអង្គ ៥ ។

អ្នកសមាទានត្រូវទទួលថាតាមលោក ឬលោកនឹងឱ្យ **បញ្ច សីលានិ សមាទិយាមិ** (ប្រែថា) ខ្ញុំព្រះករុណា សូមសមាទាននូវសីលទាំងឡាយ ៥ ដូច្នេះក៏បាន ។ អ្នកសមាទាន ត្រូវទទួលថាតាមលោក រួចហើយលោកពោលដាស់តឿនក្រើនរំឭកថា :

**ឥមំ បញ្ចង្គសមន្នាគតំ និច្ចសីលំ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ ។**

(ប្រែថា) អ្នកទាំងឡាយគប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៥ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អអស់កាលជានិច្ច ដោយសេចក្ដីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទាន ត្រូវទទួលថា **អាម ភន្តេ** (ប្រែដូចមុន) ។ រួចហើយលោកសម្ដែងអានិសង្សសីលឱ្យស្ដាប់តទៅទៀត ដូចក្នុងវិធីបច្ចេកសមាទាន ខាងដើម ។

សមាទានតែប៉ុណ្ណេះ ក៏ជាការស្រេច គតមានសូត្យញែកឈ្មោះសិក្ខាបទទាំង ៥ រាយមួយម្ដងៗ ដូចបច្ចេកសមាទានឡើយ. សមាទានតែប៉ុណ្ណេះហើយ ត្រូវរក្សាដោយតាំងវិរតិចេតនា វៀរឱ្យគ្រប់សិក្ខាបទក្នុងនិច្ចសីលទាំង ៥ ដែលខ្លួនបានចេះចាំស្គាល់ហើយនោះទៅ ។

បើឧបាសក ឧបាសិកា នឹងសមាទានឧបោសថសីលជាឯកជ្ឈសមាទាន ព្រមទាំងព្រះត្រៃសរណគមន៍ផងនោះ ត្រូវសូមដូច្នេះ :

**ឱកាស, / អហំ / មយំ / ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ / យាចាម;**

**ទុតិយម្បិ / អហំ / មយំ / ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា អដ្ឋង្គសមន្នាគតំ ឧបោសថំ / យាចាមិ / យាចាម;**

**តតិយម្បិ / អហំ / មយំ / ភន្តេ តិសរណេន សហ ឯកជ្ឈំ**

តត្វា អដ្ឋង្គសមន្នាគតំ ឧបោសថំ / យាចាមិ / យាចាម / អនុគ្គហំ

កត្វា សីលំ ទេថ / មេ / នោ / ភន្តេ ។

ប្រែដូចវិធីប្រែសូមនិច្ចសីលជាឯកជ្ឈសមាទានខាងដើម ប្លែកគ្នាតែត្រង់ថា អដ្ឋង្គសម–ន្នាគតំ ឧបោសថំ (ប្រែថា) នូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ ប៉ុណ្ណោះ ក្រៅពីនោះដូចគ្នាទាំងអស់ ។

រួចហើយលោកអ្នកឱ្យសីល លោកតាំង នមោ ៣ ចប់ ហើយឱ្យព្រះត្រៃសរណគមន៍, អ្នកសមាទានត្រូវទទួលតាមលោក ដូចវិធីសមាទាននិច្ចសីលខាងដើម, រួចហើយលោកឱ្យនូវឧបោសថសីលជាឯកជ្ឈសមាទានថា :

អដ្ឋង្គសមន្នាគតំ ឧបោសថំ សមាទិយាមិ (ប្រែថា) ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ ។

អ្នកសមាទាន ត្រូវទទួលថាតាមលោក ឬ លោកនឹងឱ្យ អដ្ឋ សីលានិ សមាទិ–យាមិ (ប្រែថា) ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ ដូច្នេះក៏បាន, អ្នកសមាទាន ត្រូវទទួលថាតាមលោក រួចហើយអ្នកសមាទាន សូមកំណត់ឧបោសថកាលថា :

ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ។

(ប្រែដូចមុន) ។

រួចហើយលោកអ្នកឱ្យសីល លោកពោលដាស់តឿនក្រើនរំឭកថា :

ឥមានិ អដ្ឋ សិក្ខាបទានិ ឧបោសថសីលវសេន ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ ។

(ប្រែថា) អ្នកទាំងឡាយគប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៨ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អ ដោយអំណាចនៃឧបោសថសីល អស់កាលកំណត់ត្រឹម ១ ថ្ងៃ ១ យប់នេះ ដោយសេចក្ដីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទាន ត្រូវទទួលថា អាម ភន្តេ (ប្រែដូចមុន) ។ រួចហើយលោកសម្ដែងអានិសង្សសីលឱ្យស្ដាប់តទៅទៀត ន័យដូចមុន ។

សមាទានតែប៉ុណ្ណេះ ក៏ជាការស្រេច ឥតមានសូធ្យញែកឈ្មោះសិក្ខាបទទាំង ៨ រាយមួយម្ដងៗ ដូចបច្ចេកសមាទានឡើយ, សមាទានតែប៉ុណ្ណេះហើយ ត្រូវរក្សាដោយតាំងវិរតិចេតនា វៀរឱ្យគ្រប់សិក្ខាបទទាំង ៨ ក្នុងឧបោសថសីល ដែលខ្លួនបានចេះចាំស្ទាត់ហើយនោះទៅ ។

សូម្បីឧបាសក ឧបាសិកា នឹងអធិដ្ឋានជានិច្ចសីល ឬឧបោសថសីល ដោយខ្លួនឯងក្ដី ក៏គប្បីបញ្ចេញវចីភេទអធិដ្ឋានតាមបែបជាបច្ចេកៈ ឬឯកជ្ឈៈ ដូចបានពោលមកហើយនោះចុះ។

ត្រង់វិធីដែលលោកសម្ដែងអានិសង្សសីល ឱ្យអ្នកសមាទានស្ដាប់នោះ បើលោកឱ្យសីលលោកឈ្លាស ចេះចាំច្រើន ហើយអាចនឹងសម្ដែងក្នុងពេលនោះបាន ក៏គួរនឹងសម្ដែងតាមន័យប្លែកៗ ដោយអាងលើព្រះពុទ្ធភាសិតឱ្យអ្នកសមាទានស្ដាប់នោះ ក៏ជាការប្រពៃក្រៃពេក, អ្នកសមាទានបានស្ដាប់ហើយ ក៏នឹងកើតមានសេចក្ដីជ្រះថ្លា ព្រមទាំងចម្រើនសតិបញ្ញាដោយក្រៃលែងឡើងទៀត ហើយនឹងបានផលានិសង្សច្រើនណាស់ លោកអ្នកឱ្យសីលនិងអ្នកសមាទាន ។

វិធីសមាទានសីលជាឯកជ្ឈសមាទាន

ចប់តែប៉ុណ្ណេះ

# អង្គនៃនិច្ចសីល

## បាណាតិបាត មានអង្គ ៥

១- បាណោ សត្វមានជីវិត ។

២- បាណសញ្ញិតា សេចក្តីដឹងថាសត្វមានជីវិត ។

៣- វធកចិត្តំ គិតនឹងសម្លាប់ ។

៤- ឧបក្កមោ ព្យាយាមនឹងសម្លាប់ ។

៥- តេន មរណំ សត្វស្លាប់ដោយព្យាយាមនោះ ។

## អទិន្នាទាន មានអង្គ ៥

១- បរបរិគ្គហិតំ ទ្រព្យដែលមានម្ចាស់គេហួងហែងរក្សា ។

២- បរបរិគ្គហិតសញ្ញិតា សេចក្តីដឹងថាទ្រព្យមានម្ចាស់របស់គេហួងហែងរក្សា ។

៣- ថេយ្យចិត្តំ គិតនឹងលួច ។

៤- ឧបក្កមោ ព្យាយាមនឹងលួច ។

៥- តេន ហរណំ លួចបានមកដោយព្យាយាមនោះ ។

## កាមេសុមិច្ឆាចារ មានអង្គ ៤

១- អគមនីយដ្ឋានំ ស្ត្រីដែលមិនគួរនឹងគប់រក គឺស្ត្រីដែលមានគេហួងហែងរក្សា ។

២- តស្មឹ សេវនចិត្តំ គិតនឹងសេពមេថុនធម្មនិងស្ត្រីនោះ ។

៣- ឧបក្កមោ ព្យាយាមនឹងសេពមេថុនធម្ម ។

៤- មគ្គេន មគ្គប្បដិបាទនំ ញុំាងមគ្គនិងមគ្គឱ្យដល់គ្នា ។

### មុសាវាទ មានអង្គ ៤

១- អតថំ វត្ថុ វត្ថុមិនពិត ។

២- វិសំវាទនចិត្តំ គិតនឹងពោលឱ្យខុស ។

៣- តជ្ជោ វាយាមោ ព្យាយាមនឹងពោលឱ្យខុស ។

៤- បរស្ស តទត្ថវិជាននំ ញុំាងអ្នកដទៃឱ្យដឹងច្បាស់នូវសេចក្តីខុសនោះ ។

### សុរាមេរយៈ មានអង្គ ៤

១- មជ្ជនីយវត្ថុ វត្ថុជាទីតាំងនៃសេចក្តីស្រវឹង គឺសុរា និងមេរ័យ ។

២- បាតុកម្យតាចិត្តំ គិតបំរុងនឹងផឹក ។

៣- តជ្ជោ វាយាមោ ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ ។

៤- តស្ស បានំ បានផឹកនូវទឹកស្រវឹងនោះឱ្យកន្លងបំពង់កចូលទៅ ។

## អង្គនៃឧបោសថសីល

អង្គនៃ បាណាតិបាត និង អទិន្នាទាន ដូចនិច្ចសីលខាងដើម

### អព្រហ្មចរិយៈ មានអង្គ ៤

១- ភេទនវត្ថុ វត្ថុជាទីទម្លាយនូវសីល គឺទ្វារទាំង ៣០ ចំពោះត្រង់ទ្វារណាមួយ ។

២- សេវនចិត្តំ គិតនឹងសេព ។

៣- តជ្ជោ វាយាមោ ព្យាយាមនឹងសេពនូវមេថុនធម្មនោះ ។

៤- មគ្គេន មគ្គប្បដិបាទនំ ញុំាងមគ្គនិងមគ្គឱ្យដល់គ្នា ។

អង្គនៃ មុសាវាទ និង សុរាមេរយៈ ដូចនិច្ចសីលខាងដើម

## ទិវាវិកាលភោជនៈ មានអង្គ ៣

១- វិកាលោ កាលខុស គឺព្រះអាទិត្យជ្រេទៅហើយ ដរាបទល់និងអរុណរះ ។

២- យាវកាលិកំ របស់ដែលគួរបរិភោគបានក្នុងកាល គឺតាំងពីអរុណរះឡើងដរាបដល់ថ្ងៃត្រង់ ។

៣- អជ្ឈោហរណំ បានលេបចូលទៅក្នុងបំពង់ក ។

## នច្ចគីតៈ ព្រមទាំង មាលា រួមគ្នាជាសិក្ខាបទ ១ មានអង្គ ៦

១- នច្ចគីតាទិ ការលេងល្បែងមានរាំនឹងច្រៀងជាដើម ។

២- គន្ធតម្បុគាចិត្តំ គិតបំរុងនឹងធ្វើ ។

៣- សូតនស្សនត្ថាយគមនំ ទៅដើម្បីនឹងស្ដាប់ ឬមើលហើយបានស្ដាប់ ឬមើល ។

៤- មាលាទិ វត្ថុសម្រាប់ប្រដាប់កាយ មានផ្កាកម្រងជាដើម ។

៥- ធារណច្ឆន្ទតា សេចក្ដីប្រាថ្នានឹងប្រដាប់តាក់តែង ។

៦- គស្ស ធារណំ បានប្រដាប់តាក់តែងនូវវត្ថុសម្រាប់ប្រដាប់កាយ មានផ្កាកម្រងជាដើមនោះ ។

## ឧច្ចាសយនៈ មានអង្គ ៣

១- ឧច្ចាសយនមហាសយនំ ទីដេកទីអង្គុយដ៏ខ្ពស់ ដ៏ប្រសើរហួសប្រមាណ ។

២- បរិភោគចិត្តំ គិតនឹងដេក ឬអង្គុយ ។

៣- បរិភោគករណំ បានដេក ឬអង្គុយ ។

កាលបើឧបាសក ឧបាសិកា ប្រព្រឹត្តឱ្យកន្លងនូវសិក្ខាបទណា១ លុះតែព្រមដោយអង្គក្នុងសិក្ខាបទនោះ១ ទើបបានឈ្មោះថាកន្លង, បើមិនទាន់ព្រមដោយអង្គនោះ ក៏មិនបានឈ្មោះថាកន្លងនូវសិក្ខាបទនោះ១ឡើយ ។

អង្គនៃនិច្ចសីល និង ឧបោសថសីល
ចប់តែប៉ុណ្ណេះ

# ឧបោសថកាលសង្ខេប

ឧបោសថកម្មរបស់ឧបាសក-ឧបាសិកា បើពោលដោយកាល ដែលជាទីរក្សានូវឧបោសថ-សីលនោះ មានពីរប្រការគឺ បកតិឧបោសថ ១ បដិជាគរឧបោសថ ១ ។ ឧបោសថកម្មដែលប្រព្រឹត្តទៅដោយប្រក្រតី គឺឧបោសថកម្មដែលអ្នកប្រាជ្ញទាំងឡាយ លោកធ្វើមកហើយអំពីដើម ឈ្មោះថា "បកតិឧបោសថ", ឧបោសថកម្មនៃបុគ្គលភ្ញាក់រឭករឿយៗ គឺរឭកដល់ឧបោសថសីល ដែលជាកុសល គឺខ្លួនត្រូវសន្សំ ឈ្មោះថា "បដិជាគរឧបោសថ" ។

ឯកាលនៃបកតិឧបោសថនោះ ក្នុង១ខែ មាន ៨ថ្ងៃ គឺថ្ងៃចំណែកខាងសុក្កបក្ខ (ខ្នើត) ៤ថ្ងៃ, ខាងកាឡបក្ខ (រនោច) ៤ថ្ងៃ, គឺត្រង់ថ្ងៃ៥កើត ៨កើត ១៤កើត ១៥កើត, ៥រោច ៨រោច ១៤រោច ១៥រោច បើខែខ្វះត្រង់ថ្ងៃ១៤រោច ថយមក១៣រោចវិញ, ត្រង់ថ្ងៃ១៥រោច ថយមក១៤រោចវិញ, ក្នុង១ខែ មានកាលនៃបកតិឧបោសថ ៨ថ្ងៃ ដូច្នេះ ។

ឯកាលនៃបដិជាគរឧបោសថនោះ ក្នុង១ខែ មាន ១១ថ្ងៃ គឺត្រង់ថ្ងៃ៤កើត ៦កើត ៧កើត ៩កើត ១៣កើត, ១រោច ៤រោច, ៦រោច, ៧រោច, ៩រោច, ១៣រោច បើខែខ្វះត្រង់ថ្ងៃ១៣រោច ថយមក១២រោចវិញ, ថ្ងៃទាំង១១ ក្នុងខែមួយៗនេះ ជាថ្ងៃខាងដើម និងខាងចុងនៃបកតិឧបោសថ ឬថាជាថ្ងៃអមនៃបកតិឧបោសថ គឺជាកាលនៃបដិជាគរ-ឧបោសថ ។

ត្រង់ថ្ងៃឯទៀត ក្រៅអំពីបកតិឧបោសថ និងបដិជាគរឧបោសថនោះ មាន១១ថ្ងៃ គឺត្រង់ថ្ងៃ១កើត[១] ២កើត ៣កើត ១០កើត ១១កើត ១២កើត, ២រោច ៣រោច ១០រោច ១១រោច ១២រោច, បើខែខ្វះ មានតែ១០ថ្ងៃ ព្រោះត្រង់ថ្ងៃ១២រោច ទុកជាបដិជាគរ-ឧបោសថ, ថ្ងៃទាំង១១ ឬ ១០នេះ មិនមែនកាលនៃឧបោសថណាមួយឡើយ គ្រប់ៗខែទាំងអស់ ។

នឹងអធិប្បាយពីកិច្ចដែលនឹងធ្វើនូវឧបោសថកម្ម គឺបកតិឧបោសថ និងបដិជាគរឧបោសថ ជាសេចក្ដីខ្លីៗបន្តិច គ្រាន់ជាទីចំណាំសំគាល់របស់ឧបាសក ឧបាសិកា ទាំងឡាយក្នុងព្រះពុទ្ធ-សាសនា, ឯបកតិឧបោសថកម្មនោះ គឺឧបោសថសីល ដែលឧបាសក ឧបាសិកា ត្រូវទទួល

---

(១)- ក្នុងសុត្រខ្លះ មានសម្ដែងថា ថ្ងៃ ១ កើតនេះ ក៏រាប់ជាថ្ងៃបដិជាគរឧបោសថ ដែរ ។

សមាទានកាន់រក្សានូវសិក្ខាបទទាំង ៨ ក្នុងថ្ងៃបកតិឧបោសថកាល កំណត់១ថ្ងៃ ១យប់ តាមលំដាប់កាលនៃបកតិឧបោសថនោះ, ឯបដិជាគរឧបោសថនោះ គឺឧបោសថសីល ដែលឧបាសក ឧបាសិកា ត្រូវដុសខាត់សំអាតចិត្ត នឹករឭកដល់សិក្ខាបទទាំង ៨ ដែលជាអង្គនៃឧបោសថសីល, តែឧបាសក ឧបាសិកា មិនត្រូវសមាទានឡើយ គ្រាន់តែបណ្ដុះចិត្តឱ្យឃ្លាតឆ្ងាយអំពីកាមគុណ ៥ ហើយបំរុងចាំដំណើរនៃបកតិឧបោសថ គឺគ្រាន់តែតាំងចិត្តវៀរគ្រប់សិក្ខាបទទាំង ៨ មានបាណាតិបាតជាដើម ដូចជារក្សានូវឧបោសថសីលក្នុងថ្ងៃបកតិឧបោសថ-កាលនោះដែរ, ប្លែកគ្នាតែមិនសមាទាន និងសមាទានប៉ុណ្ណោះ គឺថាបដិជាគរឧបោសថនោះមិនមានសមាទានទេ គ្រាន់តែតាំងចិត្តវៀរគ្រប់សិក្ខាបទ ដែលត្រូវវៀរអស់ថ្ងៃ១ យប់១ ជាកំណត់, ឯបកតិឧបោសថសីលនោះ ត្រូវសមាទានទទួលកាន់យកនូវសិក្ខាបទទាំង ៨ រក្សាអស់ថ្ងៃ១ យប់១ នោះដែរ, វេលាដល់គ្រប់កំណត់កាល បកតិឧបោសថសីលថយទៅហើយ ត្រូវតាំងចិត្តទៅជូនដំណើរ នៃឧបោសថសីលនោះអស់ថ្ងៃ១ យប់១ ទៀត គឺតាំងចិត្តវៀរគ្រប់សិក្ខាបទទាំង ៨ តែមិនបាច់ទទួលសមាទានទេ គឺគ្រាន់តែញុំាងចិត្តឱ្យប្រព្រឹត្តទៅតាមបកតិ-ឧបោសថសីល ដែលខ្លួនទទួលសមាទានអំពីថ្ងៃម្សិលប៉ុណ្ណោះឯង ។

ឯបកតិឧបោសថកាលនោះ កាលព្រះសម្មាសម្ពុទ្ធគង់ធរមាននៅឡើយ ព្រះអង្គសម្ដែងទុកថា ក្នុង១ខែមាន ៦ថ្ងៃ ខាងខ្នើត ៣ថ្ងៃ ខាងរនោច ៣ថ្ងៃ គឺត្រង់ថ្ងៃ ៨កើត ៨រោច ហៅថា "អដ្ឋមីឧបោសថ", ១៤កើត ១៤រោច ហៅថា "ចាតុទ្ទសីឧបោសថ", ១៥កើត ១៥រោច ហៅថា "បណ្ណរសីឧបោសថ", បើខែខ្វះ ត្រង់ថ្ងៃ១៥រោច ត្រូវថយចុះ មកថ្ងៃ ១៤រោចវិញ, លុះដល់ព្រះអង្គចូលបរិនិព្វានទៅបាន ៣ខែ ព្រះអរហន្តទាំងឡាយ ៥០០ អង្គ មានព្រះមហាកស្សបត្ថេរជាដើម លោកប្រជុំធ្វើបឋមសង្គាយនាផ្ទៀងផ្ទាត់ធម៌វិន័យ លោកយល់ឃើញថា នៅរយាលថ្ងៃខាងដើមនោះពេកណាស់, ទើបលោកលើកយកថ្ងៃ ៥កើត ៥រោច មកកំណត់ទុកជាថ្ងៃបកតិឧបោសថផង រួមជាឧបោសថកាល ក្នុង១ខែៗមាន ៨ថ្ងៃៗ ព្រោះត្រង់ថ្ងៃ ៥កើត ៥រោច ជាថ្ងៃឧបោសថកាលដែរ ហៅថា "បញ្ចមីឧបោសថ"។

ចប់ឧបោសថកាល

ដោយសង្ខេបតែប៉ុណ្ណោះ

# នាទេតព្វកិច្ច

ឧបាសក ឧបាសិកា បានទទួលសមាទាននូវឧបោសថសីល ក្នុងថ្ងៃឧបោសថកាលនោះរួចហើយ ហើយចង់ឱ្យបានផលានិសង្សច្រើនក្នុងថ្ងៃនោះ ក្នុងយប់នោះ ត្រូវសង្រួមកាយវាចាឱ្យបានសមគួររៀបរយតាមពុទ្ធានុញ្ញាតទុកមក ។

ឯការដែលសង្រួមកាយឱ្យបានសមគួរនោះ គឺត្រូវលះបង់នូវគ្រឿងសៅហ្មងដល់ព្រហ្មចារីសីល ដែលខ្លួនបានសមាទានហើយក្នុងថ្ងៃនោះ យប់នោះ ។ សង្រួមវាចាឱ្យបានសមគួរនោះ គឺត្រូវលះបង់នូវតិរច្ឆានកថាទាំង ៣២ យ៉ាង មាននិយាយអំពីបាយ ថាអាក្រក់ល្អជាដើម ហើយគួរប្រកបពោលនូវពាក្យជាទីសប្បាយ ១៣ ប្រការ មានពោលអំពីសីល ៥ សីល ៨ និងអានិសង្ស នៃសីល ៥ សីល ៨, អំពីសមាធិកម្មដ្ឋាន ៤០, អំពីវិបស្សនាបញ្ញាជាដើម ។

បើបានសង្រួមកាយវាចា ឱ្យបានសមគួរហើយ, ក្នុងថ្ងៃនោះ យប់នោះ ត្រូវស្តាប់ធម៌ទេសនា ឬធ្វើធម្មសាកច្ឆា គឺសាកសួរអំពីធម៌, បើមិនបានស្តាប់ធម៌នោះទេ ត្រូវសង្រួមចិត្ត គឺតាំងចម្រើននូវកម្មដ្ឋានក្នុងសមថកម្មដ្ឋានទាំង ៤០ប្រការ ត្រង់កម្មដ្ឋានណាមួយក៏បាន ។ ឯកម្មដ្ឋានទាំង៤០នោះ មានសេចក្តីពិស្តារក្នុងគម្ពីរវិសុទ្ធិមគ្គបាលី ឬសម្រាយ ត្រង់សមាធិនិទ្ទេសជានិទ្ទេសទី ២, ក្នុងទីនេះមិនបានសម្តែងអំពីកម្មដ្ឋានទាំងនោះដោយសព្វគ្រប់ទេ គ្រាន់តែប្រាប់របៀប និងធម៌ដែលត្រូវចម្រើននោះខ្លះប៉ុណ្ណោះ ។ ព្រះសុភាសិតសម្តែងថា "អ្នកដែលនឹងចម្រើននូវកម្មដ្ឋានទាំង ៤០ប្រការ ត្រង់កម្មដ្ឋានណាមួយក្តី នោះត្រូវចម្រើននូវមូលកម្មដ្ឋានគឺពុទ្ធានុស្សតិកម្មដ្ឋានសិន ហើយទើបចម្រើននូវកម្មដ្ឋានឯទៀតតទៅ តាមគួរដល់អធ្យាស្រ័យ" ។

## វិធីដែលនឹងចម្រើននោះ ដូច្នេះ :

ឧបាសក ឧបាសិកា មុននឹងចម្រើនកម្មដ្ឋាននោះ ត្រូវពិចារណានូវទោសនៃកាមគុណឱ្យឃើញច្បាស់ថា រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ទាំង ៥នេះ រមែងកើតទោសទុក្ខផ្សេងៗ ឬនឹងពិចារណានូវខន្ធ ៥ ឱ្យឃើញថាជា អនិច្ចំ ទុក្ខំ អនត្តា គឺឱ្យឃើញថា រូបខន្ធនេះមិនទៀង មិនតាំងនៅ តែងវិនាសទៅដោយហេតុផ្សេងៗ មានវិនាសដោយចំហាយក្តៅ និងត្រជាក់ជាដើម រូបនេះរមែងនាំមកនូវសេចក្តីទុក្ខព្រួយ, រូបនេះរមែងបែកធ្លាយជាធម្មតា រក

ខ្លឹមសារគ្មានសោះឡើយ ឯវេទនាខន្ធ សញ្ញាខន្ធ សង្ខារខន្ធ វិញ្ញាណក្ខន្ធសោត ក៏ជាអនិច្ចំ ទុក្ខំ អនត្តា ដូចនឹងរូបក្ខន្ធនោះដែរ ។

ម្យ៉ាងទៀត គប្បីពិចារណាធម៌ដែលជាទីសង្វេគនោះថា ជនទាំងឡាយដែលកើតមកក្នុងលោកនេះ រកទីពឹងពំនាក់ឱ្យមាំមួននោះពុំមាន សុទ្ធតែអ្នកកំព្រាម្នាក់ឯង មានមាតាបិតា ស្វាមីភរិយា កូនប្រុស-ស្រី មិត្តសម្លាញ់ មានទ្រព្យសម្បត្តិ ក៏ទុកដូចជាគ្មាន ព្រោះថាជនទាំងឡាយ មានមាតាបិតាជាដើមនោះ មិនអាចនឹងបែងចែកនូវសេចក្ដីសុខទុក្ខ ឱ្យដល់គ្នានឹងគ្នាបានឡើយ, មិនអាចនឹងជួយការពារ ឬជូនដំណើរគ្នាទៅក្នុងកាលដែលមរណសង្គ្រាមមកដល់ចំពោះរូបនីមួយៗនោះបានឡើយ ពេលដែលមរណសង្គ្រាមមកដល់ខ្លួន សត្វទាំងអស់ក៏ជាអ្នកឥតមានគ្នីគ្នាឡើយ, បើប្រទះបានសេចក្ដីទុក្ខ ដែលកើតអំពីអកុសលកម្មដែលខ្លួនធ្វើហើយក្នុងកាលមុនស្លាប់នោះ ក៏ត្រូវតែទទួលយកនូវសេចក្ដីនោះដោយឆាប់រហ័ស ឬបើប្រទះបានសេចក្ដីសុខដែលជាផលនៃកុសលកម្ម ដែលខ្លួនបានកសាងល្អមកហើយ ក្នុងពេលមុនស្លាប់នោះ ក៏ត្រូវទទួលរងនូវសេចក្ដីសុខនោះដោយបរិបូណ៌ ចំពោះតែខ្លួនមួយប៉ុណ្ណោះ ទោះខ្លួនមានទ្រព្យសម្បត្តិក្នុងលោកនេះតិចច្រើនប៉ុន្មានៗក្ដី ក៏មិនអាចយកទៅផងបានឡើយ ។

កាលបើ ឧបាសក ឧបាសិកា បានពិចារណាដូច្នេះហើយ ក៏នឹងឃើញថា មនុស្សសត្វប្រុសស្រីទាំងអស់ នឹងរកគ្នីគ្នាមកជាទីពឹងពំនាក់ ឱ្យបានមាំមួននោះពុំមានឡើយ, ឃើញតែគុណទាំងឡាយ មានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងទាន សីល ភាវនា ជាដើមនេះឯង ទើបជាទីពឹងដ៏វិសេស អាចនឹងជួយឧបត្ថម្ភគាំពារទំនុកបំរុង ក្នុងកាលដែលមច្ចុសង្គ្រាមមកផ្ដាច់ផ្ដិលនូវជីវិតិន្ទ្រិយ៍របស់សត្វទាំងពួងនោះ ឱ្យបានសុខស្រួលរៀងរាបដរាបទៅដល់លោកខាងមុខទៀតបាន ។

ឧបាសក ឧបាសិកា កាលបើបានពិចារណាឃើញសេចក្ដីយ៉ាងនេះហើយ ក៏នឹងមានចិត្តឱនទៅកាន់ព្រះពុទ្ធគុណ ព្រះធម្មគុណ ព្រះសង្ឃគុណ, បើឃើញថាចិត្តរបស់ខ្លួនឱនទៅកាន់គុណព្រះរតនត្រ័យហើយ គប្បីពិចារណានូវព្រះនាម របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទាំង ១០ ព្រះនាម មាន "អរហំ" ជាដើម ឱ្យបានកើតសេចក្ដីជ្រះថ្លា ក្នុងព្រះនាមទាំងនោះហើយ គប្បីលើកឡើងនូវព្រះនាមទាំងនោះមកភាវនា គឺថាយកគុណទាំងនោះ មកនឹករំពឹងតែក្នុងចិត្តម្យ៉ាង មិនបានបញ្ចេញវាចាឱ្យលាន់ឮឡើយ ។

ឯកិច្ចដែលនឹងអង្គុយចម្រើនភាវនានោះ ក្នុងបាលីដែលជាពុទ្ធភាសិត បង្គាប់ថាអង្គុយពែនជើង ហើយធ្វើកាយឱ្យត្រង់ល្មមស្រួល ហើយបែរមុខចំទៅខាងមុខ តម្កល់ស្មារតីឱ្យនឹងនៅក្នុងអារម្មណ៍ ដែលខ្លួនបំរុងនឹងលើកឡើង មកកាន់វិធីភាវនានោះ ។

## វិធីដែលនឹងភាវនាធម៌ មាន ៣ យ៉ាងគឺ :

១- ឱ្យរំពឹងថា **ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ។បេ។ ពុទ្ធោ ភគវាតិ** ហើយត្រឡប់មកតាំងនឹករំពឹងខាងដើមទៅទៀត, រំពឹងយ៉ាងនេះ ទោះ១រយចប់ ឬ ១ពាន់ចប់ក៏បាន តាមកម្លាំងសទ្ធា ។ល។

២- នឹងនឹករំពឹងថា **ភគវា ឥតិបិ ភគវា អរហំ សោ ភគវា ឥតិបិ សម្មាសម្ពុទ្ធោ សោ ភគវា ឥតិបិ វិជ្ជាចរណសម្បន្នោ ។បេ។ សោ ភគវា ឥតិបិ ភគវា** ហើយត្រឡប់មកតាំងនឹករំពឹងពីខាងដើមទៅទៀត នឹករំពឹងយ៉ាងនេះបាន ១រយចប់ ឬ១ពាន់ចប់ ក៏បាន ។

៣- នឹងនឹករំពឹងតែ ១បទៗ ដូចរំពឹងថា **អរហំៗ** ឬថា **សម្មាសម្ពុទ្ធោៗ** ។ល។ **ពុទ្ធោៗ** ឬថា **ភគវាៗ** ដូច្នេះក៏បាន នឹងរំពឹងយ៉ាងនេះក្នុង ១បទៗ ទោះបាន ១រយចប់ក្តី ១ពាន់ចប់ក្តីក៏បាន តាមពេញចិត្តរបស់ខ្លួន, ត្រូវនឹករំពឹងដោយដឹងសេចក្តីផង ដូចមានបែបប្រែក្នុងត្រៃប្រណាមខាងដើមនោះស្រាប់ហើយ ។

ឯទីសេនាសនៈដែលឧបាសក ឧបាសិកា នឹងអង្គុយចម្រើននោះ គប្បីរកទីឱ្យស្ងាត់ ទាំងពេលសោត ក៏ត្រូវរកឱ្យស្ងាត់ចាកសូរស័ព្ទសំឡេងទាំងពួង កុំឱ្យលាន់ឮគឹកកង ដើម្បីនឹងធ្វើឱ្យអារម្មណ៍តាំងនៅនឹងល្អ ។

កាលបើឧបាសក ឧបាសិកា បានតាំងភាវនារំពឹងដល់ពុទ្ធគុណដូច្នេះហើយ ក៏នឹងអាចឱ្យកើតបានតែត្រឹមបីតិ ៥ យ៉ាង :

១- **ខុទ្ទកា បីតិ** សេចក្តីត្រេកអរព្រឺរោមព្រឺស្បែក,

២- **ខណិកា បីតិ** សេចក្តីត្រេកអរប្រាកដដូចជាផ្លេកបន្ទោរ,

៣- ឱក្កន្តិកា បីតិ សេចក្ដីត្រេកអរមានអាការប្រាកដ ដូចជារលកទឹកបោកខ្ទប់មកត្រូវ,

៤- ឧព្វេង្គា បីតិ សេចក្ដីត្រេកអរខ្លាំង អាចញ៉ាំងកាយឱ្យអណ្ដែតឡើង,

៥- ផរណា បីតិ សេចក្ដីត្រេកអរធ្វើឱ្យត្រជាក់ជ្រួតជ្រាបទូទៅក្នុងកាយ ។

បីតិទាំង ៥ យ៉ាងនេះ ត្រង់បីតិណាមួយ រមែងកើតឡើងដោយអំណាចការនាំរំពឹងដល់ពុទ្ធគុណដែលជាមូលកម្មដ្ឋាន ហើយនឹងបានផលានិសង្ស អាចឱ្យសម្រេចតែត្រឹមឧបចារជ្ឈានប៉ុណ្ណោះ មិនអាចនឹងឱ្យសម្រេចដល់អប្បនាឈាន គឺបឋមជ្ឈាននោះបានឡើយ ព្រោះពុទ្ធគុណនេះ ជាគុណជ្រាលជ្រៅអនេកអនន្តពន់ពេកណាស់ អ្នកដែលចម្រើននោះ មិនអាចនឹងពិចារណាឱ្យយល់សព្វគ្រប់ទៅបាន ។

ចប់ភាវេតព្វកិច្ច

ដោយសង្ខេបតែប៉ុណ្ណោះ

# វិធីសមាទានសីល ១០

ឧបាសក ឧបាសិកា នឹងសមាទាននូវសីល ១០ អំពីបុគ្គលដទៃ គឺភិក្ខុ ឬសាមណេរនោះ គប្បីសូធ្យនមស្ការថ្វាយបង្គំ រឭកដល់គុណព្រះរតនត្រ័យជាមុនសិន រួចហើយត្រូវសូមនូវសីល ១០ ព្រមទាំងព្រះត្រៃសរណគមន៍ ចំពោះភិក្ខុ ឬសាមណេរ ដែលខ្លួននឹងសមាទាននោះថា :

**ឧកាស, / អហំ / មយំ / ភន្តេ តិសរណេន សហ ទស សីលានិ / យាចាមិ / យាចាម;**

**ទុតិយម្បិ / អហំ / មយំ / ភន្តេ តិសរណេន សហ ទស សីលានិ / យាចាមិ / យាចាម;**

**តតិយម្បិ / អហំ / មយំ / ភន្តេ តិសរណេន សហ ទស សីលានិ / យាចាមិ / យាចាម / អនុគ្គហំ កត្វា សីលំ ទេថ / មេ / នោ / ភន្តេ ។**

ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវសីលទាំងឡាយ ១០ ព្រមទាំងព្រះត្រៃសរណគមន៍ ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវសីលទាំងឡាយ ១០ ព្រមទាំងព្រះត្រៃសរណគមន៍ សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង ។

បើអ្នកសមាទានមានតែម្នាក់ ត្រូវថា **អហំ** ថា **យាចាមិ** ត្រង់ប្រែត្រូវថា "ខ្ញុំព្រះករុណា" សូម ថា **មេ** ត្រង់ប្រែត្រូវថា "ដល់ខ្ញុំព្រះករុណា" បើគ្នាច្រើនតាំងពីពីរនាក់ឡើងទៅ នឹងសូមតែម្នាក់ថា **មយំ** ថា **យាចាម** ក៏បាន ត្រង់ប្រែត្រូវថា "ខ្ញុំព្រះករុណាទាំងឡាយ" សូម ថា **នោ** ត្រង់ប្រែត្រូវថា "ដល់ខ្ញុំព្រះករុណាទាំងឡាយ".

តែថាបើគ្នាច្រើន ហើយសូមសូធ្យព្រមគ្នានោះ នឹងសូធ្យសូម ថា អហំ ថា យាចាមិ ថា មេ ក៏បាន ព្រោះសូធ្យសូមទាំងអស់គ្នា, លុះសូមដូច្នេះរួចហើយ លោកអ្នកឱ្យសីល លោកសូធ្យ នមោ ៣ ចប់ ហើយលោកឱ្យនូវព្រះត្រៃសរណគមន៍និងនិច្ចសីល, អ្នកសមាទាន ត្រូវទទួលថាតាមលោក ដោយបញ្ចេញវចីភេទឱ្យច្បាស់លាស់, កុំទទួលខ្សឹបៗ ។

កាលបើឧបាសក ឧបាសិកា សមាទានសីល ១០ ព្រមទាំងព្រះត្រៃសរណគមន៍រួចហើយ លោកអ្នកឱ្យសីលត្រូវថា :

**យមហំ វទាមិ តំ វទេហិ** ប្រែថា "អាត្មាពោលពាក្យណា ចូរអ្នកពោលនូវពាក្យនោះ" ។ បើឧបាសក ឧបាសិកាច្រើនគ្នា តាំងពីពីរនាក់ឡើងទៅ, លោកអ្នកឱ្យសីលត្រូវថា :

**យមហំ វទាមិ តំ វទេថ** ប្រែថា "អាត្មាពោលពាក្យណា ចូរអ្នកទាំងឡាយពោលនូវពាក្យនោះ"។ អ្នកទទួលសីលត្រូវតបថា **អាម ភន្តេ** "ព្រះករុណាលោកម្ចាស់" ។

រួចហើយលោកអ្នកឱ្យសីល លោកតាំង នមោ ៣ ចប់ បន្ទាប់មកឱ្យព្រះត្រៃសរណគមន៍តទៅទៀត, អ្នកសមាទានត្រូវទទួលតាមលោក ដូចវិធីសមាទាននិច្ចសីល, និងឧបោសថសីលខាងដើម រួចហើយលោកឱ្យនូវសីល ១០ ដូច្នេះថា :

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា កាន់យកនូវវត្ថុដែលគេមិនបានឱ្យ ដោយកាយ ឬដោយវាចា ។

**អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម។

**មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ពោលនូវពាក្យកុហក ។

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។

**វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា បរិភោគនូវភោជនាហារក្នុងកាលខុស ។

**នច្ចគីតវាទិតវិសូកទស្សនា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា រាំនិងច្រៀង និងប្រគំនិងមើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ ។

**មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ទ្រទ្រង់និងប្រដាប់តាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រងនិងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។

**ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកទីសេនាសនៈ ដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។

**ជាតរូបរជតប្បដិគ្គហណា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ទទួលកាន់យកនូវមាសនិងប្រាក់ដោយខ្លួនឯង ឬប្រើអ្នកដទៃឱ្យទទួលកាន់យក ហើយត្រេកអរចំពោះមាសនិងប្រាក់នោះ ។

លុះទទួលសីល ១០ ចប់ហើយ លោកអ្នកឱ្យសីលគួរប្រាប់បញ្ជាក់ថា :

ឥមានិ ទស សិក្ខាបទានិ អប្បមាទេន សម្មារក្ខិតព្វំ ។

ប្រែថា អ្នកត្រូវរក្សាដោយប្រពៃនូវសិក្ខាបទទាំងឡាយ ១០ ដោយសេចក្ដីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

បើអ្នកសមាទានមានតែម្នាក់ត្រូវថា "អ្នក", បើគ្នាច្រើនត្រូវថា "អ្នកទាំងឡាយ" ។

អ្នកសមាទានត្រូវទទួលថា អាម ភន្តេ ប្រែថា (ករុណាលោកម្ចាស់) ។

លំដាប់មកទៀត លោកអ្នកឱ្យសីលសម្ដែងអានិសង្សសីលដោយសង្ខេប ឬដោយពិស្ដារ ឱ្យអ្នកសមាទានស្ដាប់តាមកាលគួរ តាមតែសម្ដែងអានិសង្សសីលត្រង់ណាក៏បាន គឺទៅតាមសមត្ថភាពរបស់លោកអ្នកឱ្យសីល ។

## អានិសង្សសីលសង្ខេប

សីលេន សុគតឹ យន្តិ
សីលេន ភោគសម្បទា
សីលេន និព្វុតឹ យន្តិ
តស្មា សីលំ វិសោធយេ ។

ប្រែថា សត្វទាំងឡាយទៅកាន់ឋានសួគ៌បានក៏ព្រោះសីល សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈក៏ព្រោះសីល សត្វទាំងឡាយទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វានបានក៏ព្រោះសីល ព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជម្រះនូវសីលឱ្យបរិសុទ្ធ កុំឱ្យសៅហ្មងឡើយ ។

កិកីវ អណ្ឌំ ចមរីវ វាលធឹ
បិយំវ បុត្តំ នយនំវ ឯកកំ
តថេវ សីលំ អនុរក្ខមានកា
សុបេសលា ហោថ សទា សគារវា ។

សត្វត្រដេវវិច រក្សានូវស៊ុតវា យ៉ាងណាមិញ, សត្វចាមរី រក្សានូវកន្ទុយវា យ៉ាងណាមិញ, មាតារក្សានូវកូនប្រុស ជាទីស្រឡាញ់តែមួយ យ៉ាងណាមិញ, ជនមានភ្នែកតែម្ខាងរក្សានូវភ្នែក យ៉ាងណាមិញ, អ្នកទាំងឡាយ កំពុងរក្សាសីល ជាអ្នកមានសីលជាទីស្រឡាញ់ដ៏ក្រៃលែង ចូរជាអ្នកប្រកបដោយសេចក្ដីគោរពសីល ឱ្យបានសព្វកាល ក៏យ៉ាងនោះដែរ ។

សីលំ យោគិស្ស លង្ការោ
សីលំ យោគិស្ស មណ្ឌនំ
សីលេហិ លង្កតោ យោគី
មណ្ឌនេ អគ្គតំ គតោ ៕

សីលជាគ្រឿងអលង្ការរបស់យោគី (អ្នករក្សាសីល) សីលជាគ្រឿងប្រដាប់របស់យោគី (អ្នករក្សាសីល) យោគី (អ្នករក្សាសីល) ប្រដាប់តាក់តែងដោយសីលទាំងឡាយ បានដល់នូវភាវៈខ្ពង់ខ្ពស់ក្នុងការប្រដាប់ (រាងកាយ) ។

## អធិប្បាយសង្ខេប

សីលនេះលោករាប់ថាជា អរិយទ្រព្យ ជាទ្រព្យប្រសើរវិសេសថ្លៃថ្លា ជាងទ្រព្យមានវិញ្ញាណ ឥតវិញ្ញាណរបស់បុរសស្ត្រីក្នុងលោកនេះ ។ ពុទ្ធសាសនិកជន អ្នកមានវិចារណញ្ញាណគង់នឹងអាចរិះរកឃើញយល់បានដោយងាយ ។

ន បុប្ផគន្ធោ បដិវាតមេតិ
ចន្ទនំ តគរមល្លិកា វា
សតញ្ច គន្ធោ បដិវាតមេតិ
សព្វា ទិសា សប្បុរិសោ បវាយតិ ៕

ក្លិនផ្កាបក់ផ្សាយច្រាសខ្យល់ពុំបានទេ, ក្លិនខ្លឹមចន្ទន៍ក្ដី ក្រស្នាក្ដី ក្លិនផ្កាម្លិះរួតក្ដី បក់ផ្សាយច្រាសខ្យល់ពុំបានទេ, មានតែក្លិននៃពួកសប្បុរស (អ្នកមានសីល) ទើបបក់ផ្សាយច្រាសខ្យល់បាន, សប្បុរស (អ្នកមានសីល) បក់ផ្សាយក្លិនសព្វទិសានុទិស ទាំងបណ្ដោយខ្យល់ ទាំងច្រាសខ្យល់ ។

ចន្ទនំ តគរំ វាបិ
ឧប្បលំ អថ វស្សិកី
ឯតេសំ គន្ធជាតានំ
សីលគន្ធោ អនុត្តរោ ។

ខ្លឹមចន្ទន៍ក្តី ក្រស្នាក្តី ផ្កាឧប្បលក្តី ផ្កាម្លិះលាក្តី (សុទ្ធតែមានក្លិនក្រអូប) ប៉ុន្តែក្លិនសីលក្រអូបក្រៃលែងជាងគន្ធជាតិទាំងនុ៎ះ (ឥតគន្ធជាតិអ្វីក្រអូបដូចក្លិនសីលឡើយ) ។

សព្វេសំ គន្ធជាតានំ សម្បត្តី អភិភុយ្យតិ
អចិយាតី ទសទិសា សីលគន្ធោ បវាយតិ ។

ក្លិនសីលរមែង (ក្រអូប) គ្របសង្កត់នូវគន្ធជាតិសម្បត្តិក្នុងពូកផ្កាទាំងអស់, ក្លិនសីលរមែងសាយភាយបក់ទៅកាន់ទិសទាំង ១០ ឥតមានទើសទាក់ឡើយ ។

យា មនុស្សេសុ សម្បត្តិ យា ច ទេវេសុ សម្បទា
ន សា សម្បន្នសីលស្ស ឥច្ឆិតា ហោតិ ទុល្លភា ។

សម្បត្តិឯណា ក្នុងមនុស្សទាំងឡាយ សម្បទាឯណា ក្នុងទេវតាទាំងឡាយ សម្បត្តិនិងសម្បទានោះ ជនអ្នកមានសីលមិនបាច់ប្រាថ្នាឡើយ ជារបស់បានងាយៗដោយមិនលំបាកឡើយ (ដូច្នេះជនអ្នកមានសីល្ល រមែងបានសម្រេចនូវបំណងគ្រប់យ៉ាង) ។

សីលវន្តំ ន ពាធន្តិ អាសវា ទិដ្ឋធម្មិកា
សម្បរាយិកទុក្ខានំ មូលំ ខណតិ សីលវា ។

អាសវៈទាំងឡាយ ក្នុងបច្ចុប្បន្ន មិនគ្របសង្កត់នូវសីលវន្ត ជនអ្នកមានសីល, ជនអ្នកមានសីល ជាអ្នកជីកគាស់រំលើងនូវឫសគល់ដែលជាមើម នៃសេចក្តីទុក្ខទាំងឡាយក្នុងលោកខាងមុខ ។

# បែបអ្នករក្សាសីល ១០

ឧបាសក ឧបាសិកា អ្នករក្សាសីល ១០ ត្រូវកោរសក់, បើមានពុកមាត់ ពុកចង្កា ក៏ត្រូវកោរផងដែរ, ត្រូវកាត់ក្រចកដៃជើងឱ្យស្មើនឹងសាច់ ត្រូវស្លៀកពាក់ស ឬពានាស់ពត់ស ផងក៏បាន តាមគួរដល់ការលៃលក ឱ្យសមរម្យតាមសភាពបុរសនិងស្ត្រី ។

សីលកើតមានឡើងដោយសារវិរតិចេតនា ពុំមែនដោយសារកោរសក់ ស្លៀកពាក់សទេ ក៏ពិតមែនហើយ, ប៉ុន្តែការកោរសក់ស្លៀកពាក់សនេះ ជាប្រវេណីមួយសម្រាប់គ្រហស្ថអ្នករក្សាសីល ១០ ក្នុងព្រះពុទ្ធសាសនា, ជាគ្រឿងសំគាល់ ឱ្យឃើញប្លែកពីគ្រហស្ថទាំងពួង ទាំងជាភស្តុតាងដល់ផ្លូវចិត្តរបស់គ្រហស្ថអ្នកកាន់សីល ១០ នោះផងទៀត, ប៉ុន្តែកុំយល់ថាដូចគ្នា នឹងអ្នកដែលស្លៀកពាក់សតាមធម្មតា ឬអ្នកដែលកោរសក់ កោរពុកមាត់ ពុកចង្កាតាមធម្មតា ឥតបានសមាទានកាន់សីលសោះនោះឡើយ ។

អ្នកកាន់សីលនិងអ្នកមិនកាន់សីល មានសភាពផ្សេងផ្ទុយគ្នាដោយផ្លូវចិត្ត ដោយចរិយា និងគុណសម្បត្តិ, សូម្បីអ្នកកាន់សីលផងគ្នា ក៏គង់ផ្សេងទីទៃពីគ្នា ដោយថ្នាក់សីលធម៌ដែរ, គឺ ភិក្ខុមានសីលខ្ពស់ជាងសាមណេរ, សាមណេរមានសីលខ្ពស់ជាង គ្រហស្ថអ្នកកាន់សីល ១០, គ្រហស្ថអ្នកកាន់សីល ១០ មានថ្នាក់ខ្ពស់ជាងអ្នកកាន់សីល ៨, អ្នកកាន់សីល ៨ មានថ្នាក់ខ្ពស់ជាងអ្នកកាន់សីល ៥ ។

អ្នកកាន់សីលទាំងនេះ សុទ្ធតែគោរពគ្នាតាមលំដាប់ថ្នាក់សីល, ទាំងតាមលំដាប់ថ្នាក់អាយុវស្សាចាស់ក្មេង ហើយនឹងគុណសម្បត្តិផងទៀត ទើបសមគួរតាមលំអានគន្លងគារវធម៌ក្នុងព្រះពុទ្ធសាសនា នឹងបោរាណកធម៌ក្នុងកាលព្រេងនាយ, សូម្បីសត្វតិរច្ឆានធំតូចដូចយ៉ាងសត្វទទា ស្វា ដំរី ដែលចេះគោរពគ្នាតាមអាយុចាស់ក្មេង ក៏អាចបានសុគតិភពជាទិដ្ឋានុគតិឱ្យមនុស្សយកតម្រាប់បានដែរ ។

វិធីសមាទានសីល ១០

ចប់តែប៉ុណ្ណេះ

# អកុសលកម្មបថ

គន្លង ឬផ្លូវនៃអំពើជាអកុសល ហៅថាអកុសលកម្មបថ មាន ១០ យ៉ាងគឺ កាយកម្ម អំពើដែលសម្រេចដោយកាយមាន ៣ យ៉ាង, វចីកម្ម អំពើដែលសម្រេចដោយវាចាមាន ៤ យ៉ាង, មនោកម្ម អំពើដែលសម្រេចដោយចិត្តមាន ៣ យ៉ាង, រួមត្រូវជា ១០ យ៉ាង ។

## កាយកម្ម ៣ យ៉ាង

១- **បាណាតិបាតោ** កិរិយាសម្លាប់សត្វដោយកាយរបស់ខ្លួន ឬប្រើឱ្យគេសម្លាប់ដោយវាចា ។

២- **អទិន្នាទានំ** កិរិយាលួចលាក់ឆក់ដណ្តើមទ្រព្យគេដោយកាយរបស់ខ្លួន ឬប្រើគេឱ្យលួចលាក់ឆក់ដណ្តើមដោយវាចា ។

៣- **កាមេសុ មិច្ឆាចារោ** កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺធ្វើនូវមេថុនសេវនៈនិងស្ត្រីដែលមានគេហួងហែងរក្សា ។

## វចីកម្ម ៤ យ៉ាង

១- **មុសាវាទោ** កិរិយាពោលនូវពាក្យកុហក ។

២- **បិសុណាវាចា** កិរិយាពោលនូវពាក្យញុះញង់សិកសៀតបំបែកបំបាក់អ្នកដទៃ ។

៣- **ផរុសវាចា** កិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកជេរប្រទេចអ្នកដទៃជាដើម ។

៤- **សម្ផប្បលាបោ** កិរិយាពោលនូវពាក្យរោយរាយ ឥតប្រយោជន៍ ។

## មនោកម្ម ៣ យ៉ាង

១- **អភិជ្ឈា** ចិត្តសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបម្រុងនឹងឱ្យបានមកជាទ្រព្យរបស់ខ្លួន ។

២- **ព្យាបាទោ** ចិត្តចងគំនុំគុំគួនគិតប៉ងនឹងឱ្យអ្នកដទៃដល់នូវសេចក្តីវិនាស ។

៣- **មិច្ឆាទិដ្ឋិ** គំនិតយល់ខុសហើយប្រកាន់ឡើងថាជាត្រូវ ។

# អង្គនៃអកុសលកម្មបថ

អង្គនៃ បាណាតិបាត, អទិន្នាទាន, កាមេសុមិច្ឆាចារ, និង មុសាវាទ, ដូចបានពោលមក ក្នុងនិច្ចសីលខាងដើមរួចហើយ ។

## បិសុណាវាចា មានអង្គ ៤

១- ភិន្ទិតព្វោ បរោ អ្នកដទៃដែលមានរូប គឺខ្លួនគប្បីញុះញង់បំបែក ។

២- ភេទនបុរេក្ខារតា គិតនឹងញុះញង់បំបែកអ្នកដទៃ ។

៣- តជ្ជោ វាយាមោ ព្យាយាមនឹងញុះញង់បំបែកអ្នកដទៃនោះ ។

៤- តស្ស តទត្ថវិជាននំ ញុំាងអ្នកនោះឱ្យដឹងច្បាស់ នូវដំណើរដែលខ្លួនញុះញង់បំបែកនោះ ។

## ផរុសវាចា មានអង្គ ៣

១- អក្កោសិតព្វោ បរោ អ្នកដទៃដែលមានរូប គឺខ្លួនគប្បីជេរប្រទេច ។

២- កុបិតចិត្តំ ចិត្តខឹងរទេះ ។

៣- អក្កោសនា បានជេរប្រទេចគេ ។

## សម្ផប្បលាប មានអង្គ ២

១- ភារតយុទ្ធសីតាហរណាទិនិរត្ថកថា ពាក្យឥតប្រយោជន៍ មានរឿងចម្បាំងនៃមហាភារត និងរឿងរាពណ៍លួចនាំនាងសីតាយកទៅជាដើម ។

២- តថារូបីកថាកថនំ បានពោលនូវពាក្យឥតប្រយោជន៍មានសភាពដូច្នោះ ។

## អភិជ្ឈា មានអង្គ ២

១- បរភណ្ឌំ ទ្រព្យរបស់អ្នកដទៃ ។

២- អត្តនោ បរិណាមនំ គិតចង់បង្អោនទ្រព្យរបស់អ្នកដទៃនោះ ឱ្យបានមកជាទ្រព្យរបស់ខ្លួន ដោយកលឧបាយផ្សេងៗ ។

## ព្យាបាទ មានអង្គ ២

១- បរសត្តោ អ្នកដទៃក្រៅពីខ្លួន ។

២- តស្ស តំ តំ ទិនាសចិន្តា គិតគុំគួនប្រុងនឹងឱ្យអ្នកនោះ ដល់នូវសេចក្តីវិនាស ដោយហេតុនោះៗ ។

## មិច្ឆាទិដ្ឋិ មានអង្គ ២

១- វត្ថុនោ ច គហិតាការទិបរីតតា ចិត្តប្រែប្រួលដោយអាការខុសអំពីព្រះរតនត្រ័យជាដើម ។

២- យថា ច តំ គណ្ហាតិ តថាភាវេន តស្សុបដ្ឋានំ គំនិតដែលយល់ខុសនោះ ឃើញខុសយ៉ាងណា ក៏ប្រកាន់សេចក្តីខុសនោះ ថាជាត្រូវវិញ ។

អកុសលកម្មបថទាំង ១០ ប្រការ ដូចបានពោលមកហើយនេះ ទោះត្រង់បទណាក្តី បើលុះតែព្រមដោយអង្គនោះៗ ទើបត្រូវទោសដល់អ្នកដែលប្រព្រឹត្តខុស, អ្នកនោះនឹងបាននូវសេចក្តីទុក្ខសេចក្តីវិនាសក្នុងលោកនេះ និងបរលោកនាយ, បើទុកជាមិនទាន់ឱ្យផលឱ្យឃើញច្បាស់ក្នុងលោកនេះ លុះដល់ទៅក្នុងបរលោកនាយ ក៏គង់នឹងឱ្យផលដល់អ្នកនោះពុំខានឡើយ, បើមិនទាន់ព្រមដោយអង្គនោះៗ គឺថាបើនៅខ្វះណាមួយនោះ ក៏មិនបានឈ្មោះថាមានទោសក្នុងអកុសលកម្មបថ ដល់អ្នកដែលប្រព្រឹត្តខុសនោះឡើយ ។៚

អកុសលកម្មបថ ១០ ប្រការ ព្រមទាំងអង្គ
ចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

# កុសលកម្មបថ

គន្លង ឬផ្លូវនៃអំពើជាកុសល ហៅថាកុសលកម្មបថ មាន ១០ យ៉ាងគឺ កាយកម្ម អំពើដែលសម្រេចដោយកាយមាន ៣ យ៉ាង, វចីកម្ម អំពើដែលសម្រេចដោយវាចា មាន ៤ យ៉ាង, មនោកម្ម អំពើដែលសម្រេចដោយចិត្តមាន ៣ យ៉ាង, រួមត្រូវជា ១០ យ៉ាង ។

## កាយកម្ម ៣ យ៉ាង

១- **បាណាតិបាតា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយា ធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ។

២- **អទិន្នាទានា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយា កាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា ។

៣- **កាមេសុ មិច្ឆាចារា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយា ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

## វចីកម្ម ៤ យ៉ាង

១- **មុសាវាទា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយា ពោលនូវពាក្យកុហក ។

២- **បិសុណាយ វាចាយ វេរមណី** ចេតនាជាហេតុវៀរចាកកិរិយា ពោលនូវពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ ។

៣- **ផរុសាយ វាចាយ វេរមណី** ចេតនាជាហេតុវៀរចាកកិរិយា ពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម ។

៤- **សម្ផប្បលាបា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយា ពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

## មនោកម្ម ៣ យ៉ាង

១- **អនភិជ្ឈា** មិនមានចិត្តសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបម្រុងនឹង

ឱ្យបានមកជាទ្រព្យរបស់ខ្លួន ។

២- អព្យាបាទោ មិនមានចិត្តចងគំនុំគុំគួនគិតប៉ងនឹងឱ្យអ្នកដទៃ ដល់នូវសេចក្ដីវិនាសឡើយ ។

៣- សម្មាទិដ្ឋិ គំនិតយល់ឃើញត្រូវពិត ដោយប្រកាន់ឡើងថាជាត្រូវមែន ។

អ្នកឯណាបានប្រព្រឹត្តត្រូវតាមកុសលកម្មបថ ១០ ប្រការ ដូចពោលមកហើយនេះ, អ្នកនោះនឹងបានសេចក្ដីសុខ សេចក្ដីចំរើនក្នុងលោកទាំងពីរ គឺក្នុងលោកនេះ និងក្នុងបរលោកជាប្រាកដ ។៚

កុសលកម្មបថ ១០ ប្រការ

ចប់ដោយសង្ខេបតែប៉ុណ្ណេះ

# អដ្ឋង្គិកមគ្គ ៨

អដ្ឋង្គិកមគ្គជា ផ្លូវប្រកបដោយអង្គ ៨ ប្រការគឺ:

១- សម្មាទិដ្ឋិ : សេចក្ដីយល់ឃើញត្រូវ

២- សម្មាសង្កប្ប : ការត្រិះរិះត្រូវ

៣- សម្មាវាចា : ពោលពាក្យត្រឹមត្រូវ

៤- សម្មាកម្មន្ត : ការងារល្អប្រពៃ

៥- សម្មាអាជីវ : ការចិញ្ចឹមជីវិតត្រូវ

៦- សម្មាវាយាម : ព្យាយាមត្រូវ

៧- សម្មាសតិ : សេចក្ដីរឭកត្រូវ

៨- សម្មាសមាធិ : ការតាំងចិត្តត្រូវ

# អដ្ឋង្គិកមគ្គ ៨

## ប្រែកាព្យពាក្យ ៧

អដ្ឋង្គិកមគ្គទាំងប្រាំបី ជាផ្លូវព្រះអរិយទាំងឡាយ
ដំណើរដ៏ល្អតែងនាំកាយ ទៅកាន់ប្រឡាយព្រះនិព្វាន ។
សម្មាទិដ្ឋិ ឃើញត្រូវស្រេច ឃើញព្រះអរិយសច្ចទាំងបួនមាន
ឃើញមែនឃើញពិតព្រះនិព្វាន ឃើញសុខសឹងគ្មានទោសទុក្ខា ។
វីអង្គសម្មាសង្កប្បោនេះ តម្រិះដែលត្រិះត្រង់ឧស្សាហ៍
ភាវូច្ចធុញ្ញចប់ក្ដីប្រាថ្នា ចិន្ដាចង់ចៀសចាកកាមគុណ ។
សម្មាវាចា ពោលពាក្យពិត សុចរិតមិនពោលមុសាស៊ុន
មិនសិកមិនសៀតឆ្លៀតពាក្យធ្ងន់ ពាក្យណាជាគុណរំថ្លែងចរចា ។
សម្មាកម្មន្ដោ ធ្វើការត្រូវ ចៀសផ្លូវមេថុនមិនប្រាថ្នា
មិនលបមិនលួចទ្រព្យនរណា បាណាចៀសមិនសម្លាប់សត្វ ។
សម្មាអាជីវោ កាន់សុចរិត ចិញ្ចឹមជីវិតគិតប្រយ័ត្ន
មិនលក់មិនដូរញមនុស្សនិងសត្វ បំបាត់ជំនួញប្រាំប្រការ ។
សម្មាវាយាមោ ព្យាយាមនូវ ធ្វើត្រូវមិនឱ្យធ្លោយប្រាថ្នា
ព្យាយាមរវាំងបាំងអកុសលា មិនឱ្យខ្លាំងក្លាកើតឡើងបាន ។
ព្យាយាមលះបាបដែលមានហើយ មិនធ្វើកន្តើយឱ្យរំខាន
រំលត់ចាកទុក្ខផុតសន្ដាន កុំឱ្យកើតមានក្ដីវេទនា ។
ព្យាយាមញ៉ាំងកុសលដែលមានពិត ឱ្យរីតចម្រើនច្រើនមហិមា
សម្មាសតិ តាំងសទ្ធា ភាវនារំលឹកក្នុងរាងកាយ ។
បញ្ញាពិចារណានឹករឿយៗ ក្នុងចិត្តគិតព្រួយហើយនឿយណាយ
អនិច្ចំ ទុក្ខំ ទុក្ខក្នុងកាយ គ្មានខ្លឹមគ្មានស្រោយអង្គអនត្តា ។
សម្មាសមាធិ ធ្វើចិត្តត្រូវ ហើយតាំងខ្ជាប់នូវកម្មដ្ឋានា
ធ្វើឈានឱ្យបានដោយបញ្ញា ឱ្យបានឯកត្តាជាប្រធាន ។

# ធម៌ស្មូត្រផ្សេងៗ

# តេជះខ្ញុំសាង

តេជះខ្ញុំសាង សំអិតសំអាង ឱនកាយវាចា
សូមសុខសុភាព រួចពីទុក្ខា ឆ្លងដល់ត្រើយមហា
ពោលគឺនិព្វាន ។

គ្រប់ជាន់គ្រប់ជាតិ កុំឱ្យខ្ញុំឃ្លាត ពីសីលនិងទាន
គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន
ដល់ស្ថានថ្ងៃថ្លា ។

ខ្ញុំជូនមគ្គផល ចំពោះទៅដល់ មាតាបិតា
គុណគ្រូព្រះឧ– បជ្ឈាយាចារ្យ គុណញ្ញាតកា
ប្រាំពីរសន្តាន ។

ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកស្ថាន
ខ្ញុំជូនមគ្គផល កុសលថ្កើងថ្កាន សូមសុខក្សេមក្សាន្ត
ដល់ស្ថានផុតទុក្ខ ។

ខ្ញុំសូមសច្ចា កើតជាតិណាៗ ៗ សូមឱ្យបានសុខ
សូមមានបញ្ញា ភ្លឺថ្លាមោះមុត ៖ រួចផុតពីទុក្ខ
ដល់និព្វានហោង ។

# ពាក្យសូមប្រាថ្នា

ខ្ញុំសូមសច្ចា  ប្តឹងអស់ទេវតា  សោឡសសួគ៌ឋាន
លោកកត់សំគាល់  ដោយទិព្វវិញ្ញាណ  ខ្ញុំប្រតិស្ឋាន
ចំពោះព្រះអង្គ ។

ខ្ញុំធ្វើបុណ្យទាន  ធ្វើសីលប៉ុន្មាន  ចិត្តខ្ញុំស្មោះត្រង់
ចំពោះព្រះពុទ្ធ  ព្រះធម៌ព្រះសង្ឃ  ទេវតាគ្រប់អង្គ
ជួយជាសាក្សី ។

ជាតិនេះទៅមុខ  កុំឱ្យមានទុក្ខ  សូមសុខសួស្តី
បច្ចុប្បន្នទាន់ព្រះ-  សិអារ្យមេត្រីយ៍  ផុតឆ្ងាយលោកិយ៍
ដល់បរលោកនាយ ។

កុសលតូចធំ  ខ្ញុំសាងសន្សំ  មគ្គផលទាំងឡាយ
សូមនាំវិញ្ញាណ  ទៅបរលោកនាយ  ជៀសចាកអបាយ
នរកទាំង ៤ ។

កុំឱ្យឃើញយល់  កម្មអកុសល  កុំជិតដល់ខ្លួន
សូមឱ្យរួចផុត  រលត់សាបសូន្យ  មគ្គផលជួយជ្រោមជ្រែង
ឱ្យបានសម្រេច ។

ដូចក្តីប្រាថ្នា  ចិត្តខ្ញុំជ្រះថ្លា  ចងចាំមិនភ្លេច
កសាងសីលទាន  ទោះច្រើនឬតិច  ឱ្យបានសម្រេច
ដល់និព្វានហោង ។

# បត្តិទានគាថា

ពុទ្ធសាសនិកជន ដែលបានធ្វើកុសលណាមួយរួចហើយ បើមានប្រាថ្នានឹងឱ្យចម្រើនផលានិសង្ស ដល់ខ្លួនដ៏ច្រើនឡើងទៀតនោះ គប្បីឧទ្ទិសផ្សាយផលនៃកុសលនោះ ដល់សត្វទាំងឡាយដោយកុសលចិត្តជាបុញ្ញកិរិយាវត្ថុ ១០ ដែលហៅថាបត្តិទាន គឺកិរិយាឱ្យនូវចំណែកបុណ្យដល់អ្នកដទៃ ដោយបត្តិទានគាថានេះ ដូច្នេះថា ៖

យំ កិញ្ចិ កុសលកម្មំ  កត្តព្វំ កិរិយំ មម
កាយេន វាចាមនសា  តិទសេ សុគតំ កតំ ។
យេ សត្តា សញ្ញិនោ អត្ថិ  យេ ច សត្តា អសញ្ញិនោ
កតំ បុញ្ញផលំ មយ្ហំ  សព្វេ ភាគី ភវន្តុ តេ ។
យេ តំ កតំ សុវិទិតំ  ទិន្នំ បុញ្ញផលំ មយា
យេ ច តត្ថ ន ជានន្តិ  ទេវា គន្ត្វា និវេទយុំ ។
សព្វេ លោកម្ហិ យេ សត្តា  ជីវន្តាហារហេតុកា
មនុញ្ញំ ភោជនំ សព្វេ  លភន្តុ មម ចេតសាតិ ។

ប្រែថា យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម អំពើជាកុសលឯណាមួយ ដែលខ្ញុំគប្បីធ្វើ,

១

កាយេន វាចាមនសា ដោយទ្វារទាំង ៣ គឺកាយ វាចា ចិត្ត,

តិទសេ សុគតំ កតំ អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឱ្យកើត ក្នុងឋានត្រៃត្រិង្សសួគ៌បាន,

យេ សត្តា សញ្ញិនោ អត្ថិ សត្វទាំងឡាយឯណា គឺមនុស្ស ឬទេវតា ឬព្រហ្ម ដែលជាសត្វមានសញ្ញាក្តី,

យេ ច សត្តា អសញ្ញិនោ សត្វទាំងឡាយឯណា ជាអសញ្ញីសត្វ គឺសត្វឥតមានសញ្ញាក្តី,

កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ សត្វទាំងឡាយទាំងអស់នោះ ចូរឱ្យបាននូវចំណែកផលនៃបុណ្យ ហើយចូរសោយនូវផលនៃបុណ្យ ដែលខ្ញុំបានធ្វើហើយ បាន

ឧទ្ទិសផ្សាយឱ្យទៅនេះចុះ,

យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណា បានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរបានសោយនូវផលនៃបុណ្យ ដែលខ្ញុំបានឧទ្ទិសឱ្យទៅនេះចុះ,

យេ ច តត្ថ ន ជានន្តិ ម្យ៉ាងទៀត បណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណា មិនបានដឹងនូវផលនៃបុណ្យ ដែលខ្ញុំបានធ្វើហើយនោះ,

ទេវា គន្ត្វា និវេទយុំ សូមទេវតាទាំងឡាយ អញ្ជើញទៅឱ្យដំណឹងដល់សត្វទាំងឡាយនោះ ឱ្យបានដឹងផងថា៖ ជនឯណោះគេបានធ្វើបុណ្យហើយ គេឧទ្ទិសផ្សាយបុណ្យនោះ មកដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរអនុមោទនាត្រេកអរ នឹងបុណ្យនោះចុះ,

សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា សត្វទាំងឡាយឯណាក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារហើយរស់នៅ,

មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសា សត្វទាំងឡាយទាំងអស់នោះ ចូរឱ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញឫទ្ធិ តាមចិត្តនៃខ្ញុំឧទ្ទិសផ្សាយទៅឱ្យនេះចុះ ។·

## យំកិញ្ចិ

ប្រែ. ជាពាក្យកាព្យ

កុសលកម្មតិចតួចឯណា ដែលចិត្តជ្រះថ្លាហើយខ្ញុំបានធ្វើ
ដោយកាយវាចាចិត្តខ្ញុំអើពើ គួរនាំទៅលើកើតឋានត្រៃត្រិង្ស ។
សត្វមានសញ្ញាឯណាបានដឹង បុណ្យដែលខ្ញុំប្រឹងខំធ្វើនេះក្តី
សូម្បីពួកសត្វជាអសញ្ញី ក៏ខ្ញុំគប្បីចែកបុណ្យនេះឱ្យ ។
ថាបើពួកសត្វនោះមិនដឹងហើយ ក៏ខ្ញុំសូមឱ្យទេវតាមានឫទ្ធិ
អញ្ជើញទៅប្រាប់ទៅដាស់តឿនចិត្ត ដោយក្តីអាណិតសត្វក្នុងលោកា ។
ឱ្យបានដឹងហើយដោយចិត្តមេត្តា ត្រេកអរគ្រប់គ្នាក្នុងលោកទាំងមូល
សូមមានអាហាររស់នៅដោយស្រួល ដោយបានទទួលផលបុណ្យនេះហោង ។

# យំកិច្ច

## ប្រែ. កាព្យមួយបែបទៀត

| | | |
|---|---|---|
| បុណ្យដែលខ្ញុំបានធ្វើហើយ | ព្រះគុណអើយខ្ញុំសច្ចា | |
| ឧទ្ទិសផលនេះណា | ជូនមាតាបិតាខ្ញុំ | ។ |
| ជីដូននិងជីតា | គ្រូអាចារ្យទាំងតូចធំ | |
| ញាតិមិត្រគ្រប់និគម | មកជួបជុំទទួលផល | ។ |
| ដែលកូនចៅបានធ្វើ | នូវអំពើជាកុសល | |
| សូមទានឱ្យបានដល់ | ទោះមណ្ឌលឆ្ងាយយ៉ាងណា | ។ |
| កុសលទាំងអស់ហ្នឹង | សូមទីពឹងលើទេវតា | |
| សូមមានចិត្តមេត្តា | នាំផលាទាំងអស់នេះ | ។ |
| ទៅជូនឱ្យខ្ញុំផង | ដូចបំណងកុំបីធ្វេស | |
| កូនចៅនៅឯណោះ | មិនប្រហែសបញ្ជូនមក | ។ |
| សូមមានចិត្តរីករាយ | ដោយសប្បាយទទួលយក | |
| កូនចៅបានលៃលក | បញ្ជូនមកគ្រប់ៗគ្នា | ។ |
| ដើម្បីសោយផលទាន | ទទួលបាននូវសុខជា | |
| កូនចៅទាំងអស់គ្នា | សូមបូជាជូនទៅហោង | ៕ |

# បត្តិទានគាថា

សម្រាប់សូត្រក្នុងវត្ត

យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ តា ធម្មទានេន ភវន្តុ បូជិតា សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ ថេរា ច មជ្ឈា នវកា ច ភិក្ខវោ សារាមិកា ទានបតី ឧបាសកា គាមា ច ទេសា និគមា ច ឥស្សរា សប្បាណភូតា សុខិតា ភវន្តុ តេ ជលាពុជា យេ បិ ច អណ្ឌសម្ភវា សំសេទជាតា អថវោបបាតិកា និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សង្ខយំ ឋាតុ ចិរំ សតំ ធម្មោ ធម្មធរា ច បុគ្គលា សង្ឃោ ហោតុ សមគ្គោ ច អត្ថាយ ច ហិតាយ ច អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ វុឌ្ឍឹ សម្បាបុណេយ្យាម ធម្មេ អរិយប្បវេទិតេ ។

ប្រែថា យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ ទេវតាទាំងឡាយឯណា មានប្រក្រតីនៅក្នុងទីវត្តជាទីនៅនៃសង្ឃ ពូង់ខឿនព្រះសថូប ពូង់ខឿនព្រះពោធិព្រឹក្សក្នុងទីនោះៗ,

តា ធម្មទានេន ភវន្តុ បូជិតា ទេវតាទាំងឡាយនោះ ជាបុគ្គលគឺយើងទាំងឡាយបូជាហើយដោយធម្មទាន,

សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ ចូរធ្វើនូវសួស្តីក្នុងមណ្ឌលនៃវត្តជាទីនៅនៃសង្ឃនេះ,

ថេរា ច មជ្ឈា នវកា ច ភិក្ខវោ ភិក្ខុទាំងឡាយជាថេរៈក្តី ជាកណ្តាលក្តី ទើបនឹងបួសក្តី,

សារាមិកា ទានបតី ឧបាសកា ឧបាសក និងឧបាសិកាទាំងឡាយ ដែលជាម្ចាស់នៃទាន ព្រមទាំងអារាមិកជន គឺក្មេងវត្តក្តី,

**គាមា ច ទេសា និគមា ច ឥស្សរា** ជនទាំងឡាយដែលជាអ្នកស្រុកក្តី ជាអ្នកប្រទេសក្តី ជាអ្នកនិគមក្តី ដែលជាឥស្សរៈជាធំក្តី,

**សប្បាណភូតា សុខិតា ភវន្តុ តេ** សត្វទាំងឡាយនោះៗ ចូរឱ្យបានដល់នូវសេចក្តីសុខ,

**ជលាពុជា យេ បិ ច អណ្ឌសម្ភវា សំសេទជាតា អថវោបបាតិកា** មួយវិញទៀត សត្វទាំងឡាយឯណា ដែលជាជលាពុជៈកំណើតក្តី ដែលជាអណ្ឌជៈកំណើតក្តី ដែលជាសំសេទជៈកំណើតក្តី ដែលជាឧបបាតិកៈកំណើតក្តី,

**និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ** សត្វទាំងឡាយទាំងអស់នោះ កាលបើបានអាស្រ័យនូវធម៌ដ៏ប្រសើរ ជានិយ្យានិកធម៌ហើយ ចូរធ្វើនូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខចុះ,

**ឋាតុ ចិរំ សតំ ធម្មោ** សូមឱ្យធម៌របស់សប្បុរសទាំងឡាយ ស្ថិតនៅអស់កាលជាយូរអង្វែងទៅ,

**ធម្មធរា ច បុគ្គលា** បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ (ចូរស្ថិតនៅអស់កាលជាយូរអង្វែងទៅ),

**សង្ឃោ ហោតុ សមគ្គោ វ** សូមព្រះសង្ឃព្រមព្រៀងគ្នា,

**អត្ថាយ ច ហិតាយ ច** ដើម្បីសេចក្តីចម្រើនផង ដើម្បីសេចក្តីសម្រេចផលប្រយោជន៍ផង,

**អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ** សូមព្រះសទ្ធម្មរក្សានូវយើងទាំងឡាយ សូមរក្សានូវអ្នកដែលប្រព្រឹត្តធម៌ទាំងឡាយផង,

**វុឌ្ឍឹ សម្បាបុណេយ្យាម ធម្មេ អរិយប្បវេទិតេ** សូមឱ្យយើងទាំងឡាយបានដល់នូវសេចក្តីចម្រើនក្នុងធម៌ ដែលព្រះអរិយទាំងឡាយលោកសម្តែងហើយ ។

# បត្តិទានបត្តនគាថា

ឥមិនា បុញ្ញកម្មេន ឧបជ្ឈាយា គុណុត្តរា
អាចរិយូបការា ច មាតាបិតា បិយា មមំ
សុរិយោ ចន្ទិមា រាជា គុណវន្តា នរាបិ ច
ព្រហ្មា មារា ច ឥន្ទា ច លោកបាលា ច ទេវតា
យមោ មិត្តា មនុស្សា ច មជ្ឈត្តា វេរិកាបិ ច
សព្វេ សត្តា សុខី ហោន្តុ បុញ្ញានិ បកតានិ មេ
សុខញ្ច តិវិធំ ទេន្តុ ខិប្បំ បាបេថ វោមតំ ៕

ប្រែថា ដោយបុញ្ញកម្មនេះ ឧបជ្ឈាយ៍ទាំងឡាយ មានគុណដ៏ខ្ពង់ខ្ពស់ អាចារ្យទាំងឡាយមានឧបការៈ មាតាបិតាជាទីស្រឡាញ់នៃខ្ញុំ ព្រះអាទិត្យ ព្រះចន្ទ្រ រាជការ នរជនអ្នកមានគុណទាំងឡាយ ព្រះព្រហ្ម មារាធិរាជ ព្រះឥន្ទទាំងឡាយ លោកបាលមហារាជ និងទេវតាទាំងឡាយ ព្រះយមរាជ និងមនុស្សទាំងឡាយ ជាមិត្តនឹងគ្នាក្តី មានចិត្តជាកណ្តាលក្តី មានពៀរជាមួយគ្នាក្តិ (រួបរួមសេចក្តីថា) សូមឱ្យសព្វសត្វទាំងឡាយ មានសេចក្តីសុខរាល់គ្នា បុណ្យទាំងឡាយ ដែលខ្ញុំបានកសាងសន្សំហើយ ចូរឱ្យនូវសេចក្តីសុខទាំង ៣ ប្រការ សូមឱ្យអ្នកទាំងឡាយ បានដល់នូវអមតមហានិព្វាន ឱ្យបានឆាប់រួសរាន់ទាន់សេចក្តីប្រាថ្នាហោង ។

ឥមិនា បុញ្ញកម្មេន ឥមិនា ឧទ្ទិសេន ច
ខិប្បាហំ សុលភេចេវ តណ្ហុបាទានឆេទនំ
យេ សន្តានេ ហីនា ធម្មា យាវ និព្វានតោ មមំ
នស្សន្តុ សព្វទាយេវ យត្ថ ជាតោ ភវាភវេ
ឧជុចិត្តា សតិប្បញ្ញា សល្លេខោ វីរិយម្ហិ នា
មារា លភន្តុ នោកាសំ កាតុញ្ច វីរិយេសុ មេ
ពុទ្ធាទិបវរោ នាថោ ធម្មោ នាថោ វរុត្តមោ

នាថោ បច្ចេកពុទ្ធោ ច សង្ឃោ នាថោ ភវោ មមំ

តេ សោត្តមានុភាវេន មារោកាសំ លភន្តុ មា ។

ដោយបុញ្ញកម្មនេះផង ដោយការឧទ្ទិសនេះផង សូមឱ្យខ្ញុំបានដោយងាយយ៉ាងរូសរាន់ទាន់ចិត្ត នូវមគ្គផលជាគ្រឿងផ្តាច់បង់នូវតណ្ហានិងឧបាទាន ធម៌ទាំងឡាយណា ជាធម៌ថោកទាប គឺអកុសលធម៌ នៅក្នុងសន្តានចិត្តខ្ញុំ សូមឱ្យ (ហើនធម៌ជាអកុសលទាំងនោះ) វិនាសបាត់រៀងរាល់កាលទៅ រហូតដល់ខ្ញុំបានសម្រេចព្រះនិព្វាន (ក្នុងបច្ឆិមជាតិ), (បើ) ខ្ញុំអន្ទោលទៅចាប់កំណើតក្នុងភពតូចនិងភពធំណាៗ សូមឱ្យខ្ញុំជាបុគ្គលមានចិត្តត្រង់ មានសតិនិងបញ្ញា មានចិត្តស្អាតផូរផង់ ទាំងសូមឱ្យព្យាយាមផង (ក្នុងភពនោះៗ) មារទាំងឡាយចូរកុំបាននូវឱកាសដើម្បីឱ្យខូចព្យាយាមខ្ញុំ ព្រះពុទ្ធដូចជាប្រទីប ឬកោះដ៏ប្រសើរ ជាទីពឹងនៃខ្ញុំ ព្រះធម៌ជាទីពឹងដ៏ប្រសើរខ្ពង់ខ្ពស់នៃខ្ញុំ ទាំងព្រះបច្ចេកពុទ្ធ ក៏ជាទីពឹងនៃខ្ញុំផងដែរ ព្រះសង្ឃក៏ជាទីពឹងខ្ពង់ខ្ពស់នៃខ្ញុំដែរ ដោយឧត្តមានុភាពនៃព្រះពុទ្ធ ព្រះធម៌ ព្រះបច្ចេកពុទ្ធ និងព្រះសង្ឃនោះ មារចូរកុំបាននូវឱកាសចូលមកជ្រៀតជ្រែកឡើយ ។

## ខមាបនគាថា

យេ កេចិ ខុទ្ទកា បាណា មហន្តាបិ

មយា ហតា យេ បាណេកេ បមាទេន

កាយវាចាមនេហិ វា បុញ្ញំ មេ

អនុមោទន្តុ គណ្ហន្តុ ផលមុត្តមំ

វេរិនោ ចេ បមុញ្ចន្តុ សព្វទោសំ ខមន្តុ មេ ។

ប្រែថា សត្វទាំងឡាយណាមួយ ទោះបីតូចក្តីធំក្តី ដែលខ្ញុំបានបៀតបៀនហើយ មួយទៀតសត្វទាំងឡាយពួកខ្លះ (ដែលខ្ញុំបានធ្វើទុក្ខបុកម្នេញហើយ) ព្រោះសេចក្តីប្រមាទភ្លាំងភ្លាត់ដោយកាយវាចាចិត្ត (សត្វទាំងឡាយនោះ) ចូរអនុមោទនានូវបុណ្យរបស់ខ្ញុំចុះ ចូរទទួលយកនូវផលបុណ្យដ៏ឧត្តមចុះ បើ (សត្វទាំងឡាយឯណា) មានវៀរនឹងគ្នា (សត្វទាំងឡាយ) នោះ ចូររួចរំដោះចាកពៀរនោះទៅ "សូមសត្វទាំងឡាយអត់ទោសទាំងពួងដល់ខ្ញុំផង" ។

# សុខាភិយាចនគាថាសង្ខេប

បសន្នា ហោន្តុ សព្វេបិ　　បាណិនោ ពុទ្ធសាសនេ
សម្មាធារំ បវេច្ឆន្តោ　　កាលេ ទេវោ បវស្សតុ
វុឌ្ឍិភាវាយ សត្តានំ　　សមិទ្ធំ នេតុ មេទនី
មាតាបិតា ច អត្រជំ　　និច្ចំ រក្ខន្តិ បុត្តកំ
ឯវំ ធម្មេន រាជានោ　　បជំ រក្ខន្តុ សព្វទា ។

ប្រែថា បសន្នា ហោន្តុ សព្វេបិ　　បាណិនោ ពុទ្ធសាសនេ

សត្វទាំងឡាយទាំងពួង ចូរជ្រះថ្លាក្នុងព្រះពុទ្ធសាសនា.

សម្មាធារំ បវេច្ឆន្តោ　　កាលេ ទេវោ បវស្សតុ
វុឌ្ឍិភាវាយ សត្តានំ　　សមិទ្ធំ នេតុ មេទនី

សូមឱ្យភ្លៀង បង្អុរនូវធារទឹកដោយប្រពៃ ចូរបង្អុរចុះក្នុងកាលដ៏គួរ ចូរបណ្តាលឱ្យផែនដីសិរិទ្ធិ គឺថាឱ្យមានជីជាតិល្អឡើង ដើម្បីឱ្យកើតសេចក្តីចម្រើន ដល់សត្វទាំងឡាយ.

មាតាបិតា ច អត្រជំ　　និច្ចំ រក្ខន្តិ បុត្តកំ

មាតាក្តី បិតាក្តី បិបាច់រក្សាជានិច្ច នូវកូនតូចជាកូនបង្កើត យ៉ាងណាមិញ.

ឯវំ ធម្មេន រាជានោ　　បជំ រក្ខន្តុ សព្វទា

សូមព្រះបរមក្សត្រទាំងឡាយ រក្សានូវប្រជាជនតាមគន្លងធម៌ ដូចជាមាតាបិតាបីបាច់រក្សានូវកូនដូច្នោះ ឱ្យបានសព្វកាលទៅហោង ។

ធម៌នេះសម្រាប់សូធ្យ
ក្នុងកាលចប់ធម៌ទេសនា ឬ ចប់ព្រះបរិត្ត

# ព័ទ្ធសីមា

ឥមស្មឹំ រាជសីមាយំ ខេត្តេ សមន្តា
សដ្ឋីយោជនសតសហស្សានិ ពុទ្ធា ធម្មា
សង្ឃា ជាលបរិក្ខេត្តេ រក្ខន្តុ សុរក្ខន្តុ ៗ

(សូធ្យបាលី ៣ ចប់)

ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃទាំងឡាយ សូមរក្សាដោយល្អក្នុងដែនដោយជុំវិញដូចជាសំណាញ់ អស់សែននៃយោជន៍ ៦០ ទាំងឡាយ ដោយជុំវិញក្នុងខេត្តព្រំដែននៃស្តេចនេះ ។

(ប្រើព័ទ្ធសីមាក្នុងទីទាំងពួងបានតាមត្រូវការ សូធ្យតែបាលីក៏បាន)

## ធម៌សម្រាប់សូធ្យផ្សាយមេត្តា

សូមសេចក្តីសុខ ទោះនៅក្នុងទីណាក៏ដោយ

អហំ សុខិតោ ហោមិ និទ្ទុក្ខោ ហោមិ អវេរោ ហោមិ អព្យាបជ្ឈោ ហោមិ អនីឃោ ហោមិ អត្តានំ បរិហរាមិ ៗ

សូមឱ្យខ្ញុំបានដល់នូវសេចក្តីសុខ កុំបីមានទុក្ខ កុំបីមានពៀរ កុំបីមានក្តៅក្រហាយ កុំបីមានក្តីលំបាក ឱ្យបានសុខរក្សាខ្លួនតទៅ ។

## ធម៌សម្រាប់សូធ្យផ្សាយមេត្តា

សព្វេ សត្តា សព្វេ បាណា សព្វេ ភូតា សព្វេ បុគ្គលា សព្វេ អត្តភាវបរិយាបន្នា សព្វា ឥត្ថិយោ សព្វេ បុរិសា សព្វេ អរិយា សព្វេ អនរិយា សព្វេ ទេវា សព្វេ មនុស្សា សព្វេ វិនិបាតិកា អវេរា អព្យាបជ្ឈា អនីឃា ហោន្តុ សុខី អត្តានំ បរិហរន្តុ ៗ

ពួកសត្វទាំងអស់ ពួកប្រាណទាំងអស់ ពួកភូតទាំងអស់ ពួកបុគ្គលទាំងអស់ ពួកសត្វដែលរាប់បញ្ចូលថាមានអត្តភាពទាំងអស់ ពួកស្ត្រីទាំងអស់ ពួកបុរសទាំងអស់ ពួកព្រះអរិយទាំងអស់ ពួកអនរិយទាំងអស់ ពួកទេវតាទាំងអស់ ពួកមនុស្សទាំងអស់ ពួកវិនិបាតទាំងអស់ សូមកុំឱ្យមានពៀរនឹងគ្នា កុំបៀតបៀនគ្នា កុំបីមានទុក្ខ សូមរក្សានូវខ្លួនឱ្យបានសុខចុះ ។

# ធម៌សូត្រផ្សាយមេត្តាទាំង ១០ ទិស

សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ ។ ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។

ប្រែថា សព្វេ បុរត្ថិមាយ ទិសាយសត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសបូព៌ា សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ.

សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសអាគ្នេយ៍ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ.

សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយ

ទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសទក្សិណ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ,

**សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសនិរតី សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ,

**សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសបស្ចិម សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ,

**សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសពាយ័ព្យ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ,

**សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសឧត្តរ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ,

**សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសឦសាន សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ,

**សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសខាងក្រោម សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ,

**សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសខាងលើ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ,

**សព្វេ [១]សត្តា អវេរា ហោន្តុ** សត្វទាំងឡាយទាំងពួង សូមកុំឱ្យមានពៀរនឹងគ្នា,

**សុខិតា[៤] ហោន្តុ** សូមឱ្យបាននូវសេចក្ដីសុខ,

**និទ្ទុក្ខា ហោន្តុ** សូមកុំឱ្យមានទុក្ខ,

**អព្យាបជ្ឈា ហោន្តុ** សូមកុំឱ្យបៀតបៀនដល់គ្នានឹងគ្នា,

**អនីឃា ហោន្តុ** សូមកុំឱ្យមានសេចក្ដីព្រួយលំបាក,

**ទីឃាយុកា ហោន្តុ** សូមឱ្យមានអាយុវែង,

**អរោគា ហោន្តុ** សូមកុំឱ្យមានរោគ,

**សម្បត្តីហិ សមិជ្ឈន្តុ** សូមឱ្យបានសម្រេច ដោយសម្បត្តិគ្រប់យ៉ាង.

សុខី អត្តានំ បរិហរន្តុ សូមឱ្យរក្សានូវខ្លួនជាសុខស្រួលចុះ,

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្តីទុក្ខ សូមឱ្យជាសត្វបាត់សេចក្តីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្តីសោក សូមឱ្យជាសត្វបាត់សេចក្តីសោកទៅហោង ។

## អានិសង្សរបស់អ្នកចម្រើនមេត្តាចិត្ត ១១ យ៉ាង

បុគ្គលណា ឧស្សាហ៍ចម្រើនមេត្តាឱ្យដុះដាលកើតក្នុងសន្ដានហើយ បុគ្គលនោះរមែងបាននូវអានិសង្ស ១១ ប្រការមិនខាន ឯអានិសង្ស ១១ ប្រការនោះគឺ :

១- សុខំ សុបតិ បុគ្គលប្រកបដោយមេត្តា រមែងដេកលក់ជាសុខស្រួលល្អ ចំណែកជនដទៃរមែងដេកលក់អាក្រក់ គឺដេកប់រះនទៀលស្រមុកលាន់ឮសម្លេងអាក្រក់ផ្សេងៗ បុគ្គលប្រកបដោយមេត្តាមិនដូច្នោះឡើយ រមែងដេកលក់ជាសុខស្រួល ហាក់ដូចជាមនុស្សចូលកាន់សមាបត្តិ ។

២- សុខំ បដិពុជ្ឈតិ អ្នកប្រកបដោយមេត្តា រមែងភ្ញាក់រឭកអំពីលក់ក៏ជាសុខស្រួលល្អ ចំណែកជនដទៃរមែងភ្ញាក់អំពីលក់អាក្រក់ គឺធ្វើសម្លេងថ្ងូរគ្រហឹមមាត់ពត់កាយ ប់រះនទៀលកាយផ្សេងៗ អ្នកប្រកបដោយមេត្តាមិនដូច្នោះឡើយ រមែងភ្ញាក់ឡើងជាសុខស្រួលល្អ ប្រៀបដូចផ្កាឈូករីក ។

៣- បាបកំ សុបិនំ ន បស្សតិ អ្នកប្រកបដោយមេត្តា កាលនឹងដេកលក់ទៅមិនបានយល់សប្តិឃើញអាក្រក់ឡើយ គឺយល់សប្តិឃើញល្អៗ ឃើញហាក់ដូចជាថ្វាយបង្គំចេតិយ ហាក់ដូចជាធ្វើបូជាព្រះរតនត្រ័យ ហាក់ដូចជាស្តាប់ធម៌ជាដើម ចំណែកជនដទៃ រមែងយល់សប្តិឃើញហាក់ដូចជាចោរដេញ ហាក់ដូចជាមនុស្សពាលមកបៀតបៀន ហាក់ដូចជាធ្លាក់ចូលទៅក្នុងជ្រោះជាដើម ។

៤- មនុស្សានំ បិយោ ហោតិ អ្នកប្រកបដោយមេត្តា រមែងជាទីស្រឡាញ់ជាទីគាប់ចិត្តនៃមនុស្សទាំងឡាយ ប្រៀបដូចជាកែវមុក្តាសម្រាប់ពាក់ដើមទ្រូង និងកម្រងផ្កាសម្រាប់ប្រដាប់ក្បាល ។

៥- អមនុស្សានំ បិយោ ហោតិ អ្នកប្រកបដោយមេត្តា រមែងជាទីស្រឡាញ់ជាទីគាប់ចិត្តនៃអមនុស្សទាំងឡាយ មានទេវតាជាដើម ។

៦- ទេវតា រក្ខន្តិ ពួកទេវតាទាំងឡាយតែងរក្សាបុគ្គល ដែលប្រកបដោយមេត្តា ប្រៀបដូចជាមាតាបិតាដែលរក្សាបុត្រ ។

៧- នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ បុគ្គលដែលប្រកបដោយមេត្តា មិនបានឆេះរលាក ឬក្តៅក្រហាយដោយភ្លើង មិនបានស្លាប់ ឬវិនាសដោយពិសបំពុល មិនបានមុតដោយគ្រឿងសស្ត្រាវុធផ្សេងៗ ។

៨- តុវដំ ចិត្តំ សមាធិយតិ ចិត្តរបស់អ្នកប្រកបដោយមេត្តា តាំងនៅខ្ជាប់ខ្ជួនល្អដោយឆាប់រហ័ស មិនបានយឺតយូរឡើយ ។

៩- មុខវណ្ណោ វិប្បសីទតិ អ្នកប្រកបដោយមេត្តា រមែងមានមុខស្រស់បស់ល្អ ប្រៀបដូចផ្លែត្នោតទុំដែលទើបនឹងជ្រុះចាកទង ។

១០- អសម្មូឡ្ហោ កាលំ ករោតិ អ្នកប្រកបដោយមេត្តា មិនបានធ្វើមរណកាលដោយសេចក្តីវង្វេង គឺគ្មានសេចក្តីវង្វេងហើយស្លាប់ គឺថាស្លាប់ដូចគេដេកលក់ស្រួល ។

១១- ឧត្តរឹ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ អ្នកប្រកបដោយមេត្តា ទុកជាមិនបានត្រាស់ដឹងនូវគុណធម៌ ខ្ពង់ខ្ពស់ជាងមេត្តាសមាបត្តិនោះទេ លុះច្យុតអំពីមនុស្សលោកនេះទៅ ក៏គង់តែបានទៅកើតក្នុងព្រហ្មលោកជាពុំខាន ។ះ១៚

## អនុមោទនារក្ខាយាចនគាថា

សូធ្យនៅពេលសមាទាន ឬពេលធ្វើកុសលណាមួយហើយ

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**

**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ ។**

ទេវតាទាំងឡាយ ស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយមានឥទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យនៃយើងទាំងឡាយ ចូររក្សានូវព្រះពុទ្ធសាសនា (ឱ្យបានឋិតថេររុងរឿង) អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**

**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ រាជានោ ។**

ទេវតាទាំងឡាយ ស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយមានឥទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យនៃយើងទាំងឡាយ ចូររក្សានូវព្រះរាជាទាំងឡាយ (ឱ្យបានឋិតក្នុងជោគជ័យ) អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**

**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ ញាតយោ ។**

ទេវតាទាំងឡាយ ស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយមានឥទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យនៃយើងទាំងឡាយ ចូររក្សានូវញាតិទាំងឡាយ (ឱ្យបានចម្រុងចម្រើននិងសុខសាន្ត) អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**

**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ ។**

ទេវតាទាំងឡាយ ស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយមានឥទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យនៃយើងទាំងឡាយ ចូររក្សានូវសត្វទាំងឡាយ (ឱ្យបានចម្រុងចម្រើននិងសុខសាន្ត) អស់កាលជាយូរអង្វែងទៅ ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ នោ សទា ៕

ទេវតាទាំងឡាយ ស្ថិតនៅពួជអាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយមានឥទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យនៃយើងទាំងឡាយ ចូររក្សានូវយើងទាំងឡាយ (ឱ្យបានចម្រុងចម្រើននិងសុខសាន្ត) សព្វៗកាល អស់កាលជាយូរអង្វែងទៅ ។

## សុភមង្គលកថា

ពាក្យពោលប្រកាសសូមសេចក្តីល្អ សេចក្តីចម្រើនគ្រប់យ៉ាង

ហោតុ សព្វំ សុមង្គលំ   រក្ខន្តុ សព្វទេវតា
សព្វពុទ្ធានុភាវេន   សព្វធម្មានុភាវេន
សព្វសង្ឃានុភាវេន   សោត្ថិ ហោតុ និរន្តរំ ៕

ប្រែថា ហោតុ សព្វំ សុមង្គលំ សុមង្គលគឺសេចក្តីចម្រើនដ៏ល្អគ្រប់យ៉ាងចូរមានដល់ខ្ញុំ,
រក្ខន្តុ សព្វទេវតា ទេវតាទាំងពួងទាំងឡាយចូររក្សានូវខ្ញុំ,
សព្វពុទ្ធានុភាវេន ដោយអានុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ,
សព្វធម្មានុភាវេន ដោយអានុភាពនៃព្រះធម៌ទាំងពួង,
សព្វសង្ឃានុភាវេន ដោយអានុភាពនៃព្រះសង្ឃទាំងពួង,
សោត្ថិ ហោតុ និរន្តរំ សូមសិរីសួស្តីចូរមានដល់ខ្ញុំឱ្យបានគ្រប់ពេល កុំបីមានចន្លោះឡើយ ។

## សូធ្យឱ្យពរជាពាក្យកាព្យ

សូមឱ្យអ្នកទាំងឡាយ សុខសប្បាយទាំងអស់គ្នា
កុំឱ្យមានរោគា ព្រមទាំងញាតិសាច់សន្តាន ។
ចូរខំប្រឹងប្រព្រឹត្ត សាងសុចរិតធម៌ឱ្យបាន
សព្វថ្ងៃសាសនាមាន ខំធ្វើទានសីលភាវនា ។
កើតមកក្នុងលោកិយ ទាំងប្រុសស្រីមានវាសនា
ខំរៀនសូធ្យធម៌អាថ៌ ទាន់សាសនាព្រះទ្រង់ញាណ ។
ដ្បិតយើងមិនស្គាល់ផ្លូវ នឹងដើរទៅព្រះនិព្វាន
ជាទីសុខក្សេមក្សាន្ត លះបង់បានចាកមន្ទិល ។

## សូធ្យផ្សាយព្រះពុទ្ធសាសនា

សូមឱ្យព្រះពុទ្ធសាសនារុងរឿងចំរើន
សូមឱ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក
សូមឱ្យលោកទាំងមូលបានប្រកបដោយសន្តិភាព
ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា នត្ថិ សន្តិ បរំ សុខំ
ពុំមានសេចក្ដីសុខដទៃ ក្រៅអំពីសេចក្ដីស្ងប់ឡើយ ។

# មង្គលសូត្រ

សំណួរៈ មង្គលគឺអ្វី ? ចូរអធិប្បាយរៀបរាប់ល្មមស្តាប់បាន ?

ចម្លើយៈ មង្គល គឺសិរីសួស្តី ឬសេចក្តីចម្រើន ។ សេចក្តីចម្រើនផ្ទុយគ្នានឹងសេចក្តីវិនាស ។ ពាក្យថា "ចំរើន" គឺរីកចំធាត់ដោយសេចក្តីល្អគ្រប់យ៉ាង តាំងពីសុខយសស័ក្តិ ទ្រព្យសម្បត្តិជាដើម ។ សេចក្តីចម្រើនដែលហៅថាមង្គលនោះ គឺជាបំណងប៉ងប្រាថ្នារបស់មនុស្ស ក្នុងលោកសន្និវាសនេះ គ្មាននរណាម្នាក់បដិសេធមិនចង់បានឡើយ ។ មង្គលនេះ មនុស្សព្រមទាំងទេវតាខំស្វះស្វែងរកអស់រយៈកាលដ៏យូរ ក៏នៅតែរកមិនឃើញ ហើយមានទស្សនៈផ្សេងៗគ្នា ខ្លះយល់យ៉ាងនេះ ខ្លះយល់យ៉ាងនោះ មិនឯកភាពគ្នាឡើយ ទោះបីជាដែកគ្នាក៏មិនដាច់ស្រេចល្មមយកជាពិតប្រាកដបាន ។

ទេវតាព្រមទាំងមនុស្សទាំងឡាយ ប្រាថ្នានូវសេចក្តីសួស្តី បាននាំគ្នាគិតរកនូវមង្គល អស់រយៈពេល ១២ ឆ្នាំ ទេវតានិងមនុស្សទាំងនោះ ក្នុង ១ ម៉ឺនចក្រវាឡ ទោះបីខំប្រឹងគិតអស់កាលយូរ (ក៏នៅតែរកពុំឃើញអ្វីជាមង្គលនោះ) រឹកោលាហលក៏កើតរហូតដល់ភពជាទីនៅនៃព្រហ្មទៀត ។

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋីសាងថ្វាយទៀបក្រុងសាវត្ថី ។ លំដាប់នោះឯង ទេវតាអង្គ ១ វេលារាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អ ញ៉ាំងវត្តជេតពនជុំវិញទាំងអស់ឱ្យភ្លឺស្វាងហើយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងទីណា ក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំអង្គព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ ។

កាលទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគដោយគាថា (យ៉ាងនេះ) ថា ៖

ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ
អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ

ទេវតានិងមនុស្សទាំងឡាយជាច្រើន ប្រាថ្នានូវសេចក្តីសួស្តី បានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គទ្រង់ព្រះមេត្តាសំដែងប្រាប់ នូវមង្គលដ៏ឧត្តម ។

(ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងតបពាក្យទេវតានោះ ដោយពុទ្ធភាសិតជាគាថាយ៉ាងនេះថា)

**អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា**

**បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ**

កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ ១ កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ ១ កិរិយាបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។

**បដិរូបទេសវាសោ ច បុព្វេ ច កតបុញ្ញតា**

**អត្តសម្មាបណិធិ ច ឯតម្មង្គលមុត្តមំ**

កិរិយានៅក្នុងប្រទេសដ៏សមគួរ ១ ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន ១ កិរិយាតម្កល់ខ្លួនដោយប្រពៃ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។

**ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិតោ**

**សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ**

ភាវៈនៃបុគ្គលបានស្តាប់បានរៀនហើយដោយច្រើន ១ សិល្បសាស្ត្រគឺសេចក្តីឆ្លៀវឆ្លាសក្នុងហត្ថកម្មរបស់អ្នកបួសនិងគ្រហស្ថ ១ វិន័យដែលបុគ្គលសិក្សាដោយប្រពៃ ១ វាចាដែលបុគ្គលពោលត្រឹមត្រូវ ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

**មាតាបិតុឧបដ្ឋានំ បុត្តទារស្ស សង្គហោ**

**អនាកុលា ច កម្មន្តា ឯតម្មង្គលមុត្តមំ**

កិរិយាបម្រើនូវមាតា ១ កិរិយាបម្រើនូវបិតា ១ សេចក្តីសង្គ្រោះដល់បុត្រនិងភរិយា ១ ការងារទាំងឡាយដែលមិនច្របូកច្របល់ ១ ទាំង ៤ នេះជាមង្គលដ៏ឧត្តម។

ទានញ្ច ធម្មចរិយា ច ញាតកានញ្ច សង្គហោ
អនវជ្ជានិ កម្មានិ ឯតម្មង្គលមុត្តមំ

កិរិយាបរិច្ចាគទាន ១ កិរិយាប្រព្រឹត្តនូវធម៌ ១ សេចក្ដីសង្គ្រោះដល់ញាតិទាំងឡាយ ១ ការងារទាំងឡាយដែលមិនមានទោស ១ ទាំង ៤ នេះជាមង្គលដ៏ឧត្ដម ។

អារតី វិរតី បាបា មជ្ជបានា ច សញ្ញមោ
អប្បមាទោ ច ធម្មេសុ ឯតម្មង្គលមុត្តមំ

កិរិយាមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាប ១ សេចក្ដីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង ១ សេចក្ដីមិនប្រមាទក្នុងធម៌ទាំងឡាយ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្ដម ។

គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា
កាលេន ធម្មស្សវនំ ឯតម្មង្គលមុត្តមំ

សេចក្ដីគោរពចំពោះបុគ្គលដែលគួរគោរព ១ កិរិយាប្រព្រឹត្តបន្ទាបនូវខ្លួន ១ សេចក្ដីត្រេកអរចំពោះរបស់ដែលមាន ១ ភាវៈនៃបុគ្គលដែលដឹងនូវឧបការៈដែលអ្នកដទៃធ្វើហើយដល់ខ្លួន ១ កិរិយាស្ដាប់នូវធម៌តាមកាល ១ ទាំង ៥ នេះ ជាមង្គលដ៏ឧត្ដម ។

ខន្តិ(១) ; ច សោវចស្សតា សមណានញ្ច ទស្សនំ
កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ

សេចក្ដីអត់ធន់ ១ ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ ១ កិរិយាបានឃើញបានជួបនូវសមណៈទាំងឡាយ ១ ធម្មសាកច្ឆា គឺកិរិយាសន្ទនាទៅវិញទៅមកនូវធម៌តាមកាល ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្ដម ។

តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចាន ទស្សនំ
និព្វានសច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ

---

(១) តាមធ្លាប់សូត្របមកថា ខន្តី តែបានពិនិត្យទៅឃើញថា ខន្តិ ត្រូវល្អជាង ។

សេចក្ដីព្យាយាមដុតនូវបាបធម៌ ១ កិរិយាប្រព្រឹត្តនូវធម្មដ៏ប្រសើរ ១ កិរិយាឃើញនូវអរិយសច្ចទាំងឡាយ ១ កិរិយាធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្ដម ។

ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ
អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តមំ

ចិត្តនៃបុគ្គលឯណា ដែលលោកធម៌ទាំងឡាយពាល់ត្រូវហើយមិនរំភើបញាប់ញ័រ ១ មិនមានសេចក្ដីសោក ១ មានធូលីគឺរាគៈទៅប្រាសហើយ ១ ជាចិត្តក្សេមក្សាន្ត ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្ដម ។

ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា
សព្វត្ថ សោត្ថឹ គច្ឆន្តិ តន្តេសំ មង្គលមុត្តមន្តិ

ទេវតានិងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្ដីក្នុងទីទាំងពួង (ម្នាលទេវតា អ្នកចូរប្រកាន់ជឿថា) មង្គលទាំង ៣៨ ប្រការ មានកិរិយាមិនសេពគប់នូវបុគ្គលពាលជាដើមនោះ របស់ទេវតានិងមនុស្សទាំងអម្បាលនោះ ជាមង្គលដ៏ឧត្ដម ។

៚

# ពុទ្ធជយមង្គលគាថា

( ឧកញ៉ា សុត្តន្តប្រីជា ឥន្ទ ប្រែជាកាព្យ )

១- ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ
គ្រីមេខលំ ឧទិតឃោរសសេនមារំ
ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទលោកាចារ្យ ផ្ចាញ់ក្រុងមារចិត្តមោហន្ធ
និម្មិតដៃមួយពាន់ កាន់សស្ត្រាវុធនានា ។
ជិះគ្រីមេខលជាតិ កោញ្ចនាទខ្ទរពសុធា
ព្រមដោយមារសេនា ពន្លឹកលន់កងស័ព្ទសាន ។
ដោយធម្មពិធី ទានបារមីជាប្រធាន
ក្រុងមារចាញ់ទ្រង់ញាណ ប្រណម្យកាយថ្វាយវន្ទា ។
វិជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ១ ព្រះឈ្នះមារគ្រានោះហោង ។

២- មារាតិរេកមភិយុជ្ឈិតសព្វរត្តឹ
ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ
ខន្តីសុទន្តវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទពិននាយកៈ ផ្ចាញ់អាឡវកយក្ខឃោរឃៅ
រឹងរូសមិនតាំងនៅ ក្នុងខន្តីគុណសត្យា ។
រហូតអស់រាត្រី ព្រះជិនស្រីទ្រង់យុទ្ធនា
ក្រៃលែងក្រុងមារា ក្នុងបឋមសម្ពោធិ ។

ដោយព្រះពិធីញាណ ទ្រង់ទូន្មានដោយខន្តី
ញ៉ាំងចិត្តអសុរី ឱ្យបង់ព្យសនីចុះវន្ទា ។
រីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះឈ្នះអាឡវ៉កយក្ខហោង ។

៣- នាឡាគិរឹ គជវរំ អតិមត្តភូតំ
ទាវគ្គិចក្កមសនីវ សុទារុណន្តំ
មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ៗ

ព្រះមុនិន្ទពិនជិនស្រី ផ្ចាញ់ដំរីឈ្មោះនាឡា
គីរីវរគជា ដំហានក្លាចុះប្រេងព្រេច ។
សាហាវឆាវឆេះក្រៃ ដូចភ្លើងព្រៃឆេះកំទេច
មុតដូចចក្រក្រុតពេជ្រ ខ្លាំងដូចកាំអសនី ។
ដោយព្រះពិធីស្រប់ ស្រោចទឹកអប់គឺបារមី
មេត្តាព្រះជិនស្រី ញ៉ាំងដំរីឱ្យជ្រះថ្លា ។
រីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះឈ្នះនាឡាគីរី ។

៤- ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ
ធាវន្តិ យោជនបថង្គុលិមាលវន្តំ
ឥទ្ធីភិសង្ខតមនោ ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ៗ

ព្រះមុនិន្ទពិនលោកត្រៃ មានព្រះទ័យធ្វើបាដិហារ្យ
ផ្ចាញ់ចោរអង្គុលិមាល៍ មានកំរងគឺម្រាមដៃ ។

នៃមនុស្សដែលគាត់កាត់ មកដោតចាត់ជាមាល័យ
អង់អាចកំណាចក្រៃ ដ៏មានដៃស្ទាត់ប្រហារ ។
កាន់ដាវដោត្រី ដេញព្រះមុនីសាស្តាចារ្យ
ចម្ងាយផ្លូវកន្តារ កណ្តាលព្រៃបីយោជនា ។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះឈ្នះអង្គុលិមាល៍ ។

៥- កត្វាន កដ្ឋមុទរំ ឥវ គព្ភិនីយា
ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ
សន្តេន សោមវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទមានព្រះភាគ ផ្ចាញ់ទ្រុស្តពាក្យនាងចិញ្ចា
អំពើធ្វើដូចជា ស្រីមានគភ៌ចាស់ចើសពោះ ។
យកឈើធ្វើជាកូន ព័ទ្ធពោះខ្លួនពោលទ្រគោះ
ព្រះពុទ្ធឈ្នះកាលនោះ ដោយសមាចារពិធី ។
រម្ងាប់ពាក្យចណ្ឌាល នាកណ្តាលជនប្រុសស្រី
ចិញ្ចាចាញ់បារមី គឺសច្ចំពាក្យសត្យា ។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះសាស្តាឈ្នះចិញ្ចា ។

៦- សច្ចំ វិហាយ មតិសច្ចកវាទកេតុំ
វាទាភិរោបិតមនំ អតិអន្ធភូតំ
បញ្ញាបទីបជលិតោ ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ      រុងរឿងស្វាចដោយបញ្ញា
ផ្ចាញ់សច្ចកៈជា      និគ្រន្ថក្រៅពុទ្ធវិន័យ ។
អធ្យាស្រ័យលះបង់      ពាក្យសត្យត្រង់តាមគាប់ចៃ
សរសើរខ្លួនឯងក្រៃ      លើកកំពស់ដូចដងទង់ ។
បង្កើតមោហ៍ងងឹត      ដោយពោលឥតពាក្យទៀងត្រង់
ព្រះទ្រង់កំចាត់បង់      ដោយប្រទីបគឺបញ្ញា ។
វិជយមង្គល      ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា      ឈ្នះសច្ចកៈនិគ្រន្ថ ។

៧- នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ
បុត្តេន ថេរភុជគេន ទមាបយន្តោ
ឥទ្ធូបទេសវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទពិនទ្រង់ញាណ      ញុំាងមោគ្គល្លានមានអំណាច
ឱ្យប្លែងជានាគរាជ      ទៅទូន្មានព្យសនីភុជង្គ ។
ឈ្មោះនន្ទោបនន្ទ      ចិត្តមោហាន្ធរឿងឫទ្ធិរង់
ទិដ្ឋិកាចទ្រនង់      ទ្រង់ផ្ចាញ់ដោយពិធីឈាន ។
គឺឱ្យឧបទេស      ឫទ្ធិវិសេសដល់មោគ្គល្លាន
ឫទ្ធិនាគអន្តរធាន      ឱនចុះចាញ់ព្រះចេស្តា ។
វិជយមង្គល      ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា      ព្រះភគវាឈ្នះនាគហោង ។

៨- ទុគ្គាហទិដ្ឋិភុជគេន សុទដ្ឋហត្ថំ
ព្រហ្មំ វិសុទ្ធិជុតិមិទ្ធិពកាភិធានំ
ញាណាគទេន វិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

| | |
|---|---|
| ព្រះមុនិន្ទពិនគោតម | ផ្ចាញ់មហាព្រហ្មឈ្មោះពកា |
| សំគាល់ថាអាត្មា | រុងរឿងដោយគុណបរិសុទ្ធ ។ |
| ដៃកាន់អាសិរ្ពិស | គឺចិត្តទ្រឹស្តដ៏មោះមុត |
| កាន់ខុសផ្លូវសម្មុទ្ធ | មិនលើកលាកលះបង់ប្រាណ ។ |
| ទ្រង់ឈ្នះដោយពិធី | ឱសថវិសេសសម្រាន្ត |
| ផ្សំត្រូវគាប់សន្តាន | គឺព្រះញាណប្រោសទេសនា ។ |
| វិជយមង្គល | ចូរមានដល់អ្នករាល់គ្នា |
| ដោយតេជះជយា | ឈ្នះព្រហ្មឥតមានហ្មង ។ |

ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា

យោ វាចនោ ទិនទិនេ សរតេ មតន្ទី

ហិត្វានេកវិវិធានិ ចុបទ្ទវានិ

មោក្ខំ សុខំ អធិគមេយ្យ នរោ សបញ្ញោ ៗ

| | |
|---|---|
| យោ នរោ ជនឯណា | កបបញ្ញាប្រាសក្តីខ្ជិល |
| ឧស្សាហ៍សាងទានសីល | សូធ្យរំឭកព្រះធម៌ថ្លៃ ។ |
| គាថាប្រាំបីបទ | នេះកំណត់ឈ្មោះពុទ្ធជ័យ |
| ខំសូធ្យសព្វៗថ្ងៃ | កើតមង្គលជានិរន្តរ៍ ។ |
| សោ នរោ វិជននោះ | បានរំដោះរោគអាសន្ន |
| ឧបទ្រពអនេកលន់ | មានប្រការផ្សេងៗផង ។ |
| នឹងដល់ធម៌ក្សេមក្សាន្ត | គឺនិព្វានសុខកន្លង |
| លែងទុក្ខទាំងបួនកង | ដោយពុទ្ធជ័យមង្គលនេះ ។ |

ចប់

ពុទ្ធជយមង្គលគាថា

# មោរបរិត្ត

**ឧទេតយញ្ចក្ខុមា ឯករាជា ហរិស្សវណ្ណោ បឋវិប្បភាសោ** ព្រះអាទិត្យនេះ ជាដួងភ្នែក (នៃលោក) ជាឯករាជ មានពណ៌ ដូចជាពណ៌នៃមាស ញុំាងប្រឹថពីឱ្យភ្លឺស្វាង ហើយរះឡើង,

**តំ តំ នមស្សាមិ ហរិស្សវណ្ណំ បឋវិប្បភាសំ** ព្រោះហេតុនោះ ខ្ញុំសូមនមស្សការនូវព្រះអាទិត្យនោះ ដែលមានពណ៌ ដូចជាពណ៌នៃមាស ញុំាងប្រឹថពីឱ្យភ្លឺស្វាង,

**តយជ្ជ គុត្តា វិហរេមុ ទិវសំ** យើងទាំងឡាយ ដែលលោកគ្រប់គ្រងរក្សាហើយក្នុងថ្ងៃនេះ គប្បីនៅជាសុខអស់ ១ ថ្ងៃ,

**យេ ព្រាហ្មណា វេទគូ សព្វធម្មេ** ព្រាហ្មណ៍ទាំងឡាយឯណា ដល់នូវវេទក្នុងធម៌ទាំងពួង,

**តេ មេ នមោ តេ ច មំ បាលយន្តុ** ព្រាហ្មណ៍ទាំងឡាយនោះ (ចូរទទួល) នូវកិរិយានមស្សការរបស់ខ្ញុំ ម្យ៉ាងទៀត ព្រាហ្មណ៍ទាំងឡាយនោះ ចូររក្សានូវខ្ញុំ,

**នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា** សូមនមស្សការថ្វាយបង្គំ ចំពោះព្រះពុទ្ធជាម្ចាស់ទាំងឡាយ សូមនមស្សការថ្វាយបង្គំ ចំពោះពោធិញ្ញាណ (នៃព្រះពុទ្ធទាំងឡាយនោះ),

**នមោ វិមុត្តានំ នមោ វិមុត្តិយា** សូមនមស្សការថ្វាយបង្គំចំពោះ (ព្រះអរិយបុគ្គលទាំងឡាយ) ដែលលោកផុតហើយចាករាគាទិក្កិលេស សូមនមស្សការថ្វាយបង្គំ ចំពោះវិមុត្តិធម៌ (នៃព្រះអរិយបុគ្គលទាំងឡាយនោះ),

**ឥមំ សោ បរិត្តំ កត្វា មោរោ ចរតិ ឯសនា** ក្ងោកនោះ លុះតែបានធ្វើនូវព្រះបរិត្តនេះហើយ ទើបចរទៅដើម្បីស្វែងរកអាហារ ។

**អបេតយញ្ចក្ខុមា ឯករាជា ហរិស្សវណ្ណោ បឋវិប្បភាសោ** ព្រះអាទិត្យនេះ ជាដួងភ្នែក (នៃលោក) ជាឯករាជ មានពណ៌ ដូចជាពណ៌នៃមាស ញ៉ាំងប្រឹថពីឱ្យភ្លឺស្វាង ហើយអស្តង្គតទៅ,

**តំ តំ នមស្សាមិ ហរិស្សវណ្ណំ បឋវិប្បភាសំ** ព្រោះហេតុនោះ ខ្ញុំសូមនមស្សការនូវព្រះអាទិត្យនោះ ដែលមានពណ៌ ដូចជាពណ៌នៃមាស ញ៉ាំងប្រឹថពីឱ្យភ្លឺស្វាង,

**តយជ្ជ គុត្តា ទិវសម្ពេ រត្តឹ** យើងទាំងឡាយ ដែលលោកគ្រប់គ្រងរក្សាហើយក្នុងថ្ងៃនេះ គប្បីនៅជាសុខអស់ ១ រាត្រី,

**យេ ព្រាហ្មណា វេទគូ សព្វធម្មេ** ព្រាហ្មណ៍ទាំងឡាយឯណា ដល់នូវវេទក្នុងធម៌ទាំងពួង,

**តេ មេ នមោ តេ ច មំ បាលយន្តុ** ព្រាហ្មណ៍ទាំងឡាយនោះ (ចូរទទួល) នូវកិរិយានមស្សការរបស់ខ្ញុំ ម្យ៉ាងទៀត ព្រាហ្មណ៍ទាំងឡាយនោះ ចូររក្សានូវខ្ញុំ,

**នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា** សូមនមស្សការថ្វាយបង្គំ ចំពោះព្រះពុទ្ធជាម្ចាស់ទាំងឡាយ សូមនមស្សការថ្វាយបង្គំ ចំពោះពោធិញ្ញាណ (នៃព្រះពុទ្ធទាំងឡាយនោះ),

**នមោ វិមុត្តានំ នមោ វិមុត្តិយា** សូមនមស្សការថ្វាយបង្គំចំពោះ (ព្រះអរិយបុគ្គលទាំងឡាយ) ដែលលោកផុតហើយចាករាគាទិក្កិលេស សូមនមស្សការថ្វាយបង្គំ ចំពោះវិមុត្តិធម៌ (នៃព្រះអរិយបុគ្គលទាំងឡាយនោះ),

**ឥមំ សោ បរិត្តំ កត្វា មោរោ ចរតិ ឯសនា** ក្ងោកនោះ លុះតែបានធ្វើនូវព្រះបរិត្តនេះហើយ ទើបបានសម្រេចនូវកិរិយានៅ ។

ៜៜ

# ជយបរិត្តគាថា

មហាការុណិកោ នាថោ ហិតាយ សព្វបាណិនំ

បូរេត្វា បារមី សព្វា បត្តោ សម្ពោធិមុត្តមំ

ព្រះសម្មាសម្ពុទ្ធ ជាទីពឹងនៃសត្វលោក ទ្រង់ប្រកបដោយមហាករុណា ព្រះអង្គបំពេញនូវបារមីទាំងឡាយទាំងពួង ដើម្បីប្រយោជន៍ដល់សត្វទាំងអស់ ហើយទ្រង់បានដល់នូវសម្ពោធិញ្ញាណដ៏ឧត្តមហើយ ។

ឯតេន សច្ចវជ្ជេន ហោតុ តេ ជយមង្គលំ

ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមជ័យមង្គលកើតមានដល់អ្នក ។

ជយន្តោ ពោធិយា មូលេ សក្យានំ នន្ទិវឌ្ឍនោ

ឯវំ ត្វំ វិជយោ ហោហិ ជយស្សុ ជយមង្គលេ

អបរាជិតបល្លង្កេ សីសេ បថវិបោក្ខរេ

អភិសេកេ សព្វពុទ្ធានំ អគ្គប្បត្តោ បមោទតិ

ព្រះសម្មាសម្ពុទ្ធ ទ្រង់ញ៉ាំងសេចក្ដីត្រេកអរនៃសាក្យៈទាំងឡាយឱ្យចម្រើន ព្រះអង្គឈ្នះមារហើយ បានដល់នូវភាពជាបុគ្គលប្រសើរបំផុត ទ្រង់រីករាយ (ចំពោះធម៌ដែលព្រះអង្គត្រាស់ដឹង) លើអបរាជិតបល្ល័ង្កជាជយមង្គល ទៀបគល់ពោធិព្រឹក្ស ត្រង់ផ្ចិតផែនដីដូចជាស្លឹកឈូក ជាទីអភិសេកនៃព្រះពុទ្ធគ្រប់ព្រះអង្គ (យ៉ាងណាមិញ) សូមឱ្យអ្នកជាបុគ្គលមានជម្នះឈ្នះ (អស់សត្រូវ) យ៉ាងនោះឯង ។

សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ

សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ

(ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ពេលនោះ) ឈ្មោះថាជានក្ខត្តឫក្សល្អ ជាមង្គលល្អ ជាពេលភ្លឺស្វាងល្អ ជាពេលនៃអរុណរះល្អ

ជាខណៈល្អ ជាយាមល្អ (ទានដែលបុគ្គលបានបូជាហើយ) ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះ) ឈ្មោះថាជាគ្រឿងបូជាល្អ ។

**បទក្ខិណំ កាយកម្មំ វាចាកម្មំ បទក្ខិណំ**

**បទក្ខិណំ មនោកម្មំ បណិធិ តេ បទក្ខិណា**

(ក្នុងថ្ងៃនោះ) កាយកម្ម ក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន វចីកម្ម ក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន មនោកម្ម ក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន សេចក្តីប្រាថ្នាទាំងឡាយរបស់អ្នកទាំងនោះ ក៏ឈ្មោះថានាំឱ្យមានសេចក្តីចម្រើន

**បទក្ខិណានិ កត្វាន លភន្តត្ថេ បទក្ខិណេ**

បុគ្គលដែលបានធ្វើនូវកាយកម្ម វចីកម្ម មនោកម្ម គួរដល់សេចក្តីចម្រើន (យ៉ាងនេះ) ហើយ ក៏រមែងបាននូវប្រយោជន៍ ដ៏ចម្រើនទាំងឡាយ ។

# បារមីធម៌ ១០ យ៉ាង

១-ទានបារមី គុណជាតិជាហេតុដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះការឱ្យទាន ។

២-សីលបារមី គុណជាតិជាហេតុដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះការរក្សាសីល ។

៣-នេក្ខម្មបារមី គុណជាតិជាហេតុដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះការចេញបួស ។

៤-បញ្ញាបារមី គុណជាតិជាហេតុដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះការយល់ឃើញច្បាស់ ។

៥-វិរិយបារមី គុណជាតិជាហេតុដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះការព្យាយាម ។

៦-ខន្តិបារមី គុណជាតិជាហេតុដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះសេចក្ដីអត់ធន់ ។

៧-សច្ចបារមី គុណជាតិជាហេតុដល់នូវត្រើយ គឺព្រះនិព្វានព្រោះសេចក្ដីទៀងត្រង់ ។

៨-អធិដ្ឋានបារមី គុណជាតិជាហេតុដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះការតាំងចិត្តស៊ប់ក្នុងកុសលធម៌ ។

៩-មេត្តាបារមី គុណជាតិជាហេតុដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះសេចក្ដីស្រឡាញ់រាប់អាន ដោយការតាំងចិត្ត មិនព្យាបាទដល់ជនដទៃ ។

១០-ឧបេក្ខាបារមី គុណជាតិជាហេតុដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះការតាំងចិត្តនៅជាកណ្ដាល ក្នុងសត្វនិងសង្ខារទូទៅ ។

# បារមី ៣០ ប្រការ

**ទានបារមី**

ឥតិបិ ទានបារមីសម្បន្នោ សោ ភគវា
ឥតិបិ ទានឧបបារមីសម្បន្នោ សោ ភគវា
ឥតិបិ ទានបរមត្ថបារមីសម្បន្នោ សោ ភគវា

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ ទានបារមី ទានឧបបារមី ទានបរមត្ថបារមី ដូច្នេះផង

**សីលបារមី**

ឥតិបិ សីលបារមីសម្បន្នោ សោ ភគវា
ឥតិបិ សីលឧបបារមីសម្បន្នោ សោ ភគវា
ឥតិបិ សីលបរមត្ថបារមីសម្បន្នោ សោ ភគវា

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ សីលបារមី សីលឧបបារមី សីលបរមត្ថបារមី ដូច្នេះផង

**នេក្ខម្មបារមី**

ឥតិបិ នេក្ខម្មបារមីសម្បន្នោ សោ ភគវា
ឥតិបិ នេក្ខម្មឧបបារមីសម្បន្នោ សោ ភគវា
ឥតិបិ នេក្ខម្មបរមត្ថបារមីសម្បន្នោ សោ ភគវា

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ នេក្ខម្មបារមី នេក្ខម្មឧបបារមី នេក្ខម្មបរមត្ថបារមី ដូច្នេះផង

**បញ្ញាបារមី**

ឥតិបិ បញ្ញាបារមីសម្បន្នោ សោ ភគវា
ឥតិបិ បញ្ញាឧបបារមីសម្បន្នោ សោ ភគវា
ឥតិបិ បញ្ញាបរមត្ថបារមីសម្បន្នោ សោ ភគវា

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ { បញ្ញាបារមី / បញ្ញាឧបបារមី / បញ្ញាបរមត្ថបារមី } ដូច្នេះផង

<u>**វីរិយបារមី**</u> { ឥតិបិ វីរិយបារមីសម្បន្នោ សោ ភគវា / ឥតិបិ វីរិយឧបបារមីសម្បន្នោ សោ ភគវា / ឥតិបិ វីរិយបរមត្ថបារមីសម្បន្នោ សោ ភគវា }

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ { វីរិយបារមី / វីរិយឧបបារមី / វីរិយបរមត្ថបារមី } ដូច្នេះផង

<u>**ខន្តិបារមី**</u> { ឥតិបិ ខន្តិបារមីសម្បន្នោ សោ ភគវា / ឥតិបិ ខន្តិឧបបារមីសម្បន្នោ សោ ភគវា / ឥតិបិ ខន្តិបរមត្ថបារមីសម្បន្នោ សោ ភគវា }

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ { ខន្តិបារមី / ខន្តិឧបបារមី / ខន្តិបរមត្ថបារមី } ដូច្នេះផង

<u>**សច្ចបារមី**</u> { ឥតិបិ សច្ចបារមីសម្បន្នោ សោ ភគវា / ឥតិបិ សច្ចឧបបារមីសម្បន្នោ សោ ភគវា / ឥតិបិ សច្ចបរមត្ថបារមីសម្បន្នោ សោ ភគវា }

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ { សច្ចបារមី / សច្ចឧបបារមី / សច្ចបរមត្ថបារមី } ដូច្នេះផង

<u>**អធិដ្ឋានបារមី**</u> { ឥតិបិ អធិដ្ឋានបារមីសម្បន្នោ សោ ភគវា / ឥតិបិ អធិដ្ឋានឧបបារមីសម្បន្នោ សោ ភគវា / ឥតិបិ អធិដ្ឋានបរមត្ថបារមីសម្បន្នោ សោ ភគវា }

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ
- អធិដ្ឋានបារមី
- អធិដ្ឋានឧបបារមី
- អធិដ្ឋានបរមត្ថបារមី

ដូច្នេះផង

**<u>មេត្តាបារមី</u>**
- **ឥតិបិ មេត្តាបារមីសម្បន្នោ សោ ភគវា**
- **ឥតិបិ មេត្តាឧបបារមីសម្បន្នោ សោ ភគវា**
- **ឥតិបិ មេត្តាបរមត្ថបារមីសម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ
- មេត្តាបារមី
- មេត្តាឧបបារមី
- មេត្តាបរមត្ថបារមី

ដូច្នេះផង

**<u>ឧបេក្ខាបារមី</u>**
- **ឥតិបិ ឧបេក្ខាបារមីសម្បន្នោ សោ ភគវា**
- **ឥតិបិ ឧបេក្ខាឧបបារមីសម្បន្នោ សោ ភគវា**
- **ឥតិបិ ឧបេក្ខាបរមត្ថបារមីសម្បន្នោ សោ ភគវា**

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិបូណ៌ហើយដោយ
- ឧបេក្ខាបារមី
- ឧបេក្ខាឧបបារមី
- ឧបេក្ខាបរមត្ថបារមី

ដូច្នេះផង

**សមតឹសបារមិតានុភាវេន មយ្ហំ ហន្ត្វា សព្វេ ទុក្ខសោករោគភយូ-បទ្ទវទោមនស្សុបាយាសេ អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ ។**

ដោយអានុភាព នៃបារមីទាំង ៣០ (នៃព្រះដ៏មានព្រះភាគអង្គនោះ) សូមឱ្យកំចាត់បង់នូវទុក្ខសោក រោគភ័យឧបទ្រព ទោមនស្សនិងឧបាយាសៈទាំងឡាយទាំងពួង ទាំងសេចក្តីអន្តរាយទាំងឡាយរបស់ខ្ញុំ ចូរឱ្យវិនាសបាត់ទៅកុំបីមានសេសសល់ឡើយ ។

## គារវៈ ៦ យ៉ាង

១- ពុទ្ធគារវតា គោរពព្រះពុទ្ធ

២- ធម្មគារវតា គោរពព្រះធម៌

៣- សង្ឃគារវតា គោរពព្រះសង្ឃ

៤- សិក្ខាគារវតា គោរពសិក្ខា

៥- អប្បមាទគារវតា គោរពអប្បមាទធម៌

៦- បដិសណ្ឋារគារវតា គោរពបដិសណ្ឋារៈ

## អនុស្សតិ ១០ យ៉ាង

១- ពុទ្ធានុស្សតិ រឭកដល់គុណព្រះពុទ្ធ

២- ធម្មានុស្សតិ រឭកដល់គុណព្រះធម៌

៣- សង្ឃានុស្សតិ រឭកដល់គុណព្រះសង្ឃ

៤- សីលានុស្សតិ រឭកដល់សីលរបស់ខ្លួន

៥- ចាគានុស្សតិ រឭកដល់ទានដែលខ្លួនបរិច្ចាគហើយ

៦- ទេវតានុស្សតិ រឭកដល់គុណព្រះធម៌ធ្វើឱ្យកើតជាទេវតា

៧- មរណានុស្សតិ រឭកដល់សេចក្តីស្លាប់

៨- កាយគតានុស្សតិ រឭកដល់កាយឱ្យឃើញថាមិនស្អាតមិនល្អ

៩- អានាបានុស្សតិ រឭកដល់ខ្យល់ដង្ហើមចេញចូល

១០- ឧបសមានុស្សតិ រឭកដល់ធម៌ជាទីស្ងប់រម្ងាប់ គឺព្រះនិព្វាន

# ពិធីក្នុងព្រះពុទ្ធសាសនា

១

៖

៩

[illegible]

# ពិធីក្នុងព្រះពុទ្ធសាសនា

ឧបាសក ឧបាសិកា ទាយក ទាយិកា ឬលោកអ្នកដែលជាប្រមុខ ចាត់ការត្រូវចេះត្រូវយល់ក្នុងពិធីនោះៗ មានកិច្ចរៀបចំអាសនៈព្រះពុទ្ធរូប និងអាសនៈសម្រាប់ព្រះសង្ឃ, អាសនៈព្រះពុទ្ធរូបត្រូវរៀបដាក់ខាងស្តាំដៃ នៃអាសនៈព្រះសង្ឃ (គឺព្រះសង្ឃគង់នៅខាងឆ្វេងព្រះពុទ្ធរូប) មានរៀបចំគ្រឿងសក្ការៈបូជាព្រះរតនត្រ័យ មានទៀន ធូបកម្រងផ្កា ឬវត្ថុផ្សេងៗ ដែលជាគ្រឿងលំអលើអាសនៈ ។

បន្ទាប់មកលោកអាចារ្យ ឬសាមីដើមបុណ្យមានធ្វើបដិសណ្ឋារៈដល់ភ្ញៀវ និងការទទួលបដិសណ្ឋារៈគារវៈចំពោះព្រះភិក្ខុសង្ឃរួចស្រេចហើយ លោកអាចារ្យ ឬ លោកអ្នកប្រមុខនៃបុណ្យ ចាប់ផ្តើមធ្វើពិធីនមស្សការព្រះរតនត្រ័យ សមាទានសីល អារាធនា ព្រះសង្ឃចំរើនព្រះបរិត្ត មានជាអាទិ៍ ៖

## បរិត្តភាសនាយាចនគាថា

- ពាក្យអារាធនាព្រះភិក្ខុសង្ឃសូមឱ្យចំរើនព្រះបរិត្ត

វិបត្តិប្បដិពាហាយ សព្វសម្បត្តិ សិទ្ធិយា
**សព្វទុក្ខវិនាសាយ បរិត្តំ ព្រូថ មង្គលំ ។**
**វិបត្តិប្បដិពាហាយ សព្វសម្បត្តិ សិទ្ធិយា**
**សព្វភយវិនាសាយ បរិត្តំ ព្រូថ មង្គលំ ។**
**វិបត្តិប្បដិពាហាយ សព្វសម្បត្តិ សិទ្ធិយា**
**សព្វរោគវិនាសាយ បរិត្តំ ព្រូថ មង្គលំ ។**

ប្រែថា សូមព្រះករុណាទាំងឡាយ ចំរើននូវព្រះបរិត្តជាជ័យមង្គល ដើម្បីនឹងការពារបញ្ចៀសនូវវិបត្តិ គឺសេចក្តីអន្តរាយទាំងពួង ដើម្បីនឹងឱ្យបានសម្រេច នូវសម្បត្តិគ្រប់យ៉ាង ដើម្បីនឹងញ៉ាំង ទុក្ខ ភ័យ រោគ ទាំងអស់ឱ្យវិនាសបាត់ទៅ ។

លុះលោកអាចារ្យអារាធនានិមន្តដូច្នេះហើយ ព្រះសង្ឃអ្នកចំរើនព្រះបរិត្តនោះ ត្រូវសូធ្យធម៌ "សគ្គេ កាមេ ។ល។ អយម្ភទន្តា" ប្រកាសអញ្ជើញទេវតារួចហើយ ទើបចំរើនព្រះបរិត្តពុទ្ធមន្ត តាមសមគួរដល់ពុទ្ធានុញ្ញាត ក្នុងខុទ្ទកវត្ថុក្ខន្ធកៈ ក្នុងព្រះវិន័យ ។

## ទេវតាបកាសនគាថា

ពាក្យប្រកាសអញ្ជើញពពួកទេវតា

**សគ្គេ កាមេ ច រូបេ គិរិសិខរតដេ ចន្តលិក្ខេ វិមានេ ទីបេ រដ្ឋេ ច គាមេ តរុវនគហនេ គេហវត្ថុម្ហិ ខេត្តេ ភុម្មា ចាយន្តុ ទេវា ជលថលវិសមេ យក្ខគន្ធព្វនាគា តិដ្ឋន្តា សន្តិកេ យំ មុនិវរវចនំ សាធវោ មេ សុណន្តុ ។**

**ធម្មស្សវនកាលោ អយម្ភទន្តា,**

**ធម្មស្សវនកាលោ អយម្ភទន្តា,**

**ធម្មស្សវនកាលោ អយម្ភទន្តា ។**

ប្រែថា ទេវតាទាំងឡាយ ដែលស្ថិតនៅក្នុងស្ថានសួគ៌ ដែលជាកាមភពនិងរូបភពក្តី ភុម្មទេវតាទាំងឡាយ ដែលស្ថិតនៅក្នុងទិព្វវិមាន គឺលើកំពូលភ្នំ ឬភ្នំដែលដាច់ក្តី ពួជ៏អាកាសក្តី នៅនាកោះ និងដែននិងស្រុកក្តី នៅនាដើមព្រឹក្សានិងព្រៃញាតស្បាតឬទីស្រែចំការក្តី យក្ខនិងគន្ធព្វនិងនាគទាំងឡាយ ដែលស្ថិតនៅនាទីទឹកទីគោក ឬទីមិនរាបស្មើ ដែលនៅក្នុងទីជិតនេះក្តី សូមអញ្ជើញមកប្រជុំគ្នា (ក្នុងទីនេះ) ពាក្យឯណាដែលជាពាក្យព្រះសក្យមុនីដ៏ប្រសើរ (ដែលយើងនឹងសូត្រឥឡូវនេះ) លោកអ្នកសប្បុរសទាំងឡាយ ចូរស្តាប់នូវពាក្យនោះ (អំពីសម្នាក់) នៃខ្ញុំ (ដោយគោរព) ។

**ធម្មស្សវនកាលោ អយម្ភទន្តា** បពិត្រលោកអ្នកដ៏ចំរើនទាំងឡាយ ពេលនេះជាពេលគួរនឹងស្តាប់នូវព្រះធម៌ (៣ដង) ។

## ពាក្យប្រកាសមុនអារាធនាធម៌ទេសនា

(បទព្រហ្មគីត)

| | |
|---|---|
| អហំ រីខ្ញុំម្ចាស់ | សូមប្រកាសក្រាបប្រណិប័តន៍ |
| ដល់អស់ពួកបរិស័ទ | ដែលលះកាត់ក្តីកង្វល់ ។ |
| ហើយមកប្រជុំគ្នា | ព្រោះប្រាថ្នាយកកុសល |
| ហេតុនេះសូមតម្កល់ | តាំងចិត្តស្តាប់ធម៌ទេសនា ។ |
| ដើម្បីជាការបុណ្យ | នឹងជាគុណច្រើនណាស់ណា |
| អំណាចស្តាប់ទេសនា | ដោយជ្រះថ្លាក្នុងសន្តាន ។ |
| សូមតាំងចិត្តឱ្យស្អាត | ខ្ញុំអារាធនាថ្វាន |
| និមន្តលោកនិទាន | ទេសន៍ទូន្មានយើងរាល់គ្នា ។ |
| ពេលនេះសូមបរិស័ទ | ដែលប្រណិប័តន៍គាល់ត្រៀបត្រា |
| កុំពោលកុំចរចា | និយាយគ្នាបែរមុខក្រោយ ។ |
| សូមផ្ចង់នូវសញ្ញា | ផ្ទៀងសោតាស្តាប់កុំធ្លោយ |
| ទើបនឹងបានផលសោយ | អានិសង្សប្រាំប្រការ ។ |

## ធម្មទេសនាយាចនគាថា

ពាក្យសូមអារាធនាធម្មកថិក សម្តែងធម៌ទេសនា

ព្រហ្មា ច លោកា ធិបតី សហម្បតី

កតញ្ជលី អន្ធិវរំ អយាចថ ។

សន្តីធ សត្តាប្បរជក្ខជាតិកា

ទេសេតុ ធម្មំ អនុកម្បិមំ បជំ ។

សទ្ធម្មភេរី ចិនយញ្ញ តាយំ

សុត្វាន ពន្ធំ អភិធម្មច្ឆម្មំ ៗ
អារកោជយន្តោ ចតុសច្ចទណ្ឌំ
បព្វោធនេយ្យេ បរិសាយ មជ្ឈេ ៗ

សហម្បតីព្រហ្មា ភគវន្តំ អាយាចថ
តុណ្ហីភាវេន តំ ញត្វា ការុញ្ញេនាធិវាសយ ៗ
តម្ហា វុដ្ឋាយ បាទេន មិគទាយំ តតោ គតោ
បញ្ចវគ្យានយោ នេយ្យេ អមំបាយេសំ ធម្មតោ ៗ
តតោ បត្វភិ សម្ពុទ្ធោ អនូនា ធម្មទេសនំ
មាឃចស្សានិ ទេសេសិ សត្តានំ អត្ថសិទ្ធកំ ៗ
តេន សាធុ អយ្យោ ភន្តេ ទេសេតុ ធម្មទេសនំ
សព្វាយិធ បរិសាយ អនុកម្បិ ភាគចេ ៗ

ប្រែ. (បទព្រហ្មគិត)

គ្រានោះសហម្បតី- ព្រហ្មជាឥស្សរលោកា
ចូលគាល់ព្រះសាស្ដា លើកហត្ថាសិរោរាប ។
ហើយពោលពាក្យទូលថា សូមករុណាស្ដេចទ្រង់ជ្រាប
ត្បិតសត្វអន់ទន់ទាប ទុព្វលភាពបាបក្រៃក្រាស់ ។
ទន្ទឹងព្រះធម៌ថ្លៃ ជានិស្ស័យបច្ច័យច្បាស់
ឥឡូវទ្រង់បានត្រាស់ ត្រេកអរណាស់ពុំកន្ទើយ ។
សត្វខ្លះក្រាស់ដោយកាម មិនយល់តាមត្រៃលក្ខណ៍ឡើយ
ឥឡូវយល់ខ្លះហើយ ដោយអំណាចព្រះមានបុណ្យ ។
បើបានស្ដាប់ទេសនា បញ្ញាក្លាខ្លាំងលើសមុន
សូមព្រះដ៏មានបុណ្យ ទ្រង់និមន្តត្រាស់ទេសនា ។
ប្រោសសត្វបំបាត់សោក ទាំងភពរោគរូបតណ្ហា

ងងឹតប្រែជ្រះថ្លា រកឹតបញ្ញាភិយោយល់ ។
ត្រៃលោកគោកត្រៃលក្ខណ៍ សង្សារចក្ររិលមិនដល់
អវិជ្ជាជាឫសគល់ ជាបច្ច័យនៃសង្ខារ ។
នាំសត្វឱ្យសោកសៅ លិចលង់នៅក្នុងសង្សារ
បញ្ចមារមោហន្ធការ រឹតរុំហ៊ុំជុំជាប់នៅ ។
ហេតុនេះសូមព្រះអង្គ ប្រោសស្រោចស្រង់ដាក់សំពៅ
ចំឡងសត្វឆ្លងទៅ កាន់ត្រើយត្រាណនិព្វាននាយ ។
ដូចកល់ប្រទីបធំ សាយត្រសុំភ្លឺព្រោងព្រាយ
បំភ្លឺសត្វទាំងឡាយ ឱ្យសប្បាយក្សាន្តភិរម្យ ។
ព្រះសទ្ធម្មជាស្តរជ័យ ព្រះវិន័យជារាងធំ
ព្រះសូត្រជាខ្សែរុំ ព្រះអភិធម្មជាស្បែកដាស ។
អរិយសច្ចជាអន្លង សម្រាប់ទូងឱ្យឮច្បាស់
សត្វលោកងោកងុយណាស់ ឮស្គរដាស់ក្រោកឡើងបាន ។
បរិស័ទ ៤ ចំពូក ដូចផ្កាឈូកក្នុងជលស្ថាន
ខ្លះផុសចាំសូរ្យឆាន រះនឹងរីកដោយរស្មី ។
ព្រះធម៌ជាសូរ្យសែង ៖ រះឡើងចែងចាំងរស្មី
បំភ្លឺលោកទាំងបី ៖ ឱ្យយល់ផ្លូវស្ថានសុខា ។

សហម្បតីព្រហ្ម ឱនបង្គំអារាធនា
សម្ដេចព្រះភគវា ដោយគាថាយ៉ាងនេះឯង ។
ព្រះពុទ្ធទ្រង់អនុកូល ព្រមទទួលនឹងសម្ដែង
ដោយគុណ្ហីភាពថ្លែង តាមភារៈគុណករុណា ។
ទើបក្រោកចាកទីនោះ ភក្ត្រាឆ្ពោះព្រៃមិគទាយ៍
យាងចេញចរលីលា ពីទីនោះដោយព្រះបាទ ។

ញុំាងសត្វផុតពុទ្ធចក្រ មានបញ្ញវត្ថ័យជាអាទិ៍
ឱ្យផឹកអម្រឹតជាតិ រសនិព្វានតាមធម្មតា ។
ចាប់ដើមពីនោះឯង ទ្រង់សំដែងធម៌ទេសនា
ធ្វើពុទ្ធក្រិត្យា អស់វស្សាសែសិបប្រាំ ។
ពុំថយពុំបន្ទូរ ប្រយោជន៍យូរអង្វែងឆ្នាំ
សម្រេចពុទ្ធកម្ម ដល់សព្វសត្វទាំងភពត្រៃ ។
ហេតុនោះឥឡូវនេះ យើងខ្ញុំនេះសាទរក្រៃ
បពិត្រព្រះគុណថ្លៃ សូមនិមន្តប្រោសទេសនា ។
អនុគ្រោះពួកបរិស័ទ ដែលជាប់ខាត់ដោយមោហា
ឱ្យកើតមានបញ្ញា ប្រាកដនាទីនេះហោង ។

## ពាក្យអារាធនាធម៌ទេសនា មួយបែបទៀត

ឧភាស មយំ យើងខ្ញុំតាំងចិត្តជ្រះថ្លា
សង្រួមកាយវាចា ផ្ទៀងសោតាចាំស្តាប់ធម៌ ។
គោរពថ្វាយវន្ទា ត្រ័យរតនាកែវបវរ
គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃអង្គសាវ័ក ។
ហើយសូមអារាធនា ធម៌ទេសនាដោយចិត្តស្ម័គ្រ
សំដៅឆ្ពោះអរិយមគ្គ អរិយផលព្រះនិព្វាន ។
បពិត្រព្រះករុណា សូមមេត្តាប្រោសប្រទាន
ធម៌ទេសនាទូន្មាន ដល់យើងខ្ញុំទាំងអស់គ្នា ។
ឱ្យបានជាពូជបុណ្យ និងជាគុណកើតបញ្ញា
ព្រោះស្តាប់ធម៌ទេសនា ព្រះករុណាគ្រានេះហោង ។

# ធម៌សុខោ

សុខោ ពុទ្ធានមុប្បាទោ កិរិយាកើតឡើងនៃព្រះពុទ្ធទាំងឡាយ ជាហេតុនាំមកនូវសេចក្តីសុខ,

សុខា សទ្ធម្មទេសនា កិរិយាសម្តែងនូវព្រះសទ្ធម្ម គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ជាទីនាំមកនូវសេចក្តីសុខ,

សុខា សង្ឃស្ស សាមគ្គី សេចក្តីព្រមព្រៀងគ្នានៃព្រះសង្ឃ ជាគុណជាតិនាំមកនូវសេចក្តីសុខ,

សមគ្គានំ តបោ សុខោ តបៈគុណនៃព្រះសង្ឃទាំងឡាយ អ្នកព្រមព្រៀងគ្នា ជាហេតុនាំមកនូវសេចក្តីសុខ,

ទិវា តបតិ អាទិច្ចោ ព្រះអាទិត្យរុងរឿងបានតែក្នុងវេលាថ្ងៃ,

រត្តិមាភាតិ ចន្ទិមា ព្រះចន្ទរុងរឿងបានតែក្នុងវេលាយប់,

សន្នទ្ធោ ខត្តិយោ តបតិ ព្រះមហាក្សត្រលុះទ្រង់គ្រឿងប្រដាប់សម្រាប់រាជ ទើបរុងរឿងបាន,

ឈាយី តបតិ ព្រាហ្មណោ ព្រាហ្មណ៍លុះតែចំរើននូវឈាន ទើបរុងរឿងបាន,

អថ សព្វមហោរត្តិំ ពុទ្ធោ តបតិ តេជសា ឯព្រះពុទ្ធជាម្ចាស់ ទ្រង់រុងរឿងដោយតេជៈទាំងថ្ងៃទាំងយប់,

ឯតេន សច្ចវជ្ជេន សុវត្ថិ ហោតុ សព្វទា សេចក្តីសុខសួស្តី សូមកើតមានក្នុងកាលទាំងពួង ដោយកិរិយាពោលនូវពាក្យសច្ចនេះ ។

ហិរិឱត្តប្បសម្បន្នា សុក្កធម្មសមាហិតា

សន្តោ សប្បុរិសា លោកេ ទេវធម្មាតិ វុច្ចរេ

សប្បុរសទាំងឡាយ មានចិត្តរម្ងាប់ប្រកបព្រមហើយដោយ ហិរិ និង ឱត្តប្បៈ (ថែមទាំង) មានចិត្តចុះសិប់ចំពោះធម៌មានពណ៌ស (គឺសុចរិតធម៌) ។ អ្នកប្រាជ្ញទាំងឡាយលោកឱ្យនាមថា អ្នកមានទេវធម៌ក្នុងលោក ។

សគ្គោ សទ្ធម្មំ សុត្វា សព្ពញ្ញុ ជិនសាសនេ

កប្បានំ សតសហស្សានិ ទុគ្គតឹ សោ ន គច្ឆតិ

បុគ្គលឯណា បានស្តាប់នូវព្រះសទ្ធម្មរបស់ព្រះសាស្តា (ដែលរាប់បញ្ចូល) ក្នុងពាក្យប្រៀនប្រដៅនៃព្រះវិជិតមារទាំងពួង បុគ្គលនោះរមែងមិនទៅកាន់ទុគ្គតិអស់សែនកប្ប ។

ធម្មោ ហវេ រក្ខតិ ធម្មចារឹ

ធម្មោ សុចិណ្ណោ សុខមាវហាតិ

ឯសានិសំសោ ធម្មេ សុចិណ្ណេ

ន ទុគ្គតឹ គច្ឆតិ ធម្មចារីតិ ។

*សេចក្តីថា* មានតែធម៌ប៉ុណ្ណោះទេ តែងរក្សានូវបុគ្គលអ្នកប្រព្រឹត្តធម៌ ធម៌ដែលបុគ្គលសន្សំល្អហើយ តែងនាំសេចក្តីសុខមកឱ្យ នេះជាអានិសង្សនៃធម៌ ដែលបុគ្គលសន្សំល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិឡើយ ។

## ថ្វាយខ្លួនចំពោះព្រះរតនត្រ័យ

ឥមាហំ ភន្តេ ភគវា អត្តភាវំ រតនត្តយស្ស បរិច្ចជាមិ

បពិត្រ ព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គសូមប្រគល់កាយ ថ្វាយខ្លួនចំពោះព្រះរតនត្រ័យគឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដើម្បីចំរើនធម៌ក្នុងឱកាសនេះតទៅ ។

## ថ្វាយខ្លួនចំពោះលោកគ្រូធម្មាចារ្យ

ឥមាហំ ភន្តេ ធម្មាចរិយ អត្តភាវំ តុម្ហាកំ បរិច្ចជាមិ

បពិត្រ ព្រះធម្មាចារ្យដ៏ចំរើន ខ្ញុំព្រះករុណាសូមប្រគល់កាយ ថ្វាយខ្លួនចំពោះព្រះធម្មាចារ្យ ដើម្បីចំរើនធម៌ក្នុងឱកាសនេះតទៅ ។

## វិធីសូមកម្មដ្ឋាន

សព្វទុក្ខនិស្សរណនិព្វានសច្ឆិករណត្ថាយ

មេ ភន្តេ កម្មដ្ឋានំ ទេហិ

បពិត្រ លោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់មេត្តាប្រទាននូវកម្មដ្ឋាន ដល់ខ្ញុំព្រះករុណា ដើម្បីប្រយោជន៍នឹងធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលជាធម៌រលាស់នូវខ្លួនចេញចាកទុក្ខទាំងពួង ។

## អារក្ខកម្មដ្ឋាន

កម្មដ្ឋានគួររក្សារឿយៗ

ពុទ្ធានុស្សតិ មេត្តា ច អសុភំ មរណស្សតិ

ឥច្ចេតោ ចតុរារក្ខា ភាវេតព្វា បុនប្បុនំ

វន្ទាមិ ពុទ្ធំ គុណសាគរន្តំ

សត្តា សទា ហោន្តុ សុខី អវេរា

កាយោ ជិគុច្ឆោ សកលោ ទុគ្គន្ធោ

គច្ឆន្តិ សព្វេ មរណំ តថាហំ ។

អារក្ខកម្មដ្ឋាន ៤ យ៉ាងនេះគឺ ពុទ្ធានុស្សតិ ១ មេត្តា ១ អសុភ ១ មរណស្សតិ ១ គួរសាធុជនចំរើនរឿយៗថា ខ្ញុំសូមថ្វាយបង្គំចំពោះ ព្រះសម្ពុទ្ធទ្រង់មានព្រះគុណដ៏ធំទូលាយដូចសាគរ សូមសត្វទាំងឡាយមានតែសេចក្ដីសុខ មិនមានពៀរនឹងគ្នាសព្វកាល រាងកាយទាំងមូល (នេះ) មានក្លិនអាក្រក់គួរខ្ពើម រអើមក្រៃពេកណាស់ សព្វសត្វទាំងអស់ រមែងដល់នូវសេចក្ដីស្លាប់ ទាំងខ្លួនអាត្មាអញក៏ដូច្នោះដែរ ។

វន្ទាមិ ធម្មំ សុគតេន ទុត្តំ

សត្តា សទា ហោន្តុ សុខី អវេរា

កាយោ ជិយញ្ញោ សគលោ ទុគ្គន្ធោ

គច្ឆន្តិ សព្វេ មរណំ គថាហំ ។

ខ្ញុំសូមថ្វាយបង្គំ ចំពោះព្រះធម៌ ដែលព្រះសុគតទ្រង់ត្រាស់សម្ដែងហើយ សូមសត្វទាំងឡាយមានតែសេចក្ដីសុខ មិនមានពៀរនឹងគ្នាសព្វកាល រាងកាយទាំងមូល (នេះ) មានក្លិនអាក្រក់គួរខ្ពើម រអើមក្រៃពេកណាស់ សព្វសត្វទាំងអស់ រមែងដល់នូវសេចក្ដីស្លាប់ ទាំងខ្លួនអាត្មាអញក៏ដូច្នោះដែរ ។

ចន្ទាមិ សង្ឃំ មុនិរាជបុត្តំ

សត្តា សទា ហោន្តុ សុខី អវេរា

កាយោ ជិយញ្ញោ សគលោ ទុគ្គន្ធោ

គច្ឆន្តិ សព្វេ មរណំ គថាហំ ។

ខ្ញុំសូមថ្វាយបង្គំ ចំពោះព្រះសង្ឃ ដែលជាបុត្រនៃព្រះសម្ពុទ្ធជាស្ដេចនៃអ្នកប្រាជ្ញ សូមសត្វទាំងឡាយមានតែសេចក្ដីសុខ មិនមានពៀរនឹងគ្នាសព្វកាល រាងកាយទាំងមូល (នេះ) មានក្លិនអាក្រក់គួរខ្ពើម រអើមក្រៃពេកណាស់ សព្វសត្វទាំងអស់ រមែងដល់នូវសេចក្ដីស្លាប់ ទាំងខ្លួនអាត្មាអញក៏ដូច្នោះដែរ ។

# ទង់ព្រះពុទ្ធសាសនា



ទង់ព្រះពុទ្ធសាសនា មានពណ៌ ៦ គឺ ៖

**១- ពណ៌ខៀវ** តំណាងកាលព្រះពុទ្ធ យោនយកកំណើតជាស្តេចស្រីពិរាស្រ្ត មានឥន្ទ្រព្រាហ្មណ៍ មកសុំព្រះនេត្រទាំងគូរបស់ព្រះអង្គ ។ ទ្រង់បានខ្វេះផ្នៀលភ្នែកទាំងគូនោះ ដាក់ជាទានដល់ឥន្ទ្រព្រាហ្មណ៍ ។

**២- ពណ៌លឿង** តំណាងកាលព្រះពុទ្ធយោនយកកំណើតជាវិទិបណ្ឌិត មានព្រះឥន្ទ្រនិម្មិតធ្វើជា ជាងទងមកសុំសាច់ព្រះអង្គ ដើម្បីបិទបំពេញរូបបដិមា ដែលខ្វះខាត ។ វិទិបណ្ឌិតបានកាត់សាច់ របស់ខ្លួនឱ្យជាងទងនោះ យកទៅច្នៃប្រើតាមបំណង ។

**៣- ពណ៌ក្រហម** តំណាងកាលព្រះពុទ្ធ យោនយកកំណើតជាមាណព ឈ្មោះបទុមកុមារ មានមាតាត្រូវពស់ចឹកជិតមរណា ហើយត្រូវពេទ្យប្រាប់ថា មានតែឈាមចេញពីបេះដូងមនុស្សមួយមុខគត់ ដែលអាចព្យាបាលជម្ងឺបែបនេះបាន ។ បទុមកុមារសុខចិត្តបូជាបេះដូងរបស់ខ្លួន ដើម្បីបិទពិសពស់ខាំមាតាឱ្យមានជីវិតរស់នៅឡើងវិញ ។

**៤- ពណ៌ស** តំណាងកាលព្រះពុទ្ធយោនយកកំណើតជាវេស្សន្តរ ហើយបានឱ្យដំរីស (បច្ច័យនាគ) ជាទានដល់ព្រាហ្មណ៍ ។

**៥- ពណ៌មាឡុបាន** តំណាងកាលព្រះពុទ្ធ យោនយកកំណើតជាវិជ្ជាធរ មានយក្សមកចាប់មាតាយកទៅ ។ វិជ្ជាធរក៏បានអារសាច់របស់ខ្លួនឱ្យយក្សស៊ី ដើម្បីលោះយកមាតាមកវិញ ។

**៦- ពណ៌ឥន្ទធនូ** (ពណ៌ផ្លេកបន្ទោរ) តំណាងកាលព្រះពុទ្ធ យោនយកកំណើតជាសត្វទន្សាយ មានឥន្ទ្រព្រាហ្មណ៍មកសុំសាច់ជាអាហារ ។ ទន្សាយពោធិសត្វឱ្យសាច់ជាទានដល់ឥន្ទ្រព្រាហ្មណ៍ ដោយលោតចូលទៅក្នុងភ្នក់ភ្លើង ។

## កំណាព្យពាក្យ ៧

ព្រះរាជនិពន្ធដោយ សម្តេចព្រះសង្ឃរាជ **ជោតញ្ញាណោ (ជួន ណាត)**

១- ពណ៌ខៀវកាលផ្ទៀលព្រះនេត្រា ឱ្យឥន្ទ្រព្រាហ្មណ៍ណាកាលជាស្តេច
នាមស្រីពិរាស្រ្តចង់សម្រេច ឱ្យបានសពេជ្ញសាស្តាចារ្យ ។
២- ពណ៌លឿងកាលអារសាច់ធ្វើមាស បិទលនអង្គព្រះបដិមា
ព្រះឥន្ទ្រជាជាងច្នៃរចនា ស្រែកសាធុការពេញផែនដី ។
៣- ក្រហមពណ៌ឈាមតីបេះដូង ផ្ទៀលពីដើមទ្រូងដោយឃាតខ្មី
បិទពិសពស់ខាំព្រះជនី គង់រស់ជីវីជាស្បើយទៅ ។
៤- ពណ៌សកាលឱ្យដីស មង្គលបវរមាសផ្ទិនផ្ទៅ
ត្រូវរាស្រ្តបណ្តេញមិនឱ្យនៅ ឱ្យទាំងកូនចៅភរិយា ។
៥- ហង្សបាទលោហិតម៉ស់ អារសាច់ខ្លួនតាំងជូរមាតា
កាលយក្សវាចាប់បរិភោគ្គា ជីវិតមាតារស់វិងខ្មី ។
៦- ផ្លេកពណ៌រាយកាលជាទន្សាយ ឱ្យទានពុំស្តាយជីវិតក្តី
លោតចូលភ្នក់ភ្លើងពុំថាអ្វី ឱ្យជាចំណីឥន្ទ្រព្រាហ្មណា
ពណ៌ទាំងប្រាំមួយនោះសោតណា ក្លាយមកកើតជាឆព្វណ្ណរង្សី ។

# ពុទ្ធប្បវត្តិសង្ខេប

## បទពាក្យ ៧

យើងខ្ញុំបរិស័ទពុទ្ធសាសនា
ចំពោះព្រះពុទ្ធដែលជាម្ចាស់
ចងចាំថ្ងៃខែឆ្នាំឱ្យច្បាស់
សង្ខេបខ្លីៗឱ្យរត់មាត់
យាងចូលកាន់គភ៌ផ្ទៃកា
ប្រសូតឆ្នាំចថ្ងៃសុក្រស្មោះ
សោយរាជ្យកត្តិកថ្ងៃអាទិត្យ
បួសចោះអាសាឍព្រហស្បតិ៍ត្រូវ
បរិនិព្វានថ្ងៃអង្គារ
នៅខែពិសាខព្រះសម្ពុទ្ធ
យើងបាត់ព្រះពុទ្ធទាន់សាសនា
អ្នកប្រព្រឹត្តធម៌ឈ្មោះស្រឡាញ់
បំណាច់អ្នកកាន់ពុទ្ធសាសនា
គឺថ្ងៃ-ខែ-ឆ្នាំឱ្យហ្មត់ចត់

ឱនកាយវាចាចិត្តគោរព
គ្រប់គ្នាត្រូវចាំឱ្យទៀងទាត់ ។
នៃព្រះពុទ្ធម្ចាស់គឺប្រវត្តិ
កំណត់ចាំបានពេលទាំងអស់ ។
អាសាឍមាសាថ្ងៃព្រហស្បតិ៍
ពិសាខឈើលាស់ដើមរង្គូវ ។
ប្រជុំព្រាហ្មណ៍ព្រឹទ្ធនាឆ្នាំឆ្លូវ
ត្រាស់នៅវេកាពិសាខពុធ ។
បរិស័ទគ្រប់គ្នាកើតតក់ស្លុត
រលត់បញ្ចក្ខន្ធនាឆ្នាំម្សាញ់ ។
ធម៌ជាអាចារ្យកុំគ្មានក្តាញ់
ចំពោះអង្គអញ្ជុតថាគត ។
ត្រូវចាំសាវតារនៃព្រះពុទ្ធ
ទើបបានកំណត់ជាពុទ្ធជន ។

# ពុទ្ធកិច្ច ៥ យ៉ាង

(បទពាក្យ ៧)

ពុទ្ធកិច្ច ៥ យ៉ាងគឺអ្វីខ្លះ
ចូរចាំឱ្យច្បាស់គ្រប់រូបា
បំណាច់អ្នកកាន់ពុទ្ធសាសនា
ត្រូវចាំកិច្ចការនៃព្រះអង្គ ។
ពេលព្រឹកទ្រង់យាងបិណ្ឌបាត
តាមផ្ទះមានញាតិចាំរបង
ជូនមួយអង្គឯងជូនមានសង្ឃ
តម្រង់តាមសត្វមាននិស្ស័យ ។
រសៀលទ្រង់ត្រាស់សម្តែងធម៌
ដល់សត្វនិករដោយអាល័យ
បើសត្វមិនយល់ទ្រង់ឧបមេយ្យ
បកស្រាយសេចក្តីឱ្យយល់បាន ។
ព្រលប់ប្រទានព្រះឱវាទ
ដល់សង្ឃឱ្យស្អាតល្អកល្យាណ
កុំឱ្យប្រព្រឹត្តខុសលំអាន
តាមផ្លូវដែលបានទ្រង់បញ្ញត្ត ។
អាធ្រាត្រទ្រង់ដោះស្រាយបញ្ហា
ដែលពួកទេវតាមកច្រើនក្តាត់
សម្តែងព្រះសូត្របរមត្ថ
តាមពពួកសត្វដែលសង្ស័យ ។
ជិតភ្លឺប្រមើលនិស្ស័យសត្វ
តើអាចប្រតិបត្តិមានកម្រៃ
ដែលគួរត្រាស់ដឹងព្រះធម៌ថ្លៃ
តាមឧបនិស្ស័យសត្វលោកា ។
សែសិបប្រាំឆ្នាំឥតមានខ្វះ
ព្រះអង្គនឿយណាស់លើសមនុស្សា
ឥតមានសម្រាកព្រះកាយា
ឥតមាននរណាប្រដូចបាន ។
យើងបាត់ព្រះពុទ្ធទាន់សាសនា
ធម៌ជាអាចារ្យទូន្មានប្រាណ
ប្រព្រឹត្តត្រង់ផ្លូវត្រូវលំអាន
ដរាបដល់ឋាននិព្វានហោង ។

# បទ គោរពទង់ព្រះពុទ្ធសាសនា

សូមមើលទង់ជ័យ ឆព្វណ្ណរង្សី ដែលមានរស្មីភ្លឺស្រស់ល្អ
ខៀវលឿងក្រហម ព្រមទាំងពណ៌ស ហង្សបាទនិងពណ៌ដ៏ភ្លឺផ្លេក ។

ប្រទេសតូចធំ បានស្ម័គ្រស្មាគម ជំនុំគ្នាច្រើនអនេក
ព្រមយករស្មី ព្រះពុទ្ធគួរត្រេក ប្រសើរពន់ពេកក្រៃកន្លង ។

ធ្វើជាសញ្ញា ទង់ជ័យសាសនា នៃសមុទ្ទធំចម្បង
ចូរយើងរាល់គ្នា យកចិត្តចាំចង នឹកដល់ព្រះអង្គជាអម្ចាស់ ។

ទោះជាតិផ្សេងគ្នា ក៏ត្រូវដឹងថា សុទ្ធសឹងតែជាពុទ្ធសាសន៍
ត្រូវមានសាមគ្គី ទាំងក្មេងទាំងចាស់ ប្រឹងប្រែងឱ្យណាស់គ្រប់ៗគ្នា ។

សូមសាសនាពុទ្ធ ថ្កុំថ្កើងខ្ពស់ផុត រុងរឿងវិសុទ្ធថ្លៃថ្លា
ហើយមានជ័យជោគ ផ្សាយពេញលោកា ដោយជនជ្រះថ្លារាប់ច្រើនលាន ។

មានចិត្តស្នេហា គោរពបូជា ចំពោះព្រះធម៌ដ៏កល្យាណ
ទាំងមនុស្សទេវា ស្នេហាគ្រប់ប្រាណ ប្រាថ្នាចង់បានសេចក្តីសុខ ។

យើងខេមរជាតិ នាំគ្នាខ្មីឃ្មាត កាន់ធម៌នឹងបានផុតទុក្ខ
រួបរួមសាមគ្គី ពីនេះទៅមុខ យើងនឹងបានសុខក្សេមក្សាន្តត្រាណ។

ព្រមព្រៀងប្រព្រឹត្ត កាន់ធម៌សុចរិត ឆ្ពោះទៅកាន់ឋាននិព្វាន
ជាទីផុតទុក្ខ បានសុខក្សេមក្សាន្ត ជាតិយើងនឹងបានសោយសុខា ។

# ឆព្វណ្ណរង្សី

ពួកយើងអ្នកកាន់សាសនា
ទ្រង់មានឆព្វណ្ណរង្សី
ផ្សាយចេញពីព្រះកាយទ្រង់
ឆ្មៀលឆ្មាត់កាយឆើតឆាយល្អ
កំណើតនៃព្រះរស្មី
ធ្វើទានឥតមានរួញរា
១- រស្មីពណ៌ខៀវនោះណា
ឱ្យទានដល់ឥន្រ្ទព្រាហ្មណ៍បាត់
២- រស្មីពណ៌លឿងភ្លឺថ្លា
បិទពុទ្ធរូបភ្លឺឱភាស
៣- រស្មីក្រហមនោះណា
បទុមស៊ូប្តូរជីវិត
៤- រស្មីពណ៌សសុទ្ធសាធ
ឱ្យដីរសល្អសោភា
៥- រស្មីពណ៌ដូចជើងហង្ស
វិទ្យាធរអារសាច់ប្រាណ
៦- រស្មីពណ៌ផ្លេកពណ្ណរាយ
ឱ្យទានសាច់ឈាមជីវិត
រស្មីខៀវលឿងក្រហម
ត្រូវជាប្រាំមួយប្រការ

ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
គឺព្រះរស្មីទាំងប្រាំមួយពណ៌ ។
រុងរឿងឫទ្ធិវង្គប្រសើរបវរ
ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា ។
កើតដោយបារមីនៃព្រះភគវា
កាលដែលនៅជាព្រះពោធិសត្វ ។
កាលឆ្មៀលនេត្រា ដោយទ្រង់ចិត្តកាត់
កាលនៅជាក្សត្រនាមស្រីពិរាស្ត្រ ។
កាលដែលទ្រង់អារសាច់រំលែធ្វើមាស
ព្រះឥន្ទ្រជាងមាសក្រុងវ័យបណ្ឌិត ។
កាលដែលមាតាពស់ខាំស្លាប់ពិត
អារបេះដូងបិទធ្វើថ្នាំមាតា ។
កាលជាព្រះបាទវេស្សន្តរក្សត្រា
ដល់ព្រាហ្មណ៍ប្រាថ្នាយកពោធិញ្ញាណ ។
កាលមាតាទ្រង់យក្សចាប់យកបាន
ឱ្យយក្សសាមាន្យស៊ីប្តូរជីវិត ។
កាលជាទន្សាយ សសបណ្ឌិត
ដល់ឥន្ទ្រព្រាហ្មណ៍ពិតថាអត់អាហារ ។
សហង្សបាទព្រមទាំងផ្លែកអស្ចារ្យ
ទាំងចាស់កុមារចូរចាំទុកអើយ ។

ចប់

# ពាក្យអារាធនាមុនពេលទេសនា

ឱសាធុជនទាំងប្រុសស្រី គប្បីត្រងត្រាប់ស្តាប់ទេសនា
បើបានស្តាប់ហើយកើតបញ្ញា រីងរឹតជ្រះថ្លាភ្លឺក្នុងចិត្ត ។
ចូរអ្នកសង្រួមកុំនិយាយ កុំឱ្យរាយមាយធ្លាយតំនិត
ពិបាកត្រចៀកអ្នកនៅជិត គេស្តាប់ធម៌ពិតកើតសៅហ្មង ។
បើរោយស្រពន់ចុកដៃជើង គួរយើងថយទៅតម្រង់ខ្នង
កុំនិយាយគ្នាឮឆ្លើយឆ្លង អ្នកផងទៀយណាយអន្តរាយធម៌ ។
ទៅកើតខាងមុខមនុស្សគថ្លង់ ខ្វិនខ្វាក់ខ្វៀនខ្វង់ល្ងិតល្ងង់ខ្លៅ
គួរយើងកោតខ្លាចតរៀងទៅ កុំឱ្យហ្មងសៅដល់អ្នកស្តាប់ ។
ស្តាយអើយសែនស្តាយជាតិកំណើត មិនគួរមកកើតឱ្យមានស្នាប់
ស្មានថារស់យូរទៅជាឆាប់ កោតមិនប្រញាប់ស្តាប់ទេសនា ។
មិនស្និទ្ធចិត្តស្នេហ៍គ្រក្នុងព្រះធម៌ ក្រអើយសែនក្រជាអស្ចារ្យ
ក្រនឹងបានស្តាប់ព្រះពុទ្ធដីកា កើតមកនេះណាមហាសែនក្រ ។
ហេតុនេះបរិស័ទទាំងប្រុសស្រី ចូរតាំងស្មារតីផ្ទៀងសោតា
ស្តាប់នូវធម្មរសធម៌ទេសនា កើតមានផលាគ្រានេះហោង ។

# ធម៌អន្លង់ ៤ ប្រការ

## ពាក្យអារាធនាមុនពេលទេសនា

| | | | | |
|---|---|---|---|---|
| បពិត្រព្រះគុណ | ព្រះករុណា | គង់លើអាសនា | សក្តិសមរម្យ | |
| ដឹកនាំទេសនា | ប្រោសយើងខ្ញុំ | ដើម្បីអប់រំ | កាយវាចា | ។ |
| យើងខ្ញុំគ្រប់គ្នា | ត្រូវលិចសូង | ធ្លាក់ក្នុងអន្លង់ | បួនប្រការ | |
| អន្លង់ទីមួយ | គឺកាមា | ដោយពេញសត្វា | ក្នុងកាមគុណ | ។ |
| អន្លង់ទីពីរ | ភវោឃៈ | ទាញសត្វទម្លាក់ | ក្នុងទុក្ខធំ | |
| វិលកើតវិលស្លាប់ | ជានិរន្តរ៍ | ឥតមានស្រាកស្រាន្ត | ក្នុងភពបី | ។ |
| អន្លង់ទីបី | ទិដ្ឋោឃៈ | ទាញសត្វទម្លាក់ | ក្នុងអវិចី | |
| ដោយទិដ្ឋិយល់ | មិនប្រពៃ | បុណ្យក្តីបាបក្តី | ឥតអំពើ | ។ |
| អន្លង់ទីបួន | គឺអវិជ្ជា | បាំងសត្វនានា | ឱ្យស្មាក់ស្មើរ | |
| នាំសត្វវង្វេង | មិនឱ្យធ្វើ | អំពើបុណ្យទាន | សីលភាវនា | ។ |
| ហេតុនេះព្រះគុណ | ព្រះករុណា | គង់លើអាសនា | ព្រះធម្មា | |
| ដឹកនាំយើងខ្ញុំ | ទាំងអស់គ្នា | ឡើងជិះនាវា | ព្រះត្រៃលក្ខណ៍ | ។ |
| កំចាត់កិលេស | និងតណ្ហា | ព្រមទាំងអវិជ្ជា | ដោយអរិយមគ្គ | |
| កាច់បំបាក់បង់ | សង្សារចក្រ | ចូលកាន់អមតៈ | និព្វានហោង | ។ |

# ពាក្យស្លូធ្យសរសើរធម្មទេសនា

ហេតុតែព្រះគុណចេះឈ្លាសឆ្លាត ធម៌ណាចង្អៀតចេះកែខៃ
វែកញែកឱ្យច្បាស់អស់សង្ស័យ បញ្ញាទន់ខ្ចីគង់ស្តាប់បាន ។
ពីរោះសាច់ធម៌ដ៏ប្លែកៗ ពីរោះពន់ពេកក្នុងសន្តាន
សូម្បីអ្នកល្ងង់គង់ស្តាប់បាន តាមរសសាច់ធម៌រកប្រៀបគ្មាន ។
នាកាលសម្តេចព្រះភគវា ទេសនាធម្មាប្រោសប្រទាន
ព្រះធម៌នាំសត្វទៅនិព្វាន រាប់ម៉ឺនសែនលានស៊ើរគ្មានសល់ ។
ធម៌នោះពីរោះផ្អែមយ៉ាងណា គឺព្រះករុណាប្រទានផល
ព្រះធម៌នាំសត្វសព្វសាកល លុះដល់មគ្គផលសល់តិចគ្នា ។
សាសនាសម្តេចព្រះភគវន្ត កន្លងរាប់ពាន់ឆ្នាំនានា
នៅតែសាវ័កព្រះភគវា ទេសនាធម្មាពីរោះក្រៃ ។
មិនគឺសាវ័កអង្គឯណា គឺព្រះករុណាទេសន៍ថ្មីៗ
បញ្ចប់ឯវិសង្ខេបខ្លី យើងខ្ញុំប្រុសស្រីស្តាយណាស់ណា ។
មិនទាន់អស់ចិត្តនឹងស្តាប់ធម៌ នឹងឃាត់អង្វរមិនហ៊ានថា
ក្រែងនឿយព្រះកាយព្រះករុណា សូមសាធុការប៉ុណ្ណោះហើយ ។
ហត្ថខ្ញុំទាំងគូផ្គងប្រណម្យ លើកឡើងបង្គំគុណកែវបី
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃថ្លៃ សូមបានសិរីដូចប្រាថ្នា ។
ខ្ញុំសូមខមាទោសទាំងឡាយ ក្រែងភ្លាត់ដោយកាយឬវាចា
ចិត្តមានគ្រោតគ្រាតត្រង់ធម៌ណា ដូចមានមាត្រាសូត្រក្រោយហោង ។

# វំលឹកគុណព្រះរតនត្រៃ

អហឺរខ្ញុំសូមអភិវាទ គុណព្រះមុនីនាថមកុដលោកា
ព្រះអង្គតួឯកម្ចាស់សាសនា ប្រោសមនុស្សទេព្តាសត្វភពត្រៃ ។
ទ្រង់មិនប្រកាន់ជាតិវណ្ណៈ តាមជាន់តាមថ្នាក់ដូចសព្វថ្ងៃ
ឱ្យតែសត្វណាមាននិស្ស័យ អង្គព្រះជិនស្រីប្រោសទេសនា ។
បង្គំនឹកគុណដល់ព្រះធម៌ បង្ហាញផ្លូវល្អដល់សត្តា
ទុកដូចជាស្ពានយានភេត្រា ចម្លងសត្វណាប្រតិបត្តិត្រូវ ។
ជាមនុស្សសុចរិតចិត្តសម្មា- ទិដ្ឋិប្រាថ្នាផុតសោកសៅ
ព្រះធម៌តែងយោងសណ្តោងទៅ កាន់ទីលំនៅស្ថានសុខា ។
បង្គំនឹកគុណដល់ព្រះសង្ឃ ព្រះអង្គទ្រទ្រង់សីលសិក្ខា
ទុកជាស្រែបុណ្យជនជ្រះថ្លា ប្រាថ្នាដូសដងយកមគ្គផល ។
លោកទ្រទ្រង់ផ្នួសបួសប្រតិបត្តិ ដើម្បីកំចាត់ធម៌អកុសល
ព្រះទ័យស្ងប់ស្ងាត់បាត់កង្វល់ ខ្វាយខ្វល់តែពីផ្លូវសាសនា ។
គុណកែវទាំងបីថ្លៃអនេក រុងរឿងចម្លែកប្លែកអស្ចារ្យ
ខ្ញុំសូមបន្ទន់កាយវាចា លុតលើកហត្ថាថ្វាយបង្គំ ។

ដោយ ឃិន ចន់

# វិធីវេរភត្ត

និង

# បច្ច័យផ្សេងៗ

# ក្បួនធ្វើពិធី

និង

# ចម្រៀងមង្គល

## វិធីថេរភត្ត និង បច្ច័យផ្សេងៗ

បើឧបាសក ឧបាសិកា មានបសាទសទ្ធា គឺជំនឿប្រកបដោយសេចក្ដីជ្រះថ្លាកើតឡើងក្នុងសន្ដាន មានប្រាថ្នានឹងវេរភត្តទាំង ១៩ ប្រការ ភត្តណាមួយក៏បាន តាមប្រាថ្នា ។

### ឯភត្តទាំង ១៩ នោះគឺ

១- សង្ឃភត្តំ វេរទូវភត្តដល់សង្ឃ

២- ឧទ្ទេសភត្តំ វេរទូវភត្តដល់ភិក្ខុ ១ អង្គ ឬ ២ អង្គ ឬក៏ ៣ អង្គជាដើម តាម ពាក្យដែលសង្ឃសម្ដែងឱ្យ ។

៣- និមន្តនភត្តំ វេរទូវភត្តដល់ភិក្ខុដែលខ្លួន និមន្តមកហើយប្រគេន ។

៤- សលាកភត្តំ វេរទូវភត្តដល់ភិក្ខុទាំងឡាយ ដែលខ្លួនសរសេរឈ្មោះក្នុងស្លាកហើយចាប់ ។

៥- បក្ខិកភត្តំ វេរទូវភត្តដល់ភិក្ខុសង្ឃក្នុងសុក្កបក្ខ គឺចំណែកខាងខ្នើត ឬកាឡបក្ខ គឺចំណែកខាងរនោច ផ្នែក្នុង ១ បក្ខប្រគេនតែ ១ ថ្ងៃ មិនមានកំណត់ថ្ងៃណា ។

៦- ឧបោសថិកភត្តំ វេរទូវភត្តដល់ភិក្ខុសង្ឃក្នុងថ្ងៃឧបោសថកាល ។

៧- បាដិបទិកភត្តំ វេរទូវភត្តដល់ភិក្ខុសង្ឃក្នុងថ្ងៃ ១ កើត ឬ ១ រោច ។

៨- អាគន្តុកភត្តំ វេរទូវភត្តដល់ភិក្ខុសង្ឃ ដែលទើបមកដល់ថ្មី ។

៩- គមិកភត្តំ វេរទូវភត្តដល់ភិក្ខុសង្ឃ ដែលមានដំណើរនឹងទៅកាន់ទីណាមួយ ។

១០- គិលានភត្តំ វេរទូវភត្តដល់ភិក្ខុសង្ឃដែលមានជំងឺ ។

១១- គិលានុបដ្ឋាកភត្តំ វេរទូវភត្តដល់ភិក្ខុសង្ឃ ជាអ្នករក្សាជំងឺភិក្ខុសាមណេរផងគ្នា។

១២- និច្ចភត្តំ វេរទូវភត្តដែលត្រូវប្រគេនជានិច្ចដល់ភិក្ខុសង្ឃ ។

១៣- កុដិភត្តំ វេរទូវភត្តដល់ភិក្ខុសង្ឃ នៅលំនៅមានកុដិជាដើម (ភត្តនេះ ហៅបានតាមឈ្មោះទីកន្លែងដែលសង្ឃនៅ) ។

១៤- វារិភត្តំ វេរទូវភត្តដល់ភិក្ខុសង្ឃ ដោយចាត់ចែងជាវេន ។

១៥- ទិវាភត្តំ វេរនូវភត្តាហារដល់ភិក្ខុសង្ឃ សាមណេរដែលនៅក្នុងវត្តមួយៗ បានឆាន់គ្រប់គ្រាន់បរិបូណ៌ទាំងអស់ ។

១៦- ចតុក្កភត្តំ វេរនូវភត្តាហារចំពោះភិក្ខុសង្ឃ ៤ អង្គៗ ដែលខ្លួនបានសូមនិមន្តអំពីគណៈសង្ឃៗ បានចាត់មកទទួលចង្ហាន់បិណ្ឌបាតនៅផ្ទះខ្លួនរាល់ៗ ថ្ងៃពុំដែលដាច់ ។

១៧- អដ្ឋកភត្តំ វេរនូវភត្តាហារចំពោះភិក្ខុសង្ឃ ៨ រូប ដែលខ្លួនបានសូមនិមន្តអំពីគណៈសង្ឃៗ បានចាត់មកទទួលចង្ហាន់បិណ្ឌបាតនៅផ្ទះខ្លួនរាល់ៗ ថ្ងៃពុំដែលដាច់ ។

១៨- គុឡភត្តំ វេរនូវភត្តាហារដែលលាយដោយស្ករអំពៅ មានបាយដំណើបបបរស្ករទំលតជាដើម ចំពោះភិក្ខុសង្ឃ សាមណេរដែលនៅក្នុងវត្តមួយៗ តាមសទ្ធា ។

១៩- មតកភត្តំ វេរនូវភត្តឧទ្ទិសចំពោះបុគ្គលដែលស្លាប់ហើយ (ឬបុគ្គលចែកឋានថ្មីៗ)

ភត្តទាំង ១៩ ប្រការនេះ បើទាយកទាយិកាប្រាថ្នានឹងវេរភត្តណាមួយ ត្រូវដាក់ឈ្មោះភត្តនោះ ត្រង់បាលីដែលវង់ក្រចកយ៉ាងនេះ (........................) ទុកនោះចុះ ។

## បាលីវេរភត្តច្រើនបែប

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (សូធ្យ ៣ ចប់)

អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស្ស ឥមំ (ឥត្ថន្នាមំ) សបរិក្ខារំ ពុទ្ធប្បមុខស្ស[១] សង្ឃស្ស ទេម, តេ គុណវន្តានយោ ឥមំ (ឥត្ថន្នាមំ) អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោ-ទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុច្ចន្តុ ឥមិនា និស្សន្ទេន ។

ទុតិយម្បិ .... ។ តតិយម្បិ .... ។

---

(១)- បើមានះរៀបភោជនាហារដោយឡែកផ្សេង ជាតង្វាយព្រះពុទ្ធរូបក្នុងទីនេះ ទើបត្រូវដាក់បាលីថា (ពុទ្ធប្បមុខស្ស) នេះ បើមិនមានតង្វាយព្រះពុទ្ធរូបទេ កុំដាក់បាលីនេះ ។ ប៉ែកខាងសេចក្តីប្រែ ក៏ដូចគ្នាដែរ ។

វេ្របិចា បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើនអើយ[1] វិចង្កាន់បិណ្ឌបាតនៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយ សូមឧទ្ទិស ចំពោះដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតានិងបិតាជាដើម ហើយយើងខ្ញុំទាំងឡាយ វេរ (នូវភត្តប្រការនេះជាឈ្មោះ) នេះ ព្រមទាំងបរិក្ខារប្រគេនដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន សូមលោកអ្នកដ៏មានគុណទាំងឡាយ មានមាតានិងបិតាជាដើមនោះ សំគាល់ (នូវភត្តប្រការនេះជាឈ្មោះ) នេះ ថាដូចជារបស់នៃខ្លួន ហើយសូមអនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមឱ្យរួចរដោះចាកទុក្ខទោស (និងពៀរវេរា) ទាំងពួង ឱ្យបានសម្រេចដោយសម្បត្តិទាំងឡាយ ៣ ប្រការ គឺសម្បត្តិមនុស្ស ១ សម្បត្តិទេវតា ១ សម្បត្តិព្រះនិព្វាន ១ ដោយសមគួរតាមសេចក្តីប្រាថ្នា របស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្ស ដែលហូរជូនទៅមិនដាច់នេះហោង ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

ត្រង់បទថា "ឥត្ថន្នាមំ" នោះ ត្រូវបញ្ចូលឈ្មោះ "ភត្ត" តាមប្រាថ្នាយ៉ាងដូចម្តេច "សង្ឃភត្ត" បញ្ចូលថា "សង្ឃភត្តំ នូវសង្ឃភត្ត" ។

## វេរភត្តមួយបែបទៀត

បើឧទ្ទិសផលជូនចំពោះដល់ លោកអ្នកដ៏មានគុណទាំងឡាយ មានមាតានិងបិតាជាដើម ដែលធ្វើកាលកិរិយាទៅកាន់បរលោកនាយ គួរវេរដូចខាងក្រោមនេះ :

អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ (បណ្ណរសទិវសត្ថាយ ឯកមាសាធិក ឯកសំវច្ឆរំ) កាលកតានំ មាតាបិតូនំ គុណវន្តានំ ឧទ្ទិស្ស ឥមំ (សង្ឃភត្តំ) សបរិវារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម ភេ គុណវន្តោ ឥមំ (សង្ឃភត្តំ) អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុច្ចន្តុ ឥមិនា និស្សន្ទេន ។

ទុតិយម្បិ .... ។ តតិយម្បិ .... ។

(១)- សរសេរត្រឹមត្រូវ ដ៏ចំរើនអើយ. ប៉ុន្តែត្រូវអានថា (ដ៏ចំរើនណើយ) ។

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើនអើយ  រីចង្ហាន់បិណ្ឌបាតនៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ ហើយយើងខ្ញុំទាំងឡាយ សូមឧទ្ទិស ចំពោះដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតានិងបិតាជាដើម ដែលធ្វើកាលកិរិយាទៅកាន់លោកខាងនាយ (ចំនួនមួយឆ្នាំ មួយខែដប់ប្រាំថ្ងៃ នឹងថ្ងៃនេះហើយ) យើងខ្ញុំទាំងឡាយ វេរនូវ (សង្ឃភត្ត) នេះ ព្រមទាំងបរិវារប្រគេនដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន សូមលោកអ្នកដ៏មានគុណទាំងឡាយ មានមាតានិងបិតាជាដើមនោះ សំគាល់នូវ (សង្ឃភត្ត) នេះ ថាដូចជារបស់នៃខ្លួន សូមលោកអនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមឱ្យរួចរដោះចាកទុក្ខទោស (និងពៀរវេរា) ទាំងពួង ឱ្យបានសម្រេចដោយសម្បត្តិទាំងឡាយ ៣ ប្រការ គឺសម្បត្តិមនុស្ស ១ សម្បត្តិទេវតា ១ សម្បត្តិព្រះនិព្វាន ១ ដោយសមគួរតាមសេចក្តីប្រាថ្នា របស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្ស ដែលហូរជូនទៅមិនដាច់នេះហោង ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

## វេរភត្តមួយបែបទៀត

បើឧទ្ទិសផលជូនចំពោះបិតា គួរផ្លាស់បាលីឱ្យទៅជាបុំលិង្គឯកវចនៈ ដូចខាងក្រោមនេះ

អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ (បណ្ណរសទិវសុត្តរ ឯកមាសាធិក ឯកសំវច្ឆរំ) កាលកតស្ស បិតុនោ គុណវន្តស្ស ឧទ្ទិស្ស ឥមំ (សង្ឃភត្តំ) សបរិវារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម សោ គុណវា ឥមំ (សង្ឃភត្តំ) អត្តនោ សន្តកំ វិយ មញ្ញមានោ អនុមោទតុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈតុ សព្វទុក្ខា បមុញ្ចតុ ឥមិនា និស្សន្ទេន ។

ទុតិយម្បិ .... ។ តតិយម្បិ .... ។

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើនអើយ  រីចង្ហាន់បិណ្ឌបាតនៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ ហើយយើងខ្ញុំទាំងឡាយ សូមឧទ្ទិស

ចំពោះដល់លោកអ្នកដ៏មានគុណ គឺបិតា (ឈ្មោះ.....................) ដែលធ្វើកាលកិរិយាទៅកាន់លោកខាងនាយ (ចំនួនមួយឆ្នាំ មួយខែដប់ប្រាំថ្ងៃ នឹងថ្ងៃនេះហើយ) យើងខ្ញុំទាំងឡាយ វេរទូវ (សង្ឃភត្ត) នេះ ព្រមទាំងបរិវារប្រគេនដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន សូមលោកអ្នកដ៏មានគុណ គឺបិតា (ឈ្មោះ.....................) នោះ សំគាល់ទូវ (សង្ឃភត្ត) នេះ ថាដូចជារបស់នៃខ្លួន សូមលោកអនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមឱ្យរួចរដោះចាកទុក្ខទោស (និងពៀរវេរា) ទាំងពួង ឱ្យបានសម្រេចដោយសម្បត្តិទាំងឡាយ ៣ ប្រការ គឺសម្បត្តិមនុស្ស ១ សម្បត្តិទេវតា ១ សម្បត្តិព្រះនិព្វាន ១ ដោយសមគួរតាមសេចក្តីប្រាថ្នា របស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្ស ដែលហួរជូនទៅមិនដាច់នេះហោង ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

## វេរភត្តមួយបែបទៀត

បើឧទ្ទិសផលជូនចំពោះមាតា គួរផ្លាស់បាលីឱ្យទៅជាឥត្ថីលិង្គឯកវចនៈ ដូចខាងក្រោមនេះ

អយំ នោ ' ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ (បណ្ណរសទិវសត្ថាយ ឯកមាសាធិក ឯកសំវច្ឆរំ) កាលកតាយ មាតុយា គុណវន្តិយា ឧទ្ទិស្ស, ឥមំ (សង្ឃភត្តំ) សបរិវារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម សា គុណវន្តី ឥមំ (សង្ឃភត្តំ) អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទតុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈតុ សព្វទុក្ខា បមុញ្ចតុ ឥមិនា និស្សន្ទេន ។

ទុតិយម្បិ .... ។ តតិយម្បិ .... ។

ប្រែថា បពិត្រព្រះគម្តែងសង្ឃដ៏ចំរើនអើយ វិចង្ហាន់បិណ្ឌបាតនៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ ហើយយើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះដល់លោកអ្នកដ៏មានគុណ គឺមាតា (ឈ្មោះ.....................) ដែលធ្វើកាលកិរិយាទៅកាន់លោកខាងនាយ (ចំនួនមួយឆ្នាំ មួយខែដប់ប្រាំថ្ងៃ នឹងថ្ងៃនេះហើយ) យើងខ្ញុំទាំងឡាយ

វេរនូវ (សង្ឃភត្ត) នេះ ព្រមទាំងបរិវារប្រគេនដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន សូមលោកអ្នកដ៏មានគុណ គឺមាតា (ឈ្មោះ....................) នោះ សំគាល់នូវ (សង្ឃភត្ត) នេះ ថាដូចជារបស់នៃខ្លួន សូមលោកអនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមឱ្យរួចរដោះចាកទុក្ខទោស (និងពៀរវេរា) ទាំងពួង ឱ្យបានសម្រេចដោយសម្បត្តិទាំងឡាយ ៣ ប្រការ គឺសម្បត្តិមនុស្ស ១ សម្បត្តិទេវតា ១ សម្បត្តិព្រះនិព្វាន ១ ដោយសមគួរតាមសេចក្តីប្រាថ្នា របស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្ស ដែលហូរជូនទៅមិនដាច់នេះហោង ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

## របៀបវេរភត្តមួយបែបទៀត

គឺវេរឧទ្ទិសព្រះរាជកុសល ថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធនៃអតីត ព្រះមហាក្សត្រិយ៍គ្រប់ព្រះអង្គ ដែលទ្រង់សោយរាជសម្បត្តិ ក្នុងប្រទេសកម្ពុជា ដូចខាងក្រោមនេះ ៖

អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនច ឧប្បាទិតោ ឥមស្មឹ កម្ពុជរដ្ឋេ សព្វេ រាជានោ បរមរាជពញ្ញាយាតាទិកេ គុណវន្តេ ឧទ្ទិស្ស ឥមំ (សង្ឃភត្តំ) សបរិវារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម សព្វេ តេ ឥមំ (សង្ឃភត្តំ) អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន ។

ទុតិយម្បិ .... ។ តតិយម្បិ .... ។

ប្រែថា បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើនអើយ វិចង្ហាន់បិណ្ឌបាតនៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ ហើយយើងខ្ញុំទាំងឡាយ សូមឧទ្ទិសព្រះរាជកុសល ថ្វាយចំពោះ (ព្រះវិញ្ញាណក្ខន្ធនៃអតីត) ព្រះមហាក្សត្រិយ៍គ្រប់ព្រះអង្គ ដែលទ្រង់សោយរាជសម្បត្តិ ក្នុងប្រទេសកម្ពុជានេះ មានព្រះករុណាព្រះបាទសម្តេច ព្រះបរមរាជាពញ្ញាយ៉ាតជាដើម (ព្រមទាំងព្រះរាជវង្សានុវង្ស) ខ្ញុំព្រះករុណាទាំងឡាយវេរនូវ (សង្ឃភត្ត)នេះ

ព្រមទាំងបរិវារប្រគេនដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន សូមព្រះករុណាថ្លៃវិសេសគ្រប់ព្រះអង្គ សំគាល់នូវ (សង្ឃភត្ត) នេះ ចាំដូចជាព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ហើយទ្រង់អនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមឱ្យរួចរដោះចាកទុក្ខទោស (និងពៀរវេរា) ទាំងពួង ឱ្យបានសម្រេចដោយសម្បត្តិទាំងឡាយ ៣ ប្រការ គឺសម្បត្តិមនុស្ស ១ សម្បត្តិទេវតា ១ សម្បត្តិព្រះនិព្វាន ១ តាមសព្វព្រះរាជហឫទ័យរបស់ព្រះករុណាថ្លៃវិសេសគ្រប់ព្រះអង្គ ព្រមទាំងព្រះរាជវង្សានុវង្ស ដោយអំណាចផលានិសង្ស ដែលទូលព្រះបង្គំជាខ្ញុំ ឧទ្ទិសថ្វាយជូនទៅមិនដាច់នេះហោង ។ .... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

## របៀបវេរមតកភត្ត

វេរនូវភត្តឧទ្ទិសចំពោះបុគ្គលដែលស្លាប់ហើយ (ឬបុគ្គលដែលចែកឋានថ្មីៗ)

អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ (បញ្ចូលឈ្មោះ..........................................)(១) ឥតិ នាមអាទិកេ គុណវន្តេ ឧទ្ទិស្ស ឥមំ (មតកភត្តំ) សបរិក្ខារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម, តេ គុណវន្តាទយោ ឥមំ (មតកភត្តំ) អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន ។

ទុតិយម្បិ .... ។ តតិយម្បិ .... ។

ប្រែថា បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើនអើយ វិចង្ហាន់បិណ្ឌបាតនៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះដល់លោកអ្នកដ៏មានគុណទាំងឡាយ មាន (បញ្ចូលឈ្មោះ..........................................) ជាដើម ដែលបានធ្វើកាលកិរិយាទៅហើយនោះ ហើយយើងខ្ញុំទាំងឡាយ វេរ (នូវមតកភត្តនេះ) ព្រមទាំងបរិក្ខារប្រគេនដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន សូមលោកអ្នកដ៏មានគុណទាំងឡាយ មាន (បញ្ចូលឈ្មោះ..........................................) ជាដើមនោះ សំគាល់

---

(១)- នៅក្នុងវង់ក្រចកចុចៗ (..........................................) នេះ គឺសម្រាប់បញ្ចូលឈ្មោះ បុគ្គលដែលចែកឋានហើយ

(នូវមត្តកភត្តនេះ) ថាដូចជារបស់នៃខ្លួន ហើយសូមអនុមោទនាយកចុះ លុះអនុមោទនារួច ហើយ សូមឱ្យរួចរដោះចាកទុក្ខទោស (និងពៀរវេរា) ទាំងពួង ឱ្យបានសម្រេចដោយសម្បត្តិ ទាំងឡាយ ៣ ប្រការ គឺសម្បត្តិមនុស្ស ១ សម្បត្តិទេវតា ១ សម្បត្តិព្រះនិព្វាន ១ ដោយសមគួរតាមសេចក្តីប្រាថ្នា របស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាច ផលានិសង្ស ដែលហួរជូនទៅមិនដាច់នេះហោង ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

## វេរផ្កាហិរញ្ញវត្ថុ

មយំ ភន្តេ សទ្ធាសម្បន្នា[១] ឥធ អារាមេ (សេនាសនករណត្ថាយ)[២] ឥមានិ ហិរញ្ញបុប្ផានិ ឥធានេត្វា សង្ឃស្ស បវារេម ។

សាធុ ភន្តេ សង្ឃោ វិនយានុរូបំ កប្បិយការកស្ស ហត្ថេ ឋបិតានិ ហិរញ្ញបុប្ផានិ បដិជានាតុ មាតាបិតាទីនញ្ច គុណវន្តានំ អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ទុតិយម្បិ ....។ តតិយម្បិ ....។

ប្រែថា បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយមានសទ្ធាជ្រះថ្លា បាននាំមកនូវ ផ្កាហិរញ្ញវត្ថុទាំងឡាយ មកដាក់ទុកក្នុងទីនេះ សូមបវារណាចំពោះព្រះសង្ឃ (ដើម្បីកសាងសេនាសនៈ ក្នុងវត្ត.......................................នេះ) ។

បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើនអើយ សូមព្រះសង្ឃទទួលដឹងនូវ ផ្កាហិរញ្ញវត្ថុទាំងឡាយ ដែលយើងខ្ញុំទាំងឡាយ បានទុកដាក់ហើយ ក្នុងដៃនៃកប្បិយការកៈ ដ៏សមគួរដល់វិន័យ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខគ្រប់ប្រការ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

---

(១)- សទ្ធាសម្បន្នា ប្រែថា ដល់ព្រមហើយដោយសទ្ធា ទើបត្រឹមត្រូវតាមច្បាប់វេយ្យាករណ៍បាលី ។

(២)- ត្រូវបញ្ចូលបាលី (ឈ្មោះវត្ត.......................................) ដែលត្រូវកសាងត្រង់កន្លែងវង់ក្រចក ។

## វេរចតុប្បច្ច័យជាសង្ឃទាន

មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា សង្ឃស្ស ទេម, សាធុ ភន្តេ សង្ឃោ ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហតុ មាតាបិតុ-អាទីនញ្ចេវ គុណវន្តានំ អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ។

ទុតិយម្បិ .... ។ តតិយម្បិ .... ។

ប្រែថា បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ បាននាំមកនូវបច្ច័យទាំងឡាយ ៤ នេះ មកដាក់ទុកក្នុងទីនេះ ហើយវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយក នូវបច្ច័យទាំងឡាយ ៤ នេះ ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

## វេរចតុប្បច្ច័យចំពោះភិក្ខុ ២ ឬ ៣ អង្គ

មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា សីលវន្តានំ ទេម, សាធុ ភន្តេ សីលវន្តោ ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហន្តុ មាតាបិតុ-អាទីនញ្ច គុណវន្តានំ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ទុតិយម្បិ .... ។ តតិយម្បិ .... ។

ប្រែថា បពិត្រព្រះករុណាដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ បាននាំមកនូវបច្ច័យទាំងឡាយ ៤ នេះ មកដាក់ទុកក្នុងទីនេះ សូមវេរប្រគេនដល់លោកម្ចាស់ អ្នកមានសីលទាំងឡាយ បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន សូមលោកម្ចាស់អ្នកមានសីលទាំងឡាយ ទទួលយកនូវបច្ច័យទាំងឡាយ ៤ នេះ ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

## វេរចតុប្បច្ច័យដល់ភិក្ខុ ១ អង្គ

មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា អាយស្មតោ ទេម, សាធុ ភន្តេ អាយស្មា ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហតុ មាតាបិតុ-អាទីនញ្ច គុណវន្តានំ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ៗ

ទុតិយម្បិ...ៗ តតិយម្បិ...ៗ

ប្រែថា បពិត្រព្រះករុណាដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ បាននាំមកនូវបច្ច័យទាំងឡាយ ៤ នេះ មកដាក់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះករុណាដ៏មានអាយុ បពិត្រព្រះករុណាដ៏ចំរើន សូមព្រះករុណាទទួលយក នូវបច្ច័យទាំងឡាយ ៤ នេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

## វេរកឋិនទានដល់ព្រះសង្ឃ

ឥមំ ទុស្សំ កឋិនចីវរំ សង្ឃស្ស ទេម ៗ

ទុតិយម្បិ .... ៗ តតិយម្បិ .... ៗ

ប្រែថា បពិត្រព្រះករុណាដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ សូមវេរនូវសំពត់នេះ ជាសំពត់ដើម្បីកឋិនចីវរ ប្រគេនដល់ព្រះសង្ឃ ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

## ឬនឹងវេរថា

ឥមំ ទត្ថុំ កឋិនចីវរំ សង្ឃស្ស ទេម ដូច្នេះក៏បាន. សេចក្តី ប្រែដូចគ្នា ។

## វេរគ្រឿងបរិក្ខារជាបរិវារកឋិន

**យេនម្ហាកំ[១] កឋិនំ គហិតំ កឋិនានិសំសានិ តស្សេវ ទេម ។**

**ទុតិយម្បិ .... ។ តតិយម្បិ .... ។**

ប្រែថា បពិត្រព្រះករុណាដ៏ចម្រើនអើយ កឋិនរបស់យើងខ្ញុំទាំងឡាយ គឺលោកម្ចាស់អង្គណា បានទទួលគាន់យកហើយ យើងខ្ញុំទាំងឡាយ សូមវេរនូវគ្រឿងបរិក្ខារជាបរិវារកឋិនទាំងឡាយ ប្រគេនដល់លោកម្ចាស់អង្គនោះ ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

## វេរកឋិនទាន មួយបែបទៀត

**មយំ ភន្តេ ឥមំ កឋិនចីវរំ សានិសំសំ សង្ឃស្ស ទេម, សាធុ នោ ភន្តេ សង្ឃោ ឥមំ កឋិនចីវរំ សានិសំសំ កឋិនំ អត្ថរិតុំ បដិគ្គណ្ហតុ មាតាបិតុអាទីនញ្ច គុណវន្តានំ អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

**ទុតិយម្បិ .... ។ តតិយម្បិ .... ។**

ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើនអើយ យើងខ្ញុំព្រះករុណាទាំងឡាយ សូមវេរនូវសំពត់[១]នេះ ជាសំពត់ដើម្បីកឋិនចីវរ ព្រមទាំងអានិសង្សលាភចំពោះព្រះសង្ឃ, បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃមេត្តាទទួលយក នូវកឋិនចីវរនេះ ព្រមទាំងអានិសង្សលាភ របស់យើងខ្ញុំទាំងឡាយ ដើម្បីក្រាលកឋិន, ដើម្បីបាននូវសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

---

១- ពាក្យថា យេនម្ហាកំ នេះ សំដៅយកត្រៃទាំងបី ដែលក្រាលសំពត់ណាមួយហើយ សំពត់ទាំងពីរដែលនៅសល់នោះ ទុកជាគ្រឿងបរិវាររបស់កឋិន ។

សំពត់ ៧ប្រការ ដែលព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាត ទុកឱ្យជាសំពត់សមណបរិក្ខារនោះ គឺជាសំពត់ត្រៃចីវរ ១ សំពត់សម្រាប់ងូតទឹកភ្លៀង ១ សំពត់សម្រាប់ទ្រាប់អង្គុយ ១ សំពត់សម្រាប់ក្រាលជាកម្រាល ១ សំពត់សម្រាប់គ្របបូស ឬគ្របដំបៅ ១ សំពត់សម្រាប់ជូតមុខតឹកន្សែង ១ សំពត់តូច ឬធំជាងប្រមាណ ហៅថា សំពត់បរិក្ខារចោឡៈ ១ បញ្ចូលសំពត់សម្រាប់ត្រងទឹក ១ សំពត់ចំណាំវស្សា ១ និង សំពត់អច្ចេកចីវរ ១ ថែមទៀត ត្រូវជា ១០ ។

សំពត់ទាំង ១០ ប្រការនេះ បើទាយកមានប្រាថ្នានឹងវេរសំពត់ណាមួយដល់សង្ឃ តែសំពត់នោះមានតែ ១ ត្រៃ ឬ ១ ផ្ទត់ ត្រូវដាក់ឈ្មោះសំពត់នោះ ជាបាលីឯកវចនៈ បញ្ចូលវេរដូចមានសំណៅទុកជាបែបខាងមុខនេះទាំង ១០ ប្រការគឺ

| | |
|---|---|
| ១- ឥមំ តិចីវរំ | នូវសំពត់ត្រៃចីវរនេះ |
| ២- ឥមំ វស្សិកសាដកំ | នូវសំពត់សម្រាប់ងូតទឹកភ្លៀងនេះ |
| ៣- ឥមំ និសីទនំ | នូវសំពត់សម្រាប់ទ្រាប់អង្គុយនេះ |
| ៤- ឥមំ បច្ចត្ថរណំ | នូវសំពត់សម្រាប់ក្រាលនេះ |
| ៥- ឥមំ កណ្ឌុប្បដិច្ឆាទិ | នូវសំពត់សម្រាប់គ្របបូស ឬគ្របដំបៅនេះ |
| ៦- ឥមំ មុខបុញ្ឆនចោឡំ | នូវសំពត់សម្រាប់ជូតមុខ តឹកន្សែងនេះ |
| ៧- ឥមំ បរិក្ខារចោឡំ | នូវសំពត់តូច ឬធំជាងប្រមាណជាបរិក្ខារនេះ |
| ៨- ឥមំ បរិស្សាវនំ | នូវសំពត់សម្រាប់ត្រងទឹកនេះ |
| ៩- ឥមំ វស្សាវាសិកំ | នូវសំពត់ចំណាំវស្សានេះ |
| ១០- ឥមំ អច្ចេកចីវរំ | នូវសំពត់អច្ចេកចីវរនេះ |

សំពត់ទាំង ១០ ប្រការនេះ បើត្រូវការនឹងវេរប្រគេនសំពត់ណាមួយ ឱ្យយកឈ្មោះសំពត់ដែលមានសំណៅជាបែបទុកនោះ មកដាក់ជាបាលី ដែលសម្រាប់សូធ្យវេរត្រង់កន្លែងដែលមានវង់ក្រចកស្រាប់ហើយនោះចុះ ។

## វេរត្រៃចីវរ

មយំ ភន្តេ ឥមំ (តិចីវរំ) ឥធានេត្វា សង្ឃស្ស ទេម, សាធុ ភន្តេ សង្ឃោ ឥមំ (តិចីវរំ) បដិគ្គណ្ហាតុ មាតាបិតុអាទីនញ្ច គុណវន្តានំ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ទុតិយម្បិ .... ។ តតិយម្បិ .... ។

ប្រែថា បពិត្រព្រះករុណាដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ បាននាំមក (នូវត្រៃចីវរ) នេះ មកដំកល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយក (នូវត្រៃចីវរ) នេះ ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

សំពត់ទាំង ១០ ប្រការនេះ បើទាយកមានប្រាថ្នានឹងវេរសំពត់ណាមួយដល់សង្ឃ តែសំពត់នោះមានច្រើនត្រៃ ឬ ច្រើនផ្ទត់ ត្រូវដាក់ឈ្មោះសំពត់នោះ ជាបាលីពហុវចនៈមកដាក់បញ្ចូលវេរ ដូចមានសំណៅទុកជាបែបខាងក្រោមនេះស្រាប់ ។

១- ឥមានិ តិចីវរានិ នូវសំពត់ត្រៃចីវរទាំងឡាយនេះ

២- ឥមា វស្សិកសាដិកាយោ នូវសំពត់សម្រាប់ងូតទឹកភ្លៀងទាំងឡាយនេះ

៣- ឥមានិ និសីទនានិ នូវសំពត់សម្រាប់ទ្រាប់អង្គុយទាំងឡាយនេះ

៤- ឥមានិ បច្ចត្ថរណានិ នូវសំពត់សម្រាប់ក្រាលជាកម្រាលទាំងឡាយនេះ

៥- ឥមានិ កណ្ឌុប្បដិច្ឆាទិនិ នូវសំពត់សម្រាប់គ្របបូស ឬ គ្របដំបៅទាំងឡាយនេះ

៦- ឥមានិ មុខបុញ្ឆនចោឡានិ នូវសំពត់សម្រាប់ជូតមុខ គឺកន្សែងទាំងឡាយនេះ

៧- ឥមានិ បរិក្ខារចោឡានិ នូវសំពត់តូចឬធំជាងប្រមាណជាបរិក្ខារទាំងឡាយនេះ

៨- ឥមានិ បរិស្សាវនានិ នូវសំពត់សម្រាប់ត្រងទឹកទាំងឡាយនេះ

៩- ឥមា វស្សាវាសិកាយោ នូវសំពត់ចំណាំវស្សាទាំងឡាយនេះ

១០- ឥមានិ[១] អច្ឆេកចីវរានិ នូវសំពត់អច្ឆេកចីវរទាំងឡាយនេះ

ឯសំពត់ ១០ ប្រការនេះ បើត្រូវការវេរសំពត់ណាមួយ ឱ្យយកឈ្មោះសំពត់នោះ មកដាក់ជាបាលី សម្រាប់សូត្រវេរខាងមុខនោះចុះ ត្រង់កន្លែងដែលមានវង់ក្រចកនេះស្រាប់ ។

## វេរសំពត់សម្រាប់ងូតទឹកភ្លៀង

មយំ ភន្តេ ឥមា (វស្សិកសាដិកាយោ) ឥធានេត្វា សង្ឃស្ស ទេម, សាធុ ភន្តេ សង្ឃោ ឥមា (វស្សិកសាដិការយោ) បដិគ្គណ្ហតុ មាតាបិតុ-អាទីនញ្ច គុណវន្តានំ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ៗ

ទុតិយម្បិ .... ៗ

តតិយម្បិ .... ៗ

ប្រែថា បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ បាននាំ (នូវសំពត់សម្រាប់ងូតទឹកភ្លៀងទាំងឡាយ) នេះ មកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយក (នូវសំពត់សម្រាប់ងូតទឹកភ្លៀងទាំងឡាយ) នេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

.... អស់វារៈពីរដងផង ។

.... អស់វារៈបីដងផង ។

(១)- "ឥទំ" ឬ ឥមា, ឥមានិ ប្រែថា "នេះ" ជាពាក្យចង្អុលរបស់ដែលនៅក្នុងហត្ថបាសនៃទាយកអ្នកវេរ, បើរបស់នៅក្រៅហត្ថបាសទាយកអ្នកវេរ ត្រូវថា "ឯតំ, ឯតា, ឯតានិ" ប្រែថា "នោះ" ។

## វេរសង្ឃទាន

មយំ ភន្តេ ឥមានិ ខាទនីយភោជនីយានិ សជ្ជេត្វា សង្ឃស្ស ទេម, សាធុ ភន្តេ សង្ឃោ ឥមានិ ខាទនីយភោជនីយានិ បដិគ្គណ្ហតុ មាតាបិតុអាទីនញ្ច គុណវន្តានំ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ .... ។ តតិយម្បិ .... ។

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ បានតាក់តែងនូវវត្ថុទាំងឡាយ មានខាទនីយភោជនីយាហារ គឺបង្អែមនិងចម្អាបជាដើមនេះ ហើយវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយក នូវវត្ថុទាំងឡាយ មានបង្អែមនិងចម្អាបជាដើមនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។ .... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

## វេរគណទាន

មយំ ភន្តេ ឥមានិ ខាទនីយភោជនីយានិ សជ្ជេត្វា សីលវន្តានំ ទេម, សាធុ ភន្តេ សីលវន្តោ ឥមានិ ខាទនីយភោជនីយានិ បដិគ្គណ្ហន្តុ មាតាបិតុអាទីនញ្ច គុណវន្តានំ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ទុតិយម្បិ .... ។ តតិយម្បិ .... ។

ប្រែថា បពិត្រព្រះករុណាទាំងឡាយដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ បានតាក់តែងនូវវត្ថុទាំងឡាយ មានខាទនីយភោជនីយាហារ គឺបង្អែមនិងចម្អាបជាដើមនេះ ហើយវេរប្រគេនដល់លោកម្ចាស់ អ្នកមានសីលទាំងឡាយ បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន សូមលោកម្ចាស់អ្នកមានសីលទាំងឡាយ ទទួលយកនូវវត្ថុទាំងឡាយ មានបង្អែមនិងចម្អាបជាដើមនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

## វេរបាដិបុគ្គលិកទាន

**មយំ ភន្តេ ឥមានិ ខាទនីយភោជនីយានិ សជ្ជេត្វា សីលវន្តស្ស ទេម, សាធុ ភន្តេ សីលវា ឥមានិ ខាទនីយភោជនីយានិ បដិគ្គណ្ហតុ មាតាបិតុអាទីនញ្ច គុណវន្តានំ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ៗ**

**ទុតិយម្បិ .... ៗ តតិយម្បិ .... ៗ**

ប្រែថា បពិត្រព្រះករុណាដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ បានតាក់តែងនូវវត្ថុទាំងឡាយ មានខាទនីយភោជនីយាហារ គឺបង្អែមនិងចម្អាបជាដើមនេះ ហើយវេរប្រគេនដល់ព្រះករុណា បពិត្រព្រះករុណាដ៏ចំរើន សូមលោកអ្នកមានសីល ទទួលយកនូវវត្ថុទាំងឡាយ មានបង្អែម និងចម្អាបជាដើមនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

## វេរអង្ករដល់ព្រះសង្ឃ

**មយំ ភន្តេ ឥមានិ តណ្ឌុលានិ ឥធានេត្វា សង្ឃស្ស ទេម, សាធុ ភន្តេ សង្ឃោ ឥមានិ តណ្ឌុលានិ បដិគ្គណ្ហតុ មាតាបិតុអាទីនញ្ច គុណវន្តានំ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ៗ**

**ទុតិយម្បិ .... ៗ តតិយម្បិ .... ៗ**

ប្រែថា បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ បាននាំមកនូវអង្ករទាំងឡាយនេះ មកតម្កល់ទុកក្នុងទីនេះ ហើយសូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយក នូវអង្ករទាំងឡាយនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

## វេរផ្លែឈើផ្សេងៗ

**មយំ ភន្តេ ឥមានិ នានាផលានិ ឥធានេត្វា សង្ឃស្ស ទេម, សាធុ ភន្តេ សង្ឃោ ឥមានិ នានាផលានិ បដិគ្គណ្ហតុ មាតាបិតុអាទីនញ្ច គុណវន្តានំ អម្ហាកំ ទីឃរត្តំ ហិតាយ សុខាយ ។**

**ទុតិយម្បិ....។ តតិយម្បិ....។**

ប្រែថា បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ បាននាំនូវផ្លែឈើផ្សេងៗទាំងឡាយនេះ មកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយក នូវផ្លែឈើផ្សេងៗទាំងឡាយនេះ ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

## វេរគ្រឿងសេនាសនៈ

(វេររោងឧបោសថ គឺវិហារ)

**មយំ ភន្តេ ឥមំ (ឧបោសថាគារំ) ការេត្វា ឧបោសថបវារណាទិ-សង្ឃកម្មករណត្ថាយ ចាតុទ្ទិសស្ស ភិក្ខុសង្ឃស្ស ទេម, សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ (ឧបោសថាគារំ) បដិគ្គណ្ហតុ មាតាបិតុអាទីនញ្ច គុណវន្តានំ អម្ហាកំ ទីឃរត្តំ ហិតាយ សុខាយ ។**

**ទុតិយម្បិ .... ។ តតិយម្បិ .... ។**

ប្រែថា បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយបានចាត់ចែងធ្វើ (នូវរោងសម្រាប់ធ្វើនូវឧបោសថ) នេះ ហើយវេរប្រគេនដល់ព្រះភិក្ខុសង្ឃ ដែលមកអំពីទិសទាំង ៤ ដើម្បីប្រយោជន៍ដល់កិរិយាធ្វើនូវសង្ឃកម្ម មានឧបោសថកម្មនិងបវារណាកម្មជាដើម បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើន សូមព្រះភិក្ខុសង្ឃទទួលយក (នូវរោងសម្រាប់ធ្វើនូវឧបោសថនេះ) ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

បើវេរសាលា ថា

ឥមំ សាលំ នូវសាលានេះ ។

វេរកប្បិយកុដិ ថា

ឥមំ កប្បិយកុដឹ នូវកប្បិយកុដិនេះ ។

វេរកុដិតូច ឬ តូប ថា

ឥមំ កុដឹ នូវកុដិ ឬនូវតូបនេះ ។

បើវេរកុដិធំ ថា

ឥមំ វិហារំ នូវកុដិធំនេះ ។

វេរបង្គន់ ថា

ឥមំ វច្ចកុដឹ នូវបង្គន់នេះ។

បើប្រាថ្នានឹងវេរសាលាក្តី កប្បិយកុដិក្តី កុដិតូច ឬតូបក្តី កុដិក្តី បង្គន់ក្តី ទាំង ៥ យ៉ាងនេះ នឹងរបស់ណាមួយ ឱ្យយកឈ្មោះរបស់នោះ ទាំងបាលីទាំងសម្រាយមកដាក់កន្លែងវង់ក្រចកនោះ ហើយសូធ្យវេរចុះ ។

## វេរគរុភណ្ឌ

មយំ ភន្តេ ឥមំ គរុភណ្ឌំ ឥធានេត្វា ភិក្ខុសង្ឃស្ស ទេម, សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ គរុភណ្ឌំ បដិគ្គណ្ហាតុ មាតាបិតុអាទីនញ្ច គុណវន្តានំ អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ទុតិយម្បិ .... ។ តតិយម្បិ .... ។

ប្រែថា បពិត្រព្រះគម្តែងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ បាននាំមកនូវគរុភណ្ឌនេះ មកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះគម្តែងសង្ឃដ៏ចំរើន សូមព្រះភិក្ខុសង្ឃទទួលយកនូវគរុភណ្ឌនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

# វិធីវេរគ្រឿងភេសជ្ជៈ

(បើវេរទឹកឃ្មុំ)

មយំ ភន្តេ ឥមំ (មធុំ) ឥធានេត្វា ភិក្ខុសង្ឃស្ស ទេម, សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ (មធុំ) បដិគណ្ហតុ មាតាបិតុអាទីនញ្ច គុណវន្តានំ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ៗ

ទុតិយម្បិ .... ៗ តតិយម្បិ .... ៗ

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ បាននាំមក (នូវទឹកឃ្មុំ) នេះ មកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃ បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន សូមព្រះភិក្ខុសង្ឃទទួលយក (នូវទឹកឃ្មុំ) នេះ ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

.... អស់វារៈពីរដងផង ។ .... អស់វារៈបីដងផង ។

## បើវេរប្រេង ថា

ឥមំ តេលំ នូវប្រេងនេះ ។

## បើវេរទឹកអំពៅ ថា

ឥមំ ផាណិតំ នូវទឹកអំពៅនេះ ។

## បើវេរទឹកត្នោត ថា

ឥមំ តាលោទកំ នូវទឹកត្នោតនេះ ។

## បើវេរថ្នាំរម្ងាប់រោគ ថា

ឥមំ គិលានភេសជ្ជំ នូវថ្នាំសម្រាប់រក្សានូវមនុស្សឈឺនេះ ។

បើប្រាថ្នានឹងវេរប្រេងក្ដី ទឹកអំពៅក្ដី ទឹកត្នោតក្ដី ថ្នាំរក្សានូវជំងឺក្ដីទាំង ៤ នេះ របស់ណាមួយ ឱ្យយកឈ្មោះរបស់នោះ ទាំងបាលីទាំងសម្រាយមកដាក់ត្រង់កន្លែងវង់ក្រចកនោះ ហើយសូធ្យវេរចុះ ។

វិធីវេរបច្ច័យទាំង ១៩ ប្រការ

ចប់ដោយសង្ខេប

## បាលីវេរដុំថ្មជានិមិត្តសីមា

ឧក្កាស មយំ ភន្តេ ឥមេ មហន្តេ បាសាណបិណ្ឌេ សីមាយ និមិត្តករណត្ថាយ ភិក្ខុសង្ឃស្ស ទេម, សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមេ បាសាណបិណ្ឌេ បដិគ្គណ្ហាតុ (បដិគ្គហេត្វាន ឥមេហិ បាសាណបិណ្ឌេហិ និមិត្តំ កិត្តេត្វា) ខណ្ឌសីមំ សម្មន្នតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

សូមគោរព បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយ សូមវេរនូវដុំថ្មធំទាំងឡាយនេះ ប្រគេនដល់ព្រះភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ការធ្វើជានិមិត្តសីមា បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយកនូវដុំថ្មទាំងឡាយនេះ លុះទទួលរួចហើយ សូមសំដែងនូវនិមិត្ត ដោយដុំថ្មទាំងឡាយនេះ ហើយសន្មតនូវខ័ណ្ឌសីមាចុះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

## បាលីវេររោងឧបោសថ (គឺវិហារ)

ឧក្កាស មយំ ភន្តេ យថាសទ្ធំ ធនំ បរិច្ចជិត្វា ឥមំ ឧបោសថាគារំ ការេត្វា ឧបោសថបវារណាទិសង្ឃកម្មករណត្ថាយ ចាតុទ្ទិសស្ស សង្ឃស្ស ទេម, សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ ឧបោសថាគារំ បដិគ្គណ្ហាតុ បដិគ្គហេត្វាន យថិច្ឆិតំ បរិភុញ្ជតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

សូមគោរព បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើនអើយ យើងខ្ញុំទាំងឡាយបានបរិច្ចាគនូវទ្រព្យតាមគួរដល់សទ្ធាហើយ បានចាត់ចែងការសាងសង់នូវឧបោសថាគារ គឺវិហារជារោងឧបោសថនេះ រួចហើយសូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃ ដែលនិមន្តមកអំពីទិសទាំងបួន ដើម្បីជាប្រយោជន៍ ដល់ការធ្វើនូវសង្ឃកម្ម មានឧបោសថកម្មនិងបវារណាកម្មជាដើម បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួល នូវឧបោសថាគារនេះ លុះទទួលរួចហើយ សូមប្រើប្រាស់តាមការត្រូវការចុះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

# បាលី-ប្រែ

សម្រាប់សូធ្យឧទ្ទិសបុញ្ញកិរិយាវត្ថុទាំងឡាយមានទានជាដើម

**សុទិន្នំ វត នោ ទានំ សព្វសម្បត្តិសិទ្ធកំ និព្វានសច្ចាកំ**

**អាសវក្ខយាវហំ ហោតុ អនាគតេ កាលេ ។**

វីទាននៃយើងខ្ញុំទាំងឡាយនេះ ដែលបានបូជាហើយដោយប្រពៃ សូមឱ្យបានសម្រេចដោយសម្បត្តិទាំងពួង ទាំងសូមឱ្យបានជាបច្ច័យ នាំមកនូវធម៌ជាទីអស់ទៅ នៃអាសវក្កិលេសពោលគឺព្រះនិព្វាន ក្នុងអនាគតកាលទៅខាងមុខនោះហោង ។

## វេរមួយបែបទៀតថា

**ឥទំ វត នោ បុញ្ញំ អាសវក្ខយាវហំ ហោតុ អនាគតេ កាលេ ។**

វីបុណ្យនៃយើងខ្ញុំទាំងឡាយនេះ សូមឱ្យបានជាបច្ច័យនាំមកនូវធម៌ជាទីអស់ទៅ នៃអាសវក្កិលេសគឺព្រះនិព្វាន ក្នុងអនាគតកាលទៅខាងមុខនោះហោង ។

## វេរមួយបែបទៀតថា

**ឥទំ នោ ទានំ អាសវក្ខយាវហំ ហោតុ ។**

វីទាននៃយើងខ្ញុំទាំងឡាយនេះ (ដែលបានបូជាហើយដោយប្រពៃ) សូមឱ្យបានជាបច្ច័យនាំមកនូវធម៌ជាទីអស់ទៅនៃអាសវៈ គឺកិលេសទាំងពួងហោង ។

## វេរមួយបែបទៀតថា

**ឥទំ នោ ទានំ ហោតុ សុខិតា ហោន្តុ ញាតយោ ។**

វីទាននៃយើងខ្ញុំទាំងឡាយនេះ ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយបាននូវសេចក្តីសុខ ។

# បញ្ហាទាន

ចង់ដឹងបញ្ហានេះ មុនដំបូងត្រូវដឹងថា អ្វីទៅហៅថា ទាន មានឈ្មោះដូចម្ដេច ?

**ទាន** ជានាមធម៌ គឺជាតួចេតនារបស់អ្នកឱ្យ ហៅថា **ទានចេតនា** មានឈ្មោះ ៣ យ៉ាង ដូចបាលីលោកសម្ដែងទុកថា **ទានំ នាម ចាគចេតនា វិរតិ ទេយ្យធម្មោបិ ទិយតិ ឯតេនាតិ** ទានមានឈ្មោះ ៣ យ៉ាងគឺ **ចាគចេតនា វិរតិ** និង **ទេយ្យធម៌**

១- **ចាគចេតនា** ចេតនាដែលលះ (នូវទេយ្យធម៌ឱ្យដល់អ្នកដទៃ) ។

២- **វិរតិ** ការវៀរចាកសម្លាប់សត្វបំបាត់ជីវិតសព្វសត្វនានា ។

៣- **ទេយ្យធម៌** គឺវត្ថុសម្ភារៈផ្សេងៗ ដែលគួរឱ្យ ។

## សេចក្ដីពន្យល់

-ចេតនាដែលមានសទ្ធា (ជឿ) និង **ហិរិ** (ការអៀនខ្មាស់ខ្ពើមអំពើបាប) ជាកុសលជួយបណ្ដុះបណ្ដាលឡើង អាស្រ័យដោយហេតុណាមួយ ជួយជំរុញឱ្យលះបង់ ហើយឱ្យនូវទេយ្យវត្ថុ ផ្សេងៗ ហៅថា **ចាគចេតនាទាន** ។

-ការសមាទានសីលប្រាំ វៀរចាកសម្លាប់ជីវិតគេ ឱ្យអភ័យដល់សព្វសត្វដទៃ ប្រកបដោយមេត្តាជាដើម ហៅថា **វិរតិទាន** ។

-ការឱ្យនូវរបស់ដែលគួរឱ្យ មានគ្រឿងឧបភោគនិងបរិភោគ ឬខាទនីយភោជនីយាហារជាបច្ច័យសម្រាប់ផ្គត់ផ្គង់ប្រើប្រាស់ ហូប ចុក ជាដើម ហៅថា **ទេយ្យធម្មទាន** ។

ទានមានឈ្មោះ ៣យ៉ាងនេះ ដែលមានបញ្ហាស្មុគ្រស្មាញជាងគេ គឺទេយ្យធម្មទានហ្នឹងឯងពីព្រោះទាយកទាយិកា អ្នកធ្វើច្រើនទាក់ទងលើបញ្ហា ៣ គឺ បញ្ហាឱ្យ បញ្ហាវេរ និង បញ្ហារកនិមន្តបដិគ្គាហកៈ គឺចំនួនភិក្ខុមកទទួល ។

១- បញ្ហាឱ្យ ត្រូវអាស្រ័យដោយចេតនារបស់អ្នកឱ្យ បើចេតនាតម្កល់ទានចំពោះលើព្រះសង្ឃ ហៅថា សង្ឃគតាទាន ឬសង្ឃទាន, បើចេតនាតម្កល់ទានចំពោះលើបុគ្គល តាមការជ្រើសរើសដោយការស្រឡាញ់ពេញចិត្ត ហៅថា បាដិបុគ្គលិកទាន ។

២- បញ្ហាវេរ ត្រូវអាស្រ័យដោយចំនួនភិក្ខុអ្នកទទួល បើភិក្ខុអ្នកទទួលមានតែ ១ រូប, អាចារ្យត្រូវវេរជាបុគ្គល, បើភិក្ខុអ្នកទទួលមាន ២ រូប ឬ ៣ រូប អាចារ្យត្រូវវេរជាគណៈ, បើភិក្ខុអ្នកទទួលមានពី ៤ រូបឡើងទៅ អាចារ្យត្រូវវេរជាសង្ឃ ។

៣- បញ្ហាបដិគ្គាហកៈ គឺរកនិមន្តភិក្ខុមកទទួល អាស្រ័យដោយទាយកទាយិកាម្ចាស់ទានមានការប៉ិនប្រសប់ផងដែរ គឺប្រើសម្ដីជាសង្ឃដរាប ។

ក្នុងវិន័យព្រះពុទ្ធសាសនា លោកសម្ដែងអំពីកិច្ចធ្វើទាន មានសេចក្ដីទូលំទូលាយណាស់ សូមលើកយកតែអំពីការធ្វើទានបច្ច័យ ៤ មួយយ៉ាងប៉ុណ្ណោះមកជាតួយ៉ាង ។

## ធ្វើទានបច្ច័យ ៤ ចំពោះសង្ឃ

អ្នកធ្វើបច្ច័យ ៤ បើកាលណាចាត់ចែងទេយ្យធម្មទាន បានសព្វគ្រប់បច្ច័យទាំង ៤ ហើយ ទោះបីលទ្ធភាពបានត្រឹមតែ ១ ប្រដាប់ក្ដី ២-៣-៤ ឬលើសពីនេះទៅទៀតក្ដី រួចហើយចូលទៅវត្តអារាមណាមួយ ពិតទូលប្រធានសង្ឃថា "សូមព្រះសង្ឃមេត្តាចាត់ភិក្ខុ ១ រូប ២-៣-៤ ឬលើស តាមតែអង្គណានឹងបាន និមន្តទៅទទួល សង្ឃទាន ឯផ្ទះខ្ញុំព្រះករុណា វេលាព្រឹកនេះ ឬស្អែកម៉ោងប៉ុណ្ណេះ" ។ បើការនិមន្តមានវិធីដូច្នេះ ទោះបីធ្វើតែនឹងភិក្ខុ ១ អង្គ ដែលសង្ឃចាត់មកនោះ ក៏ឈ្មោះថា សង្ឃទាន គឺបានធ្វើចំពោះសង្ឃពេញទី...... ។

ចំពោះទាយកម្ចាស់ទាន កាលណាបើភិក្ខុដែលសង្ឃចាត់ និមន្តមកដល់ផ្ទះហើយ ត្រូវតាំងចិត្តថា សង្ឃ ទទួលបដិសណ្ឋារៈជា សង្ឃ តែម្យ៉ាង ទោះបីសាមណេរក៏ដោយ ។

## របៀបវេរបច្ច័យ ៤ ជាសង្ឃទាន

ការវេរបច្ច័យ ៤ ត្រូវគិតតាមចំនួនបដិគ្គាហកៈ គឺចំនួនភិក្ខុអ្នកទទួល

១- បើភិក្ខុពី ៤ អង្គឡើងទៅ ត្រូវវេរជាសង្ឃថា

មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា សង្ឃស្ស ទេម, សាធុ ភន្តេ សង្ឃោ ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហតុ មាតាបិតុអាទីនញ្ច គុណវន្តានំ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។.

ទុតិយម្បិ .... ។ តតិយម្បិ .... ។

២- បើភិក្ខុមានតែ ២ ឬ ៣ អង្គ ត្រូវវេរជាគណៈថា

មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា អាយស្មន្តានំ ទេម, សាធុ ភន្តេ អាយស្មន្តោ ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហន្តុ មាតាបិតុ-អាទីនញ្ច គុណវន្តានំ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ទុតិយម្បិ .... ។ តតិយម្បិ .... ។

៣- បើភិក្ខុមានតែ ១ អង្គ ត្រូវវេរជាបុគ្គលថា

មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា អាយស្មតោ ទេម, សាធុ ភន្តេ អាយស្មា ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ទុតិយម្បិ .... ។ តតិយម្បិ .... ។

សូមបញ្ជាក់ថា ពាក្យថា ( ទេរ ) មានន័យថា ប្រគល់នូវបច្ច័យ ៤ ឬទេយ្យវត្ថុចំពោះចំនួនភិក្ខុ ដែលប្រធានសង្ឃ ចាត់ជាតំណាងសង្ឃ ឱ្យមកទទួលនាំយកទៅប្រគល់ឱ្យសង្ឃនៅឯវត្ត ចាត់ចែងប្រើប្រាស់តាមសមគួរ ។

ន័យនេះ សមនឹងអង្គនៃសង្ឃទានមាន ២ យ៉ាងគឺ

១- ទាយក បានសុំនិមន្តលោក ដែលជាបដិគ្គាហកៈ អំពីសំណាក់សង្ឃ ។

២- កាលណាលោក ដែលជាបដិគ្គាហកៈ និមន្តមកដល់ផ្ទះខ្លួនហើយ ខ្លួនបានតាំងចិត្តចំពោះលើសង្ឃ ។

## អំពីពាក្យថា សង្ឃ

ពាក្យថា (សង្ឃ) ។ នេះ ប្រែបានច្រើនយ៉ាង *ឧទាហរណ៍* មិគសង្ឃោ ប្រែថា ហ្វូងនៃម្រឹគ ទេវសង្ឃោ ពួកនៃទេវតា ។ល។

ស័ព្ទនេះ បើភ្ជាប់ជាមួយនឹងស័ព្ទទៃណាមួយ ក៏នៅតែរក្សាទុកអានុភាពជាពហុវចនៈទាំងអស់ ។

អំពីព្រះភិក្ខុសង្ឃ (ពាក្យសាមញ្ញ ហៅ ត្រឹមតែព្រះសង្ឃ) ។

បានពិនិត្យឃើញ ក្នុងគម្ពីរវត្តតិយសមន្តបាសាទិកាអដ្ឋកថា និង គម្ពីរកង្ខាវិតរណីជាដើម សម្តែងពន្យល់សេចក្តីថា ប្រជុំនៃភិក្ខុសង្ឃច្រើនរូប ដោយសេចក្តីមិនប្លែកគ្នា បានឈ្មោះថា សង្ឃ ។

## ឯសង្ឃនោះមាន ២ ពួកគឺ

១- ប្រជុំនៃអរិយបុគ្គលទាំង ៨ ពួក ជាភិក្ខុ ឈ្មោះទក្ខិណេយ្យបុគ្គលសង្ឃ ។

២- ប្រជុំភិក្ខុជាបុថុជ្ជន ដែលលោកសន្មតឈ្មោះថា សម្មតិសង្ឃ ។ ត្រូវជាសង្ឃពីរពួកសម្រាប់ធ្វើសង្ឃកម្ម ។

## សង្ឃទាំង ២ ពួកនេះ ចែកចេញជា ៥ ពួកទៀត ដូចតទៅ

| | | | | |
|---|---|---|---|---|
| ១- | ប្រជុំនៃភិក្ខុ | ៤ រូប | ឈ្មោះថា | សង្ឃចតុវគ្គ |
| ២- | ប្រជុំនៃភិក្ខុ | ៥ រូប | ឈ្មោះថា | សង្ឃបញ្ចវគ្គ |
| ៣- | ប្រជុំនៃភិក្ខុ | ១០ រូប | ឈ្មោះថា | សង្ឃទសវគ្គ |
| ៤- | ប្រជុំនៃភិក្ខុ | ២០ រូប | ឈ្មោះថា | សង្ឃវីសតិវគ្គ |

៥- ប្រជុំនៃភិក្ខុ ច្រើនជាង ២០ រូប ឡើងទៅ ឈ្មោះថា សង្ឃអតិរេកវីសតិវគ្គ ។

ក- សង្ឃចតុវគ្គ គួរនឹងធ្វើសង្ឃកម្មបានទាំងអស់ វៀរលែងតែសង្ឃកម្ម ៤ យ៉ាងគឺ ឧបសម្បទាកម្ម ១ បវារណាកម្ម ១ កឋិនកម្ម ១ និង អព្ភានកម្ម ១ ពុំបានឡើយ ។

ខ- សង្ឃបញ្ចវគ្គ គួរនឹងធ្វើសង្ឃកម្មបានទាំងអស់ វៀរលែងតែសង្ឃកម្ម ២ យ៉ាងគឺ ឧបសម្បទាកម្ម ក្នុងមជ្ឈិមប្រទេស ១ និង អព្ភានកម្ម ១ ពុំបានឡើយ ។

គ- សង្ឃទសវគ្គ គួរនឹងធ្វើសង្ឃកម្មបានទាំងអស់ វៀរលែងតែអព្ភានកម្ម ១ចេញធ្វើ ពុំបានឡើយ ។

ឃ- សង្ឃវីសតិវគ្គ គួរនឹងធ្វើសង្ឃកម្មបានទាំងអស់ មានអព្ភានកម្មជាដើម ឥតមាន ទាស់អ្វីឡើយ ។

ង- សង្ឃអតិរេកវីសតិវគ្គ គួរនឹងធ្វើសង្ឃកម្មបានទាំងអស់ បានដោយប្រពៃ។

ចប់

បញ្ញាទាន តែប៊ុណ្ណេះ

# ប្រស្នាត្រៃក្កុណាសខ្មែរ

# ប្រស្នាពុទ្ធគុណ

១- អរហំ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកស័ត្រូវ ពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគនិងវចីបយោគ ។

**សួរថា** ព្រះនាមអរហំនេះ ហៅបានតែព្រះសព្វញ្ញុពុទ្ធមួយព្រះអង្គទេ ឬព្រះអរហន្ត ទាំងអស់ ហៅបានដែរ ?

**ឆ្លើយថា** ព្រះនាមអរហំនេះ ហៅបានតែព្រះសព្វញ្ញុពុទ្ធមួយព្រះអង្គទេ ព្រោះព្រះអង្គ លះបង់នូវវាសនា និងបយោគបាន ឯព្រះអរហន្តដទៃៗ លះបង់មិនទាន់បាន ដូចជាព្រះ សារីបុត្រនៅជាប់កាយបយោគ ព្រះកច្ចាយនៈនៅជាប់វចីបយោគ ។

ស- ព្រះនាមទាំង ១០ មានព្រះអរហំជាដើមនេះ មានទូទៅគ្រប់អង្គព្រះសព្វញ្ញុពុទ្ធ ទាំងអស់ ឬអ្វី ?

ឆ- ព្រះនាមទាំង ១០ មានអរហំ ជាដើមនេះ មានទូទៅគ្រប់ព្រះសព្វញ្ញុពុទ្ធទាំងអស់ ព្រោះព្រះសព្វញ្ញុពុទ្ធទាំងឡាយ តែងប្រកបដោយគុណ មានអរហំជាដើមនេះ ។

ស- ព្រះនាមទាំង ១០ នេះ អ្នកណាថ្វាយដល់ព្រះអង្គ ?

ឆ- នេមិត្តិកនាម នាមកើតឯងដោយគុណនៃព្រះអង្គ ។

ស- កិលេស គឺអ្វី ? ចូររាប់ខ្លះមកមើល ?

ឆ- កិលេស គឺសេចក្ដីសៅហ្មងរបស់ចិត្ត ដែលកើតអំពីអកុសលធម៌ទាំងពួង មាន លោភៈ ទោសៈ មោហៈ ជាដើម ។

ស- វាសនា គឺអ្វី ? ប្រែជាសេចក្ដីថា ដូចម្ដេច ?

ឆ- វាសនា គឺលំនៅឬលំនាំនៃចិត្ត ប្រែថា កន្លែងដែលចិត្តធ្លាប់អាស្រ័យ ឬធ្លាប់ប្រកប ទៅមក ច្រើនជាតិណាស់ហើយ កើតជាទម្លាប់នាំចិត្តឱ្យរអិលទៅឯង ។

ស- បយោគ គឺអ្វី ? ប្រែជាសេចក្ដីថា ដូចម្ដេច ?

ឆ- បយោគ គឺការប្រកប ប្រែថា សេចក្ដីប្រកបរបស់ចិត្ត ដែលអាស្រ័យកាយ និង វាចា បើចិត្តប្រកបការមកនិងកាយ ហៅថា កាយបយោគ បើចិត្តប្រកបការមកនិងវាចា ហៅថា វចីបយោគ ។

ស- កាយ គឺអ្វី ? មានសេចក្តីអធិប្បាយ ដូចម្តេច ?

ឆ- កាយ គឺប្រជុំអាការៈទាំង ៣២ ប្រការ មានសក់ជាដើម ហៅថា កាយ ដោយសេចក្តីអធិប្បាយថា ជាកន្លែងដេកនូវរបស់ជង្គូវ ឬ ជាកន្លែងស៊ីជុះ គឺជាបង្គន់នៃសត្វជង្គូវ ឬ ជាព្រៃស្មសាន សម្រាប់កប់ខ្មោចសត្វជង្គូវផង ។

ស- កាយមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ឆ- កាយមាន ២ យ៉ាងគឺៈ រូបកាយ ១ នាមកាយ ១ ។

ស- រូបកាយ គឺអ្វី ? ចូររាប់គោលសេចក្តីខ្លះមកមើល ?

ឆ- រូបកាយ គឺ ទឹក-ដី-ភ្លើង-ខ្យល់ ដែលហៅថា ចតុភូតរូប ឬ ហៅថា មហាភូតរូប ៤ ន័យខ្លះ ហៅថា ករជកាយ ទីប្រជុំធូលី សម្ភាវភាគនៃមាតាបិតា ដែលបង្កើតបានជាបុត្រធីតា ។

ស- នាមកាយ គឺជាឈ្មោះនៃធម៌អ្វី ?

ឆ- នាមកាយ គឺជាឈ្មោះនៃធម៌គ្មានរូប មានចិត្តជាដើម ។

ស- វាចា ឬ វចី គឺអ្វី ? ចូរទាញគោលខ្លះមកពន្យល់ខ្លីៗមើល!

ឆ- វាចាក្តី វចីក្តី គឺសំដីពាក្យពោល ឬ និយាយឱ្យលាន់ឮឡើង ជាបុណ្យខ្លះ ជាបាបខ្លះ ជាបុណ្យដូចសំដីថា យើងត្រូវនាំគ្នាធ្វើទានសីលភាវនា បើជាបាបដូចជាសំដីកុហក ញុះញង់ សិកសៀត ជេរ បញ្ចោ ត្លុកកំប្លែង ជាដើម ។

២- សម្មាសម្ពុទ្ធោ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹង នូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ ។

ស- ញេយ្យធម៌ គឺធម៌អ្វី ? ចូររាប់គោលខ្លះមកមើល!

ឆ- ញេយ្យធម៌នោះ គឺធម៌ដែលបុគ្គលគប្បីដឹងមាន ខន្ធ ៥ ធាតុ ៤ អាយតនៈ ១២ និងឥន្ទ្រិយ៍ ៥ ជាដើម ។

ស- ខន្ធ ៥ នោះ ប្រែថា ដូចម្តេច ? គឺអ្វីខ្លះ ?

ឆ- បញ្ចខន្ធា ខន្ធ ៥ នោះ ប្រែថា គំនរ ៥ គឺ គំនររូប ១ គំនរវេទនា ១ គំនរសញ្ញា ១ គំនរសង្ខារ ១ គំនរវិញ្ញាណ ១ ។

ស- ចុះធាតុ ៤ នោះ ប្រែថា ដូចម្តេច ? គឺអ្វីខ្លះ ?

ឆ- ចតុធាតុ ឬ ចតុភូត ប្រែថា ធាតុ ៤ ឬ ភូត ៤ គឺ សភាវទ្រទ្រង់នូវសត្វ ឬ កើតប្រាកដ គឺៈ ដី ១ ទឹក ១ ភ្លើង ១ ខ្យល់ ១ ។

ស- អាយតនៈ ១២ ប្រែថា ដូចម្ដេច ? គឺអ្វីខ្លះ ?

ឆ- ទ្វាទសាយតនានិ ប្រែថា អណ្ដូង ១២ ឬ ប្រឡាយ ១២ គឺ កន្លែងជាទីកើតនៃអារម្មណ៍ ហៅថា អាយតនៈខាងក្នុងមាន ៦ គឺ ភ្នែក ១ ត្រចៀក ១ ច្រមុះ ១ អណ្ដាត ១ កាយ ១ ចិត្ត ១ ។ អាយតនៈខាងក្រៅមាន ៦ គឺ រូប ១ សំឡេង ១ ក្លិន ១ រស ១ សម្ផស្ស ១ ធម៌ ១ (រួមជា ១២) អាយតនៈទាំង ១២ នេះ កើតជាគូៗគ្នា ។

ស- ឥន្ទ្រិយ៍ ៥ នោះ ប្រែថា ដូចម្ដេច ? គឺអ្វីខ្លះ ?

ឆ- បញ្ចិន្ទ្រិយានិ ប្រែថា ធម្មជាតជាធំ ៥ យ៉ាង ដោយឡែកៗពីគ្នា ហៅថា ឥន្ទ្រិយ៍ គឺភ្នែកធំខាងការឃើញរូប ១ ត្រចៀកធំខាងការឮសំឡេង ១ ច្រមុះធំខាងការធំក្លិន ១ អណ្ដាតធំខាងការដឹងរស ១ កាយធំខាងការដឹងសម្ផស្ស ១ (រួមជា ៥) ។

៣- វិជ្ជាចរណសម្បន្នោ ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥ ។

ស- វិជ្ជា ៣ គឺអ្វីខ្លះ ? ចូររាប់បាលីជាគោលអាងមកផង ?

ឆ- វិជ្ជា ៣នោះគឺ បុព្វេនិវាសានុស្សតិញ្ញាណ ប្រាជ្ញារឭកតាមឃើញច្បាស់នូវបញ្ចក្ខន្ធដែលខ្លួនធ្លាប់អាស្រ័យនៅហើយក្នុងភពមុន ១ ចតូបបាតញ្ញាណ ប្រាជ្ញាឃើញច្បាស់នូវចុតិនិងបដិសន្ធិនៃសត្វ ១ អាសវក្ខយញ្ញាណ ប្រាជ្ញាឃើញច្បាស់នូវធម៌ ជាគ្រឿងធ្វើឱ្យអស់ទៅនៃអាសវៈ ១ (រួមជា ៣) ។

ស- ចុះវិជ្ជា ៨ នោះ គឺវិជ្ជា អ្វីខ្លះ ? ចូររាប់ឈ្មោះមកមើល!

ឆ- វិជ្ជា ៨ នោះគឺ បុព្វេនិវាសានុស្សតិញ្ញាណ ប្រាជ្ញារឭកតាមឃើញច្បាស់នូវបញ្ចក្ខន្ធដែលខ្លួនធ្លាប់អាស្រ័យនៅហើយក្នុងភពមុន ១ ចតូបបាតញ្ញាណ ប្រាជ្ញាឃើញច្បាស់នូវចុតិនិងបដិសន្ធិនៃសត្វ ១ អាសវក្ខយញ្ញាណ ប្រាជ្ញាឃើញច្បាស់នូវធម៌ ជាគ្រឿងធ្វើឱ្យអស់ទៅនៃអាសវៈ ១ វិបស្សនាញាណ ប្រាជ្ញាពិចារណាឃើញច្បាស់ក្នុងសង្ខារ ១ មនោមយិទ្ធិ ឫទ្ធិសម្រេចដោយចិត្ត ១ ឥទ្ធិវិធិ ឫទ្ធិសម្រេចដោយអធិដ្ឋាន ១ ទិព្វសោត ត្រចៀក

ទិព្វអាចឮសំឡេងក្នុងទីឆ្ងាយៗបាន ១ ចេតោបរិយញ្ញាណ កំណត់ដឹងចិត្តរបស់អ្នកដទៃបាន ១ (រួមជា ៨) ។

ស- ចុះ ចរណ ១៥ នោះ គឺអ្វីខ្លះ ? ចូររាប់ឱ្យគ្រប់មកមើល!

ឆ- ចរណ ១៥ នោះគឺ សីលសំវរៈ សង្រួមកាយនិងវាចាឱ្យរៀបរយ ១ ឥន្ទ្រិយសំវរៈ សង្រួមឥន្ទ្រិយ៍ទាំង ៦ ឱ្យល្អ ១ ភោជនេមត្តញ្ញុតា ភាពជាអ្នកដឹងប្រមាណក្នុងភោជន ១ ជាគរិយានុយោគ ប្រកបក្នុងការភ្ញាក់រឭកឃើញរឿយៗ ១ សទ្ធា ជឿហេតុដែលគួរជឿ ១ ហិរិ សេចក្ដីខ្មាស់អំពើទុច្ចរិត ១ ឱត្តប្បៈ សេចក្ដីតក់ស្លុតខ្លាចបាបអំពើទុច្ចរិត ១ ពាហុសច្ចៈ ភាពនៃខ្លួនជាពហុស្សូត្រ ១ វិរិយ សេចក្ដីព្យាយាម ១ សតិ សេចក្ដីរឭកបាន ១ បញ្ញា សេចក្ដីដឹងត្រូវ ១ បឋមជ្ឈាន ឈានទី ១ លះនីវរណ ៥ គឺ កាមឆន្ទៈ ព្យាបាទ ថិនមិទ្ធ ឧទ្ធច្ចកុក្កុច្ច វិចិកិច្ឆា ហើយប្រកបដោយអង្គ ៥ គឺ វិតក្ក វិចារ បីតិ សុខ ឯកគ្គតា ១ ទុតិយជ្ឈាន ឈានទី ២ លះវិតក្ក វិចារ ប្រកបដោយបីតិ សុខ ឯកគ្គតា ១ តតិយជ្ឈាន ឈានទី ៣ លះបីតិ ប្រកបដោយ សុខ ឯកគ្គតា ១ ចតុត្ថជ្ឈាន ឈានទី ៤ លះសុខ ប្រកបដោយ ឯកគ្គតា ឧបេក្ខា ១ (រួមជាចរណ ១៥) ។

៤- សុគតោ ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន ។

ស- អមតមហានិព្វាន គឺអ្វី ? ចូរប្រែបាលិនេះ មកមើល!

ឆ- គឺជាឈ្មោះនៃធម៌និងកន្លែង ដែលរំលត់ភ្លើងទុក្ខ ភ្លើងកិលេសរបស់សត្វបានហើយ មិនមានការស្លាប់ មិនមានកើតទៀត ប្រែថាទីរំលត់ទុក្ខដ៏ប្រសើរឈ្មោះថា អមតមិនស្លាប់ឡើយ ។

ស- និព្វានមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

ឆ- និព្វានមាន ៣ យ៉ាងគឺ កិលេសបរិនិព្វាន រំលត់ភ្លើងកិលេសអស់ឥតសេសសល់ ១ ខន្ធបរិនិព្វាន រំលត់ភ្លើងទុក្ខក្នុងខន្ធអស់មិនមានសេសសល់ ១ ធាតុបរិនិព្វាន រំលត់ព្រះធាតុអស់ឥតមានសេសសល់ ១ ឬទឹងហៅថា ឧបាទិសេសនិព្វាន អនុប្បាទិសេសនិព្វាន សឧបាទិសេសនិព្វាន ដូចនេះវិញក៏បាន ។

ស- ព្រះអរហន្តទាំងអស់ លោកបរិនិព្វានដូចគ្នា ឬប្លែកគ្នាដែរ ?

ឆ- ព្រះអង្គបរិនិព្វាន ប្លែកពីគ្នា មាន ២ យ៉ាងគឺ ព្រះអរហន្តអង្គខ្លះ លោកបរិនិព្វាន តែកិលេសនិងខន្ធ នៅសល់ព្រះធាតុ ព្រះអរហន្តអង្គខ្លះ លោកបរិនិព្វានទាំងធាតុផង ។

ស- ចុះព្រះសម្ពុទ្ធជាម្ចាស់នៃយើងនេះ ព្រះអង្គបរិនិព្វានអ្វីខ្លះហើយ ?

ឆ- ព្រះអង្គបរិនិព្វានកិលេសនិងខន្ធអស់ហើយ នៅសល់តែព្រះបរមសារីរិកធាតុប៉ុណ្ណោះ ដែលទុកឱ្យសត្វធ្វើសក្ការៈបូជា លុះព្រះពុទ្ធសាសនាគ្រប់ ៥០០០ វស្សា នឹងបរិនិព្វានព្រះធាតុ ថែមទៀត ។

ស- ព្រះអរហន្តមានប៉ុន្មានពួក ដែលគួរដល់ការចូលព្រះនិព្វានបាន ?

ឆ- ព្រះអរហន្ត ៣ ពួកគឺ សុក្ខវិបស្សកោ ១ តេវិជ្ជោ ១ ចតុប្បដិសម្ភិទា ១ (រួមជា ៣ ពួក) ។

៩- លោកវិទូ ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រ័យលោក ។

ស- ត្រ័យលោក គឺអ្វី ? ប្រែជាសេចក្តីថា ដូចម្តេច ?

ឆ- ត្រ័យលោក គឺលោក ៣ ប្រែថា សភាវចំរើនឡើងហើយវិនាសទៅវិញ ។

ស- ចុះលោក ៣ នោះ គឺលោកអ្វីខ្លះ ? ចូររាប់គោលមកផង ?

ឆ- លោក ៣ នោះ សង្ខារលោក គឺនាមនិងរូប ១ សត្តលោក គឺពពួកសត្វលោក ១ ឱកាសលោក គឺវត្ថុដែលមិនមានវិញ្ញាណ មានតែឈ្មោះទទេៗ បានដល់អរូបធម៌ គឺ អាកាស ១ ។

ស- ចុះ ដី-ទឹក-ភ្លើង-ខ្យល់ ទាំង ៤ នេះ លោកសង្គ្រោះចូលក្នុងលោកណា ?

ឆ- ដី-ទឹក-ភ្លើង-ខ្យល់ ទាំង ៤ នេះ ហៅថា ភាជនៈលោក គឺជាភាជនៈសម្រាប់ ដាក់សត្វ ឬ ទ្រទ្រង់ទុកនូវសត្វទាំងពួង លោកសង្គ្រោះចូលក្នុងសង្ខារលោក ។

ស- ទេវតា មនុស្ស សត្វតិរច្ឆានទាំងអស់នេះ ហៅថាអ្វី ? លោករាប់សង្គ្រោះចូល ក្នុងលោកណា ?

ឆ- ទេវតា មនុស្ស សត្វតិរច្ឆានទាំងអស់នេះ ហៅថា សត្វលោក លោកសង្គ្រោះចូល ក្នុងសត្វលោក ឬ សង្ខារធម៌ ។

ស- ចុះអាកាស គឺទីវាលៗទទេនេះ រាប់សង្គ្រោះចូលក្នុងលោកណា ?

ឆ- អាកាស គឺទីវាលទទេនេះ លោកសង្គ្រោះចូលក្នុងឱកាសលោក បើនឹងហៅថា លោក ៣ គឺ ខន្ធលោក ១ ភាជនលោក ១ ឱកាសលោក ១ ដូចនេះវិញក៏បាន ។

ស- ចុះលោកចំរើនឡើងដោយអ្វី ? វិនាសទៅវិញដោយអ្វី ?

ឆ- ចំរើនឡើងដោយធាតុ ៤ វិនាសទៅវិញដោយហេតុ ៤ ដដែល ។

៦- អនុត្តរោ ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ។

ស- សីលាទិគុណ គឺអ្វី ? ប្រែថា ដូចម្ដេច ?

ឆ- គុណគឺ សីល ប្រែថា ព្រះអង្គប្រសើរដោយគុណទាំងឡាយមានសីលជាដើម ។

ស- គុណរបស់ព្រះពុទ្ធជាម្ចាស់មាន ប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

ឆ- គុណរបស់ព្រះពុទ្ធមានច្រើនយ៉ាងណាស់ តែបើបំព្រួញឱ្យខ្លីមាន ២ យ៉ាងគឺ អត្តហិតគុណ គុណជាប្រយោជន៍ដល់ព្រះអង្គ ១ បរហិតគុណ គុណជាប្រយោជន៍ដល់សត្វដទៃ ១ (រួមជា ២) គុណមាន ៣ យ៉ាងគឺ បញ្ញាគុណ គុណគឺបញ្ញាជ្រាបច្បាស់ ក្នុងកងសង្ខារ ១ ករុណាគុណ គុណគឺសេចក្ដីករុណាប្រណីដល់សព្វសត្វ ១ វិសុទ្ធិគុណ គុណគឺសេចក្ដីបរិសុទ្ធិលះកិលេសព្រមទាំងវាសនា ១ (រួមជាគុណ ៣ យ៉ាង) ។

ឯគុណមានច្រើនរាប់មិនអស់នោះ ហៅថា អនន្តគុណៗ នោះ មានសេចក្ដីប្រៀបថា ប្រសិនបើ មានមនុស្សម្នាក់ មានក្បាលនោះមួយពាន់ ហើយក្បាលមួយៗ មានមាត់មួយរយ ក្នុងមាត់មួយៗ មានអណ្ដាតនោះមួយរយ មានជីវិតវែងរស់នៅអស់មួយកប្ប ហើយអង្គុយតែ រាប់គុណរបស់ព្រះពុទ្ធ រាល់ថ្ងៃនិងយប់ កុំឈប់ឱ្យសោះ លុះទាល់តែដល់ថ្ងៃស្លាប់ក៏ពុំអស់គុណនោះឡើយ ។

ស- ចូរសង្គ្រោះគុណទាំងអស់ បញ្ចូលគ្នាឱ្យខ្លីចុះនៅត្រឹមតែ ២ មកមើល ?

ឆ- ព្រះនាមទាំង ១០ គឺ អរហំ ១ សម្មាសម្ពុទ្ធោ ១ រាប់បញ្ចូលក្នុងបញ្ញាគុណៗនេះ សង្គ្រោះចូលក្នុងអត្តហិតគុណ. វិជ្ជាចរណសម្បន្នោ ១ សុគតោ ១ លោកវិទូ ១ អនុត្តរោ ១ រាប់បញ្ចូលក្នុងវិសុទ្ធិគុណ. បុរិសទម្មសារថិ ១ សត្ថាទេវមនុស្សានំ ១ ពុទ្ធោ ១ ភគវា ១ រាប់បញ្ចូលក្នុងករុណាគុណៗ និងវិសុទ្ធិគុណ សង្គ្រោះចូលក្នុងបរហិតគុណ ។

ស- មាតាបិតាបង្កើតយើង និងព្រះពុទ្ធជាម្ចាស់ណាមានគុណច្រើនជាងណា ? ចូរឆ្លើយឱ្យមានគោលអាងមកផង!

ឆ- ព្រះពុទ្ធជាម្ចាស់ព្រះអង្គមានគុណច្រើន ជាងមាតាបិតាព្រោះព្រះអង្គ ប្រកបដោយសម្បទា ៣ យ៉ាង ។

ស- សម្បទា ៣ យ៉ាងនោះ គឺអ្វីខ្លះ ?

ឆ- សម្បទា ៣ យ៉ាងនោះគឺ ហេតុសម្បទា ព្រះអង្គបរិបូណ៌ដោយហេតុ ១ ផលសម្បទា ព្រះអង្គបរិបូណ៌ដោយផល ១ សត្តូបការសម្បទា ព្រះអង្គបរិបូណ៌ដោយឧបការលើសត្វ ១ ។

ស- ចុះហេតុសម្បទានោះ ចែកទៅមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

ឆ- ហេតុសម្បទា ដែលថាព្រះអង្គបរិបូណ៌ដោយហេតុនោះ គឺព្រះអង្គជ្រាបហេតុដើមកំណើតទុក្ខនៃសត្វលោក ថាកើតមកអំពីមានតណ្ហា ជាពូជជាតិ មានភព ៣ ជាផែនដីផ្សាំភ្ញាស់បណ្តុះដាំនូវពូជទុក្ខ ទាំងពួងទើបទ្រង់ព្រះមេត្តាអាណិតអាសូរសត្វ ចង់ចម្លងសត្វនោះ ដោយធម្មនាវា ទៅដាក់ដល់ត្រើយ គឺព្រះនិព្វាន ។ ហេតុសម្បទានេះ ចែកចេញទៅមាន ២ យ៉ាងគឺ

ក- មហាករុណាសមាយោគ ព្រះអង្គប្រកបដោយករុណាធំ ចំពោះសត្វឥតរើសមុខ ។

ខ- ពោធិសម្ភារសម្ភរណ ព្រះអង្គទ្រង់បំពេញពុទ្ធការកធម៌ ១៨ ប្រការ មានបារមី ១០ ជាដើមអស់កោដិនិងកប្បជាច្រើន ក្នុងការកសាងព្រះអង្គជាព្រះពុទ្ធ ហើយនឹងចម្លងសត្វឱ្យផុតទុក្ខ ដោយធម្មនាវាឆ្លងកាត់មហាសមុទ្រ គឺសំសារវដ្តទៅកាន់ត្រើយ គឺព្រះនិព្វាន ។

ស- ចុះផលសម្បទានោះ ចែកទៅមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

ឆ- ផលសម្បទានោះ ចែកទៅមាន ៤ យ៉ាងគឺ

ក- ញាណសម្បទា ព្រះអង្គប្រកបដោយញាណមាន មគ្គញាណ ទសពលញ្ញាណ អនាវរណញ្ញាណ ចតុវេសារជ្ជញ្ញាណ ជាដើម ។

ខ- បហានសម្បទា ព្រះអង្គបរិបូណ៌ដោយការលះកិលេស ព្រមទាំងវាសនា ។

គ- អានុភាវសម្បទា ព្រះអង្គបរិបូណ៌ដោយឥទ្ធានុភាពច្រើន ។

ឃ- រូបកាយសម្បទា ព្រះអង្គបរិបូណ៌ដោយរូបកាយ គឺប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ និងអនុព្យញ្ជនៈ ៨០ គត់ ។

ស- ចុះសត្តូបការសម្បទានោះ ចែកទៅមានប៉ុន្មាន ? គឺអ្វីខ្លះ ?

ឆ- សត្តូបការសម្បទានោះ ចែកទៅមាន ២ យ៉ាងគឺ

ក- អាសយ រង់ចាំអប់រំបន្ទំនិស្ស័យសត្វឱ្យចាស់ក្លាឡើង មិនចេះប្រកាន់ទោសសត្វឡើយ។

ខ- បយោគ ទ្រង់ប្រកបប្រយោជន៍ដល់សត្វទូទៅមានទានសីលភាវនាជាដើម ។ ដោយហេតុនេះហើយ ទើបឆ្លើយថា ព្រះពុទ្ធអង្គមានព្រះគុណធ្ងន់ច្រើនជាងមាតាបិតាយើង ។

៧- បុរិសទម្មសារថិ ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន ។

ស- បុរស ប្រែថា ដូចម្តេច ? ចែកដោយវេនេយ្យ និងបុគ្គលមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

ឆ- បុរស ប្រែថា បុគ្គលប្រុសស្រី ឬប្រែថា ទេវតា មនុស្ស ប្រុសស្រី ដែលមាននិស្ស័យ ជាពុទ្ធវេនេយ្យគួរព្រះពុទ្ធជាម្ចាស់នឹងទូន្មានបាន ។

ឯវេនេយ្យនោះ ៣ យ៉ាងគឺ ពុទ្ធវេនេយ្យ សត្វមាននិស្ស័យត្រូវព្រះពុទ្ធទូន្មានទើបបាន ១ សាវកវេនេយ្យ សត្វមាននិស្ស័យត្រូវសាវកទូន្មានទើបបាន ដូចឆន្នត្ថេរជាដើម ១ ធាតុវេនេយ្យ សត្វមាននិស្ស័យ ត្រូវព្រះបរមសារីរិកធាតុទូន្មានទើបបាន ១ (រួមជាវេនេយ្យ ៣) បុរសនេះ បើប្រែថា បុគ្គលប្រុសស្រីវិញនោះ ចែកនិស្ស័យទៅតាមបុគ្គលជាន់ខ្ពស់ទាបមាន ៤ យ៉ាងគឺ ឧគ្ឃដិតញ្ញូបុគ្គល ជាបុគ្គលជាន់ខ្ពស់បំផុត ស្តាប់ធម៌តែមួយបទ ឬ ក្នុងបាទជាបឋម និងបាទជាគំរប់ពីរ ក៏បានសំរេចមគ្គផល ១ វិបច្ចិតញ្ញូបុគ្គល ជាបុគ្គលជាន់កណ្តាលស្តាប់ធម៌ ក្នុងបាទជាគំរប់ ៣ ឬ បាទជាគំរប់ ៤ ចប់ ទើបបានសម្រេចមគ្គផល ១ នេយ្យបុគ្គល ជាបុគ្គលជាន់ទាប បន្ទាប់ថ្នាក់កណ្តាល ស្តាប់ធម៌ចប់គាថា ជាច្រើនលើកច្រើនគ្រាហើយ លុះតែចែកចេញដោយន័យផ្សេងៗ មានឧបមា ឧបមេយ្យឱ្យស្តាប់ៗហើយ ខំចំរើនធម៌តទៅទៀត ទើបបានសំរេចមគ្គផល ១ បទបរមបុគ្គល ជាបុគ្គលជាន់ទាបបំផុត ស្តាប់ធម៌ចប់ច្រើនបទបាទ-គាថា ហើយចែកដោយបទឧបមាឧបមេយ្យ យ៉ាងល្អិតឱ្យស្តាប់ៗហើយ លុះតែខំចំរើនធម៌នោះតៗទៅ ច្រើនជាតិទៅមុខទៀត ទើបបានសំរេចមគ្គផល ១ (រួមជា បុគ្គល ៤ ពួក) ។

ស- ចុះឧបនិស្ស័យនោះ មានប៉ុន្មាន គឺអ្វីខ្លះ ?

ឆ- ឧបនិស្ស័យនោះមាន ៣ យ៉ាងគឺ ទានូបនិស្ស័យ និស្ស័យកើតអំពីធ្វើទាន ១ សីលូបនិស្ស័យ និស្ស័យកើតអំពីរក្សាសីល ១ ភាវនូបនិស្ស័យ និស្ស័យកើតអំពីធ្វើភាវនា ១ (រួមជា ៣ យ៉ាង) ។

ស- ឧបនិស្ស័យទាំង ៣ យ៉ាងនេះ ជានិស្ស័យនៃសត្វធ្វើដំណើរទៅកាន់ព្រះនិព្វានដូចគ្នា ប៉ុន្តែចង់ដឹងកម្លាំងនិស្ស័យ ៣ នេះ ណាខ្លាំងជាងណា ចូរឧបមាមកមើល ?

ឆ- ឧបនិស្ស័ទាំង ៣ យ៉ាងនេះ មានកម្លាំងខុសគ្នាលោកឧបមាដូចជាសត្វ ៣ ពួក គឺ សត្វពួក១មានឆ្អឹងជាស្លាប ដូចជាភមរជាតិ មានកន្លង់ ឃ្មុំ កន្រ្ទាយរុយ ជាដើម ហើរមិនសូវបានឆ្ងាយ នេះលោកប្រៀបដូចជាកម្លាំងទានូបនិស្ស័យ សត្វ១ពួកទៀតមានស្បែកជាស្លាប

ដូចជាជ្រីង ប្រចៀវជាដើម ហើរទៅឆ្ងាយបានមធ្យម នេះលោកប្រៀបដូចជាកម្លាំងសីលូប-និស្ស័យ សត្វ១ពួកទៀតមានស្លាបជារោម ដូចជាសត្វត្មាត រនាល ត្រៀលជាដើម ហើរទៅកាន់ទីឆ្ងាយបាន ហើយមានសន្ទុះលឿនណាស់ផង នោះលោកប្រៀបដូចកម្លាំងភាវនូបនិស្ស័យ (រួមជា ៣ យ៉ាង) ។

ស- ឱ!បើដូច្នេះ យើងនាំគ្នាធ្វើតែភាវនាទៅ កុំបាច់ធ្វើទានសីលឱ្យរវល់ច្រើន តើបានព្រះនិព្វាន ឬទេ ?

ឆ- បើនឹងកាត់យកតែភាវនូបនិស្ស័យមួយដូច្នេះ តាំងពីដើមទៅមិនបានទេ ព្រោះព្រះនិព្វាន គឺបានដោយធ្វើ ទាន សីល ភាវនា ឬ បានដោយធ្វើ សីល សមាធិ បញ្ញា លុះតែនិស្ស័យធម៌ ៣ នេះ ជុំគ្នាទើបបាន ប្រៀបដូចជាជ្រោងស្មាច ឬ មុំចង្ក្រានដាំបាយ បើខ្វះតែ ១ ក៏នឹងសម្រេចប្រយោជន៍ មិនបានឡើយ ។

៨- សត្ថាទេវមនុស្សានំ ទ្រង់ព្រះនាមថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យ នៃទេវតានិងមនុស្សទាំងឡាយ ។

ស- ព្រះអង្គជាសាស្តាចារ្យ តើព្រះអង្គធ្វើជាអ្វី ?

ឆ- គឺព្រះអង្គជាគ្រូអាចារ្យ ប្រៀនប្រដៅធម៌វិន័យ ច្បាប់ពុទ្ធសាសនា ដល់ទេវតានិងមនុស្សទាំងឡាយក្នុងលោក ។

ស- ឱ!បើដូច្នេះ ព្រះអង្គជាសាស្តាចារ្យធំមែន ព្រោះបង្រៀនធម៌ទេវតាផង មនុស្សផង ហេតុនេះទេវតា និងមនុស្សទាំងអស់ សុទ្ធតែជាកូនសិស្សរៀនធម៌និងព្រះពុទ្ធទាំងអស់គ្នា ឬមានសល់ខ្លះដែរ ?

ឆ- មានសល់ខ្លះដែរ សល់ចំពោះតែសត្វដែលគ្មានឧបនិស្ស័យប្រៀបដូចជា មនុស្សធ្វើគ្រូបង្រៀន មនុស្សក្នុងលោកសព្វថ្ងៃនេះ មនុស្សខ្វាក់ភ្នែក ថ្លង់ត គំបុតដៃ ក៏ផុតនិស្ស័យ និងចូលមករៀនអក្សរ និងលោកគ្រូនោះទៅយ៉ាងណា ន័យនេះដូចគ្នា និងមនុស្សដែលសល់ក្រៅពីសិស្ស ព្រះសាស្តានោះដែរ ។

ស- ចុះអាចារ្យមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

ឆ- អាចារ្យមាន ៤ យ៉ាងគឺ បព្វជ្ជាចារ្យ លោកអ្នកឱ្យត្រៃសរណគមន៍បំបួសសិស្ស ១ និស្សយាចារ្យ លោកអ្នកឱ្យនិស្ស័យដល់សិស្ស ១ ឧបសម្បទាចារ្យ លោកអ្នកសូធ្យស្មូ

ឧបសម្បទាឱ្យសិស្ស គឺ (គ្រូសូត្រ ១) ធម្មាចារ្យ ឬ ឧទ្ទេសាចារ្យ លោកអ្នកបង្រៀនធម៌ វិន័យ ឬ លោកអ្នកបង្រៀនបាលិអដ្ឋកថា ១ (រួមត្រូវជា ៤) ។

ស- ចុះបើអាចារ្យមាន ៤ កូនសិស្ស តើមានប៉ុន្មានយ៉ាង តើអ្វីខ្លះ ?

ឆ- សិស្សមាន ៤ យ៉ាងដែរ គឺ បព្វជ្ជន្តេវាសិក សិស្សបំបួស ១ និស្សយន្តេវាសិក សិស្សសូមនិស្ស័យ ១ ឧបសម្បទន្តេវាសិក សិស្សសូធ្យ ១ ធម្មន្តេ ឬ ឧទ្ទេស្សន្តេវាសិក សិស្សបង្រៀនធម៌ ឬបាលី ១ (រួមត្រូវជា ៤) ។

៩- ពុទ្ធោ ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយ ញុំាងអ្នកដទៃឱ្យត្រាស់ដឹងផង ។

ស- ពុទ្ធោ ដែលប្រែថា ត្រាស់ដឹង តើលោកអ្នកត្រាស់ដឹងមានប៉ុន្មានពួក តើអ្វីខ្លះ ?

ឆ- លោកអ្នកត្រាស់ដឹងមាន ៣ ពួកគឺ សព្វញ្ញុពុទ្ធ លោកត្រាស់ដឹងធម៌ទាំងពួង ឥតសេសសល់ ១ បច្ចេកពុទ្ធ លោកត្រាស់ដឹងធម៌ចំពោះខ្លួន ១ អនុពុទ្ធ លោកត្រាស់ដឹង ធម៌ តាមព្រះសព្វញ្ញុពុទ្ធ ១ (រួមជា ៣ ពួក) ។

ស- អរិយសច្ច ៤ នោះ តើអ្វីខ្លះ ?

ឆ- អរិយសច្ច ៤ នោះគឺ ទុក្ខសច្ច កងទុក្ខទាំងពួង មានជាតិទុក្ខជាដើម ជារបស់ពិត នៃព្រះអរិយៈ ១ សមុទយសច្ច កងតណ្ហាទាំងពួង មានកាមតណ្ហាជាដើម ជារបស់ពិតនៃ ព្រះអរិយ ១ និរោធសច្ច ទីរលត់ភ្លើងទុក្ខ ភ្លើងកិលេស គឺព្រះនិព្វានជារបស់ពិតនៃព្រះ-អរិយ ១ មគ្គសច្ច មគ្គប្រកបដោយអង្គ ៨ ប្រការ មានសម្មាទិដ្ឋិជាដើម ជារបស់ពិតនៃ ព្រះអរិយ ១ (រួមជា ៤ ប្រការ) ។

ស- ព្រះសព្វញ្ញុពុទ្ធព្រះអង្គកសាង ប្រកបដោយធម៌ប៉ុន្មានយ៉ាង តើអ្វីខ្លះ ? ដែលជួយ ព្រះអង្គ ឱ្យបានត្រាស់ជាព្រះពុទ្ធ ?

ឆ- ព្រះអង្គប្រកបដោយពុទ្ធការកធម៌ ១៨ ប្រការគឺ *មនុស្សត្តំ* ជាតិជាមនុស្ស ១ *លិង្គសម្បត្តិ* ភេទពេញជាបុរស ១ *ហេតុ* មានឧបនិស្ស័យគួរនឹងសំរេចព្រះអរហត្តផល ១ *សត្ថារទស្សនំ* បានជួបនឹងព្រះសាស្តាចារ្យ ១ *បព្វជ្ជា* បានបួសក្នុងព្រះពុទ្ធសាសនា ឬបួសជា តាបសឥសីក្រៅព្រះពុទ្ធសាសនា ១ *គុណសម្បត្តិ* ប្រកបដោយគុណមានឈានជាដើម ១ *អធិការោ* បានធ្វើទានដ៏ឧត្តម មានមហាបរិច្ចាគ ៥ ជាដើម ១ *ឆន្ទតា* ពេញចិត្តប្រាថ្នានូវ ពោធិញ្ញាណឥតមានចិត្តរួញរា ១ ធម៌ទាំង ៨ ប្រការនេះ ឈ្មោះថា ធម្មសមោធាន អាចឱ្យ

សំរេចសេចក្ដីប្រាថ្នាក្នុងពោធិញ្ញាណបាន ផ្សំនិងបារមី ១០ ទៀតគឺ *ទាន* ការឱ្យទាន ១ *សីល* ការរក្សាសិល ១ *នេក្ខម្ម* ចេញបួស ១ *បញ្ញា* ប្រាជ្ញា ១ *វិរិយ* ព្យាយាម ១ *ខន្តិ* អត់ធន់ ១ *សច្ចៈ* ពាក្យពិត ១ *អធិដ្ឋាន* តាំងចិត្តកំណត់ទុកមាំនៅក្នុងចិត្ត ១ *មេត្តា* ផ្សាយមេត្តាចិត្តអាណិតស្រលាញ់ចំពោះសត្វទាំងអស់ទូទៅ ១ *ឧបេក្ខា* ធ្វើចិត្តស្មើក្នុងសត្វដូចជាទំនិញនិងកូនជញ្ជីងថ្លឹងស្មើៗគ្នាទូទៅ ឥតមានស្អប់ ឬស្រឡាញ់សត្វណា ១ (រួមធម្ម សមោធាន ៨ ចូលនិងបារមី ១០ ត្រូវជា ១៨) ហៅថា ពុទ្ធការកធម៌ៗ នេះ ធ្វើមនុស្សឱ្យកើតជាព្រះពុទ្ធឡើងបាន ។

ស- ចុះបារមី ១០ នេះ ចែកជាបារមី ៣០ ដូចម្ដេច ? ចូរចែកមកមើល!

ឆ- លោកយកបារមី ១០ មកចែកជា បារមី ១ ឧបបារមី ១ បរមត្ថបារមី ១ គ្រប់បារមីទាំង ១០ ក្នុងបារមីមួយៗ ចែកជាបី ។ មានទានបារមីជាដើម ដល់ទៅឧបេក្ខាខាងចុងត្រូវជា ៣០ ។

ស- ចុះបរិច្ចាគ ៥ យ៉ាង របស់បុគ្គលសាងជាព្រះពុទ្ធនោះ គឺអ្វីខ្លះ ?

ឆ- គឺបរិច្ចាគទ្រព្យ ១ បុត្តធីតា ១ ភរិយា ១ ខ្លួនឬអវយវតូចធំ ១ ជីវិត ១ (រួមជា ៥) ។

ស- ចុះចរិយារបស់ព្រះពុទ្ធ ៣ យ៉ាងនោះ គឺអ្វីខ្លះ ?

ឆ- គឺលោកត្ថចរិយា ប្រព្រឹត្តដើម្បីសត្វលោក ១ ញាតត្ថចរិយា ប្រព្រឹត្តដើម្បីញាតិ ១ ពុទ្ធត្ថចរិយា ប្រព្រឹត្តដើម្បីត្រាស់ដឹងជាព្រះពុទ្ធ ១ (រួមជា ៣) ។

ស- ព្រះសព្វញ្ញុពុទ្ធទាំងអស់អង្គផ្សេងគ្នា ឬ ដូចគ្នា បើផ្សេងគ្នា តើផ្សេងដោយហេតុអ្វី ? ដូចម្ដេចខ្លះ ? ចូរឆ្លើយឱ្យមានអាង ?

ឆ- ផ្សេងគ្នាដោយការកសាងជា ៣ យ៉ាងដូចនេះ គឺ *បញ្ញាធិកពោធិសត្វ* មានបញ្ញាច្រើនជាងសទ្ធា និងវិរិយ កសាង ៤ អសង្ខេយ្យនិង ១ សែនកប្ប ទើបបានត្រាស់ជាព្រះពុទ្ធ. *សទ្ធាធិកពោធិសត្វ* មានសទ្ធាច្រើនជាងបញ្ញា និងវិរិយ កសាង ៨ អសង្ខេយ្យនិង ១ សែនកប្ប ទើបបានត្រាស់ជាព្រះពុទ្ធ. *វិរិយាធិកពោធិសត្វ* មានព្យាយាមច្រើនជាងបញ្ញា និងសទ្ធា កសាង ១៦ អសង្ខេយ្យនិង ១ សែនកប្ប ទើបបានត្រាស់ជាព្រះពុទ្ធ ។

១០- *ភគវា* ទ្រង់ព្រះនាមថា *ភគវា* ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រ័យភពខ្ទាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

ស- ត្រ័យភព ៣ នោះ តើអ្វីខ្លះ ?

ឆ- ភព ៣ នោះគឺ កាមភព ១ រូបភព ១ អរូបភព ១ (រួមជា ៣ ) ។

ស- កាមភពនោះ ចែកចេញទៅទៀតមានប៉ុន្មាន តើអ្វីខ្លះ ?

ឆ- កាមភព គឺកន្លែងសត្វបរិភោគកាមគុណនៅនោះ មាន ១១ កន្លែង គឺអបាយភូមិ ៤ គឺ នរក ១ ប្រេត ១ តិរច្ឆាន ១ អសុរកាយ ១ (រួមជា ៤ កន្លែង) និងកាមសុគតិ ៧ គឺ មនុស្ស ១ និងឆកាមាសួគ៌ ៦ គឺ ចាតុម្មហារាជិកា ១ តាវតិង្សា ១ យាមា ១ តុសិតា ១ និម្មានរតី ១ បរនិម្មិតវសវត្តី ១ (រួមជា ៧ កន្លែង) ផ្សំអបាយភូមិ ៤ និងកាមសុគតិ ៧ ចូលគ្នា ត្រូវជាកាមភព ១១ កន្លែង ឬ ១១ ជាន់ ។

ស- ចុះរូបភពនោះ ចែកចេញទៅជាប៉ុន្មានទៀត តើអ្វីខ្លះ ?

ឆ- រូបភព គឺកន្លែងសត្វមានរូបនៅនោះ ចែកចេញជា ១៦ កន្លែងទៀត គឺ ព្រហ្មបារិសជ្ជា ១ ព្រហ្មបុរោហិតា ១ មហាព្រហ្មា ១ បរិត្តាភា ១ អប្បមាណាភា ១ អាភស្សរា ១ បរិត្តសុភា ១ អប្បមាណសុភា ១ សុភកិណ្ហកា ១ វេហប្ផលា ១ អសញ្ញីសត្តា ១ អវិហា ១ អតប្បា ១ សុទស្សា ១ សុទស្សី ១ អកនិដ្ឋកា ១ ។

ស- ចុះអរូបភពនោះមានប៉ុន្មាន តើអ្វីខ្លះ ?

ឆ- មាន ៤ គឺ អាកាសានញ្ចាយតនៈ ១ វិញ្ញាណញ្ចាយតនៈ ១ អាកិញ្ចញ្ញាយតនៈ ១ នេវសញ្ញានាសញ្ញាយតនៈ ១ (រួមជា ៤) ។៖៙

# ប្រស្នាធម្មគុណ

ស្វាក្ខាតោ ភគវតា ធម្មោ ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែងហើយដោយល្អ ។

ស- ព្រះត្រៃបិដក ប្រែថា ដូចម្ដេច ? គឺអ្វីខ្លះ ?

ឆ- ប្រែថា កញ្ជើរ ឬល្អីបី ឬក៏ភាជនៈ សម្រាប់ដាក់នូវពុទ្ធវចនៈ ៣ គឺ ព្រះវិន័យ ១ ព្រះសូត្រ ១ ព្រះអភិធម្ម ១ ។

ស- ចុះព្រះវិន័យបិដក ដែលជាភាជនៈសម្រាប់ដាក់ព្រះវិន័យៗនេះ សម្រាប់ប្រដៅអ្វី ? មានគោលបំណងដូចម្ដេច ?

ឆ- ព្រះវិន័យជាច្បាប់សម្រាប់ប្រដៅផ្លូវកាយនិងវាចា ឱ្យមានរបៀបរៀបរយល្អ ព្រោះកាយនិងវាចានេះ ជារបស់ខាងក្រៅជាគ្រឿងលោក គេមើលឃើញ គេឮបាន ដោយមានគោលបំណងឱ្យផុតពីលោក លើកទោសនិន្ទាដល់ពុទ្ធបរិស័ទ ។

ស- វិន័យនោះ មានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

ឆ- វិន័យនោះ មានគោលដើមមាន ២ យ៉ាង គឺ គិហិវិន័យ ១ បព្វជិតវិន័យ ១ ឬនិង ហៅថា អាគារិយវិន័យ ១ អនាគារិយវិន័យ ១ ដូច្នេះវិញក៏បាន ។

ស- គិហិវិន័យ ជាវិន័យសម្រាប់ពុទ្ធបរិស័ទថ្នាក់ណា ? មានប៉ុន្មានប្រការ គឺអ្វីខ្លះ ? ចូររាប់គោលៗ មកមើល!

ឆ- គិហិវិន័យ ជាច្បាប់សម្រាប់ប្រដៅពុទ្ធបរិស័ទ ថ្នាក់គ្រហស្ថអ្នកនៅគ្រប់គ្រងផ្ទះសម្បែង ភូមិរបស់ទាយកទាយិកា ឬជាឧបាសក ឧបាសិកាច្បាប់នោះ មាន ១០ ប្រការគឺ កម្មបថ ១០ រាប់ជាគោលៗ គឺកាយកម្ម ៣ វចីកម្ម ៤ មនោកម្ម ៣ (រួមជា ១០) ។

ស- បព្វជិតវិន័យ ជាវិន័យសម្រាប់ពុទ្ធបរិស័ទថ្នាក់ណា ? មានប៉ុន្មានប្រការ គឺអ្វីខ្លះ ?

ឆ- បព្វជិតវិន័យ ជាច្បាប់សម្រាប់ប្រដៅពុទ្ធបរិស័ទថ្នាក់អ្នកបួស ភូមិជាសាមណេរ ឬជាភិក្ខុ វិន័យនោះមានចំណែកផ្សេងគ្នា បើជាសាមណេរភូមិ ត្រូវកាន់តាមវិន័យសាមណេររបស់សាមណេរ មាន ៣០ គឺ សិក្ខាបទ ១០ ទណ្ឌកម្ម ១០ នាសនង្គ ១០ (រួមជា ៣០) បើជាភិក្ខុភូមិវិញ ត្រូវកាន់តាមចតុប្បារិសុទ្ធិសីល គឺ សីលបរិសុទ្ធ ៤ យ៉ាង របស់ភិក្ខុ គឺ

បាតិមោក្ខសំវរសីល ១ ឥន្ទ្រិយសំវរសីល ១ អាជីវបារិសុទ្ធិសីល ១ បច្ចយសន្និស្សិតសីល ១ (រួមជា ៤ ប្រការ) ដែលចែកចេញ ជាសិក្ខាបទមាន ២២៧ សិក្ខាបទ ។

ស- ព្រះវិន័យ បើថាឱ្យខ្លីចុះទៅតើមានប៉ុន្មាន ? បើថាឱ្យច្រើនទៅតើមានប៉ុន្មាន ? ហៅ ដូចម្ដេច ?

ឆ- ព្រះវិន័យ បើថាឱ្យខ្លីចុះ ថាតែមួយមាត់ចប់ស្រេច សព្វបាបស្ស អករណំ ការហាមឃាត់មិនឱ្យធ្វើបាប គឺអំពើអាក្រក់គ្រប់យ៉ាង ហៅថាវិន័យ បើថាឱ្យច្រើនគឺថា ដោយចែកជា ធម្មក្ខន្ធ ព្រះវិន័យមាន ២១000 ធម្មក្ខន្ធ ។

ស- ព្រះពុទ្ធសាសនាទាំង ៣ គឺ បរិយត្តិសាសនា ១ បដិបត្តិសាសនា ១ បដិវេធសាសនា ១ ឬ ហៅថា សីលសាសនា ១ សមាធិសាសនា ១ បញ្ញាសាសនា ១ ព្រះវិន័យ នឹងសង្គ្រោះរាប់បញ្ចូលក្នុងសាសនាណា ? មានការសំខាន់ដូចម្ដេច ?

ឆ- ព្រះវិន័យ សង្គ្រោះរាប់ចូលក្នុងបរិយត្តិសាសនា ឬ សីលសាសនា។ នេះ មានការសំខាន់បំផុត ព្រោះពុទ្ធសាសនាទាំង ៣ មានព្រះវិន័យជាឫសកែវយ៉ាងមាំ អាចស្រូបយកជីជាតិនិងសំណើមទឹក គឺបច្ច័យ ៤ ដែលនៅជ្រៅក្នុងដី គឺហឫទ័យនៃទាយក ជនអ្នកឱ្យដើមឈើ គឺព្រះពុទ្ធសាសនានេះរស់នៅគ្រប់ ៥000 វស្សាទៅបាន ។

ស- ចុះព្រះសុត្តន្តបិដក ដែលជាភាជនៈសម្រាប់ដាក់ព្រះសូត្រ។ នេះ សម្រាប់ប្រដៅអ្វី? មានគោលបំណងដូចម្ដេច ?

ឆ- ព្រះសូត្រនេះ ជាធម៌សម្រាប់ប្រដៅផ្លូវចិត្តឱ្យចេះធ្វើបុណ្យទាន ធ្វើកុសលផ្សេងៗ មានគោលបំណងឱ្យដោះចិត្ត ចេញពីសេចក្ដីជាប់ចិត្ត ក្នុងទ្រព្យសម្បត្តិ យស ឬ ក្នុងវត្ថុដែលខ្លួនមាន និងបញ្ចក្ខន្ធ ដើម្បីធ្វើចិត្តឱ្យស្អាតល្អ ។

ស- ចុះព្រះសូត្រនោះមានតិចច្រើនប៉ុណ្ណា ? បើថាឱ្យខ្លីចុះមកវិញ ឬថាឱ្យច្រើនឡើងទៅ ត្រូវហៅដូចម្ដេច ?

ឆ- ព្រះសូត្រនេះ បើថាឱ្យខ្លីចុះ ថាតែមួយមាត់ចប់ កុសលស្សូបសម្បទា ការញុំាង កុសលឱ្យដល់ព្រម គឺទ្រង់ប្រដៅសត្វឱ្យបំពេញបុណ្យកុសលគ្រប់យ៉ាង ហៅថា ព្រះសូត្រ បើថាឱ្យច្រើន គឺថាដោយចែកជាធម្មក្ខន្ធ ព្រះសូត្រមាន ២១000 ធម្មក្ខន្ធ ។

ស- ចុះក្នុងពុទ្ធសាសនាទាំង ៣ នោះ ព្រះសូត្រនេះរាប់បញ្ចូលក្នុងសាសនាណា ? មានគោលសំខាន់ដូចម្ដេច ?

ឆ- ព្រះសូត្រ នេះសង្គ្រោះរាប់ចូលក្នុងបដិបត្តិសាសនា ឬ សមាធិសាសនា មានការសំខាន់ជាទីបំផុត ខាងការចងក្រងទុកនូវពុទ្ធវចនៈទាំង ៣ មិនឱ្យរាត់រាយរលាយរលត់បាត់ទៅបាន មិនឱ្យច្រឡំគ្នាបាន ប្រៀបបីដូចជាខ្សែសូត្រ ឬ អម្បោះរបស់នាយមាលាការ ដែលចងក្រងផ្កាឈើមានពណ៌ផ្សេងៗ គាត់តែងជារូបសត្វនោះ ឱ្យជាប់នៅយូរបានមិនឱ្យរបូតជ្រុះបាត់ ឬ រាត់រាយឡើយ ។

ស- ព្រះអភិធម្មបិដក ដែលជាភាជនៈសម្រាប់ដាក់ព្រះអភិធម្មៗ នេះ សម្រាប់ប្រដៅអ្វី ? មានគោលបំណងដូចម្តេច ?

ឆ- ព្រះអភិធម្មនេះ ជាធម៌សម្រាប់ប្រដៅផ្លូវចិត្ត ឱ្យបរិសុទ្ធស្អាតផូរផង់មានគោលបំណង ទីបំបែកចិត្តពីបញ្ចក្ខន្ធ ឱ្យចូលទៅកាន់ព្រះនិព្វាន ។

ស- ចុះព្រះអភិធម្មនោះ មានតិចច្រើនប៉ុណ្ណា ? បើថាឱ្យខ្លីចុះមកវិញ ឬថាឱ្យច្រើនទៅត្រូវហៅដូចម្តេច ?

ឆ- ព្រះអភិធម្មនេះ បើថាឱ្យខ្លីចុះ ថាតែមួយមាត់ចប់ គឺ *សចិត្តបរិយោទបនំ* ការញុំាង ចិត្តឱ្យស្អាតផូរផង់ ហៅថា ព្រះអភិធម្ម ចិរត្ត បសន្នេ សុគតិ បាដិគន្ខា កាលបើចិត្តស្អាតផូរផង់ហើយ ប្រាកដជាបានទៅកាន់សុគតិស្ថាន បើថាឱ្យច្រើននោះ គឺថាដោយចែកជាធម្មក្ខន្ធ ព្រះអភិធម្មមាន ៤២០០០ ធម្មក្ខន្ធ ។

ស- ចុះក្នុងពុទ្ធសាសនាទាំង ៣ នោះ ព្រះអភិធម្មនេះរាប់បញ្ចូលក្នុងសាសនាណា ? មានគោលសំខាន់ដូចម្តេច ?

ឆ- ព្រះអភិធម្មនេះ សង្គ្រោះរាប់ចូលក្នុងបដិវេធសាសនា ឬ បញ្ញាសាសនា មានការសំខាន់បំផុត ខាងលាងសំអាតចិត្ត ដោះចិត្តដែលជាប់ជំពាក់ក្នុងកាមារម្មណ៍ មានរូបជាដើម ឬក្នុងភព ៣ មានកាមភពជាដើម ឬក៏ជាប់ជំពាក់ចិត្តក្នុងលោកនានា មានខន្ធាទិលោកជាដើម ឱ្យស្អាតផូរផង់បាន ដោយបញ្ញាជាកាំបិតកាត់ខ្សែចំណងនៃចិត្ត ឬ បញ្ញាជាអាវុធកាប់ឆ្ការព្រៃស្តុក គឺកិលេសហើយដុតឱ្យឆេះ ដោយភ្លើង គឺតបៈ សេចក្តីព្យាយាមមាំ ឬ នឹងលាងចិត្តដែលប្រឡាក់នោះ ដោយទឹកថ្លា គឺសីល ដុះចិត្តដោយដុំសាប៊ូ គឺគួបញ្ញា ឬ វិចារណញ្ញាណ ឱ្យជាចិត្តស្អាតផូរផង់បាន ហើយផ្ទុកចិត្តនោះ ពេញទៅដោយមគ្គផលព្រះនិព្វាន ។

ធម្មោ ព្រះនព្វលោកុត្តរធម៌ទាំង ៩ ប្រការគឺ មគ្គ ៤ ផល ៤ និព្វាន ១ ។

ស- ហេតុអ្វីបានជាធម៌ទាំង ៩ ប្រការ ហៅថា ព្រះនព្វលោកុត្តរធម៌ ?

ឆ- ព្រោះធម៌ទាំង ៩ ប្រការ មានសោតាបត្តិមគ្គជាដើមនោះ ជាធម៌សម្រាប់ចំឡងសត្វនាំសត្វ ឱ្យឆ្លងផុតពីលោកទាំង ៣ ប្រការ មានកាមលោកជាដើម ។

ស- មគ្គ ៤ ផល ៤ និព្វាន ១ នោះ គឺអ្វីខ្លះ ? ចូររាប់មកមើល ?

ឆ- មគ្គ ៤ នោះគឺ សោតាបត្តិមគ្គ ១ សកទាគាមិមគ្គ ១ អនាគាមិមគ្គ ១ អរហត្តមគ្គ ១ ឯផល ៤ នោះគឺ សោតាបត្តិផល ១ សកទាគាមិផល ១ អនាគាមិផល ១ អរហត្តផល ១ និងនិព្វាន ១ បូកផ្សំគ្នាត្រូវជា ៩ ប្រការ ។

សន្ទិដ្ឋិកោ ជាធម៌ គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញពិត ដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹង ដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗ ក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង។

ស- ព្រះអរិយបុគ្គលមានប៉ុន្មានពួក គឺអ្វីខ្លះ ? ចូររាប់មកមើល ?

ឆ- ព្រះអរិយបុគ្គលមាន ២ ពួកគឺ លោកដែលបានសម្រេចមគ្គ ៤ ជាពួក ១ លោកដែលបានសម្រេចផល ៤ ជាពួក ១ បើរាប់រាយមាន ៨ គឺ រាប់តាមមគ្គផល ដែលលោកបានសំរេច ។

អកាលិកោ ជាធម៌ឱ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផល ក៏កើតក្នុងលំដាប់គ្នា មិនបានឃឹតយូរឡើយ ។

ស- ជាធម៌ឱ្យនូវផលមិនរង់ចាំកាល តើឱ្យដូចម្តេច ? ព្រះអរិយមគ្គនិងព្រះអរិយផល កើតក្នុងលំដាប់គ្នា នោះកើតដូចម្តេច ? ចូរឆ្លើយជាសេចក្តីឧបមាមកមើល ?

ឆ- មិនរង់ចាំកាលដូចជាពាក្យថា មើលឃើញជាដើម ក្នុងលំដាប់គ្នា ដូចពាក្យថា ផ្កា ផ្លែ រៀន ចេះជាដើម ឬដូចពាក្យថា កើត ចាស់ ឈឺ ស្លាប់ គឺជាពាក្យប្រាប់ថា ផលកើតតាមលំដាប់មគ្គ គឺសោតាបត្តិផល កើតទៅពីសោតាបត្តិមគ្គ ដូចជាផ្លែឈើណាកើតទៅពីផ្កាឈើនោះ។ តាមធម្មតាជវនចិត្តមាន៧ខណៈ មគ្គចិត្តកើតក្នុងខណៈទី៤, ផលចិត្តកើតក្នុងខណៈទី៥ ទី៦ និងទី៧, បើមគ្គចិត្តកើតក្នុងខណៈទី៥, ផលចិត្តកើតក្នុងខណៈទី៦ និងទី៧, ហើយចុះកាន់ភវង្គៈវិញ ។

ឯហិបស្សិកោ ជាធម៌គួរដល់ឯហិបស្សវិធី គឺថាព្រះអរិយបុគ្គល ដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃ ឱ្យចូលមកមើលបាន ។

ស- ឯហិបស្សវិធី ដូចម្តេច ? ហៅបុគ្គលដទៃ ឱ្យចូលមកមើលបាននោះ តើមើលដូចម្តេច ? ចូរឧបមាមកមើល ?

ឆ- ឯហិបស្សវិធី គឺវិធី ហៅអ្នកដទៃថា អ្នកចូលមក១, ឱ្យមើលបាននោះ គឺបង្ហាញរបស់ដែលខ្លួនមាន ឬខ្លួនទើបនឹងរកបាននោះ ឱ្យអ្នកដទៃឃើញ ប្រៀបដូចជាអ្នកមានកូនហៅ គេមកមើល ឬអ្នកទើបនឹងបានគ្រឿងប្រដាប់ថ្មីមានមាសប្រាក់ជាដើម ហៅគេឱ្យមើលឯលោកអ្នកបានឈានហើយ ក៏អាចសំដែងឫទ្ធិបង្ហាញឱ្យគេឃើញបាន ដូចចុល្លបន្ថកត្ថេរសំដែងឫទ្ធិនិមិត្តខ្លួនលោកតែ ១ ឱ្យទៅជារូបព្រះសង្ឃ មានរាប់ពាន់គង់ក្នុងវិហារ ឬក៏ដូចជាមហានាគត្ថេរ សំដែងសមាធិជារូបដីយ៉ាងធំមួយ ឱ្យធម្មទិន្នត្ថេរ មើលដីនោះ ចេះទាំងស្រែកទាំងបោលផងបាន ។៧។

ឱបនយិកោ ជាធម៌គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា ។

ស- បង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនានោះ គឺបង្អោនដូចម្តេច ?

ឆ- គឺលោកខំភាវនាចំរើនធម៌ណា ដែលមិនទាន់កើតឱ្យកើតឡើងក្នុងខ្លួនលោក បើមគ្គធម៌ណា ឬ ផលធម៌ណា កើតមានហើយ ក៏រក្សាធម៌នោះ ទុកដោយភាវនា ។

បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ ក្នុងចិត្តនៃខ្លួន ។

ស- បច្ចត្តំអត្ថធម៌នេះ សំដៅយកតែមគ្គ ៤ និងផល ៤ ប៉ុណ្ណោះទេ ឬអ្វី ?

ឆ- ធម៌នេះក្រៅពីមគ្គ ៤ ផល ៤ ទៀត មានច្រើនប្រការដែរ ដូចពាក្យថា អ្នកណារៀនអ្នកនោះចេះ អ្នកណារក្សាសីល អ្នកនោះបានសុខចំរើន ចំពោះខ្លួនម្នាក់១ រកអ្នកដទៃជួយមិនបានឡើយ ។៩។

# ប្រស្នាសង្ឃគុណ

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ ។

ស- សាវ័កព្រះពុទ្ធជាម្ចាស់មានប៉ុន្មានពួក ? គឺអ្វីខ្លះ ?

ឆ- មាន ២ ពួកគឺ បុថុជ្ជនសាវ័ក ១ អរិយសាវ័ក ១ ។

ស- ពុទ្ធសាវ័កទាំងពីរពួកនេះ ផ្សេងគ្នាដោយន័យ ដូចម្ដេច ?

ឆ- ផ្សេងគ្នាដូចនេះ បុថុជ្ជនសាវ័ក ឬ បោថុជ្ជនសាវ័កនោះ គឺបុគ្គលអ្នកស្ដាប់តាមជឿតាម ធ្វើតាមព្រះពុទ្ធដីកាដែរ ប៉ុន្តែមានសន្តានចិត្តជាបុថុជ្ជននៅឡើយ ទាន សីល ភាវនាធ្វើហើយតែមិនទាន់ទទួលមគ្គផល ឯអរិយសាវ័ក ក្នុងទីនេះសំដៅបុគ្គល ដែលបានទទួលមគ្គផលឯណានីមួយ មានសោតាបត្តិមគ្គជាដើមរួចហើយ ហៅថា អរិយសាវ័ក ។

ស- ចុះគន្លងព្រះនព្វលោកុត្តរធម៌ គឺអ្វីខ្លះ ? បានសេចក្ដីថា ដូចម្ដេច ?

ឆ- គឺមគ្គប្រកបដោយអង្គ ៨ ឬធម៌ ៩ ប្រការ មានសោតាបត្តិមគ្គជាដើម ដែលញ៉ាំងសត្វឱ្យឆ្លងផុតចាកលោកទាំង៣ មានកាមលោកជាដើម ដែលជាផ្លូវដើរទៅកាន់ព្រះនិព្វាន ។

ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមបដិបទា ។

ស- ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ មានប៉ុន្មានពួក គឺអ្វីខ្លះ ?

ឆ- មាន ២ ពួកគឺ សម្មតិសង្ឃ ១ ពួក, ព្រះអរិយសង្ឃ ១ ពួក ។

ស- មជ្ឈិមបដិបទា ដែលជាផ្លូវត្រង់ផ្លូវកណ្ដាលនោះ គឺផ្លូវណា ?

ឆ- គឺ សីល សមាធិ បញ្ញា ដែលមានរាប់ឈ្មោះរាយទុកក្នុងមគ្គប្រកបដោយអង្គ ៨ ប្រការ មានសម្មាទិដ្ឋិមគ្គជាដើម ។

ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ថានក្សេមផុតចាកទុក្ខទាំងពួង ។

ស- លោកប្រតិបត្តិដូចម្ដេច ? ឈ្មោះថា ប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ?

ឆ- លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវសម្មាបដិបទា ដែលជាផ្លូវប្រតិបត្តិសំរាប់ដឹងច្បាស់

ចាក់ធុះនូវព្រះនិព្វាន ដែលជាកន្លែងគម្រាយរបស់ព្រះអរិយជាម្ចាស់ទាំងឡាយ លោកតែងយាត្រាទៅកាន់ព្រះនិព្វានយ៉ាងនេះ ទើបឈ្មោះថា ញាយបដិបន្នោ ។

ម្យ៉ាងទៀត លោកប្រតិបត្តិដើម្បីចេញចាកសង្សារវដ្ដ មិនប្រតិបត្តិដើម្បីលាភ និងយស និង សេចក្ដីសរសើរ ក្នុងបច្ចុប្បន្ន ឬ ដើម្បីស្ថានសួគ៌ឡើយ ។

សាមីចិបដិន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់ សីល សមាធិ បញ្ញា ។

ស- លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម តើប្រតិបត្តិដូចម្ដេច ?

ឆ- លោកប្រតិបត្តិត្រឹមត្រូវត្រង់តាមផ្លូវ សីល សមាធិ បញ្ញា គឺលោកមានការកោតក្រែងខ្លាចអំពើខុសជានិច្ច មិនកន្លងពុទ្ធប្បញ្ញត្តិឡើយ។

ស- ព្រះសង្ឃទាំងនោះ បើរាប់ជាគូ តើមានប៉ុន្មានគូ គឺអ្វីខ្លះ ?

ឆ- យទិទំ ចត្តារិ បុរិសយុគានិ ព្រះសង្ឃទាំងនោះ បើរាប់ជាគូនៃបុរសទាំងឡាយ មាន ៤ គូ គឺ ព្រះសង្ឃដែលមានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ ១ សកទាគាមិមគ្គ និងសកទាគាមិផលជាគូ ១ អនាគាមិមគ្គ និងអនាគាមិផលជាគូ ១ អរហត្តមគ្គ និងអរហត្តផលជាគូ ១ (រួមជា ៤ គូ) ។

ស- ចុះបើរាប់រៀងជាបុរសបុគ្គលទៅវិញ តើមានប៉ុន្មាន គឺអ្វីខ្លះ ?

ឆ- អដ្ឋបុរិសបុគ្គលា បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺ ព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១ (រួមជា ៨) ។

ឯស ភគវតោ សាវកសង្ឃោ ព្រះសង្ឃទាំងនោះជាសង្ឃសាវ័ក នៃព្រះដ៏មានព្រះភាគ អាហុនេយ្យោ លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា ។

ស- ចតុប្បច្ច័យ ប្រែថា ដូចម្ដេច ? គឺអ្វីខ្លះ ?

ឆ- វត្ថុជាគ្រឿងអាស្រ័យ ៤ យ៉ាង របស់បព្វជិតគឺ ចីវរប្បច្ច័យ គ្រឿងស្លៀកដណ្ដប់ ១ បិណ្ឌបាតប្បច្ច័យ គ្រឿងបរិភោគ ១ សេនាសនប្បច្ច័យ គ្រឿងដេកអង្គុយ ១ គិលានប្បច្ច័យ គ្រឿងភេសជ្ជៈ ជាថ្នាំការពាររោគ ១ ។

បាហុនេយ្យោ លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលគាត់តែងដើម្បីញាតិ និងមិត្ត ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា ។

ស- អាគន្តុកទាន គឺអ្វី ?

ឆ- គឺទានដែលបុគ្គលរៀបប្រគេនភិក្ខុ ដែលទើបនឹងមកដល់ថ្មី ។

ស- បូជា ប្រែថា ដូចម្ដេច ? បើចែកទៅទៀត មានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

ឆ- បូជា ប្រែថា ថ្វាយ ប្រគេន ជូន ឱ្យ បើចែកដោយប្រភេទ នៃការបូជាផ្សេងគ្នា មាន ៤ យ៉ាង គឺ សក្ការៈ ការតាក់តែងវត្ថុផ្សេងៗ មានផ្កាជាដើម ១ គរុការៈ ការគោរពដោយកាយវាចាចិត្ត ១ មានៈ ការរាប់អានស្រឡាញ់ស្មោះចំពោះ ហ៊ានលះរបស់ឱ្យ ១ វណ្ណនា ការពណ៌នា គឺពោលសរសើរគុណ ១ (រួមជា ៤)។ បើចែកដោយប្រភេទនៃបុគ្គលគួរបូជាវិញ មានច្រើនប្រការ មានព្រះសព្វញ្ញុពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសង្ឃជាសាវ័កនៃព្រះពុទ្ធ មាតាបិតា គ្រូអាចារ្យជាដើម ។

ទក្ខិណេយ្យោ លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយបូជា ។

ស- ដូចម្ដេចដែលហៅថាកម្ម ? កម្មនិងផលនៃកម្មប្លែកគ្នា ដូចម្ដេច ?

ឆ- អំពើដែលបុគ្គលធ្វើដោយកាយវាចាចិត្ត ទោះបីអាក្រក់ក្ដី ល្អក្ដី ហៅថាកម្ម សេចក្ដីទុក្ខ ឬសុខ ដែលកើតអំពីកម្មនោះៗ មានប្រាកដឡើងដល់រូបបុគ្គលអ្នកធ្វើ ហៅថាផល ។

ស- បើចែកទៅមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

ឆ- កម្មបើចែកឱ្យខ្លីមានតែ ២ យ៉ាង គឺ បុញ្ញកម្ម ១ បាបកម្ម ១ ឬហៅថា កុសលកម្ម ១ អកុសលកម្ម ១ ដូច្នេះវិញក៏បាន អំពើល្អដែលជាហេតុនាំសត្វឱ្យបានសុខចំរើន ហៅថា កុសលកម្ម អំពើអាក្រក់ដែលជាហេតុនាំសត្វឱ្យបានទុក្ខវិនាស ហៅថាអកុសលកម្ម ។

អញ្ជលិករណីយោ លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ ។

ស- លោកណាខ្លះ ដែលគួរដល់អញ្ជលិកម្ម អញ្ជលិកម្ម ប្រែថា ដូចម្ដេច ?

ឆ- លោកដែលបានរាប់ឈ្មោះ មកខាងដើមរួចមកហើយ ដែលហៅថាសម្មតិសង្ឃក្ដី អរិយសង្ឃក្ដីនោះ ទោះបីលោកបានសម្រេចមគ្គផលហើយក្ដី លោកមានសន្ទានចិត្តជាបុថុជ្ជននៅឡើយក្ដី ក៏គួរធ្វើអញ្ជលិកម្ម ដែលប្រែថា ថ្វាយបង្គំដល់លោកនោះៗដែរ ។

ស- ការធ្វើអញ្ជលិកម្មមានប្រយោជន៍ ដូចម្ដេចខ្លះ ដល់លោកទាំងនោះ ហើយមានប្រយោជន៍អ្វីខ្លះ ដល់អ្នកធ្វើអញ្ជលិកម្ម ?

ឆ- ការធ្វើអញ្ជលិកម្មនោះ មានប្រយោជន៍យ៉ាងសំខាន់ ដល់លោកដោយបង្ហាញទឹកចិត្តស្មោះត្រង់ ដែលខ្លួនកោតខ្លាចគោរពរាប់អានបូជាលោក១ ក៏អាចប្រាស្រ័យនឹងខ្លួនបាន ឯខ្លួនអ្នកធ្វើអញ្ជលិកម្មនោះ ក៏នឹងមានប្រយោជន៍ដោយបុញ្ញកិរិយាវត្ថុផ្សេង១ ទាំងបានសេចក្ដីសុខចំរើនក្នុងជាតិនេះ និងជាតិខាងមុខផង ។

អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

ស- បុញ្ញក្ខេត្ត ប្រែថា ដូចម្ដេច ? មានសេចក្ដីប្រៀបធៀបយ៉ាងណា ?

ឆ- បុញ្ញក្ខេត្ត ប្រែថា ស្រែបុណ្យមានសេចក្ដីប្រៀបធៀបនឹងស្រែស្រូវ ហៅថា សាលិខេត្ត ឬ ធញ្ញខេត្ត ស្រូវក្នុងស្រែនោះ ដែលដុះល្អទៅបានអាស្រ័យនឹងស្រែមានដីជាតិល្អ មានភ្លឺជិតទឹកដក់នៅមិនធ្លុះធ្លាយយ៉ាងណា ឯបុញ្ញខេត្ត គឺស្រែបុណ្យក៏ដូចគ្នាដែរ គឺព្រះសង្ឃទុកជាស្រែ បច្ច័យ៤ ទុកជាពូជស្រូវ ចតុប្បារិសុទ្ធិសីល ទុកជាដីដីជាតិនិងសំណើមទឹកយ៉ាងនោះដែរ ឯអ្នកស្រែធ្វើស្រូវក្នុងស្រែល្អបានផល ផ្លែស្រូវច្រើនយ៉ាងណា ខាងទាយកអ្នកឱ្យទានក្នុងស្រែ គឺសង្ឃប្រតិបត្តិត្រឹមត្រូវល្អមានសីលបរិសុទ្ធ ក៏បានផលបុណ្យច្រើនយ៉ាងនោះដែរ ។

ស- ព្រះសង្ឃលោកមានគុណប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

ឆ- ព្រះសង្ឃលោកមានគុណ ២ យ៉ាង គឺអត្តហិតគុណ ១ បរហិតគុណ ១ ។

ស- អត្តហិតគុណ ប្រែថា ដូចម្ដេច ? ចែកជាប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

ឆ- អត្តហិតគុណ ប្រែថា គុណជាប្រយោជន៍ខ្លួនលោក ចែកជា ៤ យ៉ាង គឺ សុបដិបន្នោ លោកប្រតិបត្តិល្អ ១ ឧជុបដិបន្នោ លោកប្រតិបត្តិត្រង់ ១ ញាយបដិបន្នោ លោកប្រតិបត្តិដើម្បីត្រាស់ដឹង ១ សាមីចិបដិបន្នោ លោកប្រតិបត្តិត្រឹមត្រូវតាមផ្លូវ សីល សមាធិ បញ្ញា ១ (រួមជា ៤) ។

ស- ចុះបរហិតគុណនោះ ប្រែថា ដូចម្ដេច ? ចែកទៅមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

ឆ- បរហិតគុណនេះ ប្រែថា គុណជាប្រយោជន៍ដល់អ្នកដទៃ ចែកទៅមាន ៤ យ៉ាង គឺ អាហុនេយ្យោ លោកគួរទទួលចតុប្បច្ច័យដែលគេបូជា ១ បាហុនេយ្យោ លោកគួរទទួលអាគន្តុកទាន ដែលគេរៀបដើម្បីភ្ញៀវមកថ្មីហើយបូជា ១ ទក្ខិណេយ្យោ លោកគួរទទួលទានដែលបុគ្គលជឿនូវកម្ម និងផលនៃកម្មហើយបូជា ១ អញ្ជលិករណីយោ លោកគួរទទួលអញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ ១ (រួមជា ៤) ។

ស- ចុះបាលីថា នត្ថិ មេ ទាំង ៣ បទ ដែលពុទ្ធបរិស័ទសូត្រ សូមយកព្រះត្រ័យរតន៍ជាទីពឹងនោះ តើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជ្រាបបានទឹងជួយធ្វើជាពឹងបាន ដូចពាក្យសច្ចកិរិយាទេ សូមសិរីសួស្តីជ័យមង្គល នោះមែនឬទេ ?

ឆ- ឱ! ពាក្យសួរនេះ ពិបាកឆ្លើយ ព្រោះព្រះពុទ្ធបរិនិព្វានបាត់ទៅហើយ ព្រះធម៌គ្មានរូបរាងកាយដៃជើង នឹងបានជួយ បើសង្ឃឹមផ្តេកចិត្តទៅលើព្រះពុទ្ធរូបសព្វថ្ងៃ ជាដុំថ្មមិនចេះនិយាយស្តីថាអ្វី ព្រះធម៌ដែលនៅក្នុងស្លឹករឹត ឬសៀវភៅ គ្រាន់តែជាស្នាមគំនូសតួអក្សរកត់ត្រាពុទ្ធវចនៈទុក សង្ឃឹមទៅលើព្រះសង្ឃ ក៏ជាមនុស្សកូនចៅអ្នកស្រុក មានព្រះសង្ឃខ្លះលោកមិនចេះទាំងប្រែបាលី "នត្ថិ មេ" នោះថាដូចម្តេចផង យ៉ាងនេះគួរឆ្ងល់ណាស់ដែរ ប៉ុន្តែចូរប្រយ័ត្នកុំឱ្យជ្រុលគំនិតហួស ក្រែងជ្រលួសទៅលើផ្លូវខុស នឹងក្លាយទៅជាមនុស្សមិច្ឆាទិដ្ឋិ អ្នកស្លាប់គំនិតត្រូវប្រយ័ត្ន ដូចពាក្យបរម្បរាថា "ថ្វាយបង្គំព្រះពុទ្ធ ប្រយ័ត្នប៉ះលើដុំថ្ម ថ្វាយបង្គំព្រះធម៌ ប្រយ័ត្នប៉ះលើស្លឹករឹត ថ្វាយបង្គំព្រះសង្ឃ មិនជាគិតប្រយ័ត្នប៉ះលើកូនអ្នកស្រុក" ពាក្យនេះ ពោលទុកបញ្ជាក់គំនិត ឱ្យចេះរកគុណព្រះរតនត្រ័យ កុំឱ្យទើសចិត្តនៅត្រឹមដុំថ្ម ស្លឹករឹតតែប៉ុណ្ណោះ ឯអ្នកមានគំនិតល្អនោះត្រូវយល់ថា ត្រៃសរណគមន៍ គឺព្រះរតនត្រ័យ១ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ គឺសភាពដែលពិត ដែលមានប្រាកដដល់ចិត្តអ្នកធ្វើទីពឹង១ លើសភាពដែលពិតនោះ ក៏នឹងបានប្រាដកដូចបំណង ព្រោះតែចិត្តខ្លួនពិតផង កុំថាឡើយត្រឹមសិរីសួស្តីជ័យមង្គលប៉ុណ្ណោះ សូម្បីសុខក្នុងស្ថានសួគ៌និព្វាន ដែលមានតំលៃកាត់មិនបាន អ្នកធ្វើកម្មដ្ឋាន គេយកព្រះរតនត្រ័យ មានព្រះពុទ្ធជាដើមជាទីពឹង មកធ្វើជាមូលកម្មដ្ឋាន ។ នោះក៏ជួយគេឱ្យបានសម្រេចមគ្គផល ដល់ព្រះនិព្វានដូចប្រាថ្នា ហេតុនេះ ក៏សូមឆ្លើយខ្លីថា នឹងបាន ឬ មិនបានដូចបំណង ក៏មកតែពីអ្នកធ្វើពិត និងមិនពិតតែប៉ុណ្ណោះឯង (ឈ) ។

ស- ចុះបាលីថា ឧត្តមង្គេន ទាំង ៣ បទ ដែលពុទ្ធបរិស័ទ សូត្រសូមខមាទោសនិងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ នឹងជ្រាបបាន នឹងអត់ទោសឱ្យគេបាន ដូចគេសូមខមាទោសនោះ ឬទេ ? មែន ឬអ្វី ?

ឆ- សេចក្តីនេះ ដូចគ្នានឹង "នត្ថិ មេ" មិនប្លែកគ្នាប៉ុន្មានទេ ប៉ុន្តែត្រូវដឹងថា ទោសមានច្រើនប្រការ គឺលោកវជ្ជទោស ឬវដ្តទោស ទោសមានជាធម្មតាលោក ឬទោសដែលសម្រាប់វដ្ត ដូចកើតចាស់ឈឺស្លាប់ជាដើមនេះ មិនមែនសូមព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាដើមនោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ អត់ទោសឱ្យមិនបានទេ បើជាបណ្ណត្តិវជ្ជទោស ជាទោសកើតឡើងព្រោះព្រះអង្គ បញ្ញត្តិដូចតុះតិះដៀល ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាដើមនោះ ទើបព្រះពុទ្ធព្រះធម៌ ព្រះសង្ឃ អត់ទោសឱ្យបាន ដោយខ្លួនប្រកាសទោស គឺសូមខមាទោសនោះឯង ។

ស- ចុះអត់ម្ដេចកើត បើព្រះពុទ្ធចូលនិព្វានបាត់ទៅហើយ នៅតែព្រះពុទ្ធរូប ថ្ម សំណាស្ពាន់ មាស ប្រាក់ ។ល។ ដូចសព្វថ្ងៃនេះ ព្រះធម៌នៅតែសូរសំលេង ឮដោយសារលោកសូធ្យប៉ុណ្ណោះ គ្មានរូបសោះ ព្រះសង្ឃទៀតសោត ក៏មិនដឹងជាខ្លួនមានទោសខុស នឹងព្រះសង្ឃអង្គណា ?

ឆ- មានរឿងបញ្ជាក់នេះ ពន្យល់ក្នុងគម្ពីរសារត្ថសង្គហថា បើបុគ្គលណាមានទោសកំហុសនិងព្រះអរិយបុគ្គល អង្គណាមានព្រះពុទ្ធជាដើមក្ដី ខុសនិងមាតាបិតា គ្រូអាចារ្យខ្លួនក្ដី ហើយដឹងខ្លួនថា ខ្លួនខុសមានទោសហើយ ត្រូវឱ្យបុគ្គលនោះ សូមខមាទោសទើបរួចចាកទោសបាន ថាបើលោកនេះដើរទៅបាត់ក្ដី ចូលនិព្វានក្ដី ឬនិព្វានធាតុទៅក្ដី ទទួលអនិច្ចកម្ម ឬអនិច្ចធម្មទៅហើយក្ដី ត្រូវឱ្យនិមន្តសង្ឃដទៃ បាន ៤ អង្គ មកប្រកាសខមាទោស តាមទោសដែលខ្លួនខុស និងព្រះអរិយបុគ្គលអង្គនោះ ពុំនោះសោតទេ ឱ្យខមាទោសនិងអដ្ឋិធាតុ របស់លោក ឬជើងថ្ករ គឺកន្លែងបូជាសពនោះ ទើបរួចចាកទោសបាន នេះសេចក្ដីឱ្យឃើញថា ប្រាកដជាអត់បាន ទើបអ្នកប្រាជ្ញបុរាណលោកសំដែងបាលី នត្ថិ មេ និងឧត្ដមង្គេន តាំងទុកមកសម្រាប់សូមទីពឹង និងសូមខមាទោសដូច្នេះឯង យូរណាស់មកហើយ ។

## ប្រស្នាបត្តិទាន និង បត្តានុមោទន

ស- ខ្ញុំឆ្ងល់ពីចែកបុណ្យគ្នាពន់ពេក បានជាខ្ញុំមិនចង់ធ្វើបុណ្យក្រែងមិនបាននោះមានរូបដូចផ្លែឈើ ឬមានរូបដូចមាសប្រាក់ជាដើមក៏ខ្ញុំមិនឆ្ងល់ដែរ ។ ក្នុងព្រះពុទ្ធសាសនាមានច្បាប់ថា អ្នកធ្វើទានបើបានចែកបុណ្យឱ្យគេ ក៏នឹងបានផលបុណ្យថែមរឹតតែច្រើនឡើងៗ ជាទ្វេគុណ ក្នុង "បត្តិទាន" ឯក្នុង "បត្តានុមោទនៈ" ក៏មានច្បាប់ថា អ្នកទទួលអនុមោទនាត្រេកអរតាមទានគេនោះ ក៏នឹងបានទទួលផលបុណ្យ ដោយទទេឥតថ្លៃនោះផងដែរ តើនឹងបានបុណ្យរំលែកចែកគ្នាដូចម្ដេចកើត បើបុណ្យនោះគ្មានរូបសោះ គ្រាន់តែជានាមធម៌ប៉ុណ្ណោះ សូមលោកអ្នកប្រាជ្ញសង្គ្រោះកែខែឧបមាឧបមេយ្យសេចក្ដីនេះ ឱ្យខ្ញុំជាអ្នកល្ងង់ខ្លៅស្ដាប់បាន ខ្ញុំក៏នឹងសុខចិត្តយល់ព្រមធ្វើបុណ្យទាន និងគេផងមើល ?

ឆ- ខ្ញុំក៏មិនជាអ្នកប្រាជ្ញធំដុំដែរ ប៉ុន្តែអត់ទ្រាំឆ្លើយតបនិងសេចក្ដី ឆ្ងល់របស់អ្នកសួរនេះពុំបាន ក៏ឆ្លើយទៅ មុននឹងឆ្លើយបញ្ហានេះ ខ្ញុំសូមសួរបន្តិច អ្នកឯងដែលធ្វើបុណ្យដែរទេ ?

ស- ទេ ខ្ញុំមិនដែលធ្វើបុណ្យទានអ្វីទេ ?

ឆ- បើដូច្នេះអ្នកឯងដែលឃើញគេរៀនអក្សរដែរទេ ?

ស- ខ្ញុំដែលឃើញដែរ

ឆ- អើបើដូច្នេះ អ្នកចូលពិនិត្យពិចារណាអក្សរ ដែលសិស្សចេះតទៅពីគ្រូនោះ មើលកាលចំណេះអក្សរ និងលេខជាដើម ឆ្លងតាមខ្សែវិញ្ញាណទៅនឹងសិស្សនៅត្រង់ណា ? មើលឃើញ ឬទេ ?

ស- មើលមិនឃើញ ?

ឆ- អើបើដូច្នោះ ចូរអ្នកឯងចាំស្ដាប់ខ្ញុំនឹងពន្យល់ប្រាប់ ។

ស- បាទ

ឆ- បុណ្យនេះជានាមធម៌គ្មានរូបក៏ពិតមែន ប៉ុន្តែកើតមកពីវត្ថុទានដែលមានរូប ហេតុនោះ គេអាចដឹងបាន អាចកំណត់ទំហំបុណ្យបាន អាចចែកចំណែកបុណ្យនោះ ដល់អ្នកដទៃផងបាន អ្នកដទៃដែលនឹងទទួលយកបុណ្យនោះ ក៏ទទួលយកដោយត្រេកអរដូចអ្នករៀនអក្សរ គ្រូដែលបង្រៀនអក្សរគេតទៅនោះ គេអាចកំណត់វិជ្ជាដែលគេចេះបាន អាចបង្រៀនអក្សរចំឡងដាក់ទៅវិញ្ញាណសិស្សជាច្រើននាក់ ឱ្យចេះផងបាន ហើយចំណេះនោះមិនអស់ទៅណា រីតតែចំរើន ចេះចាំឡើងលើសដើមទៅទៀត ជាខ្ទេគុណមែន ឬទេ ?

ស- បាទមែនហើយ

ឆ- បើដូច្នោះ ខ្ញុំឧបមាឧបមេយ្យ ពីសេចក្ដីចែកបុណ្យនឹងទទួលបុណ្យនោះ អ្នកស្ដាប់បាន យល់បាន បាត់ឆ្ងល់ហើយ ឬនៅ ?

ឆ- បាទ៖ ខ្ញុំស្ដាប់បានយល់បានបាត់ឆ្ងល់ហើយ ខ្ញុំសូមអរគុណដល់អ្នកតាំងពីថ្ងៃនេះទៅ ខ្ញុំនឹងធ្វើបុណ្យទាន ដូចគេ ដូចឯង ដើម្បីឧទ្ទិសកុសលដល់លោកអ្នកមានគុណរបស់ខ្ញុំ ពុំខានឡើយ ។៚

ប្រស្នាត្រៃគុណសង្ខេប

ចប់ដោយបរិបូណ៌តែប៉ុណ្ណេះ

# របៀបមាឃបូជា

# នមស្សការព្រះបរមសារីរិកធាតុ[១]

មាឃចន្ទស្មិ សម្ពុទ្ធោ　　ភគវា យោ តថាគតោ
សមសីត្យាយុកកាលេ　　បរិនិព្វាយិ សោ មុនិ
តស្ស សារីរិកធាតុ　　អម្ហាកំ បមុខេ ឋិតា
តធាគតោ ច សោ សត្ថា　　ធរមានោ ច តិដ្ឋតិ
សក្ការេហិ អភិបូជេម　　តំ នមស្សាម សាទរំ
សាធុ នោ ភគវា នាថោ　　សព្វញ្ញូ សន្តិទាយកោ
ឥមេ ទលិទ្ទសក្ការេ　　អនុកម្បាយ គណ្ហតុ
ទីឃរត្តំ ហិតាយេច　　សុខាយម្ហាកំ សព្វទា ។

ព្រះតថាគត ភគវន្តមុនីអង្គណា ទ្រង់បានត្រាស់ហើយ (បើតនៅ) អស់ ៤៥ ឆ្នាំ, ព្រះតថាគតអង្គនោះ ព្រះអង្គជាមហាមុនី ទ្រង់បរិនិព្វានហើយ ក្នុងកាលដែលព្រះអង្គមានព្រះជន្មាយុ ៨០ គត់ (ឥឡូវ) ព្រះបរមសារីរិកធាតុនៃព្រះអង្គ មកប្រតិស្ឋានក្នុងទីចំពោះមុខ នៃយើងខ្ញុំព្រះអង្គ ហាក់ដូចជា ព្រះបរមសាស្តាអង្គនោះ ទ្រង់គង់ធរមាននៅឡើយ ស្តេចយាងមកក្នុងទីនេះ យើងខ្ញុំសូមបូជាចំពោះព្រះអង្គ ដោយគ្រឿងសក្ការៈទាំងឡាយ សូមនមស្សការ ព្រះអង្គដោយគោរព, សូមព្រះភគវន្តមុនីសព្វញ្ញុពុទ្ធបរមលោកនាថ ដែលតែងតែប្រោសប្រទាន សន្តិសុខដល់សត្វលោក ទ្រង់ព្រះមេត្តាប្រោស ទទួលនូវគ្រឿងសក្ការៈទាំងឡាយ របស់យើងខ្ញុំព្រះអង្គ ដែលជាសក្ការៈបូជារបស់អ្នកកំសត់ទុគ៌តនេះ ដើម្បីអនុគ្រោះយើងខ្ញុំព្រះអង្គ ឱ្យបានសម្រេចប្រយោជន៍និងសន្តិសុខ សព្វកាលវេលា យូរអង្វែងរៀងទៅហោង ។

(ក្រាបថ្វាយបង្គំ ៣ ដង)

(១)- វត្តដែលមានព្រះបរមសារីរិកធាតុ ក្នុងវេលាបុណ្យ មាឃបូជា ឬ វិសាខបូជា លោកអាចារ្យគួរនាំ នមស្សការព្រះសារីរិកធាតុ មុនប្រកាសមាឃបូជា ឬវិសាខបូជា គឺលោកអាចារ្យត្រូវអានបាលីនេះ ព្រមទាំងសម្រាយផងមួយវយៈម្តងៗ ឱ្យពុទ្ធបរិស័ទថាព្រមៗគ្នា ។ អត្ថបទនេះ សម្តេចសង្ឃរាជ ទ្រង់បានតែងឡើង ក្នុងកាល ព.ស ២៥០១ គ.ស ១៩៥៨ ។

# របៀបមាឃបូជា

មុននឹងប្រកាសមាឃបូជា សូមលោកអាចារ្យនាំឧបាសក ឧបាសិកា នមស្សការព្រះរតនត្រ័យ តាមវិធីត្រៃប្រណាមសង្ខេប ឬពិស្តារ ហើយសមាទានសីល ៥ ឬសីល ៨ រួចសឹមប្រកាសមាឃបូជា ដូចតទៅនេះ ៖

## វិធីប្រកាសមាឃបូជា

(ត្រូវលោកអាចារ្យ អានមួយឃ្លាម្តង១ ឱ្យអ្នកទាំងអស់ថាតាមព្រម១ គ្នា)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។ (ថា៣ដង)

សូមនមស្សការ ចំពោះព្រះភគវន្តមុនីអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

សម្មាសម្ពុទ្ធោ ចត សោ ភគវា យោ សព្វទុក្ខស្ស បហានាយ ធម្មំ ទេសេតិ តំ សម្មាសម្ពុទ្ធំ អានរេន នមស្សាម ។

ព្រះភគវន្តមុនីអង្គណា ទ្រង់ត្រាស់សម្តែងនូវធម៌ ដើម្បីកំចាត់បង់នូវសេចក្តីទុក្ខទាំងពួង ព្រះភគវន្តមុនីអង្គនោះ ជាព្រះសម្មាសម្ពុទ្ធពិតមែន យើងខ្ញុំព្រះអង្គ សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធអង្គនោះដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

និយ្យានិកោ ចត សោ ធម្មោ យោ សព្វទុក្ខស្ស បហានាយ ស្វាក្ខាតោ តេន ភគវតា តំ ធម្មំ អានរេន នមស្សាម ។

ព្រះធម៌ណា ដែលព្រះភគវន្តមុនីអង្គនោះ ទ្រង់ត្រាស់សម្តែងហើយដោយប្រពៃ ដើម្បីកំចាត់បង់នូវសេចក្តីទុក្ខទាំងពួង ព្រះធម៌នោះជាធម៌ស្រោចស្រង់សត្វមែនពិត យើងខ្ញុំព្រះអង្គ សូមក្រាបថ្វាយបង្គំ នូវព្រះធម៌នោះដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

**សុប្បដិបន្នោ ចត តស្ស ភគវតោ សោ សាវកសង្ឃោ យោ**

**សព្វទុក្ខស្ស បហានាយ បដិបន្នោ តំ សង្ឃំ អាទរេន នមស្សាមហំ**

ព្រះអរិយសង្ឃឯណា លោកប្រតិបត្តិដើម្បីកំចាត់បង់នូវសេចក្តីទុក្ខទាំងពួង ព្រះអរិយសង្ឃនោះ ជាសង្ឃសាវ័កនៃព្រះភគវន្តមុនីអង្គនោះ លោកប្រតិបត្តិដោយប្រពៃមែនពិត យើងខ្ញុំព្រះអង្គ សូមក្រាបថ្វាយបង្គំ នូវព្រះអរិយសង្ឃនោះដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

ថ្ងៃនេះ ជាតិថីពេញបូណ៌មី នៃខែមាឃ មានព្រះចន្ទ្រពេញវង់ ត្រូវនឹងថ្ងៃនៃសាវ័កសន្និបាត របស់ព្រះសក្យមុនី អរហន្តសម្មាសម្ពុទ្ធ ជាបរមគ្រូនៃយើង, សាវ័កសន្និបាតនោះ ប្រកបដោយអង្គ ៤ គឺ ថ្ងៃពេញបូណ៌មីខែមាឃ ព្រះចន្ទ្រចរចូលក្នុងមាឃនក្ខត្តឫក្ស នេះជាអង្គទី ១, ព្រះភិក្ខុសង្ឃមានចំនួន ១.២៥០ ឥតមានអ្នកណានិមន្ត ឬណាត់ពេលវេលាគ្នាសោះឡើយ ក៏ស្រាប់តែមកប្រជុំគ្នា ក្នុងសំណាក់នៃព្រះបរមសាស្តា នាវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ក្រុងរាជគ្រឹះ មគធរដ្ឋ នៅវេលាថ្ងៃល្ងាច នេះជាអង្គទី ២, ព្រះភិក្ខុសង្ឃទាំង ១.២៥០អង្គនោះ សុទ្ធតែជាឯហិភិក្ខុ ដូចគ្នាទាំងអស់ នេះជាអង្គទី ៣, ព្រះភិក្ខុសង្ឃទាំង ១.២៥០អង្គនោះ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ នេះជាអង្គទី ៤, ព្រះសព្វញ្ញុពុទ្ធទ្រង់គ្រាស់សម្តែង នូវឱវាទបាតិមោក្ខក្នុងទីប្រជុំនៃព្រះភិក្ខុសង្ឃនោះ ។ ការប្រជុំសាវ័កបែបនេះ ហៅថា «**ចតុរង្គសន្និបាត**» គឺការប្រជុំប្រកបដោយអង្គ ៤ ក្នុងពុទ្ធកាលនៃព្រះសក្យមុនី បរមគ្រូរបស់យើង មានតែម្តងប៉ុណ្ណោះ ។

មួយទៀត កាលដែលព្រះបរមសាស្តានៃយើង ទ្រង់មានព្រះជន្ម បើគិតតាមឈ្មោះខែ នៅខ្វះ ៤ ខែ បើគិតតាមចំនួនថ្ងៃ នៅខ្វះ ៨៨ ថ្ងៃទៀត នឹងគ្រប់ ៨០ ឆ្នាំគត់ ព្រះអង្គទ្រង់ កំណត់នូវព្រះជន្មាយុសង្ខារថា «ម្នាលភិក្ខុទាំងឡាយ គិតពីថ្ងៃនេះទៅ នៅខ្វះតែ ៣ ខែ ទៀតទេ តថាគតនឹងរំលត់ខន្ធ ចូលកាន់បរិនិព្វាន» ការកំណត់ព្រះជន្មាយុនេះ នៅថ្ងៃ ១៥ កើត ខែមាឃដែរ ។ តិថីនេះ ជាឧបលក្ខិតសម័យមួយដ៏ឧត្តម ក្នុងព្រះពុទ្ធសាសនា គឺជាថ្ងៃសម្រាប់ពុទ្ធមាមកជន ទាំងបព្វជិត ទាំងគ្រហស្ថ

ប្រជុំគ្នាធ្វើសក្ការៈបូជា ចំពោះព្រះសម្មាសម្ពុទ្ធអង្គនោះ ព្រមទាំងព្រះធម៌ ជាបរមពុទ្ធោវាទ និងព្រះអរិយសង្ឃ ជាសាវ័កព្រះអង្គ ។

ឥឡូវនេះ យើងទាំងអស់គ្នា ជាពុទ្ធសាសនិកជន បានមកប្រជុំគ្នា បានរៀបគ្រឿងសក្ការៈបូជា មានទៀន ធូប និងផ្កាភ្ញីជាដើម ក្នុងទីនេះ ដែលមានព្រះពុទ្ធរូបស្នងព្រះអង្គ[១] គង់ជាប្រធាន ហាក់ដូចជាព្រះបរមសាស្ដាអង្គនេះ ទ្រង់ស្ដេចមកគង់ក្នុងទីចំពោះមុខ នៃយើងទាំងអស់គ្នា, យើងខ្ញុំសូមថ្វាយ នូវគ្រឿងសក្ការៈបូជាទាំងនេះ ចំពោះព្រះសម្មាសម្ពុទ្ធ ព្រះអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ រតនត្រ័យទាំងបី ដោយសេចក្ដីគោរព ។

បពិត្រព្រះសក្យមុនីបរមគ្រូ ព្រះអង្គជាបូជារហបុគ្គល របស់ទេវតានិងមនុស្សក្នុងលោក ឥតមានបុគ្គលណាមួយ ត្រឹមស្មើនឹងព្រះអង្គឡើយ ទោះបីព្រះអង្គចូលបរិនិព្វានបាត់ព្រះរូបព្រះកាយ អស់កាលយូរអង្វែងទៅហើយ ក៏ពិតមែន ប៉ុន្តែទ្រង់បានប្រតិស្ឋានព្រះវិសុទ្ធោវាទ គឺព្រះធម៌វិន័យ ដ៏បរិសុទ្ធវិសេស ទុកជាតំណាងព្រះអង្គ ទាំងព្រះគុណរបស់ព្រះអង្គ ក៏នៅមានប្រាកដ ទាំងព្រះសារីរិកធាតុ និងព្រះពុទ្ធរូបស្នងព្រះអង្គ ក៏មាននៅប្រាកដដែរ សូមព្រះដ៏មានបុណ្យ ជាបរមសាស្ដា ទ្រង់ព្រះមេត្តាទទួល នូវគ្រឿងសក្ការៈបូជា របស់យើងខ្ញុំព្រះអង្គ ដែលរៀបចំថ្វាយក្នុងទីនេះ ដើម្បីជាផលានិសង្សឱ្យយើងខ្ញុំព្រះអង្គ បានប្រកបដោយឥដ្ឋមនុញ្ញផល វិបុលសុខ និងសេចក្ដីចម្រើន ដ៏ធំទូលាយ អស់កាលជាយូរអង្វែងទៅហោង ។

(ក្រាបថ្វាយបង្គំ ៣ ដង)

## ចប់ វិធីប្រកាសមាឃបូជា

លុះចប់វិធីប្រកាសមាឃបូជាហើយនេះ សូមព្រះសង្ឃទាំងអស់ នមស្ការព្រះរតនត្រ័យ តាមវិធីត្រៃប្រណាម និងធម៌សម្រាប់នមស្ការផ្សេងៗទៀត តាមដែលអាចសូត្របានគ្រប់អង្គ ។ តទៅសូមភិក្ខុ ឬ សាមណេរ មានសំឡេងពីរោះ ដែលបានហាត់ហើយ សូត្រ ២អង្គម្ដងៗ នូវ «នមស្ការគាថា» ដូចមាន ខាងចុងនេះ ហើយនិមន្ត ធម្មកថិកសម្ដែងធម៌ទេសនា ។ លុះចប់ធម៌ទេសនាហើយ ពុទ្ធបរិស័ទណា ចេះសូត្របទផ្សេងៗ ដែលស្របនឹងបុណ្យនេះ ក៏សូមសូត្រឱ្យទាល់តែទៀបភ្លឺទៅចុះ ។

(១)- ត្រង់ចន្លោះនេះ បើមានព្រះសារីរិកធាតុ, ត្រូវបញ្ចូលពាក្យថា «និងព្រះសារីរិកធាតុ» ផង ។

# មាឃបូជា

ពិធីមាឃបូជានេះ ជាសម័យដ៏ធំមួយ សឹងមាននក្ខត្តឫក្ស គួរធ្វើសក្ការៈបូជាដល់ទៅពីរដង គឺសំដៅយកត្រង់ថ្ងៃ ដែលទ្រង់សម្ដែងឱវាទបាតិមោក្ខម្ដង, ត្រង់ថ្ងៃទ្រង់ដាក់ព្រះជន្មាយុម្ដង ទើបអ្នកប្រាជ្ញបុរាណ លើកយកថ្ងៃពេញបូណ៌មីខែមាឃ ទុកជាពិធីធ្វើសក្ការៈបូជា ដរាបដល់សព្វថ្ងៃនេះ ។

ឯរបៀបរៀបចំតាក់តែងគ្រឿងសក្ការៈផ្សេងៗ មិនប្លែកគ្នាអំពីពិធី ដែលមានមកហើយនោះទេ ផ្សេងគ្នាតែបាលីសម្រាប់វេរគ្រឿងសក្ការៈតែប៉ុណ្ណោះ ។

## បាលីវេរគ្រឿងសក្ការៈមាឃបូជា

អជ្ជាយំ ភោន្តោ មាឃបុណ្ណមី សម្បត្តោ មាឃនក្ខត្តេន យុត្តោ បុណ្ណចន្ទោ ហោតិ តទា ហិ អរហន្តសម្មាសម្ពុទ្ធោ វេឡុវនេ កលន្ទកនិវាបេ មាឃបុណ្ណមិយំ វឌ្ឍមានាយ ចតុរង្គិកេ សាវក-សន្និបាតេ ឱវាទបាតិមោក្ខំ ឧទ្ទិសិត្វា វិសុទ្ធុបោសថំ អកាសិ សព្វេសំ ខីណាសវានំយេវ អឌ្ឍតេរសានំ ភិក្ខុសតានំ ។ អថ ច បន អម្ហាកំ លោកនាយកោ បាវាលចេតិយេ សតោ សម្បជានោ អសីតិយា វស្សកាលេ ឥតោ តិណ្ណំ មាសានំ អច្ចយេន តតោ បរិនិព្វាយិស្សាមីតិ អាយុសង្ខារំ ឱស្សជ្ជិ ឱស្សជ្ជិត្វា បន ភូមិចាលោ អហោសិ ។ តេនហិ មយន្ទានិ ឥមំ មាឃបុណ្ណមី នក្ខត្តសមយំ យថាត្តកាលសទិសំ សម្បត្តា តស្ស តំ តំ អនុស្សរមានា ឥធ សមាគតា តេនត្ថេន ឥមេហិ ទីបធូបបុប្ផាទិសក្ការេហិ អភិបូជេម

សាធុ នោ ភន្តេ ភគវា សសាវកសង្ឃោ សុចិរបរិនិព្វុតោបិ ឥមេ សក្ការេ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

បពិត្រលោកទាំងឡាយដ៏ចំរើន ថ្ងៃនេះជាថ្ងៃបុណ្ណមីដល់ព្រមហើយ ប្រកបហើយដោយនក្ខត្តឫក្ស មានព្រះចន្ទ្រពេញវង់ប្រាកដ, សេចក្ដីពិតថា ព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់ប្រថាប់នៅ ក្នុងវេឡុវ័នកលន្ទកនិវាបស្ថាន សម្ដែងនូវឱវាទប្បាតិមោក្ខ ធ្វើវិសុទ្ធិឧបោសថ ចំពោះភិក្ខុដប់បីរយកន្លះ គឺ(១.២៥០)អង្គ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ ក្នុងទីប្រជុំសាវ័ក ប្រកបដោយអង្គ ៤ វេលារសៀល ថ្ងៃពេញបូណ៌មីខែមាឃ ។

មួយវិញទៀត សម្ដេចព្រះលោកនាយក អម្ចាស់នៃយើង ទ្រង់ប្រថាប់នៅ ក្នុងបាវាលចេតិយ ទ្រង់មានសតិសម្បជញ្ញៈ ដាក់ចុះនូវព្រះជន្មាយុសង្ខារថា កន្លងទៅបីខែទៀត រាប់តាំងអំពីខែនេះ តថាគតនឹងបរិនិព្វាន គំរប់ព្រះជន្មាយុ ៨០ វស្សាគត់ លុះទ្រង់ដាក់ជន្មាយុសង្ខារហើយ ក៏កើតញាប់ញ័រផែនដី ។

ព្រោះហេតុនោះ ឥឡូវនេះ យើងខ្ញុំទាំងឡាយ (បើ) ដល់ថ្ងៃមាឃបុណ្ណមី ជានក្ខត្តសម័យ ប្រហែលដូចមាឃនក្ខត្តសម័យកាលនោះ ក៏រឭកដល់នូវកាលទាំងពីរនោះ ។ របស់ព្រះដ៏មានព្រះភាគ ទើបមកប្រជុំគ្នាក្នុងទីនេះ ធ្វើបូជាចំពោះព្រះរតនត្រ័យ ដោយគ្រឿងសក្ការៈបូជាទាំងឡាយ មានទៀន ធូប កម្រងផ្កាជាដើមនេះ ។ បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន សូមព្រះអង្គ ព្រមទាំងព្រះសង្ឃសាវ័ក សូម្បីបរិព្វានហើយជាយូរអង្វែង សូមទទួលយកនូវ គ្រឿងសក្ការៈទាំងឡាយនេះ ដើម្បីប្រយោជន៍ និងសេចក្ដីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាយូរអង្វែងទៅហោង ។

ចប់

វេរគ្រឿងសក្ការៈ តែប៉ុណ្ណោះ

# បទថ្វាយផ្កា

បទុមក្រពុំរីក មានចិត្តត្រេកកាច់មកថ្វាយ
បទុមក្រពុំថ្វាយ បង្កាច់កាយកបកេសរ ។
លុតលើកទាំងទសករ ប្រណម្យដោមដាក់សិរសី
ខ្ញុំក្រាបក្រោមព្រះបាទ អភិវាទវរវន្ទា ។
ថ្វាត់ថ្វាយទៅព្រះស្រី- រ័ត្នដ៏ថ្លៃស្រីកាឡា
ក្បូរក្បាច់រចនា បរិបូរណ៍បួនដណ្ដប់ហត្ថ ។
ព្រះអង្គភគវា ស្ដេចគង់នាបល្ល័ង្ករ័ត្ន
ឆ្លុះយល់កំណើតសត្វ សត្វអមរ[១] និករកាយ ។
ឆ្លោមស្លឹក-ស្លឹកត្រសុំ ត្រសាយព្រមនូវមែកមាស
បពិត្រវិសំណួម ខ្ញុំសាងសូមប្រាថ្នាកាត់
សូមឆុតចំហុតថ្វាត់ សត្តវៀងដល់និព្វានហោង ។

---

១- អមរ ប្រែថា ទេវតា ត្រូវអានថា អៈម៉ ។

# នមោ ៨ បទ

បទបង្សាវត្ត

នមោ អរ- ហតោ សម្មា- សម្ពុទ្ធស្ស មហេសិនោ
ខ្ញុំសូមបង្គំ ឆ្ពោះព្រះអរហន្ត សម្ពុទ្ធភគវន្ត កាលស្វែងរកធម៌
គឺពោធិញ្ញាណ ប្រសើរបវរ បានត្រាស់ដឹងធម៌ ដោយអរិយមគ្គ ។

នមោ ឧត្ត- ម ធម្មស្ស ស្វាក្ខា តស្សេ- វ តេនិធ
សូមថ្វាយបង្គំ ព្រះធម៌ឧត្តម ដែលព្រះបរម សម្ពុទ្ធសម្តែង
ដោយប្រពៃពិត ប្រាកដជាក់ស្តែង ព្រះធម៌នោះឯង ទុកក្នុងសាសនា ។

នមោ មហា សង្ឃស្សា បិ វិសុទ្ធសី- ល ទិដ្ឋិនោ
សូមថ្វាយបង្គំ ព្រះសង្ឃប្រសើរ ដែលលោកបានធ្វើ ទិដ្ឋិនិងសីល
ឱ្យបានបរិសុទ្ធ ផុតចាកមន្ទិល គឺទិដ្ឋិសីល លោកស្អាតអស់ហើយ ។

នមោ ឱមា- ត្យារទ្ធស្ស រតនត្តយ- ស្ស សាធុកំ
សូមថ្វាយបង្គំ ប្រជុំត្រ័យរ័ត្ន ប្រាកដដោយបទ មានបីប្រការ ៖
ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃឈ្នះមារ ប្រសើរអស្ចារ្យ ថ្លឹងថ្លែងពុំបាន ។

នមោ ឱម- ការី តស្ស តស្ស ចត្ថុ- ត្តយស្សាបិ
សូមថ្វាយបង្គំ ភុំវត្ថុបី ពិសេសពិសី ប្រសើរថ្កើងថ្កាន
ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃសព្វប្រាន តេជះកល្យាណ ដោយគុណគួរគាប់ ។

នមោ ការ- ប្បភាវេន វិគច្ឆន្តុ ឧបទ្ទវា
សូមថ្វាយបង្គំ ត្រ័យរ័ត្នសោភា ឧបទ្រពនានា ចូរវិនាសបាត់

ដោយអានុភាព បុណ្យជួយកំចាត់ ធ្វើក្តីវិបត្តិ ឱ្យស្ងាត់សូន្យទៅ ។

នមោ ភាគ- នុភាវេន សុខត្ថិ ហោ- តុ សព្វទា

សូមថ្វាយបង្គំ ត្រ័យរ័ត្នទាំងបី សូមសុខសួស្តី កើតសព្វវេលា
ដោយអានុភាព ធ្វើការវន្ទា គោរពបូជា ឆ្ពោះព្រះត្រ័យរ័ត្ន ។

នមោ ការ- ស្ស តេជេន និធិម្ហិ ហោ- មិ តេជវា

សូមថ្វាយបង្គំ ត្រ័យរ័ត្នសោភា តេជះចេស្តា ចូរមានដល់ខ្ញុំ
ក្នុងពិធីធ្វើ កិច្ចថ្វាយបង្គំ តេជះបុណ្យធំ សូមកើតឡើងហោង ។

ចប់

នមោ ៨ បទ

# គាថាប្រារព្ធមាឃបូជា

## បទបថ្យាវត្ត

មាឃនក្ខ- ត្តយុត្តាយ បុណ្ណាយ បុ- ណ្ណមាយំ យោ
អរហំ ស- ម្មាសម្ពុទ្ធោ ភគវា គោ- តមវ្ហយោ
សុទ្ធានន្ត- នយោ ញាណោ សត្ថា លោកេ អនុត្តរោ
វិហរន្តោ រាជគហេ មគធានំ គិរិព្វជេ
វិហារេ វេ- ឡុវនេវ កលន្ទក- និវាបិយេ
សង្ឃស្ស ស- ន្និបាតម្ហិ ឧត្តមេ ច- តុរង្គិកេ
អឌ្ឍតេរ- សេហិ ភិក្ខុ- សតេហិ ប- រិវារិតោ
តីហិ គាថា ហិ សង្ខិប្បំ សព្វំ ពុទ្ធា- នុសាសនំ
សមោសារេ- សិ ឱវាទំ បាតិមោក្ខំ អនុត្តរំ
តមេវម្ហ- តសម្ពុទ្ធំ សខីណាស- វសាវកំ
ចិរកាល- មតីតម្បិ បសាទេន អនុស្សរំ
អយម្បិ ប- រិសា សព្វា បសន្នា ឆ- ម្ទគាមិនី
សម្បត្តា តា- ទិសំ កាសំ សុនក្ខត្តំ សុមង្គលំ
ទីបធូបា- ទិសក្ការេ អភិសជ្ជ យថាពលំ
តេហិ បូជេ- តវេហដ្ឋ- តុដ្ឋា ឥធ សមាគតា
អភិវន្ទ- តិ បូជេតិ ភគវន្តំ សសាវកំ
កាលេន ស- ម្មុខី ភូតំ អតីតារ- ម្មណត្តនា
ឱសារេន្តំ បាតិមោក្ខំ វិសុទ្ធក- ម្មបោសថេ

ឥតោ ចេន សុបុញ្ញេន សោត្ថិ ហោតុ សទាបិនោ
សាសនំ ស- ត្ថុ អម្ហាកំ ចិរំ តិដ្ឋតុ តាទិនោតិ ៗ

ប្រែ. កាព្យបទ្យាវត្ត

ព្រះដ៏មានព្រះ ភាគអង្គឯណា ដែលមាននាមថា សមណគោតម
ព្រះអង្គកាត់បង់ កិលេសតូចធំ មិនឱ្យរួបរុំ នៅក្នុងសន្តាន ។
ព្រះអង្គត្រាស់ដឹង ប្រពៃឥតមាន គ្រូអាចារ្យប្រៀន ប្រដៅព្រះអង្គ
ទ្រង់មានសីលនិង ទិដ្ឋិផូរផង់ ករុណាគុណស្រង់ នូវសត្វទាំងឡាយ ។
និងបញ្ញាគុណ ចាក់ធ្លុះសុសសាយ ជ្រៅឆ្ងាយទូលាយ ឥតទីបំផុត
ព្រះអង្គជាគ្រូ ក្នុងត្រៃលោកឥត អ្នកណាមួយឧ- ត្តមប្រៀបផ្ទឹមបាន ។
ព្រះអង្គគង់ក្នុង វិហារវេឡុវ័ន ជានិវាបស្ថាន នៃសត្វកង្ហែន
ជិតភ្នំរាជគ្រឹះ ដែនមានរបៃបផែន ដូចភ្នំនៃដែន មគធៈទាំងឡាយ ។
ភិក្ខុជាអង្គ អរហន្តពណ្ណរាយ មួយពាន់ពីររយ ហាសិបព្រះអង្គ
ចោមរោមក្នុងកាល-ដែលប្រជុំសង្ឃ ប្រកបដោយអង្គ ទាំងបួនឧត្តម ។
ហើយទើបព្រះអង្គ ស្ដេចទ្រង់ប្រជុំ សម្ដែងឱវាទ ព្រះបាតិមោក្ខ
ដល់ទីពំនឹង មិនដឹងបើរក អ្វីមួយក្នុងលោក មកប្រៀបផ្ទឹមបាន ។
ជាសាសនានៃ ព្រះពុទ្ធដែលមាន ព្រះទ័យប្រទាន ទុកគ្រប់ព្រះអង្គ
យ៉ាងសង្ខេបខ្លី សេចក្ដីផូរផង់ ដោយគាថាទាំង ឡាយបីជំពូក ។
ក្នុងថ្ងៃពេញបូ- ណ៌មីខែមាឃ ប្រកបដោយន- ក្ខត្តឫក្សដ៏ល្អ
មួយទៀតទ្រង់ប្រ- ជុំពួកបរិវារ ហើយទ្រង់ទេស្នា សម្ដែងវិន័យ ។
ជាច្បាប់ភិក្ខុ និងនាងភិក្ខុនី ពោលគឺឧទ្ទេ- សបាតិមោក្ខ
មានអត្ថស្អាតកើត ក្នុងកាលដែលលោក សង្ឃសូធ្យរៀនមក រាល់ឧបោសថ ។
មួយទៀតទ្រង់សំ រាកឥរិយាបថ គង់សណ្ឋិតក្នុង ក្រុងវេសាលី
មានភិក្ខុចោមរោម ជុំជាប្រក្រតី ទ្រង់កំណត់ឱ្យ ភិក្ខុដឹងជាក់ ។

ថានៅបីខែ ទៀតព្រះអង្គដាក់ ធុរៈនឹងយាង ចូលព្រះនិព្វាន
បរិស័ទទាំងពួង យើងខ្ញុំនេះមាន ជ្រះថ្លាហើយបាន ប្រព្រឹត្តនូវធម៌ ។
យើងខ្ញុំសូមលើក ព្រះពុទ្ធនោះណា និងសាវ័កជា ព្រះខីណាស្រព
ដែលនិព្វានទៅ កន្លងយូរយប់ ខ្ញុំនឹកមិនឈប់ តាមដោយជ្រះថ្លា ។
យើងខ្ញុំបានដល់ ទក្ខិណេយ្យជា មង្គលសោភា ប្រាកដដូច្នោះ
យើងរៀបសក្កា- រៈទាំងឡាយនោះ មានទៀនធូបជា ដើមតាមកម្លាំង ។
ហើយមកជុំគ្នា នៅក្នុងទីនោះ បង្គំចំពោះ ហើយសូមបូជា
នូវព្រះអង្គនោះ ទ្រង់នាមភគវា និងសង្ឃដែលជា សាវ័កព្រះអង្គ ។
ក្នុងថ្ងៃពេញបូ- ណ៌មីជាវង់ ខែមាឃមានទាំង សុនក្ខត្តា
ដោយអំណាចបុណ្យ ដែលខ្ញុំបូជា មកជួយការពារ នូវយើងខ្ញុំណា ។
កុំឱ្យអន្តរាយ សព្វគ្រប់ប្រការ បៀតបៀនខ្ញុំជា ពួកពុទ្ធបរិស័ទ
សូមឱ្យសិរី សួស្តីហ្មត់ចត់ កើតមានប្រាកដ ដល់យើងខ្ញុំណា ។
សូមឱ្យចម្រើន សតិបញ្ញា សព្វគ្រប់ប្រការ កុំមានចន្លោះ
សូមឱ្យសាសនា ព្រះពុទ្ធជាម្ចាស់ យើងទាំងឡាយនោះ រុងរឿងជានិច្ច ។
គ្រប់ ៥០០០ឆ្នាំ កុំឱ្យរិលរេច សូមឱ្យសម្រេច អស់កាលយូរហោង ។

(បុរាណភាសិត)

## សត្តមហាឋាន

បទបឋ្យាវត្ត

បឋមំ ពោធិបល្លង្កំ ទុតិយំ អនិមិស្សកំ
តតិយំ ចង្កមំ សេដ្ឋំ ចតុត្ថំ រតនឃរំ ។
បញ្ចមំ អជបាលញ្ច មុចលិន្ទេន ឆដ្ឋមំ
សត្តមំ រាជាយតនំ សត្តាហំ មុនិ សេវិតំ ។
ឯតេ សត្ត មហាឋានា ជម្ពុទីបេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ទូរតោ ។

## ឋានធំ ៧ កន្លែង

ប្រែ. កាព្យបឋ្យាវត្ត

ទីមួយបល្ល័ង្ក ដែលព្រះសាស្ដា ចំរើនអានា- បានស្មតិ
ទីពីរឮសាន ពីដើមពោធិ ហៅថាអនិមិ- ស្សកចេតិយ ។
ទីបីគឺទី ដែលព្រះជិនស្រី ព្រះអង្គឃាតខ្ទី ទ្រង់យាងចង្ក្រម
ទីបួនគឺទី ដែលព្រះបរម ចំរើនអភិធម្ម ជាធម៌បរមត្ថ ។
ទីប្រាំគឺទី ដែលព្រះភគវ័ត ទ្រង់គង់ស្ងប់ស្ងាត់ ក្រោមអជបាល
ទីប្រាំមួយទី វិសេសវិសាល ស្ងិតសំរាល ក្បែរស្រះមុច្ចលិន្ទ ។
ទីប្រាំពីរគឺ ទីព្រះមុនិន្ទ សង្រួមឥន្ទ្រិយ៍ រាជាយតនា
ទីទាំងប្រាំពីរ ដែលពោលនេះណា ជាទីថ្លៃថ្លា មានពិតប្រាកដ ។
ក្នុងជម្ពូទ្វីប នេះជាកំណត់ ប្រាជ្ញលោកសន្មត ហៅថាឋានធំ
ព្រោះជាកន្លែង ដ៏ល្អឧត្តម ជាទីមនោរម្យ ដល់មនុស្សទេព្ដា ។
ជាទីសំរាប់ អ្នកមានសទ្ធា នាំគ្នាវន្ទា យកបុណ្យកុសល
ខ្ញុំសូមក្រាបថ្វាយ បង្គំឆ្ពោះដល់ ឋានធំនិមល នោះពីចម្ងាយ ។

# អដ្ឋមហាឋាន

## បទបថ្យាវត្ត

បឋមំ លុម្ពិនីជាតំ ទុតិយំ ពោធិមុត្តមំ
តតិយំ ធម្មចក្កញ្ច ចតុត្ថំ បាលិលេយ្យកំ ។
បញ្ចមំ ច នាឡាគីរី ឆដ្ឋមំ បាដិហារិយំ
សត្តមំ សិរិធេចិន្ទំ អដ្ឋមំ បរិនិព្វុតំ ។
ឯតេ អដ្ឋ មហាឋានា ជម្ពូទីបេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ទូរតោ ។

## ឋានធំ ៨ កន្លែង

### ប្រែ. កាព្យបថ្យាវត្ត

ឋានធំទាំងឡាយ ប្រាំបីកន្លែង ជាទីស្ងប់ស្ងែង ដល់ពពួកសត្វ
ទីមួយឧទ្យានៈ ជាឋានព្រៃស្ងាត់ គឺព្រៃសាលវ័ន្ត ដែលទ្រង់ប្រសូត ។
ទីពីរប្រសើរ ដែលព្រះទ្រង់ស្រូត ត្រាស់ក្រោមដើមពោ- ធិព្រឹក្សឧត្តម
ទីបីកន្លែង ដែលព្រះបរម សម្តែងព្រះធម៌ ឈ្មោះធម្មចក្រ ។
ប្រោសភិក្ខុប្រាំអង្គ គឺពួកបញ្ចវ- គ្គីយ៍ដែលជាអ្នក បំរើព្រះអង្គ
ដោយព្រះទ័យថ្លៃ មិនអាចលះបង់ ហើយយាងតម្រង់ ពីដើមពោធិ៍ទៅ ។
ទីបួនគឺទី ដែលទ្រង់គង់នៅ ក្នុងស្ថានព្រៃជ្រៅ ឈ្មោះបាលិលេយ្យក៍
ទីនោះគ្មានមនុស្ស មានតែសត្វព្រៃ គឺដំរីថ្លៃ បំរើព្រះអង្គ ។
ទីប្រាំឈ្មោះថា រតនបល្ល័ង្ក ទីដែលទ្រង់ច្បាំង នាឡាគីរី
ទីនោះមានមនុស្ស បែកពួកជាពីរ ទៅមើលឫទ្ធី សម្តេចសម្ពុទ្ធ ។
ទីប្រាំមួយកាល ព្រះសព្វញ្ញុ- តញ្ញាណជាមកុដ ធ្វើបាដិហារ្យ
ផ្ចាញ់ពួកនិគ្រន្ថ ក្រៅពុទ្ធសាសនា ឈ្នះល្បីអស្ចារ្យ គ្មាននរណាដល់ ។

ទីប្រាំពីរកាល ព្រះទសពល គង់លើមណ្ឌល ថ្មព្រះឥន្ទ្រា
ទ្រង់បានសម្តែង នូវព្រះធម្មា ប្រាកដនាមថា ធម៌អភិធម្ម ។
សងគុណមាតា ដែលមានគុណធំ លើព្រះបរម សម្ពុទ្ធមុនី
ដែលមាននាមថា មាយាទេវី នាងយាងចុះពី សួគ៌ឋានតុសិត ។
អស់ពួកទេព្តា ដង្ហែជុំជិត យាងមកសណ្ឋិត ឋានត្រៃត្រិង្សា
ទីប្រាំបីកាល អង្គព្រះសាស្តា ផ្ទំក្រោមដើមសា- លៈព្រឹក្សទាំងគូ ។
ពេលនោះឯងហើយ ព្រះសព្វញ្ញូ ព្រះអង្គជាគ្រូ យាងចូលនិព្វាន
ឋានធំប្រាំបី កន្លែងនេះមាន ប្រតិស្ឋានក្នុង ជម្ពូទ្វីបា ។
ជាទីដែលពួក មនុស្សនិងទេព្តា ធ្វើគ្រឿងសក្ការ គោរពបូជា
ខ្ញុំសូមឱនកាយ បង្គំវន្ទា ឆ្ពោះទីនោះណា អំពីចម្ងាយ ។
ដោយការប្រណម្យ បង្គំថ្វាត់ថ្វាយ ឋានធំទាំងឡាយ ប្រាំបីនោះឯង
សូមសុខចម្រើន កើនយូរអង្វែង ទុក្ខសោកចំបែង កុំកើតមានឡើយ ។
នឹងបានរួចទោស ឆ្លងដល់កោះត្រើយ ជាតិនេះឯងហើយ វាសនាខ្ពស់ខ្ពង់
សូមឱ្យខ្ញុំបាន ឋានធំឧត្តុង្គ ឧត្តមយូរលង់ គឺនិព្វានហោង ។

ចប់ ៖

ឋានធំ ៨ កន្លែង

❧❧✻❧❧

# នមក្ការគាថា

## មហានាគនមក្ការគាថា[1]

គាថានមស្ការចំពោះព្រះមហានាគ

បថ្យាវត្តឆន្ទ

សេដ្ឋោ តថាគតោ លោកេ    ពុទ្ធនាគោតិ វិស្សុតោ
នាគេន ទេសិតោ ធម្មោ    និយ្យានិកោតិ សញ្ញតោ
តស្សាបិ សាវកោ សង្ឃោ    សន្តិន្ទ្រិយោ អនាសវោ
នាករិ បាបកំ អាគុំ    តស្មា នាគោតិ វុច្ចរេ ។

កាព្យបថ្យាវត្ត (កុំច្រឡំហៅកាព្យពាក្យ ៨)

ព្រះតថាគត វិសុទ្ធក្នុងលោក ព្រះអង្គមានជោគ លើសលោកទាំងបី
ព្រះនាមពុទ្ធនាគ ជាពាក្យបាលី អស់ជនប្រុសស្រី គប្បីដឹងច្បាស់ ។
ថាជាព្រះនាម ព្រះពុទ្ធជាម្ចាស់ ប្រសើរពេកណាស់ លើសមនុស្សទេព្តា
ព្រះធម៌ដែលព្រះ- ពុទ្ធនាគទេសនា ប្រោសដល់ទេវតា មនុស្សសត្វទាំងឡាយ ។
ជាធម៌ស្រង់សត្វ ឱ្យផុតអបាយ អ្នកប្រាជ្ញទាំងឡាយ លោកបានជ្រាបច្បាស់
ព្រះអរិយសង្ឃ សាវ័កច្រើនណាស់ ជាសង្ឃនៃព្រះ- ពុទ្ធនាគជាធំ ។
សង្រួមឥន្ទ្រិយ៍ ស្រគត់ស្រគំ កិលេសតូចធំ ក្ស័យក្ស័យអស់ហើយ
លោកឈប់ស្រឡះ គ្មានប៉ះពាល់ឡើយ ព្រះសង្ឃនេះហើយ ដែលទ្រង់ប្រទាន ។
នាមថានាគោ ទុកជាប្រធាន ព្រោះហេតុពុំមាន ធម៌ដ៏លាមក
លោកឈប់ស្រឡះ លែងធ្វើអាក្រក់ ព្រោះលោកនាយក ព្រះពុទ្ធនាគនោះ ។

---

(១)- មហានាគនមក្ការគាថានេះ និងអដ្ឋវីសសម្ពុទ្ធនមក្ការគាថាខាងចុងបន្ទាប់គ្នានេះ សម្តេចព្រះមហាសុមេធាធិបតី (ជ.ណ ជោតញ្ញាណោ) ទ្រង់បានប្រែជាសម្រាយពាក្យរាយ តាំងពី ព.ស ២៤៧៦. គ.ស ១៩៣៣ ។ លោក អ៊ុខ ខេខ ប្រែជាកាព្យបោះពុម្ពជាសៀវភៅ ១ ឈ្មោះ នមក្ការគាថា តាំងពី ព.ស ២៤៨៨. គ.ស ១៩៤៥ ។

ទ្រង់ប្រោសប្រទាន នាគោថាឈ្មោះ ជាពាក្យពីរោះ ចំពោះពុទ្ធដីកា
ដោយមានគម្ពីរ ព្រះមុនីទេសនា ប្រារព្ធនឹងកា- ឡទាយីនោះ ។

វន្ទាហំ ពុទ្ធនាគញ្ច ធម្មំ នាគេន ទេសិតំ
នាគិស្សរិយសង្ឃញ្ច មហានាគន្តិ វិស្សុតំ
ពុទ្ធនាគាធិតេជេន ឧប្បន្នា ចេ ឧបទ្ទវា
រោគា ចេវន្តរាយា ច វិនស្សន្តុ អសេសតោ ៕

យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំ ចំពោះព្រះបរម ព្រះពុទ្ធនាគផង
ចំពោះព្រះធម៌ ប្រសើរកន្លង ដែលព្រះច្បាស់ច្បង ពុទ្ធនាគសម្តែង ។
និងព្រះអរិយសង្ឃ ព្រមទាំងគម្លែង មាននាមជាក់ស្តែង ហៅមហានាគោ
ជាទីសាវ័ក មានថ្នាក់សេដ្ឋោ ព្រះពុទ្ធនាគោ ប្រទានទុកមក ។
តេជះវ័ត្តត្រៃ ថ្លាថ្លៃពន្លក យើងខ្ញុំសូមជ្រក ក្រោមម្លប់សាខា
មានព្រះពុទ្ធនាគ ជាដើមថ្លៃថ្លា ទោះរោគភយា ឧបទ្រពអន្តរាយ ។
ដែលកើតមានឡើង ឱ្យប៉ើងខ្ចាត់ខ្ចាយ សូមឱ្យរលាយ វិនាសបាត់ទៅ
បើពុំទាន់មាន ឱ្យខាននៅក្រៅ ចៀសចេញឆ្ងាយទៅ កុំនៅរៀងអាយ ។
សូមសុខសព្វកាល ត្រអាលសប្បាយ សម្បត្តិទាំងឡាយ សម្បូណ៌ឥតខ្វះ ។

ចប់

នមក្ការគាថា

# អដ្ឋវីសសម្ពុទ្ធនមស្ការគាថា

គាថានមស្ការចំពោះព្រះសម្ពុទ្ធ ២៨ ព្រះអង្គ

វន្ទេ តណ្ហង្ករំ ពុទ្ធំ
វន្ទេ មេធង្ករំ មុនឹ
សរណង្ករំ មុនឹ វន្ទេ
ទីបង្ករំ ជិនំ នមេ
វន្ទេ កោណ្ឌញ្ញសត្ថារំ
វន្ទេ មង្គលនាយកំ
វន្ទេ សុមនសម្ពុទ្ធំ
វន្ទេ រេវតនាយកំ
វន្ទេ សោភិតសម្ពុទ្ធំ
អនោមទស្សឹ មុនឹ នមេ
វន្ទេ បទុមសម្ពុទ្ធំ
វន្ទេ នារទនាយកំ
បទុមុត្តរំ មុនឹ វន្ទេ
វន្ទេ សុមេធនាយកំ
វន្ទេ សុជាតសម្ពុទ្ធំ
បិយទស្សឹ មុនឹ នមេ
អត្ថទស្សឹ មុនឹ វន្ទេ
ធម្មទស្សឹ ជិនំ នមេ
វន្ទេ សិទ្ធត្ថសត្ថារំ
វន្ទេ តិស្សមហាមុនឹ
វន្ទេ ផុស្សមហាវីរំ
វន្ទេ វិបស្សិនាយកំ
សិខី មហាមុនឹ វន្ទេ
វន្ទេ វេស្សភូនាយកំ
កកុសន្ធំ មុនឹ វន្ទេ
វន្ទេ កោនាគមនំ ជិនំ
កស្សបំ សុគតំ វន្ទេ
វន្ទេ គោតមនាយកំ
អដ្ឋវីសតិមេ ពុទ្ធា
និព្វានា មតទាយកា
នមាមិ សិរសា និច្ចំ
តេ មំ រក្ខន្តុ សព្វទា ។

## កាព្យបឋ្យាវត្ត (កុំច្រឡំហៅកាព្យពាក្យ ៨)

ខ្ញុំសូមបង្គំ ព្រះបរមសម្ពុទ្ធ មាននាមប្រាកដ ព្រះតណ្ហង្ករ
ខ្ញុំសូមបង្គំ ព្រះបរមបវរ ព្រះមេធង្ករ ជាសម្ពុទ្ធា ។
សូមថ្វាយបង្គំ ប្រណម្យវន្ទា នូវព្រះភគវា ព្រះសរណង្ករ
សូមថ្វាយបង្គំ ព្រះទីបង្ករ មានញាណបវរ បារមីពោរពេញ ។
សូមថ្វាយបង្គំ នូវព្រះកោណ្ឌញ្ញ ព្រះអង្គបំពេញ ធម៌ជាកុសល
ខ្ញុំសូមបង្គំ នូវព្រះទសពល ព្រះនាមមង្គល វេងសម្ពុទ្ធៈ ។
ខ្ញុំសូមបង្គំ ប្រណម្យគារវៈ ព្រះនាមសុមនៈ សម្មាសម្ពុទ្ធ
ខ្ញុំសូមបង្គំ ព្រះបរមសុគត ព្រះនាមប្រាកដ ព្រះរេវតៈ ។
ខ្ញុំសូមបង្គំ ព្រះសម្ពុទ្ធៈ មានញាណសោភៈ ព្រះនាមសោភិត
ខ្ញុំសូមបង្គំ ប្រណម្យប្រណិត ឆ្ពោះព្រះវិជិត អនោមទស្សី ។
ខ្ញុំសូមក្រាបថ្វាយ ឱនកាយសិរសី ចំពោះព្រះមុនី ព្រះនាមបទុម
ខ្ញុំសូមឱនកាយ ថ្វាយថ្វាត់បង្គំ ចំពោះព្រះបរម ព្រះនាមនារទៈ ។
សូមថ្វាយបង្គំ ព្រះបទុមុត្តរៈ មានញាណសោភៈ វរៈពុទ្ធា
ខ្ញុំសូមបង្គំ នូវព្រះភគវា ទ្រង់ព្រះនាមា សុមេធសម្ពុទ្ធ ។
ខ្ញុំសូមបង្គំ ប្រណម្យក្រាបលុត ឆ្ពោះព្រះសម្ពុទ្ធ ព្រះនាមសុជាត
ខ្ញុំសូមបង្គំ ប្រណម្យអភិវាទ ឆ្ពោះព្រះមុនីនាថ បិយទស្សី ។
ខ្ញុំសូមបង្គំ ឆ្ពោះព្រះជិនស្រី អត្ថទស្សី បារមីខ្ពង់ខ្ពស់
ខ្ញុំសូមបង្គំ ឆ្ពោះព្រះទ្រង់យស ព្រះនាមចំពោះ ធម្មទស្សី ។
ខ្ញុំសូមបង្អោន លំទោនសិរសី បង្គំជិនស្រី ព្រះនាមសិទ្ធត្ថ
ខ្ញុំសូមបង្គំ នូវព្រះមុនីរ័ត្ន ព្រះនាមប្រាកដ តិស្សសាស្តា ។
ខ្ញុំសូមបង្គំ នូវព្រះសម្មា- សម្ពុទ្ធនាមថា ផុស្សៈមុនី
ខ្ញុំសូមបង្គំ ប្រណម្យអញ្ជលី ឆ្ពោះព្រះមុនី ព្រះនាមវិបស្សី ។

សូមថ្វាយបង្គំ ព្រះបរមជិនស្រី ព្រះនាមសិខិ សព្វំជ្ញពុទ្ធា
ខ្ញុំសូមឱនកាយ ក្រាបថ្វាយវន្ទា ឆ្ពោះព្រះភគវ៉ា ព្រះនាមវេស្សភូ ។
ខ្ញុំសូមបង្គំ លើកហត្ថទាំងគូ ឆ្ពោះព្រះជាគ្រូ នាមកកុសន្ធៈ
ខ្ញុំសូមបង្គំ ប្រណម្យគារវៈ ឆ្ពោះព្រះពុទ្ធៈ កោនាគមនោ ។
ខ្ញុំសូមឱនកាយ វាចាមនោ បង្គំពុទ្ធោ ព្រះនាមកស្សបៈ
ខ្ញុំសូមលំទោន បង្អោនសិរសៈ ឆ្ពោះព្រះសមណៈ ព្រះនាមគោតម ។
គម្រប់ម្ភៃប្រាំ បីព្រះបរម សម្ពុទ្ធជាធំ កំពូលលោកា
ទូទាំងត្រៃភព ជាម្លប់សាខា មនុស្សសត្វទេវតា មារព្រហ្មទាំងឡាយ ។
ដែលបានចូលជ្រក ក្រោមម្លប់ព្រះឆាយ បានសុខសប្បាយ គ្រប់រូបរាល់គ្នា
បានទៅសោយសុខ ក្នុងឋានសួគ៌ា ឬឋានព្រហ្មា និងព្រះនិព្វាន ។
ដោយបុណ្យបារមី នៃព្រះទ្រង់ញាណ ព្រះធម៌ប្រធាន ជាយាននាំសត្វ
តេជៈយើងខ្ញុំ ប្រណម្យថ្វាយថ្វាត់ នូវព្រះពុទ្ធរ័ត្ន គ្រប់១ព្រះអង្គ ។
ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ សាវ័កគ្រប់អង្គ ទាំងម្ភៃប្រាំបី
សូមអានុភាព ពីព្រះជិនស្រី ទាំងម្ភៃប្រាំបី ព្រះអង្គនោះឯង ។
ព្រមទាំងព្រះធម៌ ព្រះអង្គសម្តែង ទាំងព្រះគម្ពែង សង្ឃជាសាវ័ក
សូមសុខចម្រើន កើនឡើងតាមថ្នាក់ កុំឱ្យមានអាក់ អន់អាប់ឡើយណា ។
សូមឱ្យខ្ញុំបាន ដល់ឋានទេវតា ដូចក្តីប្រាថ្នា កុំបីឃ្លៀងឃ្លាត
មានព្រះនិព្វាន ជាអវសានជាតិ កុំឱ្យខ្ញុំឃ្លាត បច្ចយោ ហោតុ! ។

ចប់
អដ្ឋវីសសម្ពុទ្ធនមក្ការគាថា

# ចតុសំវេជនីយដ្ឋាន

## បទពាក្យ ៧

គ្រាដែលសម្តេចព្រះទ្រង់ញាណ ជិតចូលនិព្វានឆ្លងត្រៃភព
នោះព្រះអានន្ទបានគោរព ទូលព្រះចមភពដូច្នេះថា ។
បពិត្រសម្តេចព្រះចមត្រៃ សព្វថ្ងៃព្រះអង្គគង់ធរមាន៏
ពួកភិក្ខុសង្ឃផងនានា មាននៅក្នុងគ្រាច្រើនកន្លែង ។
តែដល់រដូវចេញវស្សា តែងតែយាត្រាត្រាច់ស្វះស្វែង
មកគាល់ព្រះអង្គជាតម្លែង គ្រប់ទីកន្លែងទាំងឆ្ងាយជិត ។
ដែលជាឱកាសដ៏បវរ ឱ្យសង្ឃស្មោះសរបានមូលមិត្ត
បានជួបជុំគ្នាយ៉ាងជិតជិត នឹងបានប្រព្រឹត្តធម៌ដូចគ្នា ។
លុះពេលព្រះអង្គនិព្វានទៅ សង្ឃនៅឯក្រោយនឹងឃ្លាតឃ្លា
មិនបានជួបចូលមូលជុំគ្នា ដូចជាពេលគង់ធរមាននៅ ។
ឯអង្គសម្តេចព្រះមានបុណ្យ ទ្រង់ឮអានន្ទពោលឆ្ពោះកូវ
ក៏ទ្រង់សម្តែងថ្លែងប្រាប់ផ្លូវ ឱ្យបរិស័ទទៅធ្វើទស្សនា ។
ថាក្រោយតថាគតនិព្វាន បរិស័ទអ្នកមានសោមនស្សា
គង់តែមានផ្លូវគួរយាត្រា ទៅធ្វើទស្សនា ៤ កំណត់ ។
១- គឺឧទ្យានលុម្ពិនី ជាទីប្រសូតតថាគត
២- គឺដើមពោធិ៍ពិតប្រាកដ ទីតថាគតត្រាស់ដឹងញាណ ។
៣- គឺទីឋានល្អក្រៃលែង សម្តែងធម្មចក្កជាធម្មយាន
៤- គឺទីចូលព្រះនិព្វាន នៅក្នុងឧទ្យានមល្លៈក្សត្រ ។
ទីសំវេជនីយដ្ឋាន ទីនោះនឹងបានចិត្តស្ងប់ស្ងាត់
ជ្រះថ្លាសង្វេគពន់ពេកក្កាត់ ដល់ពុទ្ធបរិស័ទដែលទៅដល់ ។
បើពុទ្ធបរិស័ទទាំងឡាយ មិនបានយាត្រាទៅឱ្យស្គាល់

មិនបានទៅថ្វាយបង្គំគាល់ ពីព្រោះក្ដីទ័លឬយ៉ាងណា ។
គ្រាន់តែសទ្ធាជ្រះថ្លាពិត បានបញ្ជូនចិត្តសោមនស្សា
ឱ្យទៅគោរពយ៉ាងថ្លៃថ្លា ពីឆ្ងាយទៅណាយ៉ាងចំៗ ។
ឆ្ពោះសំវេជនីយដ្ឋាន ទីទាំង ៤ ឋានដ៏ឧត្ដម
នោះអាចកើតផលប្រសើរសម តាមចិត្តនឹកចំពុទ្ធគុណរោចង ។

# ពុទ្ធបាទ ៥ ឋាន[១]

បទកាកគតិ

ព្រះទសពលញ្ញាណ ជិតចូលនិព្វាន ទ្រង់មានមេត្តា
ករុណាសាយសព្វ គន្ធព្វអសុរា គ្រុឌនាគទេវតា
សត្វមនុស្សប្រុសស្រី ។

ទ្រង់ប្រោសប្រទាន ព្រះបាទ ៥ ឋាន ទុកឱ្យវន្ទីយ៍
ព្រះបាទមួយក្នុង ចមចុងគីរី សុវណ្ណមាលី
ជាទីកំណត់ ។

ព្រះបាទសោភា មួយឋិតនៅនា សុវណ្ណបព៌ត
មួយឋិតនៅនា លង្កាប្រាកដ លើភ្នំសុទ្ធត
សុមនកូដកាប់ ។

ព្រះបាទសួស្ដី មួយនៅបុរី យោនកស្រេចស្រាប់
អ្នកនគរស្រុក យកទុកសម្រាប់ រកគ្រឿងប្រដាប់
ធ្វើពុទ្ធបូជា ។

(១)- ស្រង់ពីធម៌សរសើរព្រះបាទបុរាណ ។

ព្រះបាទសោភី មួយឋិតនៅទី ស្ថិងនម្មទា
ព្រះអង្គជាន់ទុក លើកក់ពសុធា ទុកឱ្យមច្ឆា
ក្រួញក្រាបអភិវន្ទ ។

ព្រះត្រៃលោកនាថ ទុកស្នាមព្រះបាទ ៥ ឋានសោភ័ណ
តំណាងព្រះអង្គ ឱ្យគង់ប្រាំពាន់ វស្សាគ្រប់គ្រាន់
ទើបស្ដេចនិព្វាន ។

ឱអស់យើងខ្ញុំ អភ័ព្វពេកពុំ ទាន់ព្រះទ្រង់ញាណ
ទាន់តែសាសនា បាទា ៥ ឋាន នោះសោតពុំបាន
ទៅទៀបឱ្យយល់ ។

សូមក្រួញក្រាបថ្វាយ បង្គំពីឆ្ងាយ តម្រង់ឆ្ពោះដល់
ព្រះបាទ ៥ ឋាន កល្យាណនិមល សូមមានមង្គល
តែជះជោគជ័យ ។

សូមឈ្នះលោភា ទោសៈមោហា ឧបទ្រពចង្រៃ
គ្រោះថ្នាក់ទុក្ខសោក ទាំងរោគពៀរភ័យ សូមសុខសព្វថ្ងៃ
រៀងរៀបទៅហោង ។

ចប់

ពុទ្ធបាទ ៥ ឋាន តែប៉ុណ្ណេះ

# ធាតុចេតិយនមស្ការគាថា

គាថានមស្សការព្រះចេតិយបញ្ចុះព្រះសារីរិកធាតុព្រះពុទ្ធ

មហាគោតមសម្ពុទ្ធោ    កុសិនារាយ និព្វុតោ
ធាតុវិត្ថារតំ កត្វា    តេសុ តេសុ វិសេសតោ

ខ្ញុំសូមបង្គំ    ប្រណម្យអភិវាទ    សារីរិកធាតុ    ព្រះមហាគោតម
ដែលទ្រង់និព្វាន    ក្រោមសាលព្រឹក្សធំ    ជិតបុរីរម្យ    ក្រុងកុសិនារា ។
កិរិយាផ្សាយនូវ    ព្រះធាតុនានា    ផ្សេងៗពីគ្នា    ក្នុងទីទាំងឡាយ
ខ្ញុំសូមបង្គំ    ប្រណម្យក្រាបថ្វាយ    ព្រះធាតុទាំងឡាយ    គ្រប់ទីនោះៗ ។

ឧណ្ហីសំ ចតស្សោ ទាឋា    អក្ខកា ទ្វេ ច សត្តមា
អសម្ភិន្នាច តា សត្ត    សេសា ភិន្នា ច ធាតុយោ

ព្រះសារីរិកធាតុ    ល្អស្អាតទាំងនោះ    ដែលមិនបែកសោះ    ប្រាំពីរព្រះអង្គ
គឺព្រះឧណ្ហី-[១]    សៈធាតុបញ្ចង់    មានមួយព្រះអង្គ    នៅគង់ល្អស្អាត ។
និងព្រះទាឋា[២]    សារីរិកធាតុ    ទាំងបួនល្អស្អាត    គ្មានឃ្លាតបែកចេញ
ព្រះអក្ខកធាតុ[៣]    នៅស្អាតពេញលេញ    គ្មានបែកបាក់ចេញ    ទាំងពីរព្រះអង្គ ។
ព្រះសារីរិកធាតុ    ភ្លឺស្អាតត្រចង់    ប្រាំពីរព្រះអង្គ    គង់នៅទាំងអស់
ព្រះសារីរិកធាតុ    ដ៏សេសពីនោះ    បែកចេញចំពោះ    បំណែកធំតូច ។

មហន្តា បញ្ច នាឡី ច    មជ្ឈិមា ច ឆ នាឡិយោ
ខុទ្ទកា បញ្ច នាឡី ច    សម្ភិន្នា តិវិធា មតា

ព្រះបរមធាតុ    មុនីនាថសាស្តា    ដែលបែកចេញជា    ចំណែកតូចធំ
លោកបានពោលទុក    ថាមានទំហំ    មានតូចមានធំ    មានខ្នាតកណ្តាល ។
ព្រះធាតុខ្នាតធំ    ចំនួនប្រាំនាឡិ    ព្រះធាតុកណ្តាល    ប្រាំមួយនាឡិគត់

---

(១)- ឆ្អឹងថ្ងាស ។ (២)- ព្រះចង្កូមកែវ ។ (៣)- ឆ្អឹងដងកាំបិត ។

ព្រះធាតុខ្នាតតូច ប្រាំនាឡិប្រាកដ តាមលោកកំណត់ បីយ៉ាងដូច្នេះ ។

មហន្តា តិន្នមុគ្គា ច មជ្ឈិមា តិន្នតណ្ឌុលា

ខុទ្ទកា សាសបមត្តា ឯចំ ធាតុប្បមាណិកា

ឯព្រះបរមធាតុ មានខ្នាតបីយ៉ាង លោកបានពោលអាង ទុកជាលំដាប់

ព្រះធាតុខ្នាតធំ ទំហំប៉ុនគ្រាប់ សណ្តែកបាយកាប់ កាត់មួយកំណាត់ ។

ព្រះធាតុខ្នាតកណ្តាល ដូចកាលគេកាត់ ប៉ុនមួយកំណាត់ នៃគ្រាប់អង្ករ

ព្រះធាតុខ្នាតតូច ល្អិតល្អបវរ លោកបានព្យាករណ៍ ថាប៉ុនគ្រាប់ស្ពៃ ។

មហន្តា សុវណ្ណវណ្ណា មជ្ឈិមា ផលិតប្បភា

ខុទ្ទកា ពកុលវណ្ណា ការិ ចន្ទាមិ ធាតុយោ

ព្រះសារីរិកធាតុ នៃព្រះភគវ៉ា មានពណ៌ផ្សេងគ្នា ទាំងបីវិលាស

ព្រះធាតុខ្នាតធំ មានពណ៌ដូចមាស ពន្លឺឱភាស វិសេសពេកក្តាត់ ។

ព្រះធាតុកណ្តាល វិសាលដូចរតន៍ កែវផ្លែកប្រាកដ ស្មើរចាប់ច្រឡំ

ព្រះធាតុខ្នាតតូច ដូចផ្កាពុលសម ពណ៌សស្រគាំ ពុំគួរងឿងឆ្ងល់ ។

ខ្ញុំសូមបង្គំ ប្រណម្យទៅដល់ ព្រះធាតុមង្គល ទាំងឡាយនោះផង

តេជះខ្ញុំថ្វាយ ឱនកាយរាបរង វាចាចិត្តផង សូមឆ្លងទៅដល់ ។

ទីព្រះបរមធាតុ មុនីនាថទសពល សូមជាមង្គល សុខសព្វវេលា

សូមឱ្យខ្ញុំបាន ដល់ឋានសុគាំ រហូតដល់នា ព្រះនិព្វានហោង ។

ឯកោ ថូបោ រាជគ្គហេ ឯកោ វេសាលិយា អហុ

ឯកោ កបិលវត្ថុស្មឹ ឯកោ ច អល្លកប្បកេ

ឯកោ ច រាមគាមស្មឹ ឯកោ ច វេដ្ឋទីបកេ

ឯកោ បាវេយ្យកេ មល្លេ ឯកោ ច កុសិនារកេ

ព្រះសថូបមួយបាន ប្រតិស្ឋាននា រាជគ្រឹះភាព មហាបុរី

មួយប្រតិស្ឋាន ក្រុងវេសាលី មួយនៅបុរី កបិលព័ស្តុសក្កៈ ។
ព្រះសថូបមួយនៅ អល្លកប្បកៈ ព្រះសថូបសោភៈ មួយនៅរាមគ្រាម
មួយនៅវេដ្ឋ- ទីបកៈដោយនាម ពួកក្សត្រនិងព្រាហ្មណ៍ ទុកជាសរណៈ ។
មួយនៅនាក្រុង បាវេយ្យកៈ នៅក្នុងមល្លៈ រដ្ឋជនបទ
ព្រះសថូបមួយមាន ទីឋានប្រាកដ នៅក្នុងរាជរដ្ឋ កុសិនារា ។

ឯតេ សារីរិកា ថូបា ជម្ពុទីបេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ

ព្រះសថូបទាំងឡាយ ទាំងប្រាំបីនោះ ជាទីបញ្ចុះ ព្រះសារីរិកធាតុ
ក្នុងជម្ពូទ្វីប ខ្ញុំសូមអភិវាទ នូវព្រះបរមធាតុ ទាំងឡាយទាំងនោះ ។
ក្នុងព្រះសថូប ប្រាំបីអង្គស្មោះ ដែលពួកសប្បុរស លោកតែងបូជា
ខ្ញុំសូមបង្គំ ប្រណម្យវន្ទា ទាំងមនុស្សទេវា បូជាសព្វកាល ។

ឯកា ទាឋា តិទសបុរេ ឯកា នាគបុរេ អហុ
ឯកា គន្ធារវិសយេ ឯកា សីហឡទីបកេ

ព្រះទាឋាធាតុ មុនីនាថមួយអង្គ[១] ប្រតិស្ឋានត្រង់ ក្នុងត្រៃត្រិង្សា
ព្រះទាឋាធាតុ មួយអង្គថ្លៃថ្លា ប្រតិស្ឋាននា ពិភពនាគនាយ ។
ព្រះទាឋាធាតុ មួយអង្គព្រេងព្រាយ ឋិតនគរនាយ គន្ធាររដ្ឋ
ព្រះទាឋាធាតុ មួយអង្គប្រាកដ ឋិតនៅរាជរដ្ឋ សីហឡទ្វីប ។

ឥមា ចតូសុ ឋានេសុ សត្ថុ ទាឋា បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ

ព្រះទាឋាធាតុ ទាំងឡាយឯណា ដែលព្រះសាស្ដា ទ្រង់ប្រតិស្ឋាន
ទាំងបួនកន្លែង នោះឯងមែនមាន ទ្រង់ទុកប្រទាន ឱ្យមនុស្សទេវា ។

---
(១)- ព្រះចង្កូមកែវ

ជាទីគោរព    ប្រតិបត្តិបូជា    ខ្ញុំសូមវន្ទា    ក្រាបថ្វាយបង្គំ
អំពីចម្ងាយ    ឱនកាយប្រណម្យ    ចំពោះព្រះបរ-    មធាតុនោះឯង ។

ឧទ្ធំ ទក្ខិណទាឋា ច    តាវត្តឹសេ បតិដ្ឋិតា
អធោ ទក្ខិណទាឋា ច    សីហឡទីបេ បតិដ្ឋិតា
វាមទាឋា ច ឧទ្ធម្បិ    គន្ធាររដ្ឋេ បតិដ្ឋិតា
វាមទាឋា ច អធោបិ    នាគលោកេ បតិដ្ឋិតា
បូជិតា នរទេវេហិ    អហំ វន្ទាមិ ធាតុយោ

ព្រះទាឋាធាតុ    ខាងលើខាងស្តាំ    ព្រះឥន្ទ្រនាំ    ទៅត្រៃត្រិង្សា
ព្រះទាឋាស្តាំ    ខាងក្រោមសោភា    ប្រតិស្ឋានា    សីហឡបុរី ។
ព្រះទាឋាឆ្វេង    ខាងលើសិរសី    នៅនាបុរី    ក្នុងដែនគន្ធារ
ទាឋាឆ្វេងក្រោម    នៃព្រះឈ្នះមារ    នៅក្នុងភាព    ពិភពនាគនោះ ។
ខ្ញុំព្រះករុណា    វន្ទាចំពោះ    នូវព្រះធាតុនោះ    គ្រប់ទីទាំងឡាយ
ដែលមនុស្សទេព្តា    តែងបូជាថ្វាយ    ព្រះធាតុទាំងឡាយ    ក្នុងទីនោះៗ ។

ព្រហ្មលោកេ ទុស្សធាតុ-    វាមអក្ខកធាតុយោ
សព្វេ ព្រហ្មាភិបូជេន្តិ    ថូបំ ទ្វាទសយោជនំ

ព្រះទុស្សធាតុ[១]    មុនីនាថឧត្តម    ដែលព្រះមហាព្រហ្ម    ឈ្មោះឃដិការ
ទទួលយកពី    ព្រះសាស្តាចារ្យ    ទៅទុកនមស្សការ    នៅព្រហ្មលោក ។
និងអក្ខកធាតុ[២]ឆ្វេង នៃព្រះមានជោគ    នៅក្នុងព្រហ្មលោក    ទាំងពីរព្រះអង្គ
មានព្រះសថូប    កំពស់ខ្ពស់ខ្ពង់    ដប់ពីរយោជន៍លង់    បញ្ចុះព្រះធាតុ ។
ខ្ញុំសូមបង្គំ    ព្រះបរមលោកនាថ    ចំពោះព្រះធាតុ    នៅព្រហ្មលោកនាយ ។

តាវត្តឹសម្ហិ ទេវានំ    ចូឡាមណិម្ហិ កេសកំ

(១)- ព្រះទុស្សធាតុ គឺព្រះពស្ត្រដែលព្រះអង្គផ្លាស់ចេញ បើបទ្រង់សំពត់កាសាវៈ។ (២)- ត្រូវអានថា អក្ខ.ខ:ធាតុ ។

**សព្វេ ទេវានិបូជេន្តិ បសន្នា ពុទ្ធសាសនេ**

**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

ទេវតាទាំងឡាយ ជាអ្នកជ្រះថ្លា ក្នុងពុទ្ធសាសនា បូជាចំពោះ
នូវព្រះកេសធាតុ ព្រះបរមទ្រង់យស នៅក្នុងទីខ្ពស់ ឋានត្រៃត្រិង្សា ។
ព្រះចូឡាមណី ចេតិយនោះណា ខ្ញុំសូមវន្ទា ក្រាបថ្វាយបង្គំ
ចំពោះព្រះធាតុ នៃព្រះបរម ទេវតាតូចធំ មូលមកបូជា ។

**ចត្តាឡីស សមា ទន្តា កេសា លោមា នខាបិ ច**

**ទេវា ហរន្តិ ឯកេកំ ចក្កវាឡបរម្បរា**

**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

ខ្ញុំសូមបង្គំ ប្រណម្យអភិវាទ នូវព្រះទន្តធាតុ ទាំងសែសិបផង
និងព្រះកេសធាតុ មុនីនាថជាច្បង ព្រះលោមធាតុផង និងព្រះនខធាតុ ។
ដែលពួកទេវតា នាំគ្នាខ្មីឃ្មាត នាំយកព្រះធាតុ មួយអង្គៗ
ទៅកាន់ចក្រវាឡ ដទៃពុំលង់ មួយអង្គៗ ក្នុងចក្រវាឡមួយ ។
ខ្ញុំព្រះករុណា វន្ទាលើកសំពះ បង្គំមួយៗ គ្រប់ទាំងចក្រវាឡ
ដែលពួកទេវតា មនុស្សាត្រអាល បូជាគ្រប់កាល ដោយក្តីជ្រះថ្លា ។

**អដ្ឋារស ទេ ចស្សសតេ ធម្មាសោកោ គតោ អហុ**

**ចតុរាសីតិសហស្សា ចេតិយា ច ការាបិតា**

**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

នាកាលព្រះពុទ្ធ- សករាជបាន ដោយលោកពោលអាន ទុកជាកំណត់
ពីររយដប់ប្រាំ- បីឆ្នាំប្រាកដ នោះជាមហាក្សត្រ ព្រះនាមហៅថា ។
ព្រះធម្មាសោក ព្រះទ័យជ្រះថ្លា ក្នុងពុទ្ធសាសនា បានសាងចេតិយ
ប្រាំបីម៉ឺនបួន- ពាន់ធូនជាថ្មី ថ្វាយព្រះជិនស្រី ក្នុងពុទ្ធសាសនា ។

ជាទីត្រេកអរ ទាំងមនុស្សទេព្តា តែងទៅបូជា ចេតិយទ្រង់យស
ព្រោះមានព្រះធាតុ ប្រសើរខ្ពង់ខ្ពស់ ជាទីអនុគ្រោះ ដល់មនុស្សទេវតា ។
ខ្ញុំសូមបង្គំ ព្រះបរមសាស្តា ចំពោះព្រះមហា ព្រះធាតុទាំងឡាយ
នៅក្នុងចេតិយ ដែលស្តេចសាងថ្វាយ ខ្ញុំសូមឱនកាយ ក្រាបថ្វាយវន្ទា ។
តេជះបារមី នៃព្រះភគវា ទុក្ខរោគភយា កុំបីកើតមាន
សូមសុខសព្វកាល ត្រអាលក្សេមក្សាន្ត សម្បត្តិធនធាន ចម្រើនឥតអាក់ ។
ព្រមទាំងកូនចៅ ញាតិផៅវូមរក្ស កុំបីបែកបាក់ និរាសព្រាត់ព្រាយ
ក្នុងវង្សត្រកូល មូលមិត្រសប្បាយ សម្បត្តិទាំងឡាយ កុំបីខ្វះខាត ។
តាំងពីពេលនេះ រៀង១រាល់ជាតិ កុំឱ្យឃ្លៀងឃ្លាត ពីក្តីប្រាថ្នា
សូមឱ្យខ្ញុំបាន ដល់ឋានទេវតា និងព្រះមហា និព្វាននាយហោង ។

## បទគាថា និយាយពីទ្រង់ផាស់តឿន

បរិបក្កោ វយោ មយ្ហំ បរិត្តំ មម ជីវិតំ
បហាយ វោ គមិស្សាមិ កតំ មេ សរណមត្តនោ
អប្បមត្តា សតីមន្តោ សុសីលា ហោថ ភិក្ខវោ
សុសមាហិតសង្កប្បា សចិត្តមនុរក្ខថ
យោ ឥមស្មឹ ធម្មវិនយេ អប្បមត្តោ វិហរិស្សតិ
បហាយ ជាតិសំសារំ ទុក្ខស្សន្តំ ករិស្សតីតិ ។

ប្រែ បទកាកគតិ

យើងជាពុទ្ធោ មានវ័យជរា ប្រាកដមែនហើយ ជីវិតនៃយើង
រស់មិនយូរឡើយ នឹងលះអ្នកហើយ ទៅកាន់និព្វាន ។

យថាបិ កុម្ភការស្ស កតំ មត្តិកភាជនំ
ខុទ្ទកញ្ច មហន្តញ្ច យញ្ច បក្កំ យញ្ច អាមកំ
សព្វំ ភេទនបរិយន្តំ ឯវំ មច្ចានជីវិតំ ។

ប្រែ. កាព្យពាក្យ ៨

ពួកជនណាៗ ទោះបីក្មេងចាស់ ទោះពាលផ្តេសផ្តាស ឬប្រាជ្ញបណ្ឌិត
អ្នកមានស្តុកស្តម្ភ ឬទ័លក្រីក្ត[១] អ្នកទាំងនោះពិត មានស្លាប់ទៅមុខ ។
ប្រៀបដូចចានឆ្នាំង សូនពីដីទុក តូចធំកំប៉ុក ឆ្អិនឆៅម្តេចម្តា
ភាជន៍ទាំងពួងនោះ តែងបែកប្រេះឆា ទៅជាធម្មតា ខាងចុងបំផុត ។
ជីវិតសត្វផង តែងនឹងទ្រោមទ្រុឌ មិនសម្បយុត្ត ដូច្នោះឯងហោង ។

(បុរាណភាសិត)

ចតុរង្គសន្និបាតរបស់ព្រះបរមគ្រូនៃយើងមានអង្គ ៨ គឺ ៖

១- មាឃនក្ខត្តេន យុត្តោ ថ្ងៃឧបោសថ ១៥ កើត ខែមាឃ ប្រកបដោយមាឃនក្ខត្តបូក្ស ។

២- ភេនទិ អនាមន្តិតា ព្រះអរហន្ត ១២៥០ រូប ឥតមានគេនិមន្ត ស្រាប់តែមកជុំគ្នាតាមធម្មតា ។

៣- គេសុ ឯកោ បុថុជ្ជនោ បណ្តាព្រះអរហន្តទាំងនោះ ឥតមានបុថុជ្ជនសេក្ខបុគ្គល និងអរហន្តសុក្ខវិបស្សកៈដល់ ១ អង្គឡើយ សុទ្ធតែជាព្រះខីណាស្រពទាំងអស់។

៤- ឯកោបិ ចេត្ត សត្តេន ឥតមានអង្គណាមួយ រកោរព្រះកេសដោយកាំបិតហើយបួសឡើយ សុទ្ធតែជា ឯហិ ភិក្ខុ ទាំងអស់ ។

(១)- ទិក្ក ប្រែថា ទ្រព្យ ។

# ធម៌សរសើរគុណព្រះសម្មាសម្ពុទ្ធ

| | |
|---|---|
| ខ្ញុំសូមសរសើរបុណ្យ | រំលឹកគុណព្រះជិនស្រី |
| កាលស្ដេចចាប់បដិ- | សន្ធិផ្ទៃព្រះមាតា ។ |
| បវរព្រះកន្លង | ព្រះអង្គហោងឆ្នាំរកា |
| នៅខែអាសាឍនា | ថ្ងៃព្រហស្បតិ៍ពេញបូណ៌មី ។ |
| នាកាលព្រះពោធិសត្វ | ប្រសូតថ្វាត់ចេញចាកផ្ទៃ |
| ឆ្នាំចពេញបូណ៌មី | ខែវិសាខថ្ងៃសុក្រច្បាស់ ។ |
| វេលាជិតថ្ងៃត្រង់ | ខំផ្ចិតផ្ចង់នឹកឱ្យណាស់ |
| ទន្ទេញឱ្យចាំច្បាស់ | ថ្វាយបង្គំយកបុណ្យទៅ ។ |
| កាលសោយរាជសម្បត្តិ | នោះជាក់ច្បាស់នៅឆ្នាំឆ្លូវ |
| ខែកត្តិតនោះនិត្យនៅ | ពេញបូណ៌មីថ្ងៃអាទិត្យ ។ |
| នាកាលព្រះពោធិសត្វ | ស្ដេចទ្រង់តាំងព្រះទ័យគិត |
| ចេញសាងព្រះផ្នួសពិត | នៅឆ្នាំថោះខែវិសាខ ។ |
| ថ្ងៃព្រហស្បតិ៍ជាសំដី | ពេញបូណ៌មីនោះជាអាទិ៍ |
| ឱ្យប្រុសស្រីដឹងជាតិ | ដឹងកំណើតព្រះពោធិ៍ ។ |
| បានត្រាស់នៅឆ្នាំរកា | ខែវិសាខពេញបូណ៌មី |
| ថ្ងៃពុធប្រាកដខ្ចី | ព្រះបាលីនិទានចេញ ។ |
| សម្ដេចព្រះទ្រង់ញាណ | ចូលនិព្វាននៅឆ្នាំម្សាញ់ |
| នៅខែវិសាខមិញ | ពេញបូណ៌មីថ្ងៃអង្គារ ។ |
| ខ្ញុំនឹងបង្គំនឹក | សូមរំលឹកពីអតីតា |
| កាលស្ដេចគង់ធម្មា | តែងទេស្នាប្រោសប្រទាន ។ |
| ភិក្ខុសង្ឃអង្គបរិស័ទ | ធ្លាប់ប្រណិប័តន៍ព្រះទ្រង់ញាណ |
| ពេញបូណ៌ខែមាឃមាន | ព្រះបញ្ញត្តចាត់វិន័យ ។ |

សុប្បដិបន្នោ ចត តស្ស ភគវតោ សោ សាវកសង្ឃោ យោ

សព្វទុក្ខស្ស បហានាយ បដិបន្នោ តំ សង្ឃំ អាទរេន នមស្សាមិ ៕

ព្រះអរិយសង្ឃឯណា លោកប្រតិបត្តិដើម្បីកំចាត់បង់នូវសេចក្តីទុក្ខទាំងពួង ព្រះអរិយសង្ឃនោះ ជាសង្ឃសាវ័កនៃព្រះភគវន្តមុនីអង្គនោះ លោកប្រតិបត្តិដោយប្រពៃមែនពិត យើងខ្ញុំព្រះអង្គ សូមក្រាបថ្វាយបង្គំ នូវព្រះអរិយសង្ឃនោះដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

ថ្ងៃនេះ ជាតិថីពេញបូណ៌មី នៃខែវិសាខ មានព្រះចន្ទ្រពេញវង់ ត្រូវនឹងថ្ងៃ ដែលព្រះសក្យមុនី សម្មាសម្ពុទ្ធ ជាបរមគ្រូ ទ្រង់ប្រសូត ទ្រង់បានត្រាស់ ជាសព្វញ្ញុពុទ្ធប្រាកដឡើងក្នុងលោក និងថ្ងៃដែលទ្រង់រំលត់ខន្ធ ចូលកាន់បរិនិព្វាន, តិថីនេះ ជាឧបលក្ខិតសម័យមួយដ៏ឧត្តម ក្នុងព្រះពុទ្ធសាសនា គឺជាថ្ងៃសម្រាប់ ពុទ្ធមាមកជនទាំងបព្វជិត ទាំងគ្រហស្ថ ប្រជុំគ្នាធ្វើសក្ការៈបូជា ចំពោះព្រះសម្មាសម្ពុទ្ធអង្គនោះ ព្រមទាំងព្រះធម៌ ជាបរមពុទ្ធោវាទ និងព្រះអរិយសង្ឃ ជាសាវ័កព្រះអង្គនោះ ។

ឥឡូវនេះ យើងទាំងអស់គ្នា ជាពុទ្ធសាសនិកជន បានមកប្រជុំគ្នា បានរៀបគ្រឿងសក្ការៈបូជាមានទៀនធូបនិងផ្កាភ្ញីជាដើម ក្នុងទីនេះ ដែលមានព្រះពុទ្ធរូបស្នងព្រះអង្គ(១) គង់ជាប្រធាន ហាក់ដូចជា ព្រះបរមសាស្តាអង្គនោះ ទ្រង់ស្តេចមកគង់ ក្នុងទីចំពោះមុខនៃយើងទាំងអស់គ្នា, យើងខ្ញុំសូមថ្វាយ នូវគ្រឿងសក្ការៈបូជាទាំងនេះ ចំពោះព្រះ-សម្មាសម្ពុទ្ធ ព្រះអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ រតនត្រ័យទាំងបីដោយសេចក្តីគោរព ។

បពិត្រព្រះសក្យមុនីបរមគ្រូ ព្រះអង្គជាបូជារហបុគ្គល របស់ទេវតានិងមនុស្សក្នុងលោក ឥតមានបុគ្គលណាមួយ ត្រឹមស្មើនឹងព្រះអង្គឡើយ ទោះបីព្រះអង្គចូលបរិនិព្វានបាត់ព្រះរូបព្រះកាយ អស់កាលយូរអង្វែងទៅហើយ ក៏ពិតមែន ប៉ុន្តែទ្រង់បានប្រតិស្ឋាន

(១)- ត្រង់ចន្លោះនេះ បើមានព្រះសារីរិកធាតុ, ត្រូវបញ្ចូលពាក្យថា «និងព្រះសារីរិកធាតុ» ផង ។

ព្រះវិសុទ្ធោវាទ គឺព្រះធម៌វិន័យ ដ៏បរិសុទ្ធវិសេស ទុកជាតំណាងព្រះអង្គ ទាំងព្រះគុណរបស់ព្រះអង្គ ក៏នៅមានប្រាកដ ទាំងព្រះសារីរិកធាតុ និងព្រះពុទ្ធរូបសូងព្រះអង្គ ក៏មាននៅប្រាកដដែរ សូមព្រះដ៏មានបុណ្យ ជាបរមសាស្ដា ទ្រង់ព្រះមេត្តាទទួល នូវគ្រឿងសក្ការៈបូជា របស់យើងខ្ញុំព្រះអង្គ ដែលបានរៀបចំថ្វាយក្នុងទីនេះ ដើម្បីជាផលានិសង្សឱ្យយើងខ្ញុំព្រះអង្គ បានប្រកបដោយ ឥដ្ឋមនុញ្ញផល វិបុលសុខ និងសេចក្ដីចម្រើនដ៏ធំទូលាយ អស់កាលជាយូរអង្វែងទៅហោង ។

(ក្រាបថ្វាយបង្គំ ៣ ដង)

ចប់ ពិធីប្រកាស វិសាខបូជា

លុះចប់វិធីប្រកាសវិសាខបូជាហើយនេះ សូមព្រះសង្ឃទាំងអស់ នមស្ការព្រះរតនត្រ័យតាមវិធីត្រៃប្រណាម និងធម៌សម្រាប់នមស្ការផ្សេងៗទៀត តាមដែលអាចសូធ្យបានគ្រប់អង្គតទៅ សូមភិក្ខុ ឬសាមណេរមានសំឡេងពិរោះ ដែលបានហាត់ហើយ សូធ្យ ២ អង្គម្ដងៗ នូវ «នមស្ការគាថា» ដូចមានខាងចុងនេះ ហើយនិមន្តធម្មកថិកសម្ដែងធម៌ទេសនា ។ លុះចប់ ធម៌ទេសនាហើយ ពុទ្ធបរិស័ទណា ចេះសូធ្យបទផ្សេងៗ ដែលស្របនឹងបុណ្យនេះ ក៏សូមសូធ្យឱ្យទាល់តែទើសភ្លឺទៅចុះ ។ ព្រោះក្នុងពិធីបុណ្យនេះ ពុទ្ធបរិស័ទគួរតែកំសាន្តតាមផ្លូវធម៌ឱ្យទាល់តែភ្លឺ ដើម្បីរក្សារបៀបពីបុរាណផង ។

ចប់

របៀបវិសាខបូជា

# វិសាខបូជា

វិសាខបូជានេះ មានពីរយ៉ាងគឺ ធ្វើនៅថ្ងៃពេញបូណ៌មី (១៥កើត) ខែពិសាខម្យ៉ាង ធ្វើថ្ងៃ ៨ រោច ម្យ៉ាង, ក៏ប៉ុន្តែវិសាខបូជាដែលត្រូវធ្វើនៅថ្ងៃ ៨ រោច ខែពិសាខនោះ នឹងមាននិយាយនៅខាងក្រោយ. ក្នុងខាងដើមនេះ នឹងនិយាយចំពោះវិសាខបូជា ដែលត្រូវធ្វើនៅថ្ងៃពេញបូណ៌មី (១៥កើត) ខែពិសាខ ។

វិសាខបូជានេះ បោរាណាចារ្យលោកសំដៅយកនក្ខត្តប្ញក្ស ៣ យ៉ាងគឺ កំណត់យកត្រង់ព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់ប្រសូត ១ ទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ១ ទ្រង់ចូលបរិនិព្វាន ១ ។

អាស្រ័យហេតុនេះជាអាទិ៍ ទើបអ្នកប្រាជ្ញបុរាណលោកកំណត់យក ថ្ងៃពេញបូណ៌មីនេះ ទុកជាពិធីធ្វើសក្ការៈបូជា ជាដរាបរៀងរាបមកទល់គ្នានឹងបច្ចុប្បន្ន សម័យនេះ ។

## បាលីបេរគ្រឿងសក្ការៈវិសាខបូជា

ឥទានាយំ ភន្តេ វិសាខបុណ្ណមី កាលោ សម្បត្តោ តស្ស អម្ហាកំ ភគវតោ កាល សទិសេន នក្ខត្តេន យុត្តោ បាតុភវិ ។ តថា ហិ ខោ អម្ហាកំ លោកនាយកោ សោណសំវច្ឆរេ វិសាខបុណ្ណមិយំ សុក្រវារេ គព្ភានិក្ខមនំ បត្តោ ច ភុក្ខរេ វិសាខបុណ្ណមិយំ ពុធវារស្មី សព្វញ្ញុតំ បត្តោ ច សម្បេ វិសាខបុណ្ណមិយំ អង្គារេ បរិនិព្វានំ បត្តោ ច អហោសិ ។ តស្មា មយំ សព្វេ តំ តំ តស្ស នក្ខត្តសមយំ អនុស្សរន្តា ឥធ សមាគតា ឥមេហិ ទីបធូបមាលាទីហិ សក្ការេហិ ច បូជំ ករោម ធម្មេហិ ច សាធុ ភន្តេ ភគវា សុចិរបរិនិព្វុតោបិ ឥវម អម្ហាកំ

ទុត្តបណ្ណាការភូតេ បដិគ្គណ្ហតុ សាសនស្ស ចិរត្ថាយ ចេវ អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ៕

ប្រែថា បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន កាលឥឡូវនេះ ជាថ្ងៃពេញបូណ៌មីខែពិសាខ ប្រកបដោយនក្ខត្តសម័យ ដូចសម័យរបស់ព្រះដ៏មានព្រះភាគ ជាម្ចាស់នៃយើងនោះប្រាកដ ។

ដ្បិតថាព្រះលោកនាយក ជាម្ចាស់នៃយើង កាលទ្រង់ប្រសូតចាកគភ៌ (ព្រះមាតា) ក្នុងថ្ងៃសុក្រ ពេញបូណ៌មីខែពិសាខឆ្នាំចនោះក្តី ត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ ក្នុងថ្ងៃពុធពេញបូណ៌មី ខែពិសាខឆ្នាំរកានោះក្តី ទ្រង់បរិនិព្វាន ក្នុងថ្ងៃអង្គារពេញបូណ៌មីខែពិសាខឆ្នាំម្សាញ់នោះក្តី មានហើយដោយពិត ។

ព្រោះហេតុនោះ (កាលឥឡូវនេះ) យើងខ្ញុំទាំងឡាយ រឭកនូវនក្ខត្តសម័យនោះៗរបស់ព្រះអង្គ ទើបនាំគ្នាមកជួបជុំទីនេះ ធ្វើបូជាដោយគ្រឿងសក្ការៈផ្សេងៗ មានប្រទីបទៀន ធូប និងកម្រងផ្កាជាដើមផង បូជាដោយធម៌ផង ។ បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ដែលទ្រង់បរិនិព្វានហើយ សូម្បីអស់កាលជាយូរអង្វែងហើយក្តី សូមព្រះអង្គទទួល នូវគ្រឿងបណ្ណាការទាំងនេះ ដែលជាទុត្តបណ្ណាការរបស់យើងខ្ញុំទាំងឡាយ ដើម្បីធ្វើឱ្យសាសនារុងរឿងស្ថិតស្ថេរទៅផង ដើម្បីជាប្រយោជន៍និងសេចក្តីសុខផង ដល់យើងខ្ញុំទាំងឡាយ អស់កាលជាយូរអង្វែងទៅហោង ៕

# នមោ ៨ បទ

## បទបឋ្យាវត្ត

នមោ អរ- ហតោ សម្មា- សម្ពុទ្ធស្ស មហេសិនោ

ខ្ញុំសូមបង្គំ ឆ្ពោះព្រះអរហន្ត សម្ពុទ្ធភគវន្ត កាលស្វែងរកធម៌
គឺពោធិញ្ញាណ ប្រសើរបវរ បានត្រាស់ដឹងធម៌ ដោយអរិយមគ្គ ។

នមោ ឧត្ត- ម ធម្មស្ស ស្វាក្ខា តស្សេ- វ តេនិធ

សូមថ្វាយបង្គំ ព្រះធម៌ឧត្តម ដែលព្រះបរម សម្ពុទ្ធសម្តែង
ដោយប្រពៃពិត ប្រាកដជាក់ស្តែង ព្រះធម៌នោះឯង ទុកក្នុងសាសនា ។

នមោ មហា សង្ឃស្សា បិ វិសុទ្ធសី- ល ទិដ្ឋិនោ

សូមថ្វាយបង្គំ ព្រះសង្ឃប្រសើរ ដែលលោកបានធ្វើ ទិដ្ឋិនិងសីល
ឱ្យបានបរិសុទ្ធ ផុតចាកមន្ទិល គឺទិដ្ឋិសីល លោកស្អាតអស់ហើយ ។

នមោ ឱមា- ត្យារទ្ធស្ស រតនត្តយ- ស្ស សាធុកំ

សូមថ្វាយបង្គំ ប្រជុំត្រ័យរ័ត្ន ប្រារព្ធដោយបទ មានបីប្រការ
ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃឈ្នះមារ ប្រសើរអស្ចារ្យ ថ្លឹងថ្លែងពុំបាន ។

នមោ ឱម- កាតី តស្ស តស្ស វត្ថុ- ត្តយស្សាបិ

សូមថ្វាយបង្គំ ភ្ជុំវត្ថុបី ពិសេសពិសី ប្រសើរថ្កើងថ្កាន
ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃសព្វឋាន តេជះកល្យាណ ដោយគុណគួរគាប់ ។

នមោ ការ- ប្បភាវេន វិគច្ឆន្តុ ឧបទ្ទវា

សូមថ្វាយបង្គំ ត្រ័យរ័ត្នសោភា ឧបទ្រពនានា ចូរវិនាសបាត់

ដោយអានុភាព  បុណ្យជួយកំចាត់  ធ្វើក្តីវិបត្តិ  ឱ្យស្ងាត់សូន្យទៅ ។

នមោ ភាគ- ន្ទភាវេន សុវត្ថិ ហោ- តុ សព្វទា

សូមថ្វាយបង្គំ  ត្រ័យរ័ត្នទាំងបី  សូមសុខសួស្តី  កើតសព្វវេលា
ដោយអានុភាព  ធ្វើការវន្ទា  គោរពបូជា  ឆ្ពោះព្រះត្រ័យរ័ត្ន ។

នមោ ភាគ- ស្ស តេជេន ឋិតិម្ហិ ហោ- មិ តេជសា

សូមថ្វាយបង្គំ  ត្រ័យរ័ត្នសោភា  តេជះចេស្តា  ចូរមានដល់ខ្ញុំ
ក្នុងពិធីធ្វើ  កិច្ចថ្វាយបង្គំ  តេជះបុណ្យធំ  សូមកើតឡើងហោង ។

ចប់

នមោ ៨ បទ

## នមោ ៣ បទ

បទបង្សាវិត្ត

នមោ តស្សារហន្តស្ស ភគវន្តស្ស តាទិនោ
សម្មាសាមំ ច ពុទ្ធស្ស ធម្មេ ឋិតបទានិនោ

សូមថ្វាយបង្គំ  ឆ្ពោះព្រះអរហន្ត  ទ្រង់នាមភគវន្ត  ប្រសើរបវរ
ព្រះអង្គមិនមាន  ព្រះទ័យញាប់ញ័រ  ដោយលោកធម៌  ទាំង ៨ ឡើយ ។
ទ្រង់ត្រាស់ដឹងធម៌  ដោយប្រពៃហើយ  ចែកធម៌នោះឱ្យ  ដល់សត្វទាំងពួង

នមោ តស្សេវធម្មស្ស និយ្យានិ តស្សេវ ដ្ឋតោ
បរោបានបចីធស្ស ស្វាក្ខាតស្សេវ សច្ចតោ

សូមថ្វាយបង្គំ ឆ្ពោះគុណព្រះធម៌ ស្រង់សត្វនិករ ចេញចាកសង្សារ
ជាធម៌មានភេទ ៩ ប្រការ ដែលសាស្ដាចារ្យ ពោលទុកទូន្មាន ។
មានព្រះសោតា នោះជាប្រធាន មានព្រះនិព្វាន ជាបរិយោសាន

នមោអរិយសង្ឃស្ស សព្វិន្ធកស្ស សត្ថុនោ
កិលេសានុសយេសព្វេ បហានប្បដិបត្តិយា

សូមថ្វាយបង្គំ ឆ្ពោះគុណព្រះសង្ឃ ប្រសើរគ្រប់អង្គ ជាសិស្សសាស្ដា
ជាសង្ឃប្រតិបត្តិ លះកាត់តណ្ហា ព្រះទ័យជ្រះថ្លា ភ្មានសៅហ្មងឡើយ ។
អនុស័យកិលេស លោកលះអស់ហើយ នឹងឆ្លងដល់ត្រើយ គឺព្រះនិព្វាន

## នមោ ៣ បទ រួបរួមជា ១ បទ

បទបថ្យាវត្ត

នមេ ពុទ្ធំ តិលោកគ្គំ ញេយ្យសាគរបារគុំ
តថាគតេ តរំ ធម្មំ គណញ្ច គុណសាគរំ

សូមថ្វាយបង្គំ នូវព្រះសម្ពុទ្ធ ប្រសើរខ្ពស់ផុត សត្វក្នុងត្រៃលោក
ព្រះអង្គមានញាណ ជ្រាលជ្រៅប្រាជ្ញប្រពោក ហើយឆ្លុះទ្រង់ជោត ដល់ត្រើយសាគរ ។
សូមថ្វាយបង្គំ ព្រះធម៌បវរ ញាំងសត្វនិករ ឱ្យឆ្លងចាកភព
សូមថ្វាយបង្គំ ព្រះសង្ឃជាម្លប់ គុណគួរគោរព ដូចសាគរធំ ។
តេជានុភាព ផលថ្វាយបង្គំ សូមឱ្យយើងខ្ញុំ បានសុខសព្វកាល

## គាថាប្រារព្ធពិសាខបូជា

បទបថ្យាវត្ត

ពិសាខបុ- ណ្ណមាយំយោ ជាតោអគ្គិ មជាតិយា
បត្តោចអ- ភិសម្ពោធឹ អថោបិប- រិនិព្វុតោ
លោកេអនុ- ត្តរោសត្ថា ទយាញាណ ណ្ណវាសយោ
នាយកោមោ- ក្ខមគ្គស្មឹ តិវិធត្ថូ បទេសកោ
មហាការុ- ណិកំនាថំ មយន្តំស- រណំ គតា
អាមិសេហិ ចបូជេន្តា ធម្មេហិប- ដិបត្តិយា
ឥមន្ទានិ សុនក្ខត្តំ អភិមង្គ- លសម្មតំ ។

ប្រែ. កាព្យបថ្យាវត្ត

វីរអង្គសម្ពុទ្ធ ជាម្ចាស់ឯណា ប្រពៃថ្លៃថ្លា អស្ចារ្យក្នុងលោក
ក្នុងជាតិជាទី បំផុតឥតរក អ្នកណាមានជោគ ស្មើនឹងព្រះអង្គ ។

ដែលទ្រង់ប្រសូត នៅក្រោមដើមរាំង ជាអស្ចារ្យខ្លាំង ក្នុងលោកទាំងបី
ក្នុងថ្ងៃសុក្រជា ពារពេញបូណ៌មី ខែវិសាខនៃ រវាងឆ្នាំច ។

លុះព្រះជន្មម្ភៃ ប្រាំបួនហើយក៏ ទ្រង់យាងចេញចរ ទៅបព្វជ្ជា
កណ្ដាលអធ្រាត្រ ថ្ងៃពេញបុណ្ណមា ខែអាសាឍនា រវាងឆ្នាំថោះ ។

លុះព្រះជន្មសាម សិបប្រាំទ្រង់ត្រាស់ ដឹងសព្វគ្មានខ្វះ ជាសព្វញ្ញូ
ក្នុងថ្ងៃពុធពិត ជាថ្ងៃពេញបូណ៌ ខែវិសាខោ នាឆ្នាំរកា ។

ហើយជាគ្រូធំ លើមនុស្សទេព្តា ឥតមានសាស្តា ដទៃផ្ទឹមបាន
ទ្រង់មានករុណា នឹងបញ្ញាញាណ ជ្រាលជ្រៅដូចស្ពាន មហាសមុទ្រ ។

នឹងអធ្យាស្រ័យ មិនរើសមុខមាត់ ទ្រង់យាងនាំសត្វ ក្នុងផ្លូវនិព្វាន
ហើយទ្រង់សំដែង សេចក្តីទូន្មាន បីប្រការបាន គ្រប់ពួកបរិស័ទ ។

លុះដល់ព្រះអង្គ ព្រះជន្មកំណត់ ប៉ែតសិបឆ្នាំគត់ ទ្រង់ចូលនិព្វាន
លើផែនថ្មធំ ឧត្តមក្សេមក្សាន្ត ក្រោមដើមរាំងផែន កុសិនារា ។

ក្នុងថ្ងៃអង្គារ ពារពេញបុណ្ណមា នៃវិសាខា រវាងឆ្នាំម្សាញ់
យើងខ្ញុំទាំងឡាយ មិនមានកំណាញ់ ជឿស្មោះអស់អញ្ច ក្នុងការកុសល ។

សូមដល់ព្រះពុទ្ធ ព្រះអង្គតម្កល់ ព្រះទ័យខ្ជាយខ្ពស់ ករុណាដល់សត្វ
អង្គនោះថាជា ទីពឹងប្រាកដ ស្មើដោយជីវិត ឥតពឹងដទៃ ។

ហើយសូមបូជា ដោយគ្រឿងប្រពៃ តាមពាក្យបាលី ហៅថាអាមិស
នឹងដោយទូវធ- ម្មបូជានេះ ប្រតិបត្តិមិនខុស ក្នុងព្រះធម៌ឡើយ ។

យើងខ្ញុំទាំងឡាយ ឱនកាយថ្វាយហើយ ចិត្តពុំកន្តើយ ក្រេបយកប្រយោជន៍
ចំពោះមគ្គផល ដល់ទៅបរលោក សូមឱ្យមានជោគ គ្រប់ជាតិទៅហោង ។

ចប់
គាថាប្រារព្ធវិសាខបូជា

## សត្តមហាឋាន

បទបថ្យាវត្ត

បឋមំ ពោធិបល្លង្កំ ទុតិយំ អនិមិស្សកំ
តតិយំ ចង្កមំ សេដ្ឋំ ចតុត្ថំ រតនឃរំ ៗ
បញ្ចមំ អជបាលញ្ច មុច្ចលិន្ទេន ឆដ្ឋមំ
សត្តមំ រាជាយតនំ សត្ថាហំ មុនិ សេវិតំ ៗ
ឯតេ សត្ត មហាឋានា ជម្ពុទីបេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ទូរតោ ៗ

## ឋានធំ ៧ កន្លែង

ប្រែ. កាព្យបថ្យាវត្ត

ទីមួយបល្ល័ង្ក ដែលព្រះសាស្ដា ចំរើនអានា- បានស្បតិ
ទីពីរព្យសាន ពីដើមពោធិ ហៅថាអនិមិ- ស្សកចេតិយ ។
ទីបីគឺទី ដែលព្រះជិនស្រី ព្រះអង្គយាត្រខ្មី ទ្រង់យាងចង្ក្រម
ទីបួនគឺទី ដែលព្រះបរម ចំរើនអភិធម្ម ជាធម៌បរមត្ថ ។
ទីប្រាំគឺទី ដែលព្រះភគវ័ត ទ្រង់គង់ស្ងប់ស្ងាត់ ក្រោមអជបាល
ទីប្រាំមួយទី វិសេសវិសាល ស៊ិតសំរាល ក្បែរស្រះមុច្ចលិន្ទ ។
ទីប្រាំពីរគឺ ទីព្រះមុនិន្ទ សង្រួមឥន្ទ្រីយ៍ រាជាយតនា
ទីទាំងប្រាំពីរ ដែលពោលនេះណា ជាទីថ្លៃថ្លា មានពិតប្រាកដ ។
ក្នុងជម្ពូទ្វីប នេះជាកំណត់ ប្រាជ្ញលោកសន្មត ហៅថាឋានធំ
ព្រោះជាកន្លែង ដ៏ល្អឧត្តម ជាទីមនោរម្យ ដល់មនុស្សទេព្តា ។
ជាទីសំរាប់ អ្នកមានសទ្ធា នាំគ្នាវន្ទា យកបុណ្យកុសល
ខ្ញុំសូមក្រាបថ្វាយ បង្គំឆ្ពោះដល់ ឋានធំនិមល់ នោះពីចម្ងាយ ។

# អដ្ឋមហាឋាន

## បទបឋ្យាវត្ត

បឋមំ លុម្ពិនីជាតំ ទុតិយំ ពោធិមុត្តមំ
តតិយំ ធម្មចក្កញ្ច ចតុត្ថំ បាលិលេយ្យកំ ។
បញ្ចមំ ច នាឡាគិរី ឆដ្ឋមំ បាដិហារិយំ
សត្តមំ សិរិទេវិន្ទំ អដ្ឋមំ បរិនិព្វុតំ ។
ឯតេ អដ្ឋ មហាឋានា ជម្ពុទីបេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ទូរតោ ។

## ឋានធំ ៨ កន្លែង

### ប្រែ. កាព្យបឋ្យាវត្ត

ឋានធំទាំងឡាយ ប្រាំបីកន្លែង ជាទីស្ងប់ស្ងែង ដល់ពពួកសត្វ
ទីមួយឧទ្យាន ជាឋានព្រៃស្ងាត់ គឺព្រៃសាលវ័ត្ត ដែលទ្រង់ប្រសូត ។
ទីពីរប្រសើរ ដែលព្រះទ្រង់ស្រូត ត្រាស់ក្រោមដើមពោ- ធិព្រឹក្សឧត្តម
ទីបីកន្លែង ដែលព្រះបរម សម្ដែងព្រះធម៌ ឈ្មោះធម្មចក្រ ។
ប្រោសភិក្ខុប្រាំអង្គ គឺពួកបញ្ចវ- គ្គីយ៍ដែលជាអ្នក បំរើព្រះអង្គ
ដោយព្រះទ័យថ្លៃ មិនអាចលះបង់ ហើយយាងតម្រង់ ពីដើមពោធិ៍ទៅ ។
ទីបួនគឺទី ដែលទ្រង់គង់នៅ ក្នុងស្ថានព្រៃជ្រៅ ឈ្មោះបាលិលេយ្យក៍
ទីនោះគ្មានមនុស្ស មានតែសត្វព្រៃ គឺដំរីថ្លៃ បំរើព្រះអង្គ ។
ទីប្រាំឈ្មោះថា រតនបល្ល័ង្ក ទីដែលទ្រង់ច្បាំង នាឡាគិរី
ទីនោះមានមនុស្ស បែកពួកជាពីរ ទៅមើលឫទ្ធី សម្ដេចសម្ពុទ្ធ ។
ទីប្រាំមួយកាល ព្រះសព្វញ្ញូ- តញ្ញាណជាមកុដ ធ្វើបាដិហារ្យ
ផ្ចាញ់ពួកនិគ្រន្ថ ក្រៅពុទ្ធសាសនា ឈ្នះល្បីអស្ចារ្យ គ្មាននរណាដល់ ។

ទីប្រាំពីរកាល ព្រះទសពល គង់លើមណ្ឌល ថ្មព្រះឥន្ទ្រា
ទ្រង់បានសម្តែង នូវព្រះធម្មា ប្រាកដនាមថា ធម៌អភិធម្ម ។
សងគុណមាតា ដែលមានគុណធំ លើព្រះបរម សម្ពុទ្ធមុនី
ដែលមាននាមថា មាយាទេវី នាងយាងចុះពី សួគ៌ឋានតុសិត ។
អស់ពួកទេព្តា ដង្ហែជុំជិត យាងមកសណ្ឋិត ឋានត្រៃត្រិង្សា
ទីប្រាំបីកាល អង្គព្រះសាស្តា ផ្ទំក្រោមដើមសា- លៈព្រឹក្សទាំងគូ ។
ពេលនោះឯងហើយ ព្រះសព្វញ្ញូ ព្រះអង្គជាគ្រូ យាងចូលនិព្វាន
ឋានធំប្រាំបី កន្លែងនេះមាន ប្រតិស្ឋានក្នុង ជម្ពូទ្វីបា ។
ជាទីដែលពួក មនុស្សនិងទេព្តា ធ្វើគ្រឿងសក្ការ គោរពបូជា
ខ្ញុំសូមឱនកាយ បង្គំវន្ទា ឆ្ពោះទីនោះណា អំពីចម្ងាយ ។
ដោយការប្រណម្យ បង្គំថ្វាត់ថ្វាយ ឋានធំទាំងឡាយ ប្រាំបីនោះឯង
សូមសុខចម្រើន កើនយូរអង្វែង ទុក្ខសោកចំបែង កុំកើតមានឡើយ ។
នឹងបានរួចទោស ឆ្លងដល់កោះត្រើយ ជាតិនេះឯងហើយ វាសនាខ្ពស់ខ្ពង់
សូមឱ្យខ្ញុំបាន · ឋានធំឧត្តុង្គ ឧត្តមយូរលង់ គឺនិព្វានហោង ។

៙

ចប់

ឋានធំ ៨ កន្លែង

# នមក្ការគាថា

## មហានាគនមក្ការគាថា[១]

គាថានមស្ការចំពោះព្រះមហានាគ

បឋ្យាវត្តឆន្ទ

សេដ្ឋោ តថាគតោ លោកេ ពុទ្ធនាគោតិ វិស្សុតោ
នាគេន ទេសិតោ ធម្មោ និយ្យានិកោតិ សញ្ញតោ
តស្សាបិ សាវកោ សង្ឃោ សន្តិន្ទ្រិយោ អនាសវោ
នាគោ បាបកំ អាគុំ តស្មា នាគោតិ វុច្ចរេ ។

កាព្យបឋ្យាវត្ត (កុំច្រឡំហៅកាព្យពាក្យ ៨)

ព្រះតថាគត វិសុទ្ធក្នុងលោក ព្រះអង្គមានជោគ លើសលោកទាំងបី
ព្រះនាមពុទ្ធនាគ ជាពាក្យបាលី អស់ជនប្រុសស្រី គប្បីដឹងច្បាស់ ។
ថាជាព្រះនាម ព្រះពុទ្ធជាម្ចាស់ ប្រសើរពេកណាស់ លើសមនុស្សទេវា
ព្រះធម៌ដែលព្រះ- ពុទ្ធនាគទេសនា ប្រោសដល់ទេវតា មនុស្សសត្វទាំងឡាយ ។
ជាធម៌ស្រង់សត្វ ឱ្យផុតអបាយ អ្នកប្រាជ្ញទាំងឡាយ លោកបានជ្រាបច្បាស់
ព្រះអរិយសង្ឃ សាវ័កច្រើនណាស់ ជាសង្ឃនៃព្រះ- ពុទ្ធនាគជាធំ ។
សង្រួមឥន្ទ្រិយ៍ ស្រគត់ស្រគំ កិលេសតូចធំ ក្សិណក្ស័យអស់ហើយ
លោកឈប់ស្រឡះ គ្មានប៉ះពាល់ឡើយ ព្រះសង្ឃនេះហើយ ដែលទ្រង់ប្រទាន ។
នាមថានាគោ ទុកជាប្រធាន ព្រោះហេតុពុំមាន ធម៌ដ៏លាមក
លោកឈប់ស្រឡះ លែងធ្វើអាក្រក់ ព្រោះលោកនាយក ព្រះពុទ្ធនាគនោះ ។

---

(១)- មហានាគនមក្ការគាថានេះ និងអដ្ឋវីសសម្ពុទ្ធនមក្ការគាថាខាងចុងបន្ទាប់គ្នានេះ សម្តេចព្រះមហាសុមេធាធិបតី (ជ.ណ ជោតញ្ញាណោ) ទ្រង់បានប្រែជាសម្រាយពាក្យរាយ តាំងពី ព.ស ២៤៧៦, គ.ស ១៩៣៣ ។ លោក អ៊ុំ ខេម ប្រែជាកាព្យបោះពុម្ពជាសៀវភៅ ១ ឈ្មោះ នមក្ការគាថា តាំងពី ព.ស ២៤៨៨, គ.ស ១៩៤៥ ។

ទ្រង់ប្រោសប្រទាន នាគោថាឈ្មោះ ជាពាក្យពីរោះ ចំពោះពុទ្ធដីកា
ដោយមានគម្ពីរ ព្រះមុនីទេសនា ប្រារព្ធនឹងកា- ឡុទាយីនោះ ។

ឧទ្ទេហំ ពុទ្ធនាគញ្ច ធម្មំ នាគេន ទេសិតំ
នាគិស្សរិយសង្ឃញ្ច មហានាគន្តិ ឋិស្សុតំ
ពុទ្ធនាគានិគេដេន ឧប្បន្នា ចេ ឧបទ្ទវា
រោគា ចេវន្តរាយា ច ខិនស្សន្តុ អសេសតោ ។

យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំ ចំពោះព្រះបរម ព្រះពុទ្ធនាគផង
ចំពោះព្រះធម៌ ប្រសើរកន្លង ដែលព្រះច្បាស់ច្បង ពុទ្ធនាគសម្តែង ។
និងព្រះអរិយសង្ឃ ព្រមទាំងតម្កែង មាននាមជាក់ស្តែង ហៅមហានាគោ
ជាទីសាវ័ក មានថ្នាក់សេង្ហោ ព្រះពុទ្ធនាគោ ប្រទានទុកមក ។
តេជះរ័ត្នត្រៃ ថ្លាថ្លៃពន្លក យើងខ្ញុំសូមជ្រក ក្រោមម្លប់សាខា
មានព្រះពុទ្ធនាគ ជាដើមថ្លៃថ្លា ទោះរោគភយា ឧបទ្រពអន្តរាយ ។
ដែលកើតមានឡើង ឱ្យប៉ើងខ្ចាត់ខ្ចាយ សូមឱ្យរលាយ វិនាសបាត់ទៅ
បើពុំទាន់មាន ឱ្យខាននៅក្រៅ ចៀសចេញឆ្ងាយទៅ កុំនៅរៀងអាយ ។
សូមសុខសព្វកាល ត្រអាលសប្បាយ សម្បត្តិទាំងឡាយ សម្បូណ៌ឥតខ្វះ ។

៚

ចប់

នមក្ការគាថា

## អដ្ឋវីសសម្ពុទ្ធនមក្ការគាថា

### គាថានមស្ការចំពោះព្រះសម្ពុទ្ធ ២៨ ព្រះអង្គ

| | |
|---|---|
| វន្ទេ តណ្ហង្ករំ ពុទ្ធំ | វន្ទេ មេធង្ករំ មុនឹ |
| សរណង្ករំ មុនឹ វន្ទេ | ទីបង្ករំ ជិនំ នមេ |
| វន្ទេ កោណ្ឌញ្ញសត្ថារំ | វន្ទេ មង្គលនាយកំ |
| វន្ទេ សុមនសម្ពុទ្ធំ | វន្ទេ រេវតនាយកំ |
| វន្ទេ សោភិតសម្ពុទ្ធំ | អនោមទស្សឹ មុនឹ នមេ |
| វន្ទេ បទុមសម្ពុទ្ធំ | វន្ទេ នារទនាយកំ |
| បទុមុត្តរំ មុនឹ វន្ទេ | វន្ទេ សុមេធនាយកំ |
| វន្ទេ សុជាតសម្ពុទ្ធំ | បិយទស្សឹ មុនឹ នមេ |
| អត្ថទស្សឹ មុនឹ វន្ទេ | ធម្មទស្សឹ ជិនំ នមេ |
| វន្ទេ សិទ្ធត្ថសត្ថារំ | វន្ទេ តិស្សមហាមុនឹ |
| វន្ទេ ផុស្សមហាវីរំ | វន្ទេ វិបស្សិនាយកំ |
| សិខឹ មហាមុនឹ វន្ទេ | វន្ទេ វេស្សភូនាយកំ |
| កកុសន្ធំ មុនឹ វន្ទេ | វន្ទេ កោនាគមនំ ជិនំ |
| កស្សបំ សុគតំ វន្ទេ | វន្ទេ គោតមនាយកំ |
| អដ្ឋវីសតិមេ ពុទ្ធា | និព្វានា មតទាយកា |
| នមេ តេ សិរសា និច្ចំ | តេ មំ រក្ខន្តុ សព្វទា ។ |

# កាព្យបវ្យាវត្ត (កុំច្រឡំហៅកាព្យពាក្យ ៨)

ខ្ញុំសូមបង្គំ ព្រះបរមសម្ពុទ្ធ មាននាមប្រាកដ ព្រះតណ្ហង្ករ
ខ្ញុំសូមបង្គំ ព្រះបរមបវរ ព្រះមេធង្ករ ជាសម្ពុទ្ធា ។
សូមថ្វាយបង្គំ ប្រណម្យវន្ទា នូវព្រះភគវា ព្រះសរណង្ករ
សូមថ្វាយបង្គំ ព្រះទីបង្ករ មានញាណបវរ បារមីពោរពេញ ។
សូមថ្វាយបង្គំ នូវព្រះកោណ្ឌញ្ញ ព្រះអង្គបំពេញ ធម៌ជាកុសល
ខ្ញុំសូមបង្គំ នូវព្រះទសពល ព្រះនាមមង្គល ជាសម្ពុទ្ធ: ។
ខ្ញុំសូមបង្គំ ប្រណម្យគារវៈ ព្រះនាមសុមនៈ សម្មាសម្ពុទ្ធ
ខ្ញុំសូមបង្គំ ព្រះបរមសុគត ព្រះនាមប្រាកដ ព្រះរេវតៈ ។
ខ្ញុំសូមបង្គំ ព្រះសម្ពុទ្ធ: មានញាណសោភៈ ព្រះនាមសោភិត
ខ្ញុំសូមបង្គំ ប្រណម្យប្រណិត ឆ្ពោះព្រះវិជិត អនោមទស្សី ។
ខ្ញុំសូមក្រាបថ្វាយ ឱនកាយសិរសី ចំពោះព្រះមុនី ព្រះនាមបទុម
ខ្ញុំសូមឱនកាយ · ថ្វាយថ្វាត់បង្គំ ចំពោះព្រះបរម ព្រះនាមនារទៈ ។
សូមថ្វាយបង្គំ ព្រះបទុមុត្តរៈ មានញាណសោភៈ វរៈពុទ្ធា
ខ្ញុំសូមបង្គំ នូវព្រះភគវា ទ្រង់ព្រះនាមា សុមេធសម្ពុទ្ធ ។
ខ្ញុំសូមបង្គំ ប្រណម្យក្រាបលុត ឆ្ពោះព្រះសម្ពុទ្ធ ព្រះនាមសុជាត
ខ្ញុំសូមបង្គំ ប្រណម្យអភិវាទ . ឆ្ពោះព្រះមុនីនាថ បិយទស្សី ។
ខ្ញុំសូមបង្គំ ឆ្ពោះព្រះជិនស្រី អត្ថទស្សី បារមីខ្ពង់ខ្ពស់
ខ្ញុំសូមបង្គំ ឆ្ពោះព្រះទ្រង់យស ព្រះនាមចំពោះ ធម្មទស្សី ។
ខ្ញុំសូមបង្អោន លំទោនសិរសី បង្គំជិនស្រី ព្រះនាមសិទ្ធត្ថ
ខ្ញុំសូមបង្គំ នូវព្រះមុនីរ័ត្ន ព្រះនាមប្រាកដ តិស្សសាស្តា ។
ខ្ញុំសូមបង្គំ នូវព្រះសម្មា- សម្ពុទ្ធនាមថា ផុស្សៈមុនី
ខ្ញុំសូមបង្គំ ប្រណម្យអញ្ជលី ឆ្ពោះព្រះមុនី ព្រះនាមវិបស្សី ។

សូមថ្វាយបង្គំ ព្រះបរមជិនស្រី ព្រះនាមសិខី សព៌ជ្ញពុទ្ធា
ខ្ញុំសូមឱនកាយ ក្រាបថ្វាយវន្ទា ឆ្ពោះព្រះភគវា ព្រះនាមវេស្សភូ ។
ខ្ញុំសូមបង្គំ លើកហត្ថទាំងគូ ឆ្ពោះព្រះជាគ្រូ នាមកកុសន្ធៈ
ខ្ញុំសូមបង្គំ ប្រណម្យគារវៈ ឆ្ពោះព្រះពុទ្ធៈ កោនាគមនោ ។
ខ្ញុំសូមឱនកាយ វាចាមនោ បង្គំពុទ្ធោ ព្រះនាមកស្សបៈ
ខ្ញុំសូមលំទោន បង្អោនសិរសៈ ឆ្ពោះព្រះសមណៈ ព្រះនាមគោតម ។
គម្រប់ម្ភៃប្រាំ- បីព្រះបរម សម្ពុទ្ធជាធំ កំពូលលោកា
ទូទាំងត្រៃភព ជាម្លប់សាខា មនុស្សសត្វទេវតា មារព្រហ្មទាំងឡាយ ។
ដែលបានចូលជ្រក ក្រោមម្លប់ព្រះឆាយ បានសុខសប្បាយ គ្រប់រូបរាល់គ្នា
បានទៅសោយសុខ ក្នុងឋានសួគ៌ា ឬឋានព្រហ្មា និងព្រះនិព្វាន ។
ដោយបុណ្យបារមី នៃព្រះទ្រង់ញាណ ព្រះធម៌ប្រធាន ជាយាននាំសត្វ
តេជៈយើងខ្ញុំ ប្រណម្យថ្វាយថ្វាត់ នូវព្រះពុទ្ធរ័ត្ន គ្រប់ៗព្រះអង្គ ។
ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ សាវ័កគ្រប់អង្គ ទាំងម្ភៃប្រាំបី
សូមអានុភាព ពីព្រះជិនស្រី ទាំងម្ភៃប្រាំបី ព្រះអង្គនោះឯង ។
ព្រមទាំងព្រះធម៌ ព្រះអង្គសម្តែង ទាំងព្រះតម្លែង សង្ឃជាសាវ័ក
សូមសុខចម្រើន កើនឡើងតាមថ្នាក់ កុំឱ្យមានអាក់ អន់អាប់ឡើយណា ។
សូមឱ្យខ្ញុំបាន ដល់ឋានទេវតា ដូចក្តីប្រាថ្នា កុំបីឃ្លៀងឃ្លាត
មានព្រះនិព្វាន ជាអវសានជាតិ កុំឱ្យខ្ញុំឃ្លាត បច្ចយោ ហោតុ! ។

ចប់

អដ្ឋវីសសម្ពុទ្ធនមក្ការគាថា

# ពុទ្ធបាទនមស្ការគាថា[១]

គាថានមស្ការស្ពាមព្រះបាទព្រះពុទ្ធ

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ
តិលោកកេតុំ តិភវេកនាថំ
យោ លោកសេដ្ឋោ សកលំ កិលេសំ
ឆេត្វាន ពោធេសិ ជនំ អនន្តំ ៗ

ព្រះសព្វញ្ញុពុទ្ធ វិសេសផុតត្រៃលោកា
គ្មានមនុស្សឬទេវតា ព្រហ្មាណាប្រដូចបាន ។
កម្ចាត់នូវកិលេស គ្មានឱ្យសេសនៅសល់ខាន
ញ៉ាំងជនទាំងប៉ុន្មាន ជាអនន្តឱ្យត្រាស់ដឹង ។
ខ្ញុំសូមថ្វាយបង្គំ នូវព្រះបរមជាទីពឹង
ព្រះអង្គឆ្លងផុតស្ទឹង បានដល់ច្រាំងនៃភពហើយ។
ព្រះអង្គជាទង់ជ័យ ធំត្រៃឈៃបង្ហាញត្រើយ
តែមួយព្រះអង្គហើយ ជាទីពឹងក្នុងត្រៃភព ។
មារព្រហ្មទាំងទេព្តា និងមនុស្សាតែងគោរព
ចូលជ្រកនៅក្រោមម្លប់ ពោធិញ្ញាណបានសុខា ។

យំ នម្មទាយ នទិយា បុលិនេ ច តីរេ
យំ សច្ចពន្ធ គិរិកេ សុមនា ច លគ្គេ
យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ
តំ បាទលញ្ឆនមហំ សិរសា នមាមិ ៗ

---

(១)- ពុទ្ធបាទនមស្ការគាថានេះ សម្តេចព្រះពោធិវង្ស ហួត តាត ទ្រង់បានរៀបជាសម្រាយពាក្យកាព្យ បោះពុម្ពដាក់ខាងចុងសៀវភៅសត្តបរិត្ត តាំងពី ព.ស ២៤៧៧ ។ លោក អ៊ុំ ៖ទេ តែងជាកាព្យ ពី ព.ស ២៤៨៩. ។

សូមថ្វាយបង្គំ  ទសករប្រណម្យ  ឆ្ពោះត្រង់ស្នាមព្រះបាទា
ដែលព្រះមានជោគ  ទ្រង់ព្រះមេត្តា  ជាន់ទុកឱ្យជាស្ថានថ្លៃ ។
ព្រះបាទមួយនៅនា  ស្ទឹងនម្មទា  ត្រង់ឆ្នេរខ្សាច់ប្រសើរក្រៃ
ព្រះបាទមួយទ្រង់ជាន់  ទុកនៅព្វ-  ដ៏ភ្នំគិរីសច្ចព័ន្ធ ។
ព្រះបាទមួយនៅភ្នំ  សុមនកូដ  រហូតកំពូលដ៏សោភ័ណ
ព្រះបាទមួយទៀត  ព្រះទ្រង់ជាន់  ទុកនៅនាយោនកបុរី ។
ខ្ញុំសូមបន្ទន់  កាយវាចា  និងចិត្តជ្រះថ្លាឱនសិរសី
បង្គំព្រះបាទ  ព្រះជិនស្រី  សូមសុខសួស្តីគ្រប់វេលា ។

សុវណ្ណមាលិកេ  សុវណ្ណបព្វតេ  សុមនកូដេ
យោនកបុរេ  នម្មទាយ  នទិយា
បញ្ចបាទវរំ  ឋានំ  អហំ  វន្ទាមិ  ទូរតោ ៕

ខ្ញុំសូមនមស្សការ  អំពីចម្ងាយ  នូវឋានទាំងឡាយ  ដែលមានព្រះបាទ
ទាំងប្រាំកន្លែង  ដែលព្រះមុនីនាថ  ទ្រង់យាងព្រះបាទ  លើកំពូលភ្នំ ។
សុវណ្ណមាលិក  មួយនោះជាធំ  មួយនៅលើភ្នំ  សុវណ្ណបព៌ត
មួយនៅលើភ្នំ  សុមនកូដប្រាកដ  មួយនៅរាជរដ្ឋ  យោនកបុរី ។
មួយនៅក្បែរស្ទឹង  នម្មទាជលធី  ទាំងប្រាំនាទី  ដែលទ្រង់ប្រទាន
ទុកឱ្យសព្វសត្វ  ប្រតិបត្តិជាស្ថាន  ដែលព្រះទ្រង់ញាណ  ប្រទានទុកឱ្យ ។

---

បទបង្សាវត្ត ( កុំច្រឡំហៅបទពាក្យ ៨ )

(១) បទគាថា សម្តែងអំពីកាលទ្រង់ប្រសូត

មលេន គេនាបិ អនូបលិត្តោ ឋិតោច បាទានិ បសារយន្តោ
ភជីច ឆម្មាសនតោ តរន្តោ ភវោ យាថានិច្ចមរោ នភម្ហាតិ ៗ

ប្រែ. បទភុជុង្គ

កាលអង្គព្រះសក្យបុត្ត ប្រសើរបំផុត; មិនជិតដាមដោយទ្វារមូត្រ
ព្រះកាយរបូត មិនជាប់មន្ទិល; ញើសក្អែលសៅហ្មងសុរិល
គ្រឿងជាមន្ទិល ណាមួយសោះឡើយ; ទ្រង់ឈរពេញជំហរហើយ
ព្រះបាទត្រាណត្រើយ សណ្តូកចុះត្រង់; ដូចធម្មកថិកមួយអង្គ
ចុះចាកបល្ល័ង្ក ពីគ្រែអាសនា; ពុំនោះប្រៀបដូចសុរិយា
រស្មីភ្លឺថ្លា ចេញចាកពពក; អស្ចារ្យនេះគួរនឹកភ្ញក
ពង្សពុទ្ធពន្លក ជាម្ចាស់នៃយើង ។

(បុរាណភាសិត)

(២) ទ្រង់ស្តេចយាង ៧ ជំហានបន្លឺសីហនាទ

អគ្គោហមស្មិ លោកស្មី សេដ្ឋោ ជេដ្ឋោ អនុត្តរោ
អរិយមន្តិមា មេ ជាតិ នត្ថិ ទានិ បុនព្ភវោតិ ៗ

ប្រែ. បទភុជុង្គ

យើងនេះលើសលុបលោកា ប្រសើរសេដ្ឋា ចម្បងបំផុត ។
ខ្ពង់ខ្ពស់ជាងពួកទេវបុត្រ ទេព្តានាគគ្រុឌ ក្នុងលោកទាំងបី ។
ពុំមាននរូប្រុសស្រី មានបុណ្យបារមី ស្មើនិងយើងឡើយ ។
ជាតិនេះបង្ហស់បង្ហើយ យើងសោតសះស្បើយ លែងកើតតទៅ ។
ភពថ្មីនាំវិលវល់នៅ ក្នុងអន្លង់ជ្រៅ មិនមានទៀតឡើយ។

(បុរាណភាសិត)

### (៣) បទគាថា និយាយអំពីបុព្វនិមិត្ត ៥ ប្រការ
### ក្នុងវេលាយប់ ១៤ កើត ខែ ពិសាខ

សោ រត្តិភាគេ សយិត្វា　　សុបិនេ បញ្ច អទ្ទស
បឋវិយំ សយិត្វា ច　　ភុសា នាភិសមុគ្គតា
ចតុវណ្ណោ ទិជា អាគូ　　គិរិគូថំ សមារុយ្ហ
ទុព្វណ្ណោ កិមយោ តត្ថ　　សរីរេ បរិចារិតា
តតោ សោ បតិពុជ្ឈិត្វា　　ធុវពុទ្ធោ ភវិស្សាមីតិ ៗ

ប្រែ. បទបណ្តុកគតិ

អង្គព្រះបរម　　ព្រះអង្គស្តេចផ្ទំលក់ស្កល់　　នាភាគមណ្ឌល
រាត្រីឡើបទល់ភ្លឺស្មោះ;　　ទ្រង់យល់សុបិន[១]　　ទាំងប្រាំប្លែក
មិនដែលសោះ　　ទីមួយមុននោះ　　ថាផ្ទំពោះផ្កាល់ដី;
សុបិនពីរដង　　ថាស្មៅមួយទងនៅខ្ទី　　ដុះពីនាភី
លូតលាស់ទល់ទីអាកាស;　　សុបិនទីបី　　យល់សត្វបក្សីបួនសាសន៍
ខៀវលឿងផ្សេងផ្កាស់　　មកកាន់ព្រះម្ចាស់ប្រែស;　　សុបិនទីបួន
ដង្កូវមានខ្លួនពណ៌ស　　ក្បាលខ្មៅរោមស　　តាំងពីត្រឹមកព្រះបាទ;
សុបិនទីប្រាំ　　ថាទ្រង់ស៊ូទ្រាំសង្វាត　　ចង្រ្កមស្និងស្នាធី

---

(១)- យល់ទី ១ ថា: មហាប្រឹថពីជាទីសំណឹង: ភ្នំហេមពាន្តជាខ្នើយ ព្រះហស្តឆ្វេងគងលើសមុទ្រខាងកើត, ព្រះហស្តស្តាំគងលើសមុទ្រខាងលិច: ព្រះបាទទាំងពីរសណ្តូកគងលើសមុទ្រខាងត្បូង, នេះជាបុព្វនិមិត្ត ដែលនឹងបានត្រាស់ដឹងនូវអនុត្តរធម៌ ។

ទី ២ ស្មៅចិញ្ចៀនមួយទងដុះចេញពីនាភីខ្ពស់ដល់អាកាស, នេះជាបុព្វនិមិត្ត ដែលនឹងបានប្រកាសអដ្ឋង្គិកមគ្គ ក្នុងទេវលោក និងមនុស្សលោក ។

ទី ៣ ហ្វូងដង្កូវខ្លួនសក្បាលខ្មៅ ស្រោបព្រះបាទទាំងសងខាង ពីត្រឹមជង្គង់ចុះទៅ: នេះជាបុព្វនិមិត្ត ដែលនឹងបានបរិស័ទស្លៀកពាក់សជាច្រើន ។

ទី ៤ បក្សី ៤ ពួក មានជាតិភេទផ្សេង១គ្នា មកពីទិសទាំង ៤ ដល់ទៀបព្រះបាទ ហើយក៏ក្លាយជាសសុទ្ធទាំងអស់: នេះជាបុព្វនិមិត្ត ដែលជាតិក្សត្រ, ព្រាហ្មណ៍: វេស្ស:: សូទ្រ: ចូលមកបួសក្នុងសាសនាក្លាយជាតិស្មើគ្នា ។

ទី ៥ ស្តេចចង្រ្កមលើភ្នំលាមក មិនជិតជាមដោយលាមក នេះជាបុព្វនិមិត្ត ដែលមិនជាប់ជំពាក់និងបច្ច័យទាំងបួន។

លើភ្នំគូថលាតសឹងល្អក់;   ពុំជាប់ជិតដាម   ប្រឡាក់មានស្លាមដោយភក់
និងគូថកខ្វក់   តែមួយតំណក់សោះឡើយ;   ព្រះអង្គស្តេចភ្ញាក់
មានស្មារតីជាក់ច្បាស់ហើយ   ជ្រាបសព្វគោះត្រើយ   ថាយើងនឹងហើយព្រះពុទ្ធ។

(៤) បទគាថា និយាយអំពីនាងសុជាតាថ្វាយមធុបាយាសពីព្រលឹម

ទេវាតិ សញ្ញាយ ឧទគ្គសិត្តា បាយាសបាដឹ បទស្ស ទត្វា
អាសីសនា តស្សា យថា បិ មយ្ហំ តុម្ហំ អាសយា សមិជ្ឈន្តូតិ ។

ប្រែ. បទកាកគតិ

នាងសុជាតា   មានចិត្តជ្រះថ្លា   ខ្ពង់ខ្ពស់អនេក
ដោយសំគាល់ថា   ទេវតាល្អប្លែក   ចិត្តមិនប្រកែក
ថ្វាយភាជន៍បាយាស។

ដល់អង្គចម៌ពង្ស   ព្រះទ័យបម្រុង   ប៉ងនឹងបានត្រាស់
ជ្រាបញ្ញេយ្យធម៌អាចិ   អស្ចារ្យត្រែក្រាស់   នាងតបតម្រាស់
ទូលដូច្នេះថា ។

រូបខ្ញុំព្រះអង្គ   ផ្សងក្ដីចំណង់   មកយូរហើយណា
ឥឡូវនេះបាន   សម្រេចប្រាថ្នា   ដូចដោយសទ្ធា
យ៉ាងណាទៅក្ដី ។

ឯការប៉ុនប៉ង   នៃព្រះជាម្ចាស់   តាំងទុកបារមី
សូមឱ្យសម្រេច   បានដូចសេចក្ដី   ដែលព្រះជិនស្រី
ផ្ដងដូច្នោះឯង ។

(បុរាណភាសិត)

### (៥) បទគាថា និយាយពីពុទ្ធក្ខេត្ត[១] និងស្វេតច្ឆត្រ

ទត្វាន មានុសកំ រជ្ជំ   បិតា សុទ្ធោទនោ តទា
សហម្បតិ មហាព្រហ្មា   ទេវព្រហ្មេហិ ឯកតោ
អត្តនោ វិសយំ រជ្ជំ   ទត្វា ឆត្តេន បូជយិ
សយំ នរាយនពលោ   បារមិពលបារគុំ
ជេតុំ សព្វស្ស លោកស្ស   ពោធិមណ្ឌមុបាគមិ ៦

ប្រែ. បទភុជុង្គ

| | | | |
|---|---|---|---|
| កាលនោះព្រះវរបិតា | ទ្រង់ព្រះនាមថា | ព្រះបាទសុទ្ធោទន៍ | ។ |
| ប្រទានរាជ្យហើយសម្ភោទ្យ | ឱ្យឱរសសោត | គ្រប់គ្រងផែនដី | ។ |
| ជាច្បងលើសជនប្រុសស្រី | លុះហើយព្រះបិ- | តាក្រាបវន្ទា | ។ |
| ដោយត្បូងព្រះសិរសា | បូជាបុត្រា | ដោយស្វេតច្ឆត្រ | ។ |
| មហាព្រហ្មនិងពួកបរិស័ទ | ថ្វាយរាជសម្បត្តិ | គឺវិស័យខ្លួន | ។ |
| ព្រមគ្នាបូជាថែមថ្កូន | ព្រះសិទ្ធត្ថសួន | ដោយស្វេតច្ឆត្រ | ។ |
| អយ្យបុត្តទ្រង់កំឡាំងក្លាត់ | ដែលលោករាប់ចាត់ | ថាជារាយណ៍ពល | ។ |
| ដោយព្រះអង្គឯងសោតសល់ | ស្តេចកាន់មណ្ឌល | ពោធិព្រឹក្សា | ។ |
| បម្រុងឆ្លងត្រើយនៃបារ- | មីញាណថ្លៃថ្លា | ផ្ចាញ់ពួកសព្វសត្វ | ។ |
| រូបរួមបីស្វេតច្ឆត្រ | មួយមនុស្សសម្បត្តិ | មួយទេពព្រហ្មផង | ។ |
| មួយទៀតគម្រប់បីផង | កំឡាំងច្បាស់ច្បង | ឈ្មោះនារាយពិត | ។ |

(បុរាណភាសិត)

---

(១)- ពុទ្ធក្ខេត្តមាន ៣ គឺៈ ជាតិក្ខេត្ត ហ្មឺនចក្រវាឡ ១ៈ អាណាក្ខេត្ត ពុទ្ធអាជ្ញាដែលផ្សាយទៅ ១ៈ វិសយក្ខេត្ត បានដល់ទិដ្ឋិវិស័យ ១. ឧបតិវិសយ អនុមេយ្យវិសយ ប្រែថាអារម្មណ៍ជាប់ណាង ។

(៦) បទគាថា និយាយពីទ្រង់ផ្ចាញ់មារផលាល្ងាច
ថ្ងៃ ១៥ កើត ខែ ពិសាខ (ក)

បារមិយោ ទិតិត្វាន ពោធិសត្តស្ស ភាសិតំ
គេសចរិច អាគញ្ញំ ពោធិសត្តំ គមព្រាទ្ធំ
មយំ បារមិតាយោធា ចិរំ ទេច គយោ ភគា
អជ្ជ ទស្សាម តេ ទីរ ទិជយំ ភទ្ទមត្ថុ តេ ៗ

ប្រែ. បទពំនោល

បារមីធម្មីថ្កើងថ្កាន ហាក់មានវិញ្ញាណ ដឹងដាននូវអត្ថភាសិត ។
នៃអង្គពោធិសត្វពិត ម្ចាស់ចមជីវិត មកដល់ប្រកិតព្រមគ្នា ។
ដូចស្តេចកេសរសីហា អង់អាចក្លៀវក្លា ពោលយកអាសាព្រះមុនី ។
ថាបពិត្រព្រះឥសី ស្តេចមានវីរិយ៍ ព្យាយាមពេញទីវែងឆ្ងាយ ។
យើងខ្ញុំបារមីទាំងឡាយ ដែលម្ចាស់ខ្វល់ខ្វាយ អស់កាលចម្ងាយយូរលង់ ។
ជាពលយោធាស្នងអង្គ ច្បាំងជួសចមពង្ស ដណ្តើមទាញទង់យកជ័យ ។
យើងខ្ញុំនឹងឃើញវិស័យ ពលមារប្រល័យ ចាលចាញ់ថយដៃថ្ងៃនេះ ។
ជនះប្រសើរឯងអេះ ៙ ធំអម្បាលនេះ ចូរមានដល់អង្គព្រះម្ចាស់ ។

(បុរាណភាសិត)

៚

(៦) បទគាថា និយាយពីទ្រង់ផ្ចាញ់មារផលាល្ងាច
ថ្ងៃ ១៥ កើត ខែ ពិសាខ (ខ)

បសារេត្វា មហាទីរោ ចក្កលក្ខណរញ្ជិតំ
ឯរាចណ្ណសទិសសោណ្ឌំ បទាឡ្ហក្ខរសាទិសំ
ចស្ទុន្ធរាចនិតច្ចំ ទស្សេហិ សក្យបុត្តទោ
សណ្ហារេត្ថុំ អសរត្ថោន្តី ភត្តី សាមញ្ញតា ទិយ

ឧដ្ឋហិត្វា មហោឃាច សម្មុខា សក្យបុត្តតោ
ចរត្តសិ អត្តនោ កេសេ គង្គាសោតំ បវត្តយិ ៗ

ប្រែ. បទពំនោល

| | | | |
|---|---|---|---|
| វីអង្គពង្សពុទ្ធសក្ការ | ស្ដេចមានឧស្សាហ៍ | ព្យាយាមប្រសើរកន្លង | ។ |
| សណ្ដូកព្រះហស្តល្ដាយល្ហង | កបកងចក្កផង | ប្រហែសដូចទងសោណ្ឌី | ។ |
| ដែអង្គឯភាហត្ថិ | សម្ដេចកោសិយ | ទេព្ដាធិបតីស្ថានសួគ៌ | ។ |
| ព្រះអង្គចង្អុលអាងតូ | ចិរសុន្ទរ | គឺផ្ទៃផែនដីនេះឯង | ។ |
| ប្រហែលពន្លកស្សប្រសែង | ប្រវាឡទំទែង | ចំពោះកន្លែងបល្ល័ង្ក | ។ |
| ផែនដីញាប់ញ័រស្លាំងគាំង | ទប់ទល់កំឡាំង | ឱ្យនៅរឹងតាំងពុំបាន | ។ |
| និមិត្តភេទស្រីមួយប្រាណ[១] | អង់អាចហៅហាន | ផុសថ្កានរំពេចឆាប់ខ្មី | ។ |
| ចំកណ្ដាលភក្ត្រជិនស្រី | ដូចនឹងស្រដី | ថាយើងសាក្សីប្រាកដ | ។ |
| កាលដែលអង្គព្រះសុគត | ស្ដេចត្រាច់វង្កាត់ | ទៅក្នុងវដ្ដច្រើនកប្ប | ។ |
| បន្ទំបារមីធម៌គាប់ | ទុកជាកំណប់ | ច្រូចទឹកស្មោអប់សក់ខ្ញុំ | ។ |
| ថាហើយរំសាយផ្នួងធំ | បញ្ចេញទឹកអំ- | ពីសក់បង្ហូរទៅដី | ។ |
| ខ្សែទឹកជោរជន់ឆាប់ខ្មី | ដូចកល់ទន្លេ | ពន្លិចសេនីយ៍ពួកមារ | ។ |

(បុរាណភាសិត) ប.

## (៧) បទគាថា និយាយពីពលមារថយក្រោយខ្ចាត់ខ្ចាយ

បារមិតានុភាវេន មារសេនា បរាជិតា
និក្ខន្តោទកធារេហិ សក្ខី កេសេហិ ភាចទេ
ទិសោទិសំ បលាយន្តិ ចិទ្ធំសេត្វា អសេសតោ ៗ

១- ក្នុងគម្ពីរ ជិនមហានិទាន ថាមិនមែននិមិត្តជារូបភាពទេ គ្រាន់តែរញ្ជួយផែនដី, ព្រៃភ្នំ, ភ្នំ, ប[illegible]ជាទឹកជន់ជោរ ពោរពាសលិចពលមារគ្រានោះហោង ។

ប្រែ. បទពំនោល

ពលមារចាលចាញ់បារមី ស្ទុះរត់ម្នាមី ដោយនូវឫទ្ធិទទឹក
ដែលនាងកង្ហីងរពូក បារមីយប់ព្រឹក ធ្វើជាចារីកពេជ្ជ[១] ញាណ ។
ទឹកជោរហូរលិចសព្វស្ថាន ឥតភ្លាំងភ្លឹកប្រាណ ចេញពីកងផ្នួងកេសី
កំចាត់ពលមារអសុរី ខ្ចាត់ភ្លាត់ទៅទី ទិសតូចទិសធំគ្មានសល់ ។
ខ្លះរស់ខ្លះស្លាប់រចល់ នាភាគមណ្ឌល ត្រង់គល់ពោធិព្រឹក្សា ។

(បុរាណភាសិត)

(៨) បទគាថា និយាយពីក្រុងមារថ្វាយសាធុការពរ

នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
សទេវកស្មិំ លោកស្មិំ នត្ថិ តេ បដិបុគ្គលោ
តុវំ ពុទ្ធោ តុវំ សត្ថា តុវំ មារាភិភូ មុនិ
តុវំ អនុសយេ ឆេត្វា តិណ្ណោ តារេសិ មំ បជំ ។

ប្រែ. បទព្រហ្មគីត

បពិត្រព្រះទ្រង់យស ចមបុរសប្រសើរក្រៃ
ខ្ញុំសូមផ្គុំប្រមាមដៃ ឆ្ពោះម្ចាស់ថ្លៃអង្គនោះឯង ។ ១
បពិត្រព្រះមានបុណ្យ កបគុណធ្ងន់គួរស្ញប់ស្ញែង
វិសេសខ្ពស់ចំពោះ យល់ជាក់ស្តែងជាងបុរស ។
ខ្ញុំសូមនមស្សការ ប្រជុំទ្វារបីទាំងអស់
ចំអង្គមហាបុរស ឆោមឆាយស្រស់គ្រានេះនៃ ។
ក្នុងស្ថានមនុស្សលោកា ទាំងទេវស្ថានសួគ៌ថ្លៃ
ឥតមានអ្នកឧបមេយ្យ ឧបមាដោយព្រះអង្គឡើយ ។

---

(១)- ធ្វើជាសាក្សីពេជ្ជញាណ ។

ព្រះអង្គជាសម្ពុទ្ធ ប្រសើរផុតជ្រាបដល់ត្រើយ
ព្រះអង្គគ្រូគ្រប់ហើយ មនុស្សនាគយក្សទាំងទេព្តា ។
ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់អំណាចលើខ្ញុំណា
ព្រះអង្គវើណាស់សា ក្នុងអនុស្សយាធម៌ផងគ្រប់ ។
ទ្រង់ឆ្លងសង្សារា តូឱ្យយាអន្លង់សព្ទ
ឆ្ពោះអង្គព្រះចមភព ទាំងចំឡងខ្ញុំព្រះអង្គ ។
ព្រមដោយសត្វសម្ពាយ ឱ្យចៀសឆ្ងាយចាកវិលវង់
ឱ្យទានដល់ទីម- ង្គលបញ្ចង្គគីនិព្វាន ។

(បុរាណភាសិត) ប.

(៩) បទគាថា និយាយពីវេលាត្រាស់ដឹងសព្វញ្ញុតញ្ញាណ

យាមស្មឹ បឋមេ បុព្វេ និវាសញ្ច នុត្តមោ
ទិវសោធគ្វាន យាមស្មឹ មជ្ឈិមេ ទិព្វលោគចនំ
សោ បដិច្ចសមុប្បាទេ អថ បច្ឆិមយាមកេ
និគារេត្វា សតំ ញាណំ សម្ពុសន្តោ អនេកជាតិ ១

ប្រែ. បទពាក្យប្រាំពីរ

ព្រះមហាបុរសដ៏ឧត្តម ព្រះអង្គធំលើលោកត្រៃ
ទាំងទេពនិករផងសោតនៃ ស្ដេចទ្រង់លកលៃញាណជាន់ខ្ពស់ ។
នាមហៅបុព្វេនិវាសតញ្ញាណ ជាគុណចំណានមុនបង្អស់
រំពឹងមើលឃល់ជាតិរបស់ សព្វសត្វទាំងអស់ទាំងព្រះអង្គ ។
ក្នុងយាមដំបូងពេលព្រលប់ ព្រះទ័យសញ្ចប់សញ្ចឹងស្ងង់
ភាវរកកំណើតដ៏យូរលង់ វិលទៅដូចកង់គង់ជ្រាបបាន ។
ផុតពីព្រលប់កន្លងផុតទៅ សម្ដេចចមចៅយើងគ្រប់ប្រាណ

ទ្រង់ជម្រះទិព្វចក្ខុញ្ញាណ ក្នុងរាត្រីបានពាក់កណ្ដាល ។
ឃើញសត្វផងដែលស្លាប់កើត យោនយកកំណើតតាមស្រើបស្រាល
ខ្ពស់ទាបខ្មៅសល្អគ្រកាល សោតសឹងបណ្ដាលពីកម្មផល ។
លុះតពីយាមគម្រប់ពីរ ជួបចូលយាមបីទើបនឹកដល់
អរុណរះឡើងភ្លឺអស់កល់ សម្ដេចទសពលទ្រង់រំពឹង ។
ធម៌គឺបដិច្ចសមុប្បាទ វិសេសស្អាងស្អាតល្អិតជិតឈឹង
ព្រះអង្គញ៉ាំងញាណធ្យានសន្ធឹង ព្រះទ័យសម្រឹងពិចារណា ។
បណ្ដោយច្រាស់តាំងពីដើមទី ឃើញធម៌អប្រិយ៍គឺអវិជ្ជា
សង្ខារវិញ្ញាណបន្តគ្នា ដរាបដល់គ្រានិរោធហោង ។

(បុរាណភាសិត) ប.

(១០) លុះបច្ចូសសម័យទ្រង់សម្ដែង ឧទានគាថា

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគាតិ ៗ

ប្រែ. បទមណ្ឌគតិ

អញ្ចតថាគត នៅត្រាច់រង្គាត់សញ្ចារ ក្នុងភពសង្សារ ជាទីកន្តារច្រើនជាតិ ។
ស្វែងរកតណ្ហា អ្នកសាងអត្តារូបមាឌ ឱ្យយើងរាល់ជាតិ យើងខំសង្វាតពុំជួប ។
ពុំបានប្រទះ នឹងនាយជាងផ្ទះច្រើនខួប ទុក្ខវេងត្រូតគួប ព្រោះតែជាតិរូបរឿយៗ ។
នែអ្នកនាយជាង យើងឃើញរូបរាងអ្នកហើយ តទៅកុំឡើយ កុំធ្វើផ្ទះឱ្យយើងទៀត ។
រឹឆ្អឹងជំនីរ កិលេសជាទីសឹកសៀត ជិតស្និទ្ធដូចស្អៀត យើងក៏បៀតបៀននិទ្ទា ។

ទាំងហោជាងសោត គឺកងគុម្ពោតអវិជ្ជា ផុះនៃអាត្មា គង់យើងកាប់ឆ្ការរុះរើ ។
បោចរោចកំចាត់ កំចាយឱ្យខ្ចាត់លែងធ្វើ ចិត្តយើងឡើងឈើ ខ្ពស់ស្មើដល់ស្ថាននិព្វាន ។
កន្លែងអស់ទៅ តណ្ហាកំឡៅសាមាន្យ យើងសឹងបានក្សាន្ត ក្សេមផុតឥតមានទុក្ខភ័យ ។

### (១១) ទ្រង់បរិនិព្វាន
### បទឥន្ទ្រជិត (មិនមានបាលីគាថា)

| | |
|---|---|
| វេលាពន់ព្រលប់ | ព្រះចមភពលោកាចារ្យ |
| ទទួលបដិសណ្ឋារ | រាជបរិវារក្រុមមល្ល: ។ |
| ដែលនាំគ្នាចូលគាល់ | ខ្លួនឯងផ្ទាល់ចំពោះព្រះ |
| វិជិតទ្រង់តប: | ក្រាបចំពោះសូរព្រះរោគ ។ |
| លុះដល់យាមកណ្តាល | ទ្រង់ធូរស្រាលស្រយាលរោគ |
| ព្រះទ័យវែងវិយោគ | ឆ្ពោះសត្វលោកគ្មានរើសមុខ ។ |
| ប្រទានភេទបព្វជ្ជា | ដល់ភទ្ទាដែលចូលលុក |
| មកគាល់ព្រះប្រមុខ | ទ្រង់ដោះទុក្ខក្នុងយាមនោះ ។ |
| លង់លុះបច្ឆិមយាម | ទ្រង់ហាមប្រាមភិក្ខុកំឡោះ |
| ភិក្ខុចាស់អម្បាលនោះ | ទ្រង់អនុគ្រោះឱ្យឱវាទ ។ |
| ថានៃភិក្ខុទាំងឡាយ | ចូរខ្វល់ខ្វាយកុំប្រមាទ |
| ជម្រះសីលឱ្យស្អាត | តាមក្បួនខ្នាតតថាគត ។ |
| លុះចប់ព្រះពុទ្ធដីកា | អង្គសាស្តាស្តេចរំលត់ |
| រំលាងខន្ធប្រាកដ | ចូលកាន់បទសិវ:អើយ ។ |

(សកភាសិត)

## (១២) ព្រះអានន្ទយំស្រណោះ

បទឥន្ទ្រវិជិត (មិនមានបាលីគាថា)

កាលនោះព្រះអានន្ទ　សោកពុំស្រន់ព្រោះពុថា
សម្ដេចព្រះសាស្ដា　មានពុទ្ធដីកាឱ្យឱវាទ ។
ដល់ពួកភិក្ខុហើយ　ពុំលង់ឡើយព្រះលោកនាថ
ផ្ទំស្ងៀមផ្ដងព្រះបាទ　បែរភក្ត្រស្អាតរកអានន្ទ ។
ឯព្រះអានន្ទឯង　កើតចំបែងចិត្តពេកពន់
អាល័យព្រះភគវន្ត　គិតនឹកគ្នាន់ក្ដាញ់ច្រេះថា ។
ឱះឱព្រះបរមគ្រូ　ម្ដេចមកត្រូវថ្នាក់ជរា
ទ្រុឌទ្រោមកងខន្ធា　មុខមរណាជាមិនខាន ។
រីរូបអានន្ទប្អូន　តែងតាមជូនម្ចាស់សព្វស្ថាន
ទោះស្ដេចចេញចរថ្កាន　ទៅប្រោសប្រាណទីណាក្ដី ។
អានន្ទមិនមានព្រួយ　ជាប់ជាមួយនឹងជិនស្រី
យប់ថ្ងៃជាប្រក្រតី　ជិតឆ្ងាយក្ដីឥតបើថា ។
ឥឡូវទ្រង់មកកាត់　សង្ខារខ្ចាត់ពុំមេត្តា
អាសូរខ្ញុំឡើយណា　ដែលយាត្រាតាមបំរើ ។
មួយទៀតខ្ញុំអានន្ទ　ឥតភគវន្តទៅហើយតើ
ចុះខ្ញុំនឹងបំរើ　នឹងអំពើអង្គណាទៀត ។
ទាំងគុណគឺមគ្គផល　ពុំទាន់យល់សឹងចង្អៀត
អានន្ទខ្ញុំត្រូវឆ្លៀត　ឱ្យសម្រេចទៀតបានអង្គណា ។
បើឥតព្រះអង្គហើយ　ព្រះគុណអើយខ្ញុំកំព្រា
អនាថាបាត់ភាមា　ពេញរងាម្នាក់ឯងនៅ ។
ឱស្ដាយអីស្ដាយម្ល៉េះ　ខ្លួនឯងនេះឥតព្រះចៅ
មិនដឹងបើគាល់ហៅ　ព្រះចមចៅអង្គឯណា ។

តាំងពីស្អែកនេះហើយ អាត្មាអើយក្រាលអាសនា
តាក់តែងកម្រងផ្កា គ្រឿងមាលានិងឧទកំ ។
រៀបបាត្រច្រត់ចីវរ ដោយស្មោះសភរៀបបល្ល័ង្ក
សំអាតបោសតែងតាំង ប្រុងសំរាំងថ្វាយអង្គណា ។
(សភភាសិត)

(១៣) បច្ឆិមពុទ្ធវចនៈ

បទមណ្ឌុកគតិ

ក្រោយពីអានន្ទ តូចចិត្តអាក់អន់ពន់ពេកក្រៃ
ទើបព្រះចមត្រៃ ទ្រង់ត្រាស់ប្រាស្រ័យហៅរក ។
ពួកភិក្ខុប្រាប់ថា អានន្ទអើយបាពន្លក
ព្រះទ្រង់ហៅរក ឱ្យអ្នកចូលមកឥឡូវ ។
អានន្ទឮដូច្នោះ ឈប់សោកហើយស្ទុះពុំផ្លូវ
មកតាមដម្រូវ ដែលទ្រង់ថាត្រូវឱ្យចូល ។
ទើបក្រាបបង្គំ អង្គព្រះបរមហើយទូល
ថាសូមអនុកូល ខ្ញុំអានន្ទចូលមកហើយ ។
ទ្រង់ឆ្មៀងនេត្រត្រង់ ព្រះឱស្ឋបញ្ចេញល្ងើយ១
ថាអានន្ទអើយ ចូរអ្នកល្ហែល្ហើយសោកា ។
អញតថាគត និព្វានរលត់បាត់រូបា
តែឯកអាត្មា ឯត្រង់សាសនាសល់នៅ ។
ព្រះសូត្រព្រះវិន័យ បរមត្ថធម៌ថ្លៃថ្លាលជ្រៅ
មានពាក្យប្រដៅ សម្រាប់ប្រាជ្ញខ្លៅម្ដេចម្ដា ។
នឹងធម្មក្ខន្ធ ប៉ែតហ៊ឺនបួនពាន់ថ្លៃថ្លា
ដែលអញតថា- គតតែងទេសនាប្រាប់អ្នក ។

ធម៌ទាំងនោះឯង　អានន្ទអ្នកតែងចាំជាក់
នឹងជាគ្រូអ្នក　តំណាងយើងជាក់តទៅ ។
អ្នកកុំរិះគិត　ទោមនស្សតូចចិត្តណាពៅ
ដ្បិតអត់ពីយើងទៅ　ពុំមានគ្រូនៅថែទាំ ។
មិនដូច្នោះទេ　អានន្ទកុំមេបារម្ភ
មគ្គផលប្រចាំ　យូរអម្លុងឆ្នាំប្រាំពាន់ ។
គួរអានន្ទនេះ　ព្យាយាមរួសរិះឱ្យទាន់
បានជាអរហន្ត　ក្នុងគ្រាជំនាន់ជាន់ក្រោយ ។
ដែលព្រះកស្សប　ជួបជុំរម្ងាប់ការធ្លោយ
វិវាទពោលឱ្យ　ចម្រូងនាំខ្សោយធម៌ពិត ។
ធ្វើសង្គាយនា　ជម្រះវាទាវិបរិត
ផ្ទៀងផ្ទាត់សម្រិត　សម្រាំងពិនិត្យឱ្យត្រូវ
ត្រឹមតាមគន្លង　គោលច្បាប់ដើមទងនោះកូវ
គឺយើងតម្រូវ　ចាត់ជាត្រឹមត្រូវស្រេចហើយ ។
នែបាអានន្ទ　ចូរអ្នកកុំអន់អាក់ឡើយ
រូបនេះអ្នកអើយ　នឹងបានឈ្លាសឆ្លើយប្រស្នា ។
ថ្លែងបន្ទូលស្រេច　រួចទើបសម្ដេចសាស្តា
ត្រាស់សួរភិក្ខុថា　ឥឡូវថ្មើរណាទៅហើយ ។
ពួកភិក្ខុតបថា　សូមទានមេត្តាម្ចាស់អើយ
ទៀបអរុណហើយ　នៅជិតបង្អើយនឹងភ្លឺ ។
ទ្រង់ត្រាស់ឱវាទ　ពិរោះស្អាងស្អាតផ្គាំផ្ញើ
ពាក្យពេចន៍ទុកលើ　ពួកភិក្ខុឱ្យធ្វើតាមក្រោយ ។
ថាអ្នកទាំងឡាយ　ចូរខំខ្វាយខ្វល់កុំធ្លោយ
បណ្ដែតបណ្ដោយ　ប្រហែសធ្វេសឱ្យខូចការ ។

ចូវទឹកវពឹង ថាកងខន្ធហ្នឹងអសារ
របស់សាធារណ៍ ឥតមានខ្លឹមសារមែនពិត ។
ខន្ធប្រាំគំនរ រូបនាមបញ្ចូលជាប់ស្អិត
ប្រកៀកប្រកិត ប្រកាន់យ៉ាងស្និទ្ធដូច្នេះថា ។
រូបអញនាមអញ នេះជាសំឡាញ់អាត្មា
គ្រារូបប្រេះឆា ស្រាប់តែឆេវឆាសោកស្តាយ ។
នៃភិក្ខុទាំងពួង អ្នកកុំហៃងហួងរូបកាយ
សម្រាប់បែកធ្លាយ ទ្រុឌទ្រោមភ្លាប់ក្លាយវិនាស ។
ទើបស្តេចចូលឈាន មុននឹងនិព្វានពោរពាស
តាំងពីដើមអាសន៍ គឺបឋមជ្ឈានតទៅ ។
ចេញចាកឈានហើយ ពិតពុំលង់ឡើយមេចៅ
បង្វិលញាណទៅ តម្រង់សំដៅស្ថានឯក ។
គឺស្ថាននិព្វាន ជាទីពុំមានមារវង្វេក
សុខឆាន់អនេក ឥតមានស្ថានឯកប្រៀបឡើយ ។

(សកភាសិត)

ចប់

វិសាខបូជាថ្ងៃ ១៥ កើត

# វិសាខបូជា

### ថ្ងៃ ៨ រោច

ពិធីបូជានេះ ជាមហានក្ខត្តឫក្សមួយ ដែលជាប់ទាក់ទងតមកអំពីថ្ងៃ ដែលព្រះមុនីនាថ ទ្រង់ចូលបរិនិព្វាន ហើយក៏ពួកក្សត្រមល្លរាជ បានចាត់វិធានការតម្កល់ព្រះបរមសព អស់ចំនួន ៧ ថ្ងៃ ទើបនាំហែចេញទៅកាន់មកុដពន្ធនចេតិយ ដែលមានបំណងនឹងថ្វាយព្រះភ្លើងក្នុងគ្រានោះ ។

អាស្រ័យហេតុនេះជាអាទិ៍ ទើបអ្នកប្រាជ្ញបុរាណាចារ្យ លោកកំណត់យកថ្ងៃ ៨រោច ខែពិសាខនោះ ទុកជាពិធីបូជាដ៏មហោឡារិកមួយដែរ ដែលជាប់ទាក់ទងរៀងដរាបមកដល់សព្វថ្ងៃនេះ ។

## បាលីទេវគ្រឿងសក្ការៈបូជា

អជ្ជាយំ ភោន្តោ វិសាខបុណ្ណមាយជូទិវសោ ហោតិ អដ្ឋមោ តថាគតស្ស បរិនិព្វុតកាលសទិសោ ។

តទា ហិ អសីតិយា វស្សកាលេ សម្បសំវច្ឆរេ វិសាខបុណ្ណមាយំបិ អម្ហាកំ ភគវា លោកនាយកោ បរិនិព្វុតោយេវ តទា មល្លរាជានោ អយមញ្ជូសេ ពុទ្ធសរីរំ សុនិក្ខិបិត្វា បតិមានេន្តា សត្តទិវសេ មហាសក្ការំ ករោន្តា អថ ច បន កាឡបក្ខស្ស អដ្ឋមិយំ តេជោធាតុ តំ សយមេវ សម្បជ្ជលិ ។

តស្មា មយំ សព្វេ តំ តំ អនុស្សរន្តា ឥធ សមាគតា តស្ស

សរីរធាតុយោ ច ឧទ្ទេសចេតិយោ ចេវ ឥមេហិ ទីបធូប-

មាលាទីហិ អភិបូជេម ធម្មេហិ ច សាធុ ភន្តេ ឥមេ បដិគ្គណ្ហតុ

អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

បពិត្រ ព្រះករុណាទាំងឡាយដ៏ចំរើន ថ្ងៃនេះជាថ្ងៃគំរប់ប្រាំបីក្រោយថ្ងៃ ១៥ កើត ខែពិសាខ តមកប្រហែលដូចជាថ្ងៃកាលដែល ព្រះតថាគតទ្រង់បរិនិព្វាននោះប្រាកដ ។

ព្រោះថា ព្រះដ៏មានព្រះភាគ លោកនាយកជាម្ចាស់នៃយើង ស្តេចទ្រង់បរិនិព្វាន ក្នុងថ្ងៃ ១៥ កើតខែពិសាខឆ្នាំម្សាញ់ ក្នុងគំរប់ព្រះជន្មវស្សា ៨០ ឆ្នាំ កាលនោះពួកស្តេចមល្លរាជ (ព្រមទាំងបរិស័ទ) ទាំងឡាយបានចាត់ចែងព្រះបរមសរីរសព ក្នុងព្រះមឈូសមាសរួចហើយ ធ្វើសក្ការៈបូជាអស់វារៈប្រាំពីរថ្ងៃ លុះថ្ងៃជាខាងក្រោយ, អំពីវេលាដែលព្រះមហាកស្សបៈ ថ្វាយបង្គំព្រះបាទរួចហើយ ស្រាប់តែតេជោបណ្តាលឆេះឡើងឯង បូជាព្រះបរមសរីរៈសពនោះ ក្នុងថ្ងៃជាគំរប់ប្រាំបី នៃកាឡបក្សខាងរនោច ។

ព្រោះហេតុនោះ ទើបយើងខ្ញុំទាំងឡាយ រឭកនូវកាលនោះៗ ក៏មកប្រជុំគ្នាក្នុងទីនេះ ដើម្បីធ្វើបូជាចំពោះព្រះសរីរៈធាតុផង ចំពោះឧទ្ទេសចេតិយផង របស់ព្រះដ៏មានព្រះភាគជាម្ចាស់អង្គនោះ ដោយគ្រឿងសក្ការៈទាំងឡាយ មាន ទៀន ធូប កម្រងផ្កា ជាដើមនេះផង បូជាដោយធម៌ផង បពិត្រព្រះសុគតដ៏ចំរើន (សូម្បីបរិនិព្វានហើយ) ទ្រង់ទទួលយកនូវបណ្ណាការទាំងឡាយនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខផង ដល់យើងខ្ញុំទាំងឡាយ អស់កាលជាយូរអង្វែងទៅហោង ៕

(១) គាថាប្រារព្ធវិសាខបូជា

ថ្ងៃ ៨ រោច

វិសាខបុណ្ណមាយជ្ជ     និចសោ ហោតិ អដ្ឋមោ

យាតិសេ នររទចស្ស     សុនិព្វុតស្ស តាទិនោ

មល្លេហិ សព្វគន្ធានំ     សន្ទេហិ កតចិតកោ·

បាដិហេរំ ទស្សយន្តោ សមយេ អបជ្ជលិ
តស្សន្តិមទេហាទ្ធតំ ពត្តឹស ចរលក្ខណំ
ធាតុទ្ធតេន តេជេន អជ្ឈាយិត្ថ មហេសិនោ
តាទិសោច អយន្តានិ សម្បត្តោ អភិលក្ខិតោ
តមន្តានិ សុនទ្ធត្តំ អភិមង្គលសម្មតំ ៗ

## ប្រែ. គាថាទី ៨

ថ្ងៃនេះជាថ្ងៃ តំរប់ប្រាំបី នៃថ្ងៃបុណ្ណមី ខែវិសាខា
ដែលពួកមល្លរាជ មានចិត្តជ្រះថ្លា ធ្វើសក្ការា ថ្វាយព្រះសម្ពុទ្ធ ។
ទ្រង់ប្រសើរលើស ទេវតានាគគ្រុឌ ទ្រង់អ្នកអត់ធ្មត់ ផ្ដោះលោកធម៌
រលត់ខន្ធប្រាំ លែងត្រាច់សញ្ចរ កាន់ផ្ទៃសាគរ សង្សារទៀតហើយ ។
ក្នុងកាលកន្លង យូរឆ្ងាយល្វេងល្វើយ កើតស្លាប់សឹងស្បើយ ផុតអស់កាលនោះ
ដោយទៀននិងធូប ក្រអូបសាយសុស ពេញទីប៉ុណ្ណោះ នាគ្រានោះឯង ។
រីឯជើងថ្ករ ដែលរៀបតាក់តែង សោតសឹងសំដែង ឫទ្ធិបាដិហារ្យ
បណ្ដាលឆេះឯង ហៅពេញអស្ចារ្យ បុណ្យព្រះឈ្នះមារ អស្ចារ្យនៃយើង ។
ព្រះកាយទាំងមូល កបលក្ខណ៍ថ្កុំថ្កើង ជាទីបន្ទើង សាមសិបពីរថ្ងៃ
នៃព្រះមហេសី មកភពលោកត្រៃ ឆេះឆួលសន្ធៃ ដោយតេជោធាតុ ។
កាលឥឡូវនេះ មានជោគពុំឃ្លាត ដល់មកព្រោងព្រាត ដូចកាលនោះពិត
ដែលលោកសន្មត តាមបទរិះគិត ពេញល្អវិចិត្រ ចម្បងមង្គល ។
ទាំងនក្ខត្ត- ឫក្សផងសោតសល់ ជួបចូលមកដល់ ជាមួយគ្នានេះ
យើងខ្ញុំសូមថ្លែង មង្គលប៉ុណ្ណោះ តាំងចិត្តត្រេកត្រអាល អំពីចម្ងាយ ។
មួយទៀតសូមតាំង វាចាចិត្តកាយ គោរពថ្វាត់ថ្វាយ ព្រះធាតុអស់នោះ ។

(បុរាណភាសិត)

(២) បទគាថា និយាយពីសហម្បតីព្រហ្មពោលសំវេគ

សព្វេវ និក្ខិបិស្សន្តិ ភូតា លោកេ សមុស្សយំ
យត្ថ ឯតាទិសោ សត្ថា លោកេ អប្បដិបុគ្គលោ
តថាគតោ ពលប្បត្តោ សម្ពុទ្ធោ បរិនិព្វុតោ ។

ប្រែ. បទព្រហ្មគីត

ធម្មតាពពួកសត្វ ត្រាច់រង្គាត់នៅក្នុងលោក
តែងលះកាយស្មោកគ្រោក ទីប្រជុំសរសៃឆ្អឹង ។
បោះបង់ចោលនៅអាយ ពុំនឹកស្ដាយសោះសូន្យឈឹង
ទាំងទ្រព្យហ៊ឹនដម្កឹង គង់លះចោលពុំនឹកនា ។
អម្បាលព្រះសម្ពុទ្ធ ជាចមកុដអង្គសាស្ដា
អម្ចាស់យើងនេះណា ទ្រង់ប្រើជាឆ្នើមក្នុងលោក ។
ឥតមានបុគ្គលផ្ទឹម ផ្ដតម្រឹមដោយជ័យជោគ
ទ្រទ្រង់កំឡាំងយោគ ស្មើកំឡាំងដំរីសារ ។
ម្ដេចគង់ស្ដេចនិព្វាន ទ្រាំមិនបាននឹងស្ដេចមារ
ចំណង់ជនសាធារណ៍ មរណាការពុំខានឡើយ ។

(បុរាណភាសិត) ប.

(៣) បទគាថា និយាយពីព្រះឥន្ទ្រពោលសំវេគ

អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ ។

ប្រែ. បទព្រហ្មគីត

អនិច្ចាឱរូបអើយ កើតឡើងហើយពុំទៀងទេ
សង្ខារអ្នកគិតកែ លែងឱ្យវិលចាស់ឈឺស្លាប់ ។

ស្លាប់ហើយវិលកើតទៀត រស់ប្រជ្រៀតនៅអ៊ូអាប់
ពុំស្ថិតស្ថេរចំណាប់ សឹងត្រូវស្លាប់វិញទៀតទៅ ។
ដូចដុំពពុះទឹក ទីវរីកទោះភក់ជ្រៅ
ប៉ោងឡើងហើយបែកទៅ មិនតាំងនៅយឺនយូរឡើយ ។
សង្ខារសត្វទាំងឡាយ តែងបែកធ្លាយពុំល្ហែល្ហើយ
កើតចាស់ស្លាប់ពុំស្បើយ ពុំទៀងឡើយគ្រប់ប្រការ ។
មានតែព្រះនិព្វាន រម្ងាប់ប្រានចោលសង្ខារ
ទាំងនោះឱ្យអសារ បែរបានសុខជាអនេក ។

(បុរាណភាសិត) ប.

(៤) បទគាថា និយាយពីព្រះអនុរុទ្ធពោលសំវេគ

នាហុ អស្សាសបស្សាសោ ឋិតចិត្តស្ស តាទិនោ
អនេជោ សន្តិមារព្ភ យំ កាលមករិ មុនិ
អសល្លីនេន ចិត្តេន វេទនំ អជ្ឈវាសយំ
បជ្ជោតស្សេវ និព្វានំ វិមោក្ខោ ចេតសោ អហុ ។

ប្រែ. បទមណ្ឌុកគតិ ៖

វីខ្យល់ចេញចូល តែងដើរប្រដេញ៏ធម្មតា
របស់អង្គសម្មា- សម្ពុទ្ធសាស្តាម្ចាស់យើង ។
ទ្រង់តាំងព្រះទ័យ នឹងថ្កល់ពេកក្រៃអស់ជើង
មិនញោចចុះឡើង រញ្ជួយញ័រប៉ើងដោយក្រោធ ។
ខ្យល់នោះឈប់ខាន ចេញចោលចាកប្រាណពុំកោត
ញញើតខ្លាចសោត បាត់ឈឹងមិនលោតញាប់ញ័រ ។
សម្តេចមុនី ផុតអំពល់ក្តីសញ្ជរ
ផ្លងត្រង់នគរ គឺព្រះនិព្វានស្ងប់ស្ងាត់ ។

ផ្ទៃមរណកាល នៅចំកណ្ដាលបរិស័ទ
ទ្រង់អត់ទ្រាំក្ដាត់ ចំពោះឈឺផ្ដាត់វេទនា ។
ដោយព្រះទ័យថ្លៃ ពុំមានអាល័យរូបា
ពួកកងខន្ធា សូម្បីមរណាសោះឡើយ ។
ព្រះទ័យចេញផុត ឈានដល់វិមុត្តិធម៌ហើយ
រួចស្រឡះស្បើយ ប្រៀបដូចប្រទីបចង្កេះឯង ។

(បុរាណភាសិត) ប.

(៥) បទគាថា និយាយពីព្រះអានន្ទលោលសំវេគ

តទា សយំ ភឹសនកំ តទាសិ លោមហំសនំ
សព្វាការវរូបេតេ សម្ពុទ្ធេ បរិនិព្វុតេ ៗ

ប្រែ. បទមណ្ឌុកគតិ

កាលអង្គសម្ពុទ្ធ ជាចមកុដសាស្ដា
កបដោយឥរិយា សព្វគ្រប់ប្រការឥតខ្ចោះ ។
ស្ដេចទ្រង់និព្វាន រលត់វិញ្ញាណសូន្យសោះ
ត្រង់នាចន្លោះ ដើមសាលព្រឹក្សភ្លោះពេលណា ។
ទើបបានពេលនោះ គួរឱ្យស្ញប់ស្ញែងណាស់សា
ព្រួចព្រឺលោមា ទូទាំងកាយាគួរភ្ញឹក ។
នឹកឡើងសែនស្ដាយ ផុតអធិប្បាយការនឹក
រាល់យប់រាល់ព្រឹក សម្ដេចធម្មិកម្ចាស់យើង ។

(បុរាណភាសិត) ប.

ចប់
វិសាខបូជាថ្ងៃ ៨ រោច

## គោលពិសេស

### កំណត់ថ្ងៃ-ខែ-ឆ្នាំនៃមហាបុរស

### អាទិសទ្ទេត

ចុ. រ. អា. ព្រ. ប្រ. ច. ពិ. សុក្រ
រាជ្យ. ឆ្លូវ. ក. អា. បួស. ថោះ. អា. ព្រ.
ត្រាស់. រ. ពិ. ពុធ. ជ. ម្សាញ់. មា. អា.
និ. ម្សាញ់. ពិ. អង្គារ. ស. ជូត. ពិ. ព្រ.
សា. ជូត. ពិ. អ- ង្គារ បរិបូណ៌ហោង ។

### អធិប្បាយ

១- ចុះចាប់បដិសន្ធិថ្ងៃព្រហស្បតិ៍ ១៥កើត ខែអាសាឍឆ្នាំរកា មុនពុទ្ធសកៈ ៨១ ឆ្នាំ ។
២- ប្រសូតថ្ងៃសុក្រ ១៥កើត ខែពិសាខឆ្នាំច មុនពុទ្ធសកៈ ៨០ ឆ្នាំ ។
៣- សោយរាជសម្បត្តិថ្ងៃអាទិត្យ ១៥កើត ខែកត្តិកឆ្នាំឆ្លូវ មុនពុទ្ធសកៈ ៦៤ ឆ្នាំ ។
៤- ចេញបួសថ្ងៃព្រហស្បតិ៍ ១៥កើត ខែអាសាឍឆ្នាំថោះ មុនពុទ្ធសកៈ ៥១ ឆ្នាំ ។
៥- ផ្ចាញ់មារត្រាស់ដឹងថ្ងៃពុធ ១៥កើត ខែពិសាខឆ្នាំរកា មុនពុទ្ធសកៈ ៤៥ ឆ្នាំ ។
៦- ដាក់អាយុសង្ខារថ្ងៃអាទិត្យ ១៥កើត ខែមាឃឆ្នាំម្សាញ់ មុនពុទ្ធសកៈ ៣ ខែ ។
៧- បរិនិព្វានថ្ងៃអង្គារ ១៥កើត ខែពិសាខឆ្នាំម្សាញ់ មុនពុទ្ធសកៈ ១ ឆ្នាំ ។
៨- សមោធានព្រះសារីរិកធាតុ ថ្ងៃព្រហស្បតិ៍-សុក្រ ១-២រោច ខែពិសាខឆ្នាំជូត ពុទ្ធសកៈ កន្លងបាន ៥០០០ ឆ្នាំ ។
៩- ព្រះសារីរិកធាតុនិព្វាន ថ្ងៃអង្គារ ឬពុធ ៦-៧រោច ខែពិសាខឆ្នាំជូត ពុទ្ធសកៈ កន្លងបាន ៥០០០ ឆ្នាំ ។

## បែងចែកព្រះជន្មាយុនៃព្រះមហាបុរស

១- ស្ថិតនៅក្នុងព្រះគភ៌ ១០ខែ ពេញបរិបូណ៌។

២- នៅគ្រប់គ្រងឃរាវាស មុនមានព្រះជាយា ព្រះជន្មាយុ ១៦ ឆ្នាំ ។

៣- សោយរាជសម្បត្តិអស់រយៈ ១៣ ឆ្នាំ ។

៤- ធ្វើទុក្ករកិរិយា អស់រយៈ ៦ ឆ្នាំ ។

៥- បំពេញពុទ្ធកិច្ច អស់រយៈ ៤៥ ឆ្នាំ ។

៦- រួមព្រះជន្មាយុ មហាបុរសបាន ៨០ ឆ្នាំ ។

## ហេតុការ ក្នុងរវាងព្រះជន្មាយុ មហាបុរស

១- ព្រះវរមាតាសោយព្រះទីវង្គត កាលព្រះជន្មាយុបាន ៧ ថ្ងៃ ។

២- ថ្វាយព្រះនាម កាលព្រះជន្មាយុបាន ៥ ថ្ងៃ ។

៣- ព្រះវរបិតាដីកស្រែះប្រទាន បានបងមជ្ឈាន និងសិក្សាសិល្បវិទ្យាសាស្ត្រ កាលព្រះជន្មាយុបាន ៧ ឆ្នាំ ។

៤- សោយរាជសម្បត្តិ និងអភិសេកព្រះអគ្គជាយា កាលព្រះជន្មាយុបាន ១៦ ឆ្នាំ ។

៥- ព្រះអង្គចេញបព្វជ្ជា កាលព្រះជន្មាយុបាន ២៩ ឆ្នាំ ។

៦- ព្រះអង្គបានត្រាស់ កាលព្រះជន្មាយុបាន ៣៥ ឆ្នាំ ។

៧- ព្រះអង្គបរិនិព្វាន កាលព្រះជន្មាយុបាន ៨០ ឆ្នាំ ។
ព្រះអង្គទ្រង់ប្រតិស្ឋានព្រះពុទ្ធសាសនាទុក ៥០០០ ឆ្នាំ ។

# របៀបអាសាឡ្ហបូជា

# របៀបអាសាឡ្ហបូជា

ពិធីអាសាឡ្ហបូជានេះ មានបួក្សគួរបូជាដល់ ៤ ដង គឺ:

១- **គព្ភោក្កន្តិកាល** វេលាស្តេចចុះចាប់ផ្ទៃនៃព្រះនាងមហាមាយាទេវីម្តង ។

២- **មហាភិនិក្ខមនកាល** វេលាស្តេចលះរាជសម្បត្តិចេញសាងព្រះផ្នួសម្តង។

៣- **ធម្មចក្កប្បវត្តនកាល** វេលាស្តេចធ្វើដំណើរទៅសំដែងធម្មចក្ក ប្រោស បញ្ចវគ្គីយ៍ម្តង ។

៤- **យមកប្បាដិហារិយកាល** វេលាស្តេចធ្វើយមកប្បាដិហារ្យរួចហើយ ស្តេចទៅកាន់ស្ថានតាវត្តិង្ស ដើម្បីសំដែងព្រះអភិធម្មប្រោសពុទ្ធមាតាម្តង ។

រឿងទាំង ៤. ដងនេះ នឹងមានរៀបរៀងជាសេចក្តីសម្រាប់សូធ្យបូជា ដោយសេចក្តីសង្ខេបនៅខាងមុខដូចនឹងមានតទៅ ។

មួយវិញទៀត ត្រង់បទបាលីថា: **បុព្វាសាឡ្ហ**, **ឧត្តរាសាឡ្ហ**, ដែលមានក្នុងសៀវភៅនេះ ត្រង់គ្នានឹងបទបាលីក្នុងបច្ចុប្បន្នសម័យនេះថា: **បឋមាសាឍ** **ទុតិយាសាឍ** ដែរ ព្រោះពិធីលើកខែ-ថ្ងៃ ជាពិធីហោរាសាស្ត្រធ្លាប់មានយូរយារមកហើយសូមសន្និដ្ឋានចូលចិត្ត តាមសមគួរចុះ ។

## វេរគ្រឿងសក្ការៈបូជា

អជ្ជាយំ ភន្តេ អាសាឡ្ហបុណ្ណមី សម្បត្តា អាសាឡ្ហនក្ខត្តេន យុត្តា តក្កាលសទិសេន អាសាឡ្ហនក្ខត្តេន ហោតិ, តថា ហិ អម្ហាកំ ពោធិសត្តោ ឯតាយំ អាសាឡ្ហបុណ្ណមាយំ គព្ភោក្កន្តោ ច មហាភិនិក្ខមនំ និក្ខមន្តោ ច ធម្មចក្កប្បវត្តនំ បវត្តេន្តោ ច យមកប្បាដិហារំ ករោន្តោ ច អហោសិ ។

តស្មា មយន្ទានិ សព្វេ តក្កាលសទិសំ អនុស្សរន្តា ឥធ សមាគតា ឥមេហិ ទីបធូបមាលាទីហិ សក្ការេហិ ច បូជំ ករោម ធម្មេហិ ច, សាធុ ភន្តេ ភគវា ឥមេ អម្ហាកំ ទុក្កតបណ្ណាការត្ថេ បដិគ្គណ្ហតុ ចិរំ សាសនស្ស ចិរដ្ឋាយចេវ អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

បពិត្រព្រះករុណា ទាំងឡាយដ៏ចម្រើន ថ្ងៃនេះ ជាថ្ងៃអាសាឡ្ហបុណ្ណមី ទី១៥កើត មកដល់ហើយ ប្រកបហើយដោយអាសាឡ្ហនក្ខត្តឫក្ស ប្រហែលដូចអាសាឡ្ហនក្ខត្តឫក្ស គ្រានោះដែរ សេចក្ដីពិតថា កាលនោះ ព្រះបរមពោធិសត្វជាម្ចាស់នៃយើង ស្ដេចចុះកាន់គភ៌ក្ដី ចេញសាងផ្នួសក្ដី សំដែងធម្មចក្កប្បវត្តនសូត្រក្ដី សំដែងយមកប្បាដិហារ្យក្ដី ក្នុងថ្ងៃពេញបូណ៌មីខែអាសាឍនោះ ។ ព្រោះហេតុនោះ (កាលឥឡូវនេះ) ខ្ញុំព្រះករុណាទាំងអម្បាលនេះ រឭកនូវកាលប្រហែលដូចកាលនោះ ទើបមកប្រជុំគ្នាក្នុងទីសន្និបាតនេះ ធ្វើបូជាដោយសក្ការៈទាំងឡាយ មានប្រទីប ទៀន ធូប កម្រងផ្កា ជាដើមនេះផង (បូជា) ដោយធម៌ផង បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទទួលនូវគ្រឿង បណ្ណាការទាំងឡាយនេះ ដែលជាទុគ្គតបណ្ណាការ របស់ខ្ញុំព្រះករុណាទាំងឡាយ ដើម្បីការរុងរឿងនៃសាសនាផង ដើម្បីប្រយោជន៍និងសេចក្ដីសុខ ដល់ខ្ញុំព្រះករុណាទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

(ចប់វេរគ្រឿងសក្ការៈ)

(១) បទគាថា និយាយពីស្តេចចុះកាន់គភ៌

តទា នោ សាក្យបុត្តោ អាសាឡ្ហបុណ្ណមេ សិយា
តុត្តដេ ទា តរុទារេ ទេវលោកា តតោ ចុតោ
មាតុគព្ភេ សុគណ្ឋន្តោ តត្ថ កាលំ បតិដ្ឋហិ
គាចតា សោ យថាសុខំ តម្ហា កាលំ គព្ភោបិ និក្ខមិ ៗ

ប្រែ. ឃ្លោង ៨ ពាក្យ[១]

កាលនោះរីអង្គពុទ្ធង្កុរយើង ចុះចាកភពថ្កើងគឺទេវតា
ចាប់ផ្ទៃព្រះនាងមហាមាយា មាតានាគ្រាពេញបូណ៌អាសាឍ ។
ក្នុងថ្ងៃព្រហស្បតិ៍ឆ្នាំរកាស្អាត ព្រះលោកនាថស្ថិតនៅអស់កាល
ក្នុងផ្ទៃមាតាគួរតាមក្រសាល គ្រប់កំណត់កាលស្តេចចេញចាកផ្ទៃ ។

(សកភាសិត)

(២) បទគាថា និយាយពីស្តេចចេញបព្វជ្ជា

សស[២] សំវច្ឆរេ សមេ មាសេ ឧត្តរាសាឡ្ហបុណ្ណមេ
ពោធិសត្តោ បិ អម្ហាកំ និក្ខមិត្វា អភិនេក្ខមំ
មោក្ខធម្មំ គវេសន្តោ ភវាភវេហិ បាណិនោ
បរំ បារំ តារយន្តោ សន្តំ បាបេសិ និព្វុតឹ ៗ

ប្រែ. ឃ្លោង ៨ ពាក្យ

ឯព្រះពោធិអម្ចាស់នៃយើង ទ្រង់ភ័យខ្លាចភ្លើងភពសង្សារា
កាលដែលទតយល់រូបចាស់ជរា ទាំងរូបអាពាធឈឺផ្សាសន្ធៃ។
នឹងទ្រង់យល់រូបដែលស្លាប់ក្នុងព្រៃ ថ្ងៃក្រោយទៀតនៃយល់រូបអ្នកបួស

---

(១)- មានរបៀបដូចបទបង្ក្រាវ័ត្តឆន្ទគ្រប់១អន្លើ ។ (២)- សស ប្រែថា ទន្សាយ ។

ទើបទ្រង់លះរាជ្យចេញទៅសាងផ្នួស ព្យាយាមរាន់រួសឆ្ពោះមោក្ខធម្ម ។
ថ្ងៃដប់ប្រាំកើតអាសាឍសោតសម បានឫក្សឧត្តមនៅក្នុងឆ្នាំថោះ
ប្រុងចំឡងសត្វចេញចាកភពស្មោះ សំដៅចំពោះកាន់ត្រើយខាងនាយ ។
ឱ្យបានដល់ស្ថាននិព្វានពណ្ណរាយ សុខធំទូលាយសប្បាយអនេក ។

(សកភាសិត)

(៣) បទគាថា និយាយពីទ្រង់សំដែងធម្មចក្ក

សម្ពុជ្ឈិត្វាន សម្ពុទ្ធោ លោកេ សត្ថា អនុត្តរោ
ធម្មចក្កំ បវត្តេន្តោ បញ្ចវគ្គិយគណោគថា
ឥត្ថាដេ ខារិ ហាយនេ ឧត្តរាសាឡ្ហបុណ្ណមេ
មិគទាយេ ធនេ គទា ទេវព្រហ្មាសមាគមេ ។

ប្រែ. ឃ្លោង ៨ ពាក្យ

លុះព្រះសម្ពុទ្ធត្រាស់ដឹងធម្មា បានជាសាស្តាចម្បងក្នុងលោក
ត្រិះរិះដញ្ជឹងរំពឹងវិយោគ ព្រះទ័យអនោក្សរកភិក្ខុទាំងប្រាំ ។
ព្រោះកាលដើមឡើយបាននៅថែទាំ អស់ពីរបីឆ្នាំក្នុងឧរុវេល
ឃើញព្រះសាស្តាមានវត្តដូចដែល នឹកស្មានប្រហែលថាមិនបានការ ។
នាំគ្នារត់ចោលព្រះដ៏ឈ្នះមារ ទៅនៅភពការពារាណសី
ហេតុដើមប៉ុណ្ណេះទើបព្រះជិនស្រី ទ្រង់ខំឃ្មាតខ្មីសំដៅទីនោះ ។
សំដែងធម៌កង់ត្រង់ឥតចន្លោះ ហ្មត់ចត់គ្មានខ្ចោះប្រោសភិក្ខុនោះណា
ថ្ងៃដប់ប្រាំកើតខែអាសាឡ្ហា នាឆ្នាំរកាសត្វមាន់ឥតសៅ ។
វស្សាទីមួយសម្តេចចមចៅ ទ្រង់ប្រថាប់នៅព្រៃមិគទាយ៍
កណ្តាលប្រជុំបរិស័ទព្រហ្មា ពួកមនុស្សទេវតាជួបជុំនោះដែរ ។

(សកភាសិត)

## (៤) បទគាថា និយាយពីទ្រង់ធ្វើយមកប្បាដិហារ្យ

ឆព្វស្សយេន សម្ពុទ្ធោ　　បាដិហេរំ សយំ កតោ
សសមេ ច អាសាឡ្ហេ　　បុណ្ណមេ សោ ជិនោ ទិវេ
ទេវលោកំ សុគច្ឆន្តោ　　បរិសាហិ សុរក្ខិតោ
ឆត្តឹសយោជនេហិ តំ　　សោភាមានំ មហច្ឆវី
មយន្តានិ មុនី សព្វេ　　និព្វុតី ទេ បិ ទូរតោ
កាយចិត្តេន វចសា　　អភិវន្ទាម សព្វទា
ឥមិនា តុ និស្សន្ទេន　　អាសវក្ខយំ ភវន្តុ នោ ៗ

ប្រែ. ឃ្លោង ៨ ពាក្យ

លុះកន្លងឆ្នាំប្រាំមួយហួសផុត　　ទើបព្រះសម្ពុទ្ធធ្វើឫទ្ធិចេស្តា
ព្រះអង្គទៅកាន់ទេវលោកា　　ពួកមនុស្សទេព្តសឹងច្រើនក្រាស់ក្រៃ ។
ចម្ងាយសាមសិបប្រាំមួយយោជន៍ធំ　　ហែហមបរមចមភពត្រៃ
ទាំងមុខក្រោយក្រោមលើនភាល័យ　　ជុំព្រះលោកត្រៃពេញល្អមហិមា ។
ក្នុងថ្ងៃពេញបូណ៌ខែអាសាឡ្ហា　　ឆ្នាំថោះនាមថាទន្សាយសសុទ្ធ
គឺថ្ងៃខែឆ្នាំពេលនោះប្រាកដ　　មិនបាត់រលត់ពីព្រះគម្ពីរ ។
ឥឡូវនេះយើងខ្ញុំសូមវន្ទិយ　　ឆ្ពោះព្រះមុនីដែលស្តេចនិព្វាន
សូម្បីអម្លង់យូរហើយប៉ុន្មាន　　សូមក្រាបគ្រូញប្រាណអំពីចម្ងាយ ។
ដោយកាយចិត្តចាំពាក្យនាំបរិយាយ　　ក្នុងចិត្តដែលស្តាយសព្វទិនទិវា
មួយទៀតយើងខ្ញុំសាងសូមសច្ចា　　ឱ្យដល់នូវអាសវក្ខ័យពិត
ដោយអានិសង្សដែលយើងប្រព្រឹត្ត　　តាមបទភាសិតនេះកុំឃ្លាតហោង ។

(សកភាសិត)

(៥) បទគាថា និយាយអំពីកាលទ្រង់ស្ថិតនៅក្នុងផ្ទៃ

សតោ ច សម្បជានោ ច មាតុកុច្ឆិម្ហិ ឱក្កមិ

តស្ស ឱក្កន្តិយំ សព្វា ទសសហស្សិ កម្បិថ

តតោ បុព្វនិមិត្តានិ ទ្វត្តឹសានិ តទា សិយុំ

តុដ្ឋហដ្ឋា ច សា មាតា បុត្តំ បស្សតិ កុច្ឆិយន្តិ ៗ

ប្រែ. ឃ្លោង ៨ ពាក្យ

កាលព្រះគោតមចមភពលោកត្រៃ ចុះមកកាន់ផ្ទៃព្រះពុទ្ធមាតា
មានស្មារតីចាំរាល់ទិនទិវា បណ្ដាលឫទ្ធាធំកន្លងលន់ ។
លោកធាតុទូទាំងពាន់តំបន់ កក្រើកទោរទន់សព្វទិសនានា
វេលាដែលស្ដេចសិប់ក្នុងភព្ភា និមិត្តទត្តិង្ស[១] កើតព្រមឯងឯ ។
ព្រះមាតាទ្រង់រីករាយឥតល្ហែ ព្រះនេត្របែរវេទតឃើញបុត្រនៅ
ក្នុងផ្ទៃច្បាស់លាស់ដូចមាសឆ្អិនឆ្អៅ ឯឱរសពៅពុំឃើញមាតា ។
នេះជាទំនៀមពីបោរាណា គ្រប់អង្គពុទ្ធាសឹងដូច្នោះឯង ។

(បុរាណភាសិត)

(៦) បទគាថា និយាយពីទ្រង់ក្រសាលក្នុងឧទ្យាន

អាភុជិត្វាន បល្លង្កំ និសិន្នោ រុចិរាសនេ,

ភារាបេត្វំ វិចិន្តយិ ទេហភូសនមត្តនោ

តស្ស ចិត្តំ វិទិត្វាន វិស្សកម្មស្សិទំព្រាវិ,

អលង្ករោថ សិទ្ធត្ថ មីតិទេវានមិស្សរោ

តេនាណត្តោ ច គន្ត្វាន វិស្សុករម្មា យសស្សិនោ

ទសទុស្សសហស្សេហិ សីសំ វេឋេហិ សោភណំ ៗ

(១)- និមិត្ត ៣២ ប្រការ គឺហ្វឹនលោកធាតុមានរស្មីភ្លឺសព្វទិសជាដើម បឋមសម្ពោធិ គព្ភានិក្ខមនបរិច្ឆេទ ។ មានក្នុងទំព័រខាងមុខ ។

ប្រែ. ឃ្លោង ៨ ពាក្យ

ព្រះពោធិសត្វពត់ភ្នែននឹងធឹង អង្គុយសម្រឹងលើអាសនា
ទ្រង់មានព្រះទ័យផ្គងបំណងថា ឱហ៊ំនរណាស្អិតស្អាងរាងកាយ ។
របស់ទ្រង់នឹងក្រសាលសប្បាយ ឱ្យបាត់ក្រហាយក្នុងសូននោះឯង
ព្រះឥន្ទជ្រាបច្បាស់ទើបទ្រង់ថ្លាថ្លែង ប្រើអ្នកតាក់តែងគឺវិស្សុកម្ម ។
ដោយពាក្យថាអ្នកចូលស្អាងឱ្យសម ប្រដាប់អប់រម្យអង្គឱរសថ្លៃ
ទេព្តបំរើត្រូវព្រះឥន្ទប្រើ ចុះមកស្អិតស្អាងប្រញាប់រ៉ៃៗ ។
ដោយសម្ផត់ទិព្វសសុទ្ធផុតថ្លៃ មួយពាន់ត្បូងនៃរុំដល់ព្រះសិរ
អង្គអយ្យបុត្រសឹងល្អឥតពីរ ឧបមាផ្ទឹមផ្ទៃរស្មាដៃទេព្ត ។

(បុរាណភាសិត) ប.

(៧) បទគាថា និយាយពីមុននឹងស្តេចចេញបព្វជ្ជា

ឋិតា ឧបរិបាសាទេ ៖ កិសាគោតមី តំ តទា
រាជបុត្តំ សគរសិច រាជ ឌិស្វា ភជេសិទំ
និព្វុតា នូន សា មាតា និព្វុតោ នូន សោ បិតា
និព្វុតា នូន សា នារី យស្សាយំ ឦទិសោ បតិ ។

ប្រែ. ឃ្លោង ៨ ពាក្យ

កាលនោះព្រះនាងនាមគោតមី ជាតិជាស្ត្រីព្រះញាតិផងគ្នា
ឈរនៅក្រសាលនាប្រាសាទា ឆ្មៀងព្រះនេត្រាយល់អយ្យបុត្រ ។
ទ្រង់មានលំអឆើតឆាយចំហុត ជាអង្គប្រុសផុតដូចព្រះអាទិត្យ
ទើបលាន់ព្រះឱស្ឋសរសើរក្តីពិត តាមដែលគាប់ចិត្តដូច្នេះឯងថា ។
ព្រះសិទ្ធត្ថសូនបើកូននាងណា នោះសមមាតារលត់ទុក្ខសោក
បើបានជាបុត្របិតាក្នុងលោក ឪពុកមានសោករលត់ពុំខាន ។

ប្រសិនបើបានជាបុរសពីរប្រាណ សេពសមរួមស្ថានប្តីនារីណា
នារីនោះថ្វាត់ខ្វាត់ទុក្ខភយា ព្រោះអាស្រ័យស្វាមីអង្គនេះឯង ។

(បុរាណភាសិត) ប.

(៨) បទគាថា និយាយពីដាស់ឆន្នាមាត្យ

ឥតិ ឥសំ គិរំ សុត្វា មនុញ្ញកាយ ភាសិតំ
សញ្ជាតបីតិយា បិណោ គច្ឆមានោ សកាលយំ,
បាសាទមភិរុហិត្វា វេជយន្តំ ច សុន្ទរំ
និបជ្ជិ ទេវរាជា ច សយនេ សោ មហារហោ,
អច្ចន្តសេចនំ ឆន្នំ អាមន្តេត្វា កថេសិទំ
អានេហិ ឥតិ កប្បេត្វា កណ្ឌកំ នាម សិន្ធវំ ។

ប្រែ. ឃ្លោង ៨ ពាក្យ

ព្រះពោធិសត្វច្បាស់ច្បងស្តេចស្តាប់ ចម្រៀងរៀបរាប់ដូច្នេះឯងនៃ
ដែលនាងកិសាគោតមីថ្វាថ្វៃ សរសើរចមត្រៃដោយក្តីគាប់ចិត្ត ។
លុះទ្រង់ស្តាប់ហើយព្រះអង្គរិះគិត ព្រះទ័យរីងរិតពោរពេញ្ញើតម្រេក
ស្តេចយាងទៅកាន់មន្ទីរល្អឯក ដំណាក់ខាងប៉ែកព្រះសុំយម្ពូ ។
ឡើងកាន់ប្រាសាទស្អាងស្អាតឥតគូ សណ្ឋានគំរូដូចវេជយន្ត
ទ្រង់ផ្ទំជាសុខលើព្រះអាសនៈ ថ្លៃភាប់រយពាន់ដូចស្តេចទេវតា ។
លុះទ្រង់តើនហើយដាស់នាយកណ្ឋា ប្រាកដនាមាឆន្នអាមាត្យស្រាប់
ជាអ្នកធ្លាប់ស្តាប់ពាក្យពេចន៍ខ្ពស់ទាប ស្រេចហើយថ្លែងប្រាប់បំណងនេះថា ។
ចូរព្រះស្តែងទៅដឹកយកសិន្ធវា គឺសេះកណ្ឋកចេញមករួសរើ
ចូរចងគ្រឿងអានឱ្យខ្ជាប់ប្រពៃ អង្គយើងនេះនៃនឹងចេញបួសថ្វាត់ ។

(បុរាណភាសិត) ប.

(៩) បទគាថា និយាយពីកាលទ្រង់ជួបនឹងឧបកាជីវក (ក)

សព្វាភិភូ សព្វវិទូហមស្មិ សព្វេសុ ធម្មេសុ អនូបលិត្តោ
សព្វញ្ជហោ តណ្ហក្ខយេ វិមុត្តោ សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ ។

ប្រែ. បទពំនោល[១]

តថាគតលើសលប់លោកា កន្លងនាគា ទាំងមនុស្សទេព្តមារព្រហ្ម ។
ជ្រាបច្បាស់អស់ធម៌តូចធំ ដែលនៅអប់រំ សន្តានសត្វផ្ងក្នុងភព ។
ចិត្តសោតដែលប៉ះជំពប់ ងងុយងងុប ប្រឡាក់ក្នុងភពសម្ពាយ ។
លះចោលមិនបានសោកស្តាយ ធម៌ថោកនៅអាយ សុខលាយទុក្ខក្នុងភពបី ។
រួចផុតដោយមានសិរី ឥតអន្តរាយអ្វី អំពីតណ្ហាទៀតឡើយ ។
យើងនេះជ្រាបឯងជាត្រើយ មិនមានគ្រូឡើយ នាក្រោមដើមពោធិព្រឹក្ស ។

(បុរាណភាសិត) ប.

(១០) បទគាថា និយាយពីកាលទ្រង់ជួបនឹងឧបកាជីវក (ខ)

ន មេ អាចរិយោ អត្ថិ សទិសោ មេ ន វិជ្ជតិ
សទេវកស្មឹ លោកស្មឹ នត្ថិ មេ បដិបុគ្គលោ ។
អហញ្ហិ អរហា លោកេ អហំ សត្ថា អនុត្តរោ
ឯកោម្ហិ សម្មាសម្ពុទ្ធោ សីតិភូតោស្មិ និព្វុតោ ។
ធម្មចក្កំ បវត្តេតុំ គច្ឆាមិ កាសិនំ បុរំ
អន្ធីភូតស្មឹ លោកស្មឹ អហញាហមតទុន្ទុភឹ ។

ប្រែ. ឃ្លោង ៨ ពាក្យ

តថាគតឥតមានគ្រូអាចារ្យ រកបុគ្គលណាស្មើគ្នាមិនមាន
ក្នុងលោកទោះទាំងទេវលោកស្ថាន រកគូផ្ទឹមគ្មាននឹងយើងឡើយនៃ ។

---

(១)- ធ្វើបទដូចស្មូត្រ ធារយោគ ។

យើងនេះឯងជាអរហន្តថ្លៃ ផុតសត្វក្នុងត្រៃលោកទាំងបីណា
អង្គយើងនេះឯងជាតិជាសាស្តា ប្រសើរថ្លៃថ្លាខ្ពង់ខ្ពស់បំផុត ។
ជ្រាបច្បាស់ធម៌ត្រូវតែម្នាក់ឯងគត់ បានជាសម្ពុទ្ធត្រជាក់ឥតក្តៅ
ឯកងកិលេសដែលជាគ្រឿងម៉ៅ សឹងរលត់ទៅអស់ឥតសេសសល់ ។
យើងនេះទៅកាន់បុរីមណ្ឌល កាសីសាកលដែនរដ្ឋសីមា
ដើម្បីសម្តែងព្រះធម៌ទេសនា ព្រះសូត្រនាមាហៅធម្មចក្ក ។
បំណងនឹងដាស់ពួកសត្វឱ្យភ្ញាក់ ព្រោះបានឮជាក់ស្គរនិព្វានហើយ ។

(បុរាណភាសិត) ប.

(១១) បទគាថា និយាយពីកាលស្តេចទៅកាន់ដែនពារាណសី

យស្មិំ ចិហេរា ឥសិបតេ្នច កធាបិ ភិក្ខូ ចស្សន្តិ បញ្ច នុភមេន ចរិមិ វេយ្យា
សក្តា ចនំ រមណិយំ កចធស្សិរិ នោ សព្វេច គំ ចិរុចយំ អច្ឆសិសុ ធូរ,
ធិស្វាន គំច បតិត្តមនំ អភាសុំ ឯកេមិ គណ្ហិសុ[១] មុនិស្ស សយេហិ បត្តំ
នក្កញ្ច ចីចរសុចី បរិសាចនំ កេ[២] ចាសី បដិគ្គហិកុបាហនមេ[៣] ឯកេ
អជ្ជារណញ្ច បចរំ អភិសណ្ឋរេសុំ នាថោ ចរោ ឧបនិសីទិ សុអាសនេ សោ
ឯកំ អរោច ចចនំ មធុរម្បិ គេសំ ធ្វេមេបិ ឈមភបថា ន ច សេចិកញ្ច,
ភិក្ខូហិ នាម ចិរបព្វជិគេហិ ភិក្ខវេ កេ ធ្វេ កាម៌សុខល្លិកានុយោគតោ អន្ត
អត្តាភិលាមថនុយោគបថា[៤] ឥមេ ខោ ចម្មា ន សុខមនិយា ន ច ភជ្ជិកញ្ច,
និព្វានសច្ចិករណស្ស ន សំចកន្តិ សុគេ្គ អន្ធចិចចិញ្ញហិ ឱលោភេកញ្ចំ ។

ប្រែ. បទព្រហ្មគីត

កាលគ្រានោះសោតនៃ វត្តីយ៍ថ្លៃប្រាំអង្គា
នៅគង់ចាំវស្សា នាព្រៃឥសិបតនៈ ។

(១)- គណ្ហិសូតិ គណ្ហិសុ ។ (២)- កេតិ ឯកេ ភិក្ខូតិ អត្ថោ ។ (៣)- បដិគ្គហិតុបាហនាតិ បដិគ្គហិតា ឧបាហនំ ឯវំ ។
(៤)- អត្តកិលាមបថានុយោគបថាតិ អត្តកិលាមបថានុយោគបថាតិ អត្ថោ ។

មាននៅក្នុងទីណា ព្រះសាស្ដាជាអ្នកឈ្នះ
ក្រុងមារស្ដេចរលះ រលាំងចរតាមលំដាប់ ។
សំដៅទៅកាន់ព្រៃ ត្រង់នោះនៃជាទីគាប់
ប្រសើរយ៉ាងចំណាប់ ព្រះពុទ្ធផងតែងរាប់អាន ។
ឯពួកភិក្ខុទាំងពួង បួសជម្បូងទាំងប្រាំប្រាណ
បានឃើញព្រះទ្រង់ញាណ មានរស្មីភ្លឺរន្ទាល ។
ស្ដេចមកពីចម្ងាយ ឯកអង្គកាយដោយព្រៃវាល
ព្រះភក្ត្រស្រស់ល្អច្រាល ដូចទ្រង់កាលនៅប្រក្រតី ។
លុះឃើញស្ដេចយាងដល់ ក្រោករចល់រូសម្នាម្នី
ទទួលព្រះជិនស្រី ខ្លះឃ្មាតខ្មីកាន់យកបាត្រ ។
របស់ព្រះមុនី ខ្លួនឯងមីរខំសង្វាត
ខ្លះទៀតយកឆត្រស្អាត នឹងចីវរបំពង់ម្ជុល ។
ខ្លះទទួលច្រមខណ្ឌ ខ្លះសោតកាន់កាំបិតកោរ
សុពណ៌បាទតាមត្បាជ្រួល ចោមខ្មៅខ្វលក្រាលកម្រាល ។
ព្រះពុទ្ធជាទីពឹង ប្រសើរសឹងគង់ត្រអាល
លើទីដែលគេក្រាល ហើយទើបត្រាស់ព្រះពុទ្ធដីកា ។
ពីរោះក្រាងក្រអៅ ចំពោះទៅពួកខ្ញុំសមណា
ទាំងនោះដូច្នេះថា ម្នាលភិក្ខុអ្នកចូរស្ដាប់ ។
វិធម៌ពីរអន្តា(១) នេះជាផ្លូវពុំគាប់
លាមកប្រាជ្ញពុំរាប់ អ្នកបួសគាប់ពុំគួរសេព ។
ទើបត្រាស់ទៀតផ្ទួនៗ ថែមចំនួនមានបទបែប
ឃាត់ហាមការសំណេប មិនជាបែបនៃអ្នកបួស ។
ធម៌ពីរតើអ្វីខ្លះ ? តបតម្រាស់ជាជំនួស

(១)- កាមសុខល្លិកានុយោគ ១: កាមអត្តកិលមថានុយោគ ១ ។

រាប់គោលដោយត្រួសៗ មិនឱ្យហួសនឹងបទដើម ។
ជាធម៌ពីរអន្ថា គឺស្នេហាកាមយ៉ាងឆ្អើម
បានទុក្ខធំសម្បើម នេះជាដើមក្ដីសុខមួយ ។
មួយទៀតគឺប្រាថ្នា ចង់អាត្មាប្រាស់ទុក្ខព្រួយ
បំប៉នធម៌អំណួយ ស្លាងខ្លួនមួយឱ្យបានទុក្ខ ។
ជាធម៌គម្រប់ពីរ យើងផ្ដាច់ផ្ដិលហើយញីញុក
ពួកអ្នកគួរចាំទុក កុំសេពគប់កុំសម្ដី ។
មិនមែនប្រព្រឹត្តទៅ ដើម្បីក្ដៅអស់រាគី
អស់ទោសផុតមោហ៍ ធ្វើនិព្វានឱ្យច្បាស់ឡើយ ។
ធម៌នេះមានអត្ថជ្រៅ ប្រាជ្ញឆោមឆ្លៅកុំព្រងើយ
ពិនិត្យសព្វទៅហើយ គង់ជ្រាបច្បាស់ក្នុងធម្មចក្ក ។

(សកភាសិត) ប.

## (១២) បទគាថា និយាយពីស្ដេចធ្វើយមកប្បាដិហារ្យ

ឯវម្បិ សត្ថា វិវិធំ វិចិត្តរូបំ កត្វា វិហាសេ ច បតិដ្ឋិតោ តទា
អាបជ្ជិ អាលោកកសិណំ វរំ តតោ ឧដ្ឋាយ តេជោកសិណំ សមាបជ្ជិ,
វារិស្ស ធារា ឧបរិមកាយតោ សន្ទាវតី ហេដ្ឋិមកាយតោ គិនី
តស្សាបិ សត្ថុស្ស បវត្តិតោ តថា កាយូបរិមា គិនិ សម្បវត្តិតោ,
អាបោបិ សន្ទាវតិ ហេដ្ឋិមកាយតោ តេជោ បុរិមា សរីរា បវត្តិរេ
បច្ឆា ឧទកំ សន្ទវតំ យថាក្កមំ តោយំ សរីរា បុរិមា ច សន្ទតំ,
បច្ឆាបិ សំវត្តតិ កាយតោ គិនី ទក្ខិណហត្ថា ឧទកំ ច សត្ថុនោ
ជាលា បវត្តា អថ វាមហត្ថតោ អម្ពុម្ហិសន្ទា អសិ វាមអក្ខតោ,
សត្ថុស្ស តេជោ ជរិ ទក្ខិណក្ខិតោ អាបោច សន្ទា វាមកណ្ណសោតតោ
តេជោ ច សំវត្តតិ ទក្ខិណា កណ្ណា វាម្ហាសតោច ឧទកម្បិ សន្ទតំ,

ទក្ខិណនាសាយ គិនី បវត្តិតោ អគ្គី បវត្តោ បិច វាមបស្សតោ

ទក្ខិណបស្សា ឧទកម្ពិសន្ទតំ សំវត្តិរោ អគ្គិ បិ វាមបាទតោ,

ទក្ខិណបាទា អភិសន្ទតំ ឧទកំ តេជោ ផរី ទក្ខិណអង្គុលីហិ វា

វាមេហិ អាបោ អនុធាវិ អង្គុលីហិ តេជោ ផរី ឯកិលោមកូបតោ,

ឯកេកលោមា ឧទកំ ច សន្ទតំ សំវត្តតិ អគ្គិ បិ ឯកលោមតោ

វារី វហា ឯកេកលោមកូបតោ អាបស្ស ធារាយ គិនី អសម្មិសោ

អគ្គិស្ស ខន្ធេន ឧទកំ អសម្មិសំ ទ្វេ មេ គិនី វារី ច យាវ ព្រហ្មុនា

ឧគ្គច្ឆិសុ តេជេន សត្ថុ អម្ហាកំ ៗ

ប្រែ. បទពំនោល

កាលនោះអង្គសាស្តាចារ្យ ស្តេចធ្វើបាដិហារ្យ អស្ចារ្យដោយឫទ្ធិផ្សេងៗ ។
ស្ថិតនៅទីវាលធំធេង ឆ្ងាយគួរវង្វេង នាងអាកាសវេហាស៍ ។
ទ្រង់ចូលកសិណនាមា ប្រាកដឈ្មោះថា អាបោកសិណប្រសើរ ។
ប្រុងប្រៀបរៀបចំដំណើរ ចាកឈានពុំស្មើ ទ្រង់ចូលឈានទៀតជាថ្មី ។
ឈានសោតលំដាប់ពីរបី គួរតាមបាលី ហៅថាតេជោកសិណ ។
បង្វិលចុះឡើងតាមប៊ុន បរិស័ទផងមិន អាចយកតម្រាប់បានឡើយ ។
តែយ៉ាងនេះឯងជាត្រើយ ស្ទង់ពិនិត្យហើយ គង់ជ្រាបដូចមានតទៅ ។
ធារទឹកពណ៌សសន្ធៅ រស្មីច្រាលឆៅ ហូរចេញពីកាយខាងលើ ។
កងភ្លើងប្រព្រឹត្តអើពើ ឈមមុខមកលើ បញ្ចេញពីកាយខាងក្រោម ។
អង្គព្រះសាស្តាឆាយឆោម ទឹកភ្លើងប្រលោម ចេញពីព្រះពុទ្ធកាយា ។
កងភ្លើងប្រព្រឹត្តគមនា ចេញផ្លាស់ប្តូរគ្នា ពីចំណែកកាយខាងលើ ។
អាបោទឹកសោតប្រសើរ ហូរលឿនមិនស្មើ ពីចំណែកកាយខាងក្រោម ។
ភ្លើងវិលឆេះឆាបទ្រលោម ដូចកលខ្លោចរោម ចេញពីខាងសីរា ។
ទឹកហូរប្រកិតតាមគ្នា មិនមានរូញរា ចេញចាកសីរាខាងក្រោយ ។
ស្មើៗលំដាប់លំដោយ ឥតមានមុខក្រោយ ពុំប៉ះទង្គិចនឹងគ្នា ។

ទឹកហូរចេញចាកសរីរា ខាងមុខវិញណា ភ្លើងសាចេញពីខាងក្រោយ ។
ទឹកហូរផ្លាស់ដានបណ្តោយ ពុំមានធ្លស់ធ្លោយ ចេញចាកព្រះហស្តខាងស្តាំ ។
អង្គព្រះសាស្តាសស្រាំ ភ្លើងមិនប្រចាំ ចេញចាកព្រះហស្តខាងឆ្វេង ។
ទឹកហូរដូចបាក់កញ្ចែង ចាកព្រះនេត្រឆ្វេង ភ្លើងភ្លេងចេញព្រះនេត្រស្តាំ ។
អង្គព្រះគ្រូយើងលលាំ ទឹកហូរទន្ទាំ ចេញពីព្រះសោតឆ្វេងវិញ ។
ភ្លើងឆេះបាក់ដូចប្រដេញ សន្ទុះឃ្លុលខ្ទាញ់ ចេញពីព្រះកាណ៌ខាងស្តាំ[១] ។
ទឹកសោតហូរជោរមួនមាំ គួរតាមលំនាំ ចេញពីនាសៈ[២] ខាងឆ្វេង ។
ភ្លើងច្រាលរន្ទាលធំធេង ឆួលឆេះខ្លួនឯង ចេញពីព្រះនាសខាងស្តាំ ។
ម្តងទៀតភ្លើងវិលក្រញាំ មិនឱ្យទឹកចាំ ចេញចាកចំហៀងឆ្វេងអង្គ ។
ទឹកហូរសំដៅតម្រង់ ចេញចាកព្រះអង្គ ពីចំហៀងកាយខាងស្តាំ ។
ភ្លើងលោដូចនឹងប្រខាំ ឬហាក់ដូចពាំ ចេញពីព្រះបាទខាងឆ្វេង ។
ឯទឹកហូរត្រជាក់ស្រេង តាមធម្មតាឯង ចេញចាកព្រះបាទខាងស្តាំ ។
ភ្លើងផ្សាយឬទីចំណាំ មិននឹងនៅស្ងាំ ចេញពីម្រាមស្តាំឯងឯង ។
អាបោធាតុហូរឥតល្ហែ ទឹកថ្លាគួរស្នេហ៍ ចេញម្រាមព្រះហស្តខាងឆ្វេង ។
តេជោភ្លើងទ្រោលទន្ទេង ចេញផ្សាយគួរស្ញែង ពីរណ្តៅរោមមួយ១ ។
ធារាទឹកហូរខ្លួរដូចជ្រួយ ចេញចាករោមមួយ ទ្រទេសទ្រទ្រួយជាភ្លី ។
តេគ្គីត្រឡប់ឃ្លាតខ្ចី ផ្លាស់ស្នាមប្រក្រតី ចេញពីរោមមួយវិញភ្លាម ។
វារីក៏មិនទីមទាម ងាករេជំពាម ចេញរណ្តៅរោមជួសភ្លើង ។
គំនរភ្លើងធំថ្មីថ្មើង ចេញផ្សាយរាល់ជើង មិនច្រឡំប៉ឹងដោយទឹក ។
ទឹកហូរព្ទុស្ទុះគគឹក មិនមានវរីក ច្រឡំដោយភ្លើងទទៃ ។
ភ្លើងទឹកទាំងពីរប្រពៃ ឡើងខ្ពស់សន្ធៃ ដាលដល់ពិភពព្រហ្មនាយ ។
តេជះគុណធំទូលាយ សាស្តាខ្វល់ខ្វាយ សន្សំទុកមកច្រើនកប្ប ។

(សកភាសិត)

(១)- ត្រចៀក ។ (២) ច្រមុះ ។

# បុព្វនិមិត្ត ៣២ ប្រការគឺ

១- ហ្មឺនលោកធាតុ បណ្ដាលញាប់ញ័រ នឹងមានរស្មីភ្លឺសព្វទិសានុទិស ។

២- លោកន្តរនរកដែលងងឹតជាធម្មតា ត្រឡប់ជាមានពន្លឺភ្លឺវិញ ។

៣- ជនមានចក្ខុអន្ធការ ត្រឡប់ជាមើលឃើញរូបផ្សេងៗ បានវិញ ។

៤- ជនអ្នកថ្លង់ ត្រឡប់ជាស្ដាប់សំឡេងឮបានវិញ, អ្នកគ ត្រឡប់ជានិយាយបានវិញ, អ្នកគម ត្រឡប់ជាមានកាយត្រង់វិញ, អ្នកខ្វិន ត្រឡប់ជាដើរបានវិញ ។

៥- អ្នកជាប់ចំណងខ្នោះឃ្នាង ត្រឡប់ជារបូតពីចំណងបានវិញ ។

៦- ភ្លើងនរកមានអវិចីជាដើម ក៏រលត់សូន្យ ។

៧- សេចក្ដីស្រេកឃ្លានក្នុងបេតវិស័យ ក៏ស្ងប់រម្ងាប់ ។

៨- ទ្វារបង្អួចគ្រប់ៗផ្ទះ ក៏របើកចេញឯង ។

៩- សំពៅនាវាទាំងឡាយ ក៏លឿនទៅឯង កាន់កំពង់គួរតាមប្រាថ្នា ។

១០- សត្វតិរច្ឆានទាំងឡាយ ក៏ឥតមានតក់ស្លុតភ័យភិត ។

១១- ភ្លើងកិលេសនិងរោគាព្យាធិទាំងឡាយ ក៏ស្ងប់រម្ងាប់ ។

១២- សត្វដែលមានវេរានិងគ្នា ក៏ត្រឡប់ជាមានមេត្តាចិត្តដល់គ្នាវិញ ។

១៣- ពួកសត្វផ្សេងៗ ពោលហៅរកគ្នាដោយបិយវាចា នឹងពួកសេះក៏ស្រែកសម្រែកដោយអាការពីរោះ ។

១៤- ហ្វូងដំរី ក៏បន្លឺសម្រែកគឹកកង ។

១៥- តូរ្យតន្ត្រីទាំងពួង ក៏លាន់ឮសំឡេងឡើងឯង ។

១៦- គ្រឿងប្រដាប់ដៃគឺចិញ្ចៀនជាដើម ប៉ះទង្គិចគ្នាបញ្ចេញសំឡេង បញ្ចេញរស្មីឡើងឯង ។

១៧- ទិសទាំងឡាយ ក៏មានរស្មីឱភាសរុងរឿង ។

១៨- ខ្យល់ព្យុះខ្យល់ធំ ក៏ស្ងប់មិនបក់ផាត់ទៅមក ។

១៩- មន្ទវាត ខ្យល់ស្រទន់ ក៏ផាត់ទៅមកជាសុខស្រួល ។

២០- អាកាសមេឃ ក៏បង្អុរភ្លៀងធ្លាក់ចុះ ។

២១- ធារទឹកក៏ទំលាយផែនដី បញ្ចេញទឹកហូរសព្វទិស ។

២២- ពួកបក្សាជាតិ មិនហើរផ្លូវអាកាស ត្រឡប់ជាចុះដើរដីវិញ ។

២៣- ខ្សែទឹកស៊ឹងក៏មិនហូរ ដូចទឹកក្នុងស្រះ ។

២៤- លោណវារី ទឹកប្រៃក្នុងមហាសមុទ្រ ក៏ប្រែជាសាបមានរសជាតិឆ្ងាញ់ ។

២៥- បទុមជាតិមានពណ៌ ៥ ទាំងពួងក៏កើតដេរដាសក្នុងសាគរទឹកនិងប្រឹថពី ។

២៦- ថលជាតិ ជលជាតិ ផ្កាឈើគោកក្នុងទឹក ក៏បញ្ចេញផ្ការីកស្គុះស្គាយទូទៅទាំងអស់ ។

២៧- ពួករុក្ខជាតិ លតាជាតិ ក៏បញ្ចេញផ្កា បទុមជាតិគ្រប់ៗមែក ។

២៨- ទងឈូកទាំងឡាយ ទំលាយផែនសិលា ហើយបញ្ចេញផ្ការយោងរយាន ក្នុង ១ ទង ៧ នឹងសំយុងចុះតាមអាកាស ។

២៩- បណ្តារុក្ខជាតិ លតាជាតិទាំងឡាយ ដែលមិនធ្លាប់មានផ្កាផ្លែ ក៏ត្រឡប់មានផ្កាផ្លែវិញ ។

៣០- ផ្កាមណ្ឌារវៈទិព្វទាំងឡាយ ក៏បង្អុរភ្លៀងផ្កាទិព្វជុំវិញលោកធាតុ ។

៣១- តូរ្យតន្ត្រីទិព្វទាំងឡាយ ក៏លាន់ឮសំឡេងឡើងឯងនាផ្ទៃអាកាស ។

៣២- ហ្មឺនលោកធាតុ មានទង់មានកម្រងផ្កា ដេរដាសជាប់ផាមួយគ្នាគួរនាដូចបាច់ផ្កា ឬដូចកម្រាលផ្កាអ្នកតុបតែងហើយ ទាំងវាលវិថីធី ស៊ឹងផ្សាយទៅដោយផ្កា ។

រួមជានិមិត្ត ៣២ ប្រការ កើតប្រាដកក្នុងវេលាដែលចុះកាន់ព្រះគភ៌ ។

ចប់

ពិធីអាសាឡ្ហបូជា តែបុណ្ណេះ

# របៀបអស្សយុជបូជា

# អស្សយុជបូជា

ពិធីអស្សុជបូជានេះ មានឫក្សបូជាតែមួយពេល សំដៅយកត្រង់នក្ខត្តសម័យ ដែលព្រះសម្ពុទ្ធធ្វើយមកប្បាដិហារ្យចុះចាកទេវលោក នាថ្ងៃពេញបុណ្ណមី ខែអស្សុជនោះ កាលបើដល់វេលាគួរហើយ ត្រូវពួកពុទ្ធបរិស័ទប្រជុំគ្នាតាក់តែងគ្រឿងសក្ការៈបូជាផ្សេងៗ ថ្វាយចំពោះព្រះរតនត្រ័យ ដូចក្នុងអាសាឡ្ហបូជានោះដែរ ។ ប្រសិនបើឃើញថា វេលានោះ ជួនកាលមានរវល់ដោយព្រះសង្ឃ មានកិច្ចធ្វើបវារណាអស់ពេលច្រើនជ្រុល នឹងចាត់ចែងធ្វើពិធីបូជាមិនបាន នឹងបង្អង់ខានវិញក៏ឥតមានទាស់ទេ ។

## វេរគ្រឿងសក្ការៈបូជា

ឥទានាយំ ភន្តេ អស្សយុជបូជាបុណ្ណមី មហាបវារណាកាលោ សម្បត្តោ តថាគតស្ស ទេវោរោហនកាលសទិសោ ហោតិ ។ អថ ខោ ភគវា អម្ហាកំ ទេវលោកំ គច្ឆន្តោ សត្តមេ វស្សេ តាវត្តឹសភវនេ មាតុគុណមារព្ភ អភិធម្មកថំ កថេន្តោ តត្ថ វស្សំ ឧបគមិ ។ សោ តេមាសច្ចយេន វុដ្ឋវស្សោ សសំវច្ឆរេ អស្សយុជបុណ្ណមាយំ ទេវោរោហនសមយេ វិវិធំ ឥទ្ធឹ វិកុព្វេន្តោ មនុស្សលោកំ អាគមិ ។ តស្មា មយំ សព្វេ ឥធ សមាគតា តស្ស តក្កាលសទិសំ អនុស្សរន្តា ឥមេហិ ទីបធូបមាលាទីហិ សក្ការេហិ ច បូជំ ករិម្ហា ធម្មេហិ ច សាធុ ភន្តេ ភគវា ឥមេ អម្ហាកំ ទុគ្គតបណ្ណាការភូតេ បដិគ្គណ្ហាតុ សាសនស្ស ចិរោចនត្ថាយ ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើន កាលឥឡូវនេះ ជាថ្ងៃបុណ្ណមីខែអស្សុជ ជាមហាបវារណាកាលមកដល់ហើយ ប្រហែលដូចកាលដែលព្រះតថាគត យាងចុះចាក ទេវលោកពិត ។ ព្រោះថាកាលនោះ ព្រះដ៏មានព្រះភាគជាម្ចាស់នៃយើងទាំងឡាយ ស្ដេចយាងឡើងទៅឋានទេវលោក សម្ដែងអភិធម្មកថា ប្រោសពុទ្ធមាតុគុណ ឰដ៏ពិភព តាវត្តិង្ស ក្នុងវស្សាជាគម្រប់ប្រាំពីរ ស្ដេចចាំវស្សា ក្នុងឋានតាវត្តិង្សនោះ ។ លុះកន្លង ៣ខែហើយ ព្រះដ៏មានព្រះភាគ ចេញវស្សារួចហើយ ទ្រង់ធ្វើឫទ្ធិផ្សេងៗ ក្នុងទេវោរោហនសម័យ ថ្ងៃពេញបុណ្ណមី ខែអស្សុជឆ្នាំថោះ ហើយស្ដេចចុះមកកាន់មនុស្សលោក ។ ព្រោះហេតុនោះ (កាលឥឡូវនេះ) ខ្ញុំព្រះករុណាទាំងឡាយ មកជួបជុំគ្នាក្នុងទីសន្និបាត នេះ (ដោយសេចក្ដី) រឭកនូវកាលនោះ របស់ព្រះដ៏មានព្រះភាគ បានធ្វើបូជាដោយ សក្ការៈទាំងឡាយ មានប្រទីប ទៀន ធូប កម្រងផ្កាជាដើមផង បូជាដោយធម៌ផង បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន សូមព្រះអង្គទទួលនូវគ្រឿងបណ្ណាការទាំងឡាយនេះ ដែលជាទុគ្គតបណ្ណាការ របស់ខ្ញុំព្រះករុណាទាំងឡាយ ដើម្បីការរុងរឿងនៃសាសនាផង ដើម្បីប្រយោជន៍ និងសេចក្ដីសុខ ដល់ខ្ញុំព្រះករុណាទាំងឡាយផង អស់កាលជាអង្វែង ទៅហោង ។

ចប់
វេរគ្រឿងសក្ការ

# រតនប្បណាម

ពុទ្ធោ សុសុទ្ធោ ករុណាមហណ្ណវោ    យោច្ចន្តសុទ្ធព្វរញ្ញាណលោចនោ
លោកស្ស បាបូបកិលេសឃាតកោ    វន្ទាមិ ពុទ្ធំ អហមាទរេន តំ
ធម្មោ បទីបោ វិយ តស្ស សត្ថុនោ    យោ មគ្គបាកាមតភេទភិន្នកោ
លោកុត្តរោ យោ ច តទត្ថទីបនោ    វន្ទាមិ ធម្មំ អហមាទរេន តំ
សង្ឃោ សុខេត្តាភ្យតិខេត្តសញ្ញិតោ    យោ ទិដ្ឋសន្តោ សុគតានុពោធកោ
លោលប្បហីនោ អរិយោ សុមេធសោ    វន្ទាមិ សង្ឃំ អហមាទរេន តំ
ឥច្ចេវមេកន្តភិបូជនេយ្យកំ    វត្ថុត្តយំ វន្ទយតាភិសង្ខតំ
បុញ្ញំ មយា យំ មម សព្វុបទ្ទវា មា ហោន្តុ វេ តស្ស បភាវសិទ្ធិយា។

ប្រែ. កាព្យពាក្យ ៧

ព្រះសម្ពុទ្ធម្ចាស់អង្គឯណា    ទ្រង់គុណថ្លៃថ្លាល្អហួសហ្លួង
គឺវិសុទ្ធគុណស្អាតកន្លង    ករុណាគុណផងជ្រៅទូលាយ ។
ដូចកល់អន្លង់ធារធំឯក    ល្វេងល្វើយអនេកផុតអធិប្បាយ
ទាំងបញ្ញាគុណរុងរឿងឆ្លាយ    ប្រសើរសុសសាយសព្វលើសលប់ ។
ទ្រង់សម្លាប់ចោលគ្រឿងសៅហ្មង    បាបកម្មចាំចងសត្វក្នុងភព
ដោយការព្យាយាមមិនឈរឈប់    រាល់ថ្ងៃរាល់យប់សព្វវេលា ។
យើងខ្ញុំបង្គំព្រះពុទ្ធនោះ    ល្បីកេរ្តិ៍ឈ្មោះផុតភពភា
ដោយការគោរពដ៏ថ្លៃថ្លា    ចិត្តកាយវាចាទាំងបីពិត ។
ព្រះធម៌នៃអង្គព្រះសាស្ដា    រុងរឿងភ្លឺថ្លាល្អវិចិត្រ
ដូចកលប្រទីបខ្វាត់ងងឹត    ទ្រោលបំភ្លឺជិតឆ្ងាយក្ដីណា ។
ជាធម៌ផ្នែកផ្សេងដោយប្រភេទ    មគ្គផលទាំងប៉ែតប្រាំបីឃ្លា
ជាលោកុត្តរឆ្លងលោកា    បំភ្លឺប្រាជ្ញានៃប្រយោជន៍ ។

ធម៌ណាដែលខ្ញុំថ្លែងអធិប្បាយ បន្ទំប្រែស្រាយជ្រៅលន្លោច<br>
ខ្ញុំសូមបង្គំផ្ចង់ចិត្តស្រោច មិនរួញរាញោចចាកធម៌នោះ ។<br>
ព្រះសង្ឃអង្គណាជាស្រែបុណ្យ ល្អល្អះលើសលន់ច្រើនជាន់ស្មោះ<br>
សញ្ញាថាប្រែឥតចន្លោះ ប្រសើរចំពោះរបស់ជន ។<br>
មានការយល់ត្រូវសន្តានស្ងប់ ជ្រាបធម៌ផងសព្វមិនមោហន្ធ<br>
តាមផ្លូវព្រះសុគតម្ចាស់ទិព្វគន់ លះការទាបទន់ក្តីឡេះឡោះ ។<br>
ជាអរិយសង្ឃទ្រង់ប្រាជ្ញា គឺស្ងាងជ្រះថ្លាឆ្លុះសាយសុស<br>
ទម្លាយកិលេសឥតមានមោះ មន្ទិលពព្រុះក្នុងសន្តាន ។<br>
ខ្ញុំសូមវន្ទាព្រះសង្ឃនោះ ទ្វារបីចំពោះក្រាបប្រួញប្រាណ<br>
គោរពកោតក្រែងសង្ឃប៉ុន្មាន ដែលបាននិព្វានផុតទុក្ខភ័យ ។<br>
បុណ្យដែលយើងខ្ញុំបានតាក់តែង វន្ទាចារចែងវត្ថុត្រ័យ<br>
ដែលគួរបូជារាល់សម័យ ជាឯកឥតន័យណាដូចនេះ ។<br>
អន្តរាយទាំងពួងរបស់ខ្ញុំ សូមឱ្យជោរទុំជ្រុះរបេះ<br>
កុំមានដល់ខ្ញុំអ្នកសំណេះ- សំណាលពោលគុណទាំងបីឡើយ ។<br>
សូមបានសម្រេចដោយកម្លាំង ដែលយើងខ្ញុំតាំងយ៉ាងនេះហើយ<br>
ចំពោះត្រ័យរ័ត្នម្ចាស់ត្រាណត្រើយ សូមបានសះស្បើយគ្រានេះហោង ។

(បុរាណភាសិត)

បទគាថា និយាយពីស្តេចទៅកាន់ទេវលោក

តេន ខោបិ សមយេន ពុទ្ធោ យោ លោកនាយកោ
បាដិហេរំ ករិត្វាន តាវត្តឹសមុបាគមិ ៗ
អភិធម្មកថំ កត្វា តត្ថ វស្សំ វសិ តទា
បវារេត្វាន សោ មុនី តម្ហា បតិអាគមិ ៗ
អស្សយុជបុណ្ណមហិ វស្សានោត្ថម្ហិ សម្មុតេ
សង្កស្ស ទ្វារេ ឱតរន្តោ ភូមិយំ សុបតិដ្ឋហិ ៗ
សព្វេ ទេវមនុស្សា ច តម្បុរេត្វា អត្តមនា
សុមនា ច តុដ្ឋចិត្តា សាធុការំ បវត្តីសុ ៗ
តស្មា តំ តំ បិ សព្វេសំ អនុស្សរន្តា សមាគតា
សក្ការេ អភិសង្ខត្វា តម្បូជេសុំ យថារហំ ៗ

ប្រែ. កាព្យពាក្យ ៨

សម័យនោះសោតព្រះអង្គសម្ពុទ្ធ ទ្រង់ដូចជាមកុដលើសលោកា
លុះទ្រង់ធ្វើឫទ្ធិ គឺបាដិហារ្យ ហើយគមនាការកាន់ស្ថានត្រៃត្រិង្ស ។
សម្តែងធម៌គឺ អភិធម្មជិតឈឹង លុះខំរំពឹងទើបប្រស្ថា
កាលនោះព្រះអង្គគង់ចាំវស្សា នាត្រៃត្រិង្សាសួគ៌ទេវលោក ។
ចេញវស្សាហើយព្រះមុនីចមលោក ស្តេចមានអធ្យោកមកកាន់មនុស្សនេះ
ថ្ងៃដប់ប្រាំកើតអស្សុជផ្កាយសេះ ក្នុងខែបុ័ណ្ណេះជារដូវភ្លៀង ។
ស្តេចយាងចុះត្រង់ទ្វារក្រុងឥតល្បៀង សង្កស្សទាត់ទៀងពីបុរាណនាយ
ប្រតិស្ឋានតម្រង់ព្រះកាយ លើផែនទូលាយនៃភូមិភាគ ។
លើកករបញ្ចង់លើសិរលំអុត បង្គំសម្ពុទ្ធថ្វាយវរវន្ទា
ព្រោះហេតុនោះយើងខ្ញុំរាល់រូបា រឭកកាលគ្រានោះឯងពុំដាច់ ។

បុរសមនុស្សនិងទេព្តាញាតិសាច់ ទើបលះបួរផ្តាច់ហើយមកជុំគ្នា
ចាត់ចែងរៀបចំគ្រឿងសក្ការា បូជាសាស្តាគួរតាមកម្លាំង ។

(សកភាសិត)

### បទគាថា និយាយពីស្តេចធ្វើយមកប្បាដិហារ្យរួចហើយ

ជននិយា បមុខានំ ទេវានំ ហិតការណា
តិវិក្កមំ ករិត្វាន តាវតឹសមុបាគមិ ។
សមាគតានំ ទេវានំ មជ្ឈេ បណ្ឌុសិលាតលេ
បារិច្ឆត្តកមូលស្មឹ និសីទិ បរិសាសតោ ។
សព្វេ ទេវេ អភិភុយ្យ សម្ពុទ្ធោ ហិ វិរោចតិ
ជនេត្តិយា សហាពលំ គម្ភីរតរទិដ្ឋតំ ។
ឧច្ចោចំ គុណខន្ធានំ អញ្ញេសំ គុណឧច្ចយោ
បស្សមានោ សមាសិន្នោ វាមទក្ខិណបុព្វកេ
មាករំ គុណពាហុល្យំ មានមានោ ហិ នាយកោ ។

ប្រែ. កាព្យពាក្យ ៨

រីព្រះលោកជេដ្ឋ ប្រសើរលើសអស់ ជាងក្រុមបុរស ស្តេចពុទ្ធដំណើរ
ទៅកាន់តាវត្តិង្ស ស្ថានសួគ៌ប្រសើរ មុនឡើយទ្រង់ដើរ ជាន់ឈានកន្លង ។
លើចុងដើមស្វាយ និងភ្នំពីរផង ហេតុមានបំណង ប្រយោជន៍ទេវតា
ទាំងអម្បាលមាណ មានព្រះមាយា ពុទ្ធមាតា នោះជាប្រធាន ។
ស្តេចដល់ហើយគង់ ប្រថាប់នាស្ថាន ក្រោមដើមថ្កើងថ្កាន នៃបារិច្ឆ័ត្តក៏
លើផ្ទៃសិលា ថ្មលឿងសាច់ហ្មត់ កណ្តាលបរិស័ទ ទេព្តាជួបជុំ ។
ព្រះសម្ពុទ្ធម្ចាស់ រុងរឿងត្រសុំ ដោយរស្មីឃុំ គ្របលើទេព្តា
ទ្រង់រំពឹងមើល ដោយព្រះប្រាជ្ញា យល់ច្បាស់គុណា ក្រាស់ឥតជំនះ ។

ទាំងជម្រៅជ្រៅ ទាំងធំខ្ពស់ឈ្មោះ ព្រះគុណនៃព្រះ គុណជននិយា
ខ្ពង់ខ្ពស់ដោយគុណ ជាងជននានា ដែលជាមាតា អ្នកមានគុណដែរ ។
ព្រះនាយកគង់ ស៊ប់ហើយឆ្វេងបែរ ព្រះទ័យគ្មាន់គ្នេរ រាប់ពួកទេព្តា
ដែលនៅគង់គាល់ ព្រះអង្គត្រៀបត្រា ខាងឆ្វេងស្តាំនា ខាងចំភក្ត្រា
និងព្រះមាតា មានគុណជាងជាក់ យកភ្នំមាសប្រាក់ មកប្រៀបពុំបាន ។

(បុរាណភាសិត)

## បទគាថា និយាយអំពីអានិសង្សស្តាប់ធម៌

សតំ ហត្ថី សតំ អស្សា សតំ អស្សតរី រថា
សតំ កញ្ញា សហស្សានិ អាមុត្តមណិកុណ្ឌលា
ឯកបទវិហារស្ស កលំ នគ្ឃន្តិ សោឡសិន្តិ ៗ

### ប្រែ. កាព្យពាក្យ ៧

ដំរីរាប់រយសេះរាប់រយ និងរយមេសេះអស្សតរា
ពួករថទឹមសេះរយស្មើគ្នា ពាន់នាងកញ្ញាស្រស់បំប្រិម ។
ស៊ីងពាក់កណ្ដុលជាតិកែវមណី ថ្លាថ្លៃឥតអ្វីនឹងប្រៀបផ្ទឹម
លុះយកមកផ្ទុំឱ្យត្រូវត្រឹម តម្រឹមនឹងផលជំហានវិញ ។
មិនស្មើសូម្បីមួយចំណិត ដែលអ្នកប្រាជ្ញចិតហើយចែកចេញ
ចែកហើយចែកទៀតរាប់គិតកាញ់ ចម្រាញ់ដល់ដប់ប្រាំមួយដង ។
គង់ថ្លៃអស់នោះនៅតិចពិត មិនស្មើចំណិតតូចឡើយហោង
ផលជំហានតូច-ធំកន្លង ព្រោះមានបំណងស្ដាប់ទេសនា ។

(បុរាណភាសិត)

### បទគាថា និយាយពីបញ្ហាព្រះគន្ធរចនាចារ្យ

កស្មា គច្ឆតិ ចេ ពុទ្ធោ    តាវត្តឹសេ សុរាលយេ
សត្ថស្ស បទេសោតិ    កឹ នុ ខោ តស្ស បាសំសា ៗ
នខោ តស្ស ច បាសំសា    ន ច សតស្ស បដ្ឋនា
យស្មា តស្មា ហិ សព្វេសំ    ឯសា ពុទ្ធាន ធម្មតា ៗ
គន្ត្វាន បាដិហេរញ្ច    បទស្សេតិ បទក្ខយំ
បទក្ខយំ បទស្សេត្វា    តាវត្តឹសមុបាគមិ ៗ
មាតរំ បមុខំ កត្វា    អភិធម្មំ អទេសយិ
អភិធម្មកថា តស្មា    ពុទ្ធានញ្ច ចិសោធកា ៗ
កថា អយំ សុតា តុម្ហេ    ឯទំ ចិន្តេថ សាធវោ
ឈានញ្ញា ហិ មយំ សព្វេ    មាតាបិតូសុ មារិសា ៗ
អវជ្ជំ តេសំ ផលំ សព្វំ    មានុស្សាម ហិ តេ ពលន្តិ ៗ

ប្រែ. កាព្យពាក្យ ៧

ប្រសិនបើព្រះពុទ្ធប្រសើរ    ស្ដេចពុទ្ធដំណើរកាន់ទេវតា
ស្ថានតាវត្តិង្សសួគ៌លោកា    ដោយទ្រង់យល់ថាប្រទេសសត្ថ ។
ស្ដេចសរសើរព្រះសាស្ដា    នឹងមានម្ដេចម្ដាឬបាត់ស្ងាត់
សរសើរអស់នោះនឹងប្រែខ្ចាត់    មិនមានប្រាកដដល់អង្គឬ ។
ច្នោះអង្គព្រះពុទ្ធទាំងអម្បាលមាណ    មិនទ្រង់ប្រោសប្រាណនឹងបំភ្លឺ
ឱ្យអស់ពួកសត្វមានពន្លឺ    ចុះតើប្រាថ្នាដូចម្ដេចបាន ។
ព្រោះហេតុនោះឯងការយ៉ាងនេះ    ពេញជាតម្រិះព្រះបុរាណ
ធ្វើបាដិហារ្យទៅកាន់ស្ថាន    តាវត្តិង្សពិមានគ្រប់១អង្គ ។
នេះជាទំនៀមតាមធម្មតា    ព្រះពុទ្ធអង្គណាគង់គ្រេកគ្រង់

ធ្វើបាដិហារ្យឈានតម្រង់ មិនវែលលះបង់ដល់ម្ដងឡើយ ។
ជំហានព្រះបាទតម្រប់បី[១] ស្ដេចផ្លោះដល់ទីត្រៃត្រិង្សហើយ
ធ្វើព្រះមាតាចមត្រាណត្រើយ ចំពោះភ័ក្ត្រហើយទ្រង់អើពើ ។
ថ្លែងអភិធម្មដ៏ជ្រាលជ្រៅ ជម្រៅឥតមានធម៌ណាស្មើ
ជាធម៌ខ្ពស់ផុតឥតអ្វីបើ នឹងប្រៀបផ្ទឹមស្មើឱ្យសមងាយ ។
ហេតុនោះកថាគឺអភិធម្ម ជាធម៌សុខុមធំទូលាយ
ទាំងល្អិតហ្មត់ចត់មិនឡំលាយ ព្រះពុទ្ធទាំងឡាយតែងជម្រះ ។
កថាខ្ញុំបានស្ដាប់ជាក់ អំពីសំណាក់ប្រាជ្ញជ្រៅជ្រះ
នៃអ្នកទាំងឡាយកុំបីលះ ចូរខំស្វែងស្វះកុំធ្វេស ។
នៃអ្នកទាំងឡាយមានភាពស្មើ ពួកយើងគួរធ្វើកុំប្រហែស
ត្រូវស្គាល់ជម្រៅគុណវិសេស វិសាលក្នុងម្ដាយនឹងឪពុក ។
ធ្លោះយើងទាំងពួងឃើញកម្លាំង បុណ្យផលកំបាំងខាំងលាក់មុខ
មាតាបិតាលោកទ្រាំទុក្ខ សន្ដានរំអុកក្នុងថ្ងៃនេះ ។

(បុរាណភាសិត)

(១)- ជំហានទី១ ព្រះបាទស្ដាំជាន់ចុងស្វាយឈ្មោះគណ្ឌ: ជំហានតម្រប់ពីរ ព្រះបាទឆ្វេងជាន់កំពូលភ្នំយុគន្ធរ ជំហានតម្រប់បី ជាន់កំពូលភ្នំសិនេរុ រួបរួមទៅចម្ងាយ ៦៨ សែនយោជន៍ ។

## បទគាថា និយាយពីស្ដេចចុះចាកទេវលោក

តទាបិ នាថោ បវរោ ច ពុទ្ធោ វស្សំ បវារេសិ អវោច សត្ថា
គច្ឆាមិ មានុស្សបថំ មយាតិ បុរិន្ទទោ តំ វចនម្បិ សុត្វា
តថាគតស្សេវ សុវណ្ណសោបា- ណំ រូបិសោបាណមណិសុបាណ-
ញ្ញាតិ[1] ហិ តិណ្ណំ វរសោបាណានំ សុមាបយិត្វា ខណេម ភវេសោ
សិនេរុមុទ្ធេ អចលេវ សោបា- ណានំ បិ សីសានិ បតិដ្ឋហេសុំ
សង្កស្ស ទ្វារេ សុបតិដ្ឋហេសុំ តថា ច បាទានិ វរានិ តេសំ
ឥមេសុ ពុទ្ធស្ស ទក្ខិណបស្សេ ទេវានមាហោសិ ហរីសុបាណំ[2]
តស្សេវ វាមេ រជតំ សុបាណំ អហោសិ ព្រហ្មស្ស សមាគតស្ស
មណីមយំ មជ្ឈិមមុនី[3] សុបាណំ សព្វញ្ញុនោ បាតុភវេ អមុស្មី
សត្ថា សិនេរុម្ហិ ឋិតោវ តត្ថ ឱលោកិតោ សព្វទិសំ វិវដ្ដី[4]
អធោវ យាវាវិចិតោ បិ ឯតំ លោកំ អហោសិ អថ សព្វសោវ
ឧទ្ធញ្ច សព្វំ បន ឯកលោកំ ភវគ្គព្រហ្មា វិបុលញ្ច យាវ
តទា មនុស្សាបិ អធោ បថព្យា បស្សីសុ ទេវេ ទុករេមន សព្វេ
ទេវា មនុស្សេសុ អទ្ទសីសុ ឧទ្ធំ តថាគតស្សេវ មហានុភាវេន[5] ៗ

ប្រែ. បទភាកគតិ

កាលនោះសម្ពុទ្ធ ប្រសើរបំផុត ទីពឹងសត្វា
ទ្រង់ស្ដេចកាន់ស្ថាន ត្រៃត្រិង្សសួគ៌ា នៅចាំវស្សា
ក្នុងសួគ៌ទេវលោក ។
ចេញវស្សាហើយ ពុំផ្សូវផ្សងឡើយ ទ្រង់ពោលហៅរក

---

(១)- រូបិសោបាណសោបាណញ្ចាតិ រូបិសោបាណំ មណិសោបាណញ្ច ឥតិ អត្ថោ ។ (២)- ហរិសុបាណន្តិ សុវណ្ណសោបាណំ ឥតិអត្ថោ ។ (៣)- ម ។ (៤)- វិវដ្ដិ វិវដំ ឥទ្ធិ ឥតិ អត្ថោ ។ (៥)- នាតិ បាឋសេសំ ។

សម្តេចឥន្ទ្រា ចមពលទេវលោក ដោយពុទ្ធធ្យោក
ដូច្នេះឯងថា ។

នៃមឃវ៉ា តថាគតមាន ដំណើរយាត្រា
ទៅកាន់ផ្លូវមនុស្ស ថ្ងៃបវារណា សល់នៅទិវា
ប្រាំពីរទៀតទេ ។

បុរិន្ទស្តេចស្តាប់ ព្រះតម្រាស់គាប់ នោះត្រេកឥតឯ
ហើយទើបនិម្មិត ជណ្តើរវរេ លួទាំងកាំមេ
ថ្វាយតថាគត ។

ជណ្តើរទាំងបី មួយមាសសោភី មួយប្រាក់សាច់ល្អិត
មួយទៀតកែវមណី មានរស្មីសិទ្ធ រូសរាន់ទាន់ចិត្ត
ឆាប់ដូចបំណង ។

ឯក្បាលជណ្តើរ ទាំងបីប្រសើរ ប្រតិស្ឋានរង
លើកំពូលភ្នំ ខ្ពស់ធំចម្បង ឫសជ្រៅកន្លង
រឹងមិនញាប់ញ័រ ។

រីជើងជណ្តើរ[១] សម្រាប់ដំណើរ ទាំងបីបវរ
ប្រតិស្ឋាននៅ ត្រង់ទ្វារនគរ សង្កស្សនាមករ
ទាំងបីដូចគ្នា ។

ព្រះឥន្ទ្រនិម្មិត ជណ្តើរបីពិត ថ្វាយព្រះភគវ៉ា
ជណ្តើរហរី[២] ពួកទេវតា ខាងស្តាំពុទ្ធា
អម្ចាស់នៃយើង ។

រីជណ្តើរប្រាក់ រលេចចម្លាក់ សឹងទិព្វថ្កុំថ្កើង
មានដល់ពួកព្រហ្ម ហែហាមតម្កើង ខាងឆ្វេងម្ចាស់យើង

(១)- ភ្នំសិនេរុ ឬភ្នំព្រះសុមេរុ ។ (២)- ជណ្តើរហរី គឺជណ្តើរមាស អភិធានប្បទីបិការ ។

គួរតាមវិធី ។

ឯជណ្តើរកែវ រស្មីពណ៌ខៀវ ចំកណ្តាលទី
ប្រាកដដល់អង្គ សម្ពុទ្ធមុនី ជ្រាបសព្វវាទី
នាគ្រាកាលនោះ ។

អង្គព្រះសាស្តា ស្តេចស្ថិតនៅនា សិនេរុខ្ពស់
ព្រះនេត្រឆ្មៀងមើល សព្វទិសទាំងអស់ ទ្រង់សម្តែងយស
ធ្វើឫទ្ធិផ្សេងៗ ។

ខាងក្រោមតាំងពី នរកអវិចី វាលស្រឡះឆេង
ពន្លឺតែមួយ ដូចត្រួយស្ទូវសែង រស្មីភ្លឺទេង
ឆ្លុះសព្វទិសា ។

ចំណែកខាងលើ វាលធំឥតបើ នឹងរាប់ត្រួតត្រា
ភ្លឺជាប់ជាមួយ ជំនួយគត្តា តាំងពីព្រហ្មា
ជាន់ខ្ពស់បង្អស់ ។

ពួកមនុស្សខាងក្រោម មើលឃើញរូបឆោម ពួកទេពសប្បុរស
ទូទៅរហូត លំដាប់វាលនោះ ពុំមានចន្លោះ
កាលគ្រានោះណា ។

ពួកទេពខាងលើ ឃើញមនុស្សស្មោះស្មើ ច្បាស់លាស់ដូចគ្នា
ដោយអានុភាព គុណអនន្តា អង្គព្រះតថា-
គតម្ចាស់យើងហោង។

(សកភាសិត)

បទគាថា និយាយពីស្តេចធ្វើបាដិហារ្យចុះចាកទេវលោក

យមកប្បាដិហេរស្ស ញាណេ ឋត្វា តថាគតោ
អាភាសិ ពុទ្ធវិសយំ ឥទ្ធី អនេកប្បការំ ។
សត្ថុ កាយា សម្ភូតា នីលា បីតា ច លោហិតា
ឱទាតា បិ ច មញ្ជេដ្ឋា សុបភស្សរនាមកា ។
អាធាវន្តិ វិធាវន្តិ វិប្ផុរន្តិ បរាបរំ
ជោតយន្តិ ទិសា សព្វា ឆព្វណ្ណវិធរំសិយោ ។
សត្ថា តស្មឹ នភេ តិដ្ឋ និសីទំ វិចរំ សយំ
ឧភោ ចន្ទញ្ច សុរិយញ្ច ហត្ថេនាបិ បរាមសិ ។
បមោចេសិ ជលំ កាយា តតោ អគ្គិ បមោចយិ
ឧទ្ធំ កាយា អធោ កាយា សត្ថា តំ បរិវត្តយិ ។
យតោ កាយា ជលំ មុញ្ចិ តតោ អគ្គិ បមុញ្ចយិ
យតោ អគ្គិ បមោចេសិ តតោ ជលំ បមោចយិ ។
លហុំ ជលញ្ច អគ្គិ ច ជាយន្តិ យមកា វិយ
យមកំ បាដិហីរយន្តិ តេន វុច្ចន្តិ បណ្ឌិតោ ។

ប្រែ. បទពំនោល

តថាគតស្ថិតនៅក្នុងញាណ ជាគុណចំណាន នៃបាដិហារ្យផ្ទៃផ្ទួរ ។
ទ្រង់ធ្វើឫទ្ធីផ្លាស់ប្តូរ ទឹកភ្លើងសម្បូណ៌ សឹងច្រើនប្រការអនេក ។
ឫទ្ធិសោតអស្ចារ្យពន់ពេក ហៅពេញចម្លែក ជាពុទ្ធវិស័យប្រាកដ ។
រស្មីពណ៌ខៀវលឿងអត់ ក្រហមសម៉ដ្ឋ ហង្សបាទពព្រុះភ្លឺផ្លេក ។
ស្ទុះទៅស្ទុះមកដោយឡែក ផ្សាយឆ្វាយអតិរេក ទៅៗមកៗមិនឈប់ ។

| | | | |
|---|---|---|---|
| ចេញចាកប្រជុំកាយសព្វ | នៃអង្គចមភព | ជាព្រះបរមគ្រូ | ។ |
| រស្មីបីគួបរិបូណ៌ | ពណ៌ប្រាំមួយជូរ | រុងរឿងប្រផូរសព្វទិស | ។ |
| ឯអង្គសាស្តាឆោមស្រស់ | សណ្តូកព្រះហស្ត | ចាប់ចន្ទសុរិយៈទាំងទ្វី | ។ |
| ដែលឈរអង្គយចរក្តី | ផ្ទំដោយសិរី | នៅនាអាកាសវេហាស៍ | ។ |
| បញ្ចេញទឹកពីកាយា | អគ្គិជាលា | ក៏ផ្សាយចាកកាយឯងឯ | ។ |
| ព្រះអង្គផ្លាស់ប្តូរបែររេ | ទឹកភ្លើងទាំងទ្វេ | កាយខាងលើនិងខាងក្រោម | ។ |
| ទ.ទឹកហូរដូចប្រឡោម | ចេញទៅតាមរោម | ពីចំណែកកាយខាងណា | ។ |
| កងភ្លើងក៏ឥតបើថា | ចេញចាកកាយា | ចំណែកខាងនោះដូចគ្នា | ។ |
| អគ្គិវិលវេញឆ្លេឆ្លា | ចេញពីសិរា | ត្រង់ទីចន្លោះទ.ទឹក | ។ |
| ឯទឹកហូរជោរអើក | មិនមានភ្លាំងភ្លឹក | ចេញចាកទីនោះប្រជែង | ។ |
| ទឹកភ្លើងដូចនឹងចំបែង | ប្រណាំងគ្នាឯង | មួយគូៗ យ៉ាងលឿន | ។ |
| ធ្វើឫទ្ធិទាំងពីរគ្រឿនៗ | មិនឱ្យចាញ់ល្បឿន | ថយថោកជាងគ្នាមួយៗ | ។ |
| ពួកប្រាជ្ញជាតិពន្លកត្រួយ | តែងពោលជ្រោងស្ងួយ | ដោយនូវប្រការច្នោះឯង | ។ |

(សកភាសិត)

ឧទានរបស់ព្រះសារីបុត្ត ១

គង្គាយ វាលុកា ខីយេ  ឧទកំ ខីយេ មហណ្ណវេ
មហិយា មត្តិកា ខីយេ  ន ខីយេ មម ពុទ្ធិយំ
លោកនាថំ ឋបេត្វាន  យេ ចញ្ញេ អត្ថិ បាណិនោ
បញ្ញាយ សារីបុត្តស្ស  កលំ នគ្ឃន្តិ សោឡសឹ ។

ប្រែ. បទភាកគតិ

| | | |
|---|---|---|
| ដីខ្សាច់ក្នុងស្ទឹង | មិនជាប់នៅនឹង | តែងហូរបាត់បង់ |
| ទឹកអន្លង់ជ្រៅ | រីងទៅពុំគង់ | ដីក្នុងកំលង់ |

ភូមិប្រឹថពី ។

តែងអស់រលោះ មិនតាំងស្អានស្មោះ ដូចដើមពេញទី
សឹងរបេះបាត់ ខ្ចាត់ទៅទិដ្ឋី សភាពនោះក្តី
ជាគ្រឿងឧបមា ។

ឯប្រាជ្ញាខ្ញុំ រឹកចម្រើនធំ - មិនអស់ឡើយណា
បើប្រៀបធៀបដោយ អ្នកក្រោយនានា ដែលមានប្រាជ្ញា
លើកតែឈោកទាថ ។

ប្រាជ្ញាអ្នកនោះ មកធ្មឹមស្មើស្មោះ ដូចនឹងរូបមាឌ
ប្រាជ្ញាសារីបុត្ត ដែលចិត្តសម្អាត ចិត្តលុះដល់ខ្ទាត
ដប់ប្រាំមួយដង ។

តង់នៅតូចជាង ប្រហែលរបភាង សន្ទចជាម្លង
ប្រាជ្ញាសារីបុត្ត ធំផុតកន្លង បទនោះឯងហោង
ជាគ្រឿងឧបមេយ្យ ។

បទគាថា និយាយពីទ្រង់សម្តែងធម៌ ៤ យ៉ាង

សីលំ សមាធិ បញ្ញា ច វិមុត្តិ ច អនុត្តរា
អនុពុទ្ធា ឥមេ ធម្មា គោតមេន យសស្សិនា
ឥតិ ពុទ្ធោ អភិញ្ញាយ ធម្មមក្ខាសិ ភិក្ខុនំ
ទុក្ខស្សន្តករោ សត្ថា ចក្ខុមា បរិនិព្វុតោតិ ។

ប្រែ. បទព្រហ្មគីតិ

វិធម៌ ៤ ប្រការ ព្រះឈ្មោះមារជាអម្ចាស់
គោតមស្តេចជ្រាបច្បាស់ ទើបទ្រង់ត្រាស់ដូច្នេះថា ។

ទីមួយគឺសីល់ ពីរបញ្ញ៉ាបីសមា-
ធិធម៌ដ៏ថ្លៃថ្លា បួនវិមុត្តិប្រសើរឯក ។
ព្រះពុទ្ធទ្រង់ជ្រាបហើយ ពុំលាក់ឡើយទ្រង់ប្រាំចែក
ធម៌នោះដោយចំណែក ដល់ភិក្ខុគ្រប់ប្រការ ។
ព្រះចក្ខុសម្ពុទ្ធ ជាចមកុដសាស្តាចារ្យ
ទ្រង់ឆ្លងវដ្តសង្សារ រួចផុតទុក្ខឥតមានសល់ ។
ព្រះអង្គស្តេចនិព្វាន សុខសម្រាន្តគ្មានសល់វល់
តណ្ហាទៅមិនដល់ ពុំមានចាស់ឈឺស្លាប់ឡើយ ។

## គុណព្រះនិព្វាន ៨ យ៉ាង

មទនិម្មទនោ ហោតិ បិបាសវិនយោ បិ ច
អាលយសមុគ្ឃាតោ ច វដ្ដុច្ឆេទនោ ច ហោតិ វា
តណ្ហក្ខយោ វិរាគោ ច និរោធោ ចាបិ និព្វានំ ។

ប្រែ. បទមណ្ឌុកគតិ

គុណព្រះនិព្វាន ទ្រង់ត្រាស់ថាមានប្រាំបី
មួយតាំងនៅដើមទី កាច់កិនញ៉ាំញីស្រវឹង
ទីពីរត់ទៅ លះស្រេកឃ្លានម៉ៅរីងប៉ុង
គឺកាមគុណហ្នឹង ឱ្យអស់សូន្យឈឹងបង់សៀត ។
ទីបីថ្លៃថ្លា ដកចោលអាល័យកាមទៀត
ដែលនៅប្រជ្រៀត ធ្វើឱ្យចង្អៀតឥតល្ហែ ។
ទីបួនវិញថ្វាត់ ជាគុណច្រូតកាត់ក្ដីស្នេហ៍
ដែលជាប់តខ្សែ ឱ្យដាច់ងាករវេចាកវដ្ត ។
ទីប្រាំគុណខ្ពស់ អ្នកធ្វើឱ្យអស់ប្រាកដ

តណ្ហារបស់សត្វ　　រលាយរលត់គ្មានសល់ ។
ទីប្រាំមួយនៃ　　ជាគុណនាំក្ស័យកង្វល់
តម្រេកឥតស្គល់　　គឺធ្វើឱ្យអស់គ្មានរាគ ។
ទីប្រាំពីរសោត　　នាមថានិរោធជាពាក្យ
រលត់អស់រាគ　　ផុតទុក្ខលំបាករលីង ។
ទីប្រាំបីគ្រប់　　ជាគុណគម្រប់តំណែង
តូនិព្វានឯង　　មានគុណនឹងថ្លែងពុំបាន ។

(សកភាសិត)

## ពាក្យនមស្ការ

សព្វញ្ញូសត្ថា　　ភវទានទន្តោ
អនាថនាថោ　　ភវសត្តតារី
វិសុទ្ធិសុទ្ធ-　　គ្គសុមគ្គទេសី
មោកប្បទាយី　　គុណបាគូ នោនោ ។

ប្រែ. បទព្រហ្មគីតិ

ព្រះសព្វញ្ញូសាស្តា　　កាត់តណ្ហាការលោកិយ
រើសសត្វចាកភពបី　　ដាក់ដល់ត្រើយព្រះនិព្វាន ។
បង្ហាញផ្លូវមគ្គផល　　កាត់កង្វល់លោកិយបាន
ជាគ្រូយើងគ្រប់ប្រាណ　　ទ្រង់រក្សាអស់យើងខ្ញុំ ។

(លោកអាចារ្យ អ៊ុក ជា)

ចប់

ពិធីអស្សយុជបូជាតែប៉ុណ្ណោះ

## មហាបុរិសលក្ខណៈ ៣២ ប្រការ

ព្រះភគវន្ត អរហន្ត សម្មាសម្ពុទ្ធ បរមគ្រូរបស់យើងទាំងឡាយ ព្រះអង្គប្រកបដោយមហាបុរិសលក្ខណៈ ៣២ ៖

១- **សុប្បតិដ្ឋិតបាទោ** ព្រះមហាបុរសមានព្រះបាទប្រតិស្ឋានល្អ គឺមានផ្ទៃព្រះបាទទាំងគូរាបស្មើសព្វអន្លើ ។

២- **ហេដ្ឋាបាទតលេសុ ចក្កានិ ជាតានិ** ត្រង់ផ្ទៃព្រះបាទទាំងគូ ខាងក្រោមរបស់មហាបុរស មានរូបចក្រកើតឡើង ប្រកបដោយខ្នងកង់ និងដុំព្រមទាំងកាំ ១០០០ មានចន្លោះស្មើគ្នាគ្រប់អន្លើ ។

៣- **អាយតបណ្ហិ** ព្រះមហាបុរស មានព្រះកណ្ហិគីកែងវែង ។

៤- **ទីឃង្គុលី** មានព្រះអង្គុលី គឺម្រាមព្រះហស្តនិងម្រាមព្រះបាទវែងៗ ។

៥- **មុទុតលុនហត្ថបាទោ** មានផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទដ៏ទន់ល្មើយ ។

៦- **ជាលហត្ថបាទោ** មានផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទប្រទាក់ដោយក្រឡាដូចជាសំណាញ់ ។

៧- **ឧស្សង្ខបាទោ** មានព្រះបាទ ដូចជាអណ្ដែតឡើងខាងលើ ។

៨- **ឯណេជង្ឃោ** មានព្រះជង្ឃា គឺស្មងរៀវមូលក្រសូលស្រដៀងនិងស្លងសត្វទ្រាយ ។

៩- **ឋិតកោ ច អនោនមន្តោ** កាលបើទ្រង់ឈរ មិនបាច់ឱនព្រះអង្គអាចស្ទាបអង្អែលព្រះជាណុ គឺជង្គង់ដោយផ្ទៃព្រះហស្តទាំងពីរបាន ។

១០- **កោសោហិតវត្ថគុយ្ហោ** មានព្រះអង្គាវយវៈ ដែលត្រូវលាក់កំបាំងដោយ សំពត់ឋិតនៅក្នុងស្រោម ។

១១- សុខុមច្ឆវិ មានសំបកសម្បុរថ្លៃ (ល្អើងភ្លឺអន្លង់) ដូចសម្បុរនៃមាស ។

១២- សុខុមច្ឆវី មានព្រះឆវីគឺសម្បុរថ្លៃ ល្អិតផូរផង់រលីងស្រិល រអិលធូលីធ្លាក់មកមិនជាប់ព្រះកាយ ។

១៣- ឯកេកលោមា មានព្រះលោមាតែមួយសរសៃៗ នៅក្នុងរណ្តៅរោម ១ មានរោម ១ ។

១៤- ឧទ្ធគ្គលោមា មានព្រះលោមាមានចុង ងឡើងលើ ព្រះលោមាដែលដុះឡើងហើយ មានចុងឡើងលើ ជាទក្ខិណាវដ្ដ វិលវង់ព័ទ្ធពេនទៅខាងស្ដាំ មានសម្បុរ ខៀវ ដូចជាសម្បុរនៃផ្កាអញ្ចន កួចមូលដូចជាកុណ្ឌល ។

១៥- ព្រហ្មុជ្ជុគត្តោ មានព្រះកាយត្រង់ដូចកាយនៃព្រហ្ម ។

១៦- សត្តុស្សទោ មានព្រះម៉ស សាច់ ៧ អន្លើពេញបរិបូណ៌ គឺត្រង់ខ្នងព្រះហស្តទាំងពីរ ខ្នងព្រះបាទទាំងពីរ ចង្កួយស្មាទាំងពីរ និងព្រះសូរង ។

១៧- សីហបុព្វទ្ធកាយោ មានព្រះកាយពាក់កណ្ដាលខាងលើ ដូចជាកាយនៃរាជសីហ៍ ។

១៨- ចិត្តន្តរំសោ មានព្រះបិដ្ឋិ គឺខ្នងដ៏ពេញបរិបូណ៌ (គឺថាសាច់ជាចន្លោះ នៃស្លាបប្រចៀវទាំងពីរ) ។

១៩- និគ្រោធបរិមណ្ឌលោ មានទ្រង់ទ្រាយព្រះកាយ ដូចជាបរិមណ្ឌលនៃដើមជ្រៃ កាយរបស់មហាបុរសប្រវែងណា ព្យាមរបស់មហាបុរសប្រវែងនោះដែរ គឺមានកាយនិងព្យាមស្មើគ្នា ។

២០- សមវដ្ដក្ខន្ធោ មានព្រះសូរងមូលសម ។

២១- រសគ្គសគ្គី មានព្រះប្រសាទ គឺសរសៃល្អិតឆ្មារ ដ៏លើសលែងសម្រាប់ទទួលអាហារ ។

២២- **សីហហនុ** មានព្រះហនុកា (ចង្កា) ដូចជាចង្កានៃរាជសីហ៍ ។

២៣- **ចត្តាឡីសទន្តោ** មានព្រះទន្ត ៤០ គត់ ។

២៤- **សមទន្តោ** មានព្រះទន្តរាបស្មើ ។

២៥- **អវិរឡទន្តោ** មានព្រះទន្តជិតស្និទ្ធ ។

២៦- **សុសុក្កទាឋោ** មានព្រះទាឋា គឺចង្កូមទាំង ៤ សស្អាត ។

២៧- **បហូតជិវ្ហោ** មានព្រះជិវ្ហា គឺអណ្តាតដ៏ធំវែង ។

២៨- **ព្រហ្មស្សរោ ករវិកភាណី** មានព្រះសូរស័ព្ទ ដូចជាសំឡេងនៃព្រហ្ម កាលបើបញ្ចេញវាចាលាន់ឮពីរោះ ។

២៩- **អភិនីលនេត្តោ** មានព្រះនេត្រខៀវស្រស់ ។

៣០- **គោបខុមោ** មានដួងព្រះនេត្រដូចជាកូននៃគោ ។

៣១- **ឧណ្ណា ភមុកន្តរេ ជាតា** មានព្រះឧណ្ណាលោម គឺរោមប្រជុំចិញ្ចើម ដុះត្រង់ចន្លោះ នៃព្រះភមុកា (ចិញ្ចើមមានពណ៌សក្បុស ទន់ល្មើយដូចជាសំឡី) ។

៣២- **ឧណ្ហីសសីសោ** មានព្រះសិរ ហាក់ដូចជាប្រដាប់ដោយក្បាំងមកុដស្រេចស្រាប់ ។

មហាបុរិសលក្ខណៈទាំង ៣២ ប្រការនេះ ក្នុងលក្ខណៈសូត្រ គឺជាតួព្រះពុទ្ធវាចាហូរចេញពីព្រះឱស្ឋទិព្វថ្លៃ នៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់ទេសនា ប្រោសប្រាប់ភិក្ខុផងទាំងឡាយនៅនាវត្តជេតពនរបស់ អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថីនោះឯងហោង ។

# អនុព្យញ្ជនៈ

## របស់ព្រះសម្មាសម្ពុទ្ធមាន ៨០ គឺ

១- ម្រាមព្រះហស្ត និងម្រាមព្រះបាទមានពណ៌លឿង
២- ម្រាមព្រះហស្ត និងម្រាមព្រះបាទពណ៌ខៀវ
៣- ម្រាមព្រះហស្តនិងម្រាមព្រះបាទមូលល្អ
៤- ក្រចកទាំង២០មានពណ៌ក្រហម
៥- ក្រចកទាំង ២០ ងស្មើតឡើង
៦- ក្រចកមានណៅរលោងរលើប
៧- កព្រះហស្តនិងកព្រះបាទត្រួតនៅក្នុងសាច់
៨- ព្រះបាទស្មើគ្នា
៩- ព្រះដំណើរល្អវាងយាសដូចដំណើរដំរី
១០- ព្រះដំណើរល្អដូចជាដំណើរនៃរាជសីហ៍
១១- ព្រះដំណើរល្អដូចជាដំណើរនៃហង្ស
១២- ព្រះដំណើរដូចជាដំណើរគោឧសភរាជ
១៣- បើទ្រង់ឈរហើយត្រូវយាងទៅ តែងតែលើកព្រះបាទខាងស្តាំបោះទៅមុខ ជាដរាប
១៤- ព្រះមណ្ឌលជង្គង់មូលល្អ
១៥- មានព្យញ្ជនៈជាបុរសគ្រប់គ្រាន់ គឺមិនមានកិរិយាដូចជាស្រីឡើយ
១៦- ផ្ចិតមិនខូងមិនផត គឺមូលស្មើល្អ
១៧- ពោះមានព្រះសណ្ឋានជ្រៅ
១៨- ពោះមានសណ្ឋានខ្ចៅវិលទៅខាងស្តាំ (ទក្ខិណាវដ្ត)
១៩- ភ្លៅទាំងគូមូលល្អ
២០- ព្រះហស្តទាំងគូល្អ
២១- ព្រះអវយវៈធំតូចទាំងអស់ មានលក្ខណល្អតាមចំណែកៗ
២២- សាច់ដែលគួរក្រាសក៏ក្រាស
២៣- សាច់មិនយារ ឬជ្រួញជ្រីវ
២៤- ព្រះកាយគ្មានប្រជ្រុយ ឬអាចម៍រុយ
២៥- ព្រះកាយាវយវៈសមគ្នា តាមលំដាប់លំដោយលើក្រោម
២៦- ព្រះកាយបរិសុទ្ធ គ្មានមន្ទិល
២៧- មានព្រះកម្លាំងច្រើន
២៨- មានច្រមុះខ្ពស់សម
២៩- មានសណ្ឋានច្រមុះល្អ
៣០- បបូរព្រះឱស្ឋលើ-ក្រោម មិនបានចូលចេញលើសគ្នា
៣១- ព្រះទន្តឥតគ្រឿងសៅហ្មង
៣២- ព្រះទន្តសម្បុរស័ង្ខ
៣៣- ព្រះទន្តរលីងស្អាត
៣៤- ព្រះឥន្ទ្រិយ៍ទាំង ៥ បរិសុទ្ធល្អ
៣៥- ព្រះចង្កូមទាំង ៤ មូលពេញលេញ
៣៦- វង់ព្រះភក្ត្រមានទម្រង់មូលទ្រវែងសមល្អ
៣៧- ថ្ពាល់ទាំងគូល្អភ្លឺថ្លាស្មើគ្នា
៣៨- អញ្ចាញព្រះហស្តមានស្នាមជ្រៅ
៣៩- អញ្ចាញព្រះហស្តស្នាមវែង
៤០- អញ្ចាញព្រះហស្តមានស្នាមត្រង់
៤១- អញ្ចាញព្រះហស្ត មានស្នាមក្រហមរុងរឿង

៤២- រស្មីព្រះកាយមានពន្លឺជាបរិមណ្ឌល

៤៣- ថ្ពាល់ទាំងគូពេញកំពុងណែនល្អ

៤៤- ត្របកព្រះនេត្រទូលាយវែងសម

៤៥- ព្រះនេត្រប្រកប ដោយប្រសាទទាំង៥

៤៦- ចុងសរសៃព្រះលោមាទាំងឡាយមិនបានវៀច

៤៧- អណ្ដាតមានទម្រង់ល្អ

៤៨- អណ្ដាតទន់មិនរឹង

៤៩- ដោះទាំងគូ មានទម្រង់វែងដូចជាត្របកបទុមជាតិ

៥០- រង្វង់ព្រះសុរងមានទម្រង់មូល

៥១- សរសៃទាំងពួងស្ងួតឥតមានជ្រួញ

៥២- ជួរសរសៃទាំងឡាយត្រូតនៅក្នុងសាច់ទាំងអស់

៥៣- ព្រះសិរមានទម្រង់ដូចឆត្រកែវ

៥៤- បរិមណ្ឌលថ្ងាសទូលាយវែងល្មម

៥៥- ថ្ងាសមានទម្រង់ដ៏ល្អ

៥៦- ចិញ្ចើមមានទម្រង់ដ៏ល្អដូចធ្នូ

៥៧- ព្រះរោមចិញ្ចើមមានសរសៃដ៏ល្អិត

៥៨- សរសៃព្រះរោមចិញ្ចើមដុះហើយដូលរាបទៅដោយលំដាប់

៥៩- ព្រះចិញ្ចើមធំល្មម

៦០- ព្រះចិញ្ចើមវែងផុតព្រះនេត្រ

៦១- សម្បុរថ្ងៃល្អិតឆ្មារពេញព្រះកាយ

៦២- ព្រះកាយរុងរឿងទៅដោយសិរី

៦៣- ព្រះសរីរកាយតែងភ្លឺថ្លាមិនស្អាប់សៅហ្មង

៦៤- ព្រះសរីរកាយស្រស់ភ្លឺថ្លាដូចផ្កាឈូក

៦៥- ព្រះសរីរកាយមានសម្ផស្សទន់ភ្លន់

៦៦- ក្លិនព្រះកាយក្រអូបឈ្ងុយដូចក្លិនផ្កា

៦៧- ព្រះរោមសរសៃស្មើគ្នាទាំងអស់

៦៨- ព្រះរោមមានសរសៃល្អិតឆ្មារ

៦៩- ព្រះដង្ហើមចេញចូលល្អិត

៧០- ព្រះឱស្ឋមានទម្រង់ល្អ ហាក់ដូចជាទ្រង់ញញឹមជានិច្ច

៧១- ក្លិនព្រះឱស្ឋក្រអូបដូចក្លិនឧប្បល

៧២- ព្រះកេសាខ្មៅរលោងស្រិល

៧៣- ព្រះកេសាមានក្លិនក្រអូបឈ្ងុយឈ្ងប់

៧៤- ព្រះកេសាក្រអូបដូចជាក្លិននៃផ្កាកោមល

៧៥- ព្រះកេសាមានទម្រង់មូលព័ទ្ធព្រះកេសា

៧៦- ព្រះកេសាខ្មៅស្និទ្ធ

៧៧- សរសៃព្រះកេសាឆ្មារល្អិត

៧៨- សរសៃព្រះកេសាស្ងួត

៧៩- សរសៃព្រះកេសាវិលព័ទ្ធព្រះកេសានៅខាងស្ដាំ

៨០- មានព្រះរស្មីភ្លឺចិញ្ចាចលើព្រះសិរ

# អដ្ឋុត្តរសតមង្គលគាថា

យស្ស បាទេសុ ជាតានិ ទ្វេ ចក្កានិ មហេសិនោ
នានាការេហិ បុណ្ណានិ តំ វន្ទេ បុរិសុត្តមំ ៗ
សត្តី ច សិរិវច្ឆោ ច នន្ទិយាវដ្ដមេវ ច
សោវត្ថិកោ វដំសោ ច វឌ្ឍមានញ្ច បីឋកំ
អង្កុសោ ចេវ បាសាទោ តោរណំឆត្តមេវ ច
ខគ្គោ ច តាលបណ្ណញ្ច មោរបិញ្ឆកវីជនី
ឧណ្ហីសោ បត្តបល្លង្កោ សុមនទាមំ និលុប្បលំ
រត្តសេតុប្បលញ្ចេវ បទុមំ បណ្ឌរី តថា
បុណ្ណឃដោ បុណ្ណបាតិ សមុទ្ទោ ចក្កវាឡកំ
ហេមវា ច សិនេរុ ច សុរិយោ ចន្ទិមា តថា
នក្ខត្តា ចតុរោ ទីបា ទ្វិសហស្សបរិត្តកា
ចក្កវត្តិ វដ្ដសេទ្វោ ច មច្ឆានំ យុគលំ តថា
សត្ត សត្ត មហាគង្គា មហាសេលា មហាសរា
សុបណ្ណោ សុំសុមារោ ច ធជបដាកមេវ ច
បាដង្គី វាលវីជនី កេលាសបព្វតោ តថា
សីហរាជា ព្យគ្ឃរាជា វលាហកោ ឧបោសថោ
ឆទ្ទន្តោ វាសុគី នាគោ ហំសោ ច ឧសភោ តថា
ឯរាវណោ ច មង្គរោ ភមរោ ចេវ កុក្កុដោ
សុវណ្ណកច្ឆបោ ចាបិ ហរិនាខា ចតុម្មុខា

សច្ឆកា តថា គាទី កិន្នរោ កិន្នរីបិ ច
ករវិកោ មយូរោច កោញ្ចរាជា តថេវ ច
ចក្កវាកនិដោ ចេវ ជីវញ្ជីវកនាមកា ច
ឆកាមាវចរា ទេវា ច ព្រហ្មលោកា ច សោឡស
យស្ស អដ្ឋុត្តរសតំ មង្គលានិ មហេសិនោ
បាទេសុ ទិស្សរេ និច្ចំ តំ វន្ទេ បុរិសាសភន្តិ

អដ្ឋុត្តរសតមង្គលគាថា និដ្ឋិតា

(មាន ១២ គាថា កន្លះ)

## អដ្ឋុត្តរសតមង្គលគាថា

ប្រែ. លោកប្រយោគដូចខាងក្រោម[1]

ចក្កានិ វីចក្រទាំងឡាយ ទ្វេ ពីរ ជាតានិ កើតហើយ បាទេសុ នាព្រះបាទទាំងឡាយ យស្ស សម្មាសម្ពុទ្ធស្ស នៃព្រះសម្មាសម្ពុទ្ធអង្គណា មហេសិនោ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានសីលគុណជាដើម បុណ្ណានិ ដ៏ពេញ នានាការេហិ ដោយអាការផ្សេងៗទាំងឡាយ អហំ វីខ្ញុំព្រះអង្គ វន្ទេ សូមថ្វាយបង្គំ តំ សម្មាសម្ពុទ្ធំ នូវព្រះសម្មាសម្ពុទ្ធអង្គនោះ បុរិសុត្តមំ ជាបុរសឧត្តម ។

មង្គលានិ វីមង្គលទាំងឡាយ អដ្ឋុត្តរសតំ មួយរយប្រាំបី ឥតិ ដូច្នេះ សត្តិ ច គឺលំពែងផង សិរិវច្ឆោ ច គឺពពិលផង នន្ទិយាវដ្ដមេវ ច គឺផ្កាមាលតីផង សោវត្ថិកោ ច គឺសង្វារខ្វែងឬសង្វារគាបផង វដំសោ ច គឺ ឆ្នូតផង វឌ្ឍមានញ្ច គឺបាយសីផង បីឋកំ ច គឺតាំងផង អង្កុសោ ចេវ

(១)- ប្រែ បែបបុរាណយូរហើយ ។

គឺកង្វេរផង បាសាទោ ច គឺប្រាសាទផង តោរណំ ច គឺខ្លោងទ្វារផង ឆត្តមេវ ច គឺឆត្រផង ខគ្គោ ច គឺព្រះខ័នផង តាលវណ្ដញ្ច គឺផ្លិតតាលប័ត្រ (ផ្លិតស្លឹកត្នោតផង មោរហត្ថចាមរី ច គឺផ្លិតកន្ទុយក្ងោកផង ឧណ្ហីសោ ច គឺមកុដ (ឬក្បាំង) ផង បត្តបល្លង្កោ ច គឺបាត្រនិងបល្ល័ង្កផង សុមនទាមំ ច គឺកម្រងផ្កាម្លិះផង និលុប្បលំ ច គឺឧប្បលខៀវ (លំចង់) ផង រត្តសេតុប្បលញ្ច គឺឧប្បលក្រហម (ស្បង្ក័ជ) និងឧប្បលស (ព្រលិត) ផង បទុមំ ច គឺឈូកក្រហមផង បុណ្ឌរីកំ តថា គឺឈូកសផង បុណ្ណឃដោ ច គឺក្អមពេញដោយទឹកផង បុណ្ណបាតិ ច គឺពាងពេញ ដោយទឹកផង សមុទ្ទោ ច គឺសមុទ្រផង ចក្កវាឡកំ ច គឺចក្រវាឡផង ហេមវា ច គឺភ្នំហេមពាន្តផង សិនេរុ ច គឺភ្នំសិនេរុផង សុរិយោ ច គឺព្រះអាទិត្យផង ចន្ទិមា តថា គឺព្រះចន្ទផង នក្ខត្តា ច គឺនក្ខត្តឫក្ស (ហ្វូងផ្កាយ) ផង ចតុរោ ទីបា ច គឺទ្វីបទាំងបួនផង ទ្វិសហស្សបរិត្តទីបា ច គឺទ្វីបតូចពីរពាន់ជាបរិវារផង ចក្កវត្តិ ច គឺស្ដេចចក្រពត្តិផង ទក្ខិណាវដ្ដសង្ខោ ច គឺស័ង្ខទក្ខិណាព័តផង មច្ឆា ច គឺត្រីផង យុគលំ តថា គឺត្រីគូៗផង សត្ត មហាគង្គា ច គឺស្ទឹងធំ ឬទន្លេទាំងប្រាំពីរផង សត្ត មហាសេលា ច គឺភ្នំទាំងប្រាំពីរផង មហាសរា ច គឺស្រះធំទាំងប្រាំពីរផង សុបណ្ណោ ច គឺគ្រុឌផង សំសុមារោ ច គឺក្រពើផង ធជបដាក មេវ ច គឺទង់ជ័យ និងទង់ជ្រុងផង បាដក្ខិ ច គឺអង្រឹងស្នែងផង វាលវីជនី ច គឺផ្លិតកន្ទុយសត្វ ឬរំសៃ កេលាសបព្វតោ តថា គឺភ្នំកៃលាសផង សីហរាជា ច គឺស្ដេចសីហៈផង ព្យគ្ឃរាជា ច គឺស្ដេចខ្លាផង វលាហកោ ច គឺសេះវលាហកផង ឧបោសថោ ច គឺដំរីឧបោសថផង ឆទ្ទន្តោ ច គឺដំរីឆទ្ទន្ត

វាសុកី នាគោ ច គឺនាគឈ្មោះវាសុកី (នាគពាំកែវ) ផង ហំសោ ច គឺហង្សផង ឧសភោ តថា គឺគោឧសភផង ឯរាវណោ ច គឺដំរីឯរាវ័ណផង មច្ឆោ ច គឺមង្គរផង ភមរោ ចេវ គឺភមរជាតិ (កន្លង់) ផង កុក្កុដោ ច គឺមាន់ផង សុវណ្ណកច្ឆបោ ចាបិ គឺអណ្តើកមាសផង ហរិនាវា ចតុម្មុខា ច គឺទូកមាសមានមុខបួនផង សវច្ឆកា តថា គាវី គឺមេគោ ព្រមទាំងកូនគោផង កិន្នរា ច គឺកិន្នរឈ្មោលផង កិន្នរី បិច គឺកិន្នរញីផង ករវិកោ ច គឺសត្វករវិកផង មយូរោ ច គឺក្ងោកផង កោញ្ចរាជា តថេវ ច គឺស្តេចក្រៀលផង ចក្កវាកនិដោ ចេវ គឺបក្សីចក្រពាក (ព្រហិត) ផង ជីវញ្ជីវកនាមកា ច គឺបក្សីមានឈ្មោះថា ជីវញ្ជីវក (សត្វប៉ោលគោក) ផង ឆកាមាវចរា ទេវា ច គឺកាមាវចរទេវលោក ៦ ជាន់ផង ព្រហ្មលោកា ច សោឡស គឺព្រហ្មលោក ១៦ ជាន់ផង ទិស្សរេ មាននៅប្រាកដ បាទេសុ នាព្រះបាទទាំងឡាយ យស្ស សម្មាសម្ពុទ្ធស្ស នៃព្រះសម្មាសម្ពុទ្ធអង្គណា មហេសិនោ ទ្រង់ស្វែងរកនូវគុណដ៏ធំមានសីលគុណ ជាដើមផង និច្ចំ ជានិច្ច អហំ វ៍ គឺខ្ញុំព្រះអង្គ វន្ទេ សូមថ្វាយបង្គំ តំ សម្មាសម្ពុទ្ធំ នូវព្រះសម្មាសម្ពុទ្ធអង្គនោះ បុរិសាសភំ ជាបុរសប្រសើរ ។

# សរសើរព្រះបាទ

**នមោស បាទយុគលំ នមាមិហំ**[១] ខ្ញុំសូមឱនអង្គ ក្រួញក្រាបអភិវាទ
ព្រះបាទពុទ្ធពង្ស ទាំងគូរ័ត្នរុង រឿងឫទ្ធិវង្សី ។
ខ្ញុំយកសិរសា ថ្វាយតាងបទុមា ទសង្គុលី តាងទៀនសុវណ្ណ
នេត្រាទាំងទ្វី ទុកតាងរស្មី ប្រទីបព្រោងព្រាយ ។
ខ្ញុំយកវាចា ថែងចេញពណ៌នា សរសើរព្រះលាយ- ល័ក្ខណ៍លើកតាងធូប
ក្រអូបសព្វសាយ ដូងចិត្តខ្ញុំថ្វាយ តាងរសគន្ធា ។
យកសព្វសព៌ាង្គ កាយគិតទុកតាង ពានមាសរចនា រាយរ័ត្នរុងរឿង
ថ្កល់គ្រឿងបូជា ថ្វាយព្រះបាទា ទាំងគូសោភ័ណ ។
ព្រះបាទលាយលក្ខណ៍ កើតកបកងចក្រ កែវកាំមួយពាន់ មានភ្លៅដែកងុំ
សូស្តិ៍សមសុវណ្ណ ឆ័ត្ររ័ត្នសោភ័ណ ទាល់ទូទិសទស ។
កង្វេរមាសស្អាត មានប្រាង្គប្រាសាទ ប្រសើរខ្ពង់ខ្ពស់ កើយកែវទៀងតាំង
បល្ល័ង្កស្រេចស្រស់ សឹងរ័ត្នទាំងអស់ ស្វេតច្ឆត្រព្រះខ័ន ។
មានផ្លិតតាលប័ត្រ នូវផ្លិតមោរហ័តក៏ វីជនីសុវណ្ណ លំពែងពេជ្រថ្លា
ធីតាដៃកាន់ ពពិលសោភ័ណ មកុដកែវមុនី ។
មានសយសង្វារ នៃបកែវពពាទ្យ កម្រងកែវភី ឆ័ត្រប្រាក់ឆ័ត្រមាស
ឱភាពិសី បាត្រកែវរូចី ឈូកឈរទ្រង់ផ្កា ។
ឧប្បលខៀវស មានថាសមាសល្អ ក្អមប្រាក់សុវណ្ណា ក្អមកែវប្រពៃ
នូវព្រៃហេមវា ត្រង់ផលបុប្ផា ចក្កវាឡខេត្តខ័ណ្ឌ ។
មានភ្នំព្រះសុមេរុ ភ្នំអណ្តាប់ហៃ ហៅសត្តបរិភ័ណ្ឌ ប្រាំពីរសង្កាត់
ហៅសត្តសីទន្ត័ ដុះរៀងដោយជាន់ សមុទ្ទជលធី ។

---

(១)- ចាកសាស្រ្តាស្លឹករឹត

ព្រះអាទិត្យព្រះចន្ទ្រ រះរុងរឿងរាន់ ឯកនភី កណ្ដាលហ្វូងផ្កាយ
ពណ្ណរាយរស្មី ទ្វីបធំធិបតី ទ្វីបតូចពីរពាន់ ។
មានខ្យងស័ង្ខសត្វ មានស្ដេចចក្រពត្តិ មានអាមាត្យពីរកាន់ ទង់ជ័យឆ័ត្រវត្ត
ប្រណិប័តន៍អភិវន្ទ ឥន្ទ្រព្រហ្មសោភ័ណ ឥសូរនារាយណ៍ ។
មានសត្តគង្គា និងមហាសេលា ស្រះស្រង់សប្បាយ ប្រាំពីរជាន់គត់
កំណត់ជ្រៅឆ្ងាយ ធេងធំទូលាយ រលោណៈសាគរា ។
ត្រីត្រាច់ពេញពាស ត្រីប្រាក់ត្រីមាស សុវណ្ណកច្ឆបា ក្រពើឆ្លាមម្ករ
ចរតាមជលសា មានភារភេត្រា សំពៅមាសប្រាក់ ។
គ្រុឌរាជនាគា កេសរសីហា ព្យគ្ឃរាជសិទ្ធិស័ក្តិ ដំរីរោងវ័ត្ត
ឧបោសថសោភគ្គ មានសេះពលាហ័ក នៅភ្នំហេមវ៉ា ។
ឈ្មោះកែវកៃលាស មានហេមហង្សមាស ចាក្រពាកកោញ្ចា ឯរាវ័ណនាគ
ដីវ៉ាកកិន្នរា កិន្នរីមេខលា សេកសោមបណ្ឌិត ។
ករវិកសត្វា មយូរីមយូរា ពង់ពេនពិចិត្រ មានទាំងស្ដេចត្មាត
ឃោរឃាតរីងឫទ្ធិ មានសត្វព្រហឹត ក្រហមឆ្អិនឆ្អៅ ។
មានទាំងសិង្គតោ ឈរឈានមានគោ ឧសភរាជនូវ មេគោសសុទ្ធ
មានបុត្របៀមបៅ មានប៉ានទិព្វហៅ សួគ៌ប្រាំមួយជាន់ ។
ព្រហ្មលោកសួគ៌សព្វ ប្រាំមួយដណ្ដប់ ពិមានសុវណ្ណ មានក្នុងព្រះបាទ
លោកនាថសោភ័ណ ប្រាកដជាក់ស្បាន់ មួយរយប្រាំបី ។
ព្រះត្រៃលោកនាថ យាងយាសព្រះបាទ ស្ដេចលើផែនដី ប្រោសសត្វសុសសព្វ
ភូមិភពបុរី ឈូកមាសផុសពី ផែនផែនពសុធា ។
ទទួលព្រះបាទ ព្រះមុនីនរនាថ ពិតកុំឃ្លាតឃ្លា ពុំឱ្យមានស្នាម
ទៅតាមមាគ៌ា ស្ដេចគង់អាស្នា ទើបអន្តរធាន ។
មានកាលពុំស្រួល ឈូកពុំទទួល ព្រះបាទថ្មើងថ្កាន ព្រះអង្គយាត្រា
ដោយមាគ៌ាប៉ាន ទៅទីទើបមាន វ៉ាយោជាត់ផាយ ។

ផាត់ផង់ធូលី នាំយកពីទី ព្រះបាទចេញឆ្ងាយ បែរបត់ផាយផាត់
ខ្ទាច់រ័ត្នរោយរាយ រោយឱ្យរលាយ រលុបបាត់បង់ ។
ស្ដេចយាងយាត្រា ចាកចេញកាលណា ស្មាមសោតពុំគង់ ពុំឱ្យសត្វផង
កន្លងត្រូវត្រង់ ព្រះបាទព្រះអង្គ កើតកម្មវេរា ។
ព្រះទសពលញ្ញាណ ជិតចូលនិព្វាន ទ្រង់មានមេត្តា ទេព្ដាសូត៌សព្វ
គន្ធព្វអសុរា គ្រុឌនាគទេព្ដា មនុស្សសត្វប្រុសស្រី ។
ទើបប្រោសប្រទាន ព្រះបាទប្រាំឋាន ទុកឱ្យវន្ទី បាទមួយនៅនា
ចមចុងគីរី សុវណ្ណមាលី ជាទីបរិសុទ្ធ ។
ព្រះបាទសោភា មួយនិត្យនៅនា សុវណ្ណបព៌ត បាទមួយនៅនា
លង្កាប្រាកដ លើភ្នំសន្មត សុមនកូដគាប់ ។
ព្រះបាទសោភ័ណ មួយនៅសច្ចព័ន្ធ គីរីស្រេចស្រាប់ អ្នកនគរស្រុក
យោនកសម្រាប់ រករៀបប្រដាប់ គ្រឿងគ្រប់បូជា ។
ព្រះបាទសោភី មួយនៅនទី នាមនម្មទា ព្រះអង្គដាន់ទុក
លើភក់ពសុធា ទុកឱ្យមច្ឆា គ្រូញក្រាបអភិវន្ទ ។
ព្រះទសពលញ្ញាណ ប្រោសប្រតិស្ឋាន ព្រះបាទសោភ័ណ ទាំងប្រាំថ្កើងថ្កល់
ឱ្យដល់ប្រាំពាន់ វស្សាគ្រប់គ្រាន់ ទើបស្ដេចនិព្វាន ។
ឱ!អស់យើងខ្ញុំ អភ័ព្វពេកពុំ ទាន់ព្រះទ្រង់ញាណ ទាន់តែសាសនា
ឯបាទាឋាន នោះសោតពុំបាន ទៅទៀបឱ្យយល់ ។
គ្រូញក្រាបកបកាយ បង្គំពីឆ្ងាយ សូធ្យសរសើរដល់ ព្រះបាទប្រាំឋាន
សូមមានមង្គល សូមសុខសួស្ដីសល់ តេជះជោគជ័យ ។
សូមឈ្នះលោភា ទោសាមោហោ ឧបទ្រពចង្រៃ គ្រោះកាចទុក្ខសោក
ទាំងរោគាភ័យ សូមសុខសព្វថ្ងៃ រៀងរូចនិព្វាន ។
អ្នកណាឧស្សាហ៍ រៀនលាយលក្ខណា ព្រះពុទ្ធបាទបាន ចេះចាំដាក់ជៀង
ទៀងទាត់មែនមាន ព្យាយាមប្រុងប្រាណ សូត្រសព្វវេលា ។

អ្នកនោះស្មើបាន ទាន់ព្រះទ្រង់ញាណ កាលគង់ធរមាន នឹងបានលះលាក
ចៀសចាកចតុរា បាយបាបវេរា កម្មកាចអាក្រក់ ។
បានមួយសែនកប្ប នឹងមិនដែលស្គាល់ ទុក្ខទោសលាមក ពុំរងវេទនា
នៅឋាននរក សឹងសេពសោយសុខ សោយសម្បត្តិបុណ្យ ។
បរិបូរណ៍រូបរាង សាយសព្វសព៌ាង្គ សារពើល្អល្អន់ ល្អលើសមនុស្សផង
ហ្មត់ហ្មងទ្រទន់ ទ្រទេសគួរគន់ គួរគិតស្នេហ៍ស្គាល់ ។
ចិត្តជាដឹងបុណ្យ ដឹងបាបដឹងគុណ ដឹងគួរដឹងការ ដឹងការក្បែរកោះ
ដឹងដោះដឹងសារ ដឹងសីលាចារ ដឹងអត្ថបាលី ។
កើតកបអម្បូរ អម្បាលត្រកូល ត្រកាលជាតិ ជាតិខត្តិយវង្ស
វិសេសធិបតី ធិបតិទ្ធឫទ្ធិ ឫទ្ធានុភាព ។
សព្វសក់ពេរី ទាំងទសទិសទី ប្រុងប្រើងប្រាណប្រាប ភ័ន្តទាំងភិតភ័យ
ក្រែងក្រៃក្រួញក្រាប រួញរារៀងរាប រុងរឿងថ្កើងថ្កល់ ។
ប្រុសប្រាជ្ញឈ្លាសឆ្លាត ចេះសព្វសិល្បសាស្ត្រ សារពើគតថ្កល់ លង់លុះនិព្វាន
សឹងបានដោយផល សូធ្យសរសើរដល់ ព្រះពុទ្ធបាទហោង ។

# ចប់

# នមស្ការព្រះពុទ្ធ ១០ ព្រះអង្គ
## ត្រាស់ដឹងក្នុងអនាគតកាល

មេត្តេយ្យោ នាគរុក្ខោ ច រាមពុទ្ធោបិ ចន្ទនំ ធម្មរាជា នាគរុក្ខោ សាលរុក្ខោ ធម្មសាមី ។ នារទោ ចន្ទនរុក្ខោ រង្សីមុនិ ច បិប្ផលិ ទេវទេវោ ច ចម្បកោ ចន្ទនរុក្ខោ ច បាតលិ ។ នរសីហោ ច និគ្រោធោ តិស្សពុទ្ធោ សុមង្គលោ នាគរុក្ខោ ឯតេ ទស រុក្ខា ពោធី ភវិស្សន្តិ ។ អនាគតេ ឥមេ ទស សម្ពុទ្ធេ យោ នរោ កប្បទសសតសហស្សានិ និរយំ សោ ន គច្ឆតិ ។

ខ្ញុំសូមបង្គំ គុណព្រះបរម សម្មាសម្ពុទ្ធ ទាំង១០ព្រះអង្គ
ក្នុងអនាគត សូមរួចចាកផុត ទុក្ខសោកភយា ។
ទី១ព្រះសិអារ្យ- មេត្រីថ្កើងបុណ្យបារមី ខ្ពស់លើលោកា ព្រះជន្មព្រះអង្គ
ប្រាំបីម៉ឺនវស្សា កំពស់ហត្ថា ប៉ែតសិបប្រាំបី ។
ដើមខ្ទឹងជាពោ- ធិព្រឹក្សសេដ្ឋោ ចាំងចែងរង្សី ផុសរ័ត្នបល្ល័ង្ក
ទីនាំងសួស្តី ស្តេចគង់សិរី ត្រាស់ធម្មទេសនា ។
ទី២ព្រះរាមខ្ពស់ខ្ពង់ ពូជពោធិវង្ស ត្រាស់ឡើងកាលណា ព្រះជន្មព្រះអង្គ
ប្រាំបួនម៉ឺនវស្សា ជាព្រះសម្មា- សម្ពុទ្ធរ័ត្ន ។
ព្រះកាយព្រះអង្គ ខ្ពង់ខ្ពស់លន្លង់ ដល់ប៉ែតសិបហត្ថ ដើមចន្ទន៍ក្រហម
ជាពោធិ៍ថ្កើងថ្កាត់ ក្លិនក្លែបផាយផាត់ រាយរុះដល់ដី ។
ផុសរ័ត្នបល្ល័ង្ក ជាព្រះទីនាំង ថ្វាយព្រះជិនស្រី ស្តេចគង់សោយសុខ
វិមុត្តិប្រពៃ ត្រាស់ដឹងធម៌ថ្លៃ ឥតមានចន្លោះ ។
ទី៣ព្រះបាទបសេន- ទិកោសលេន្ទ្រ ទ្រង់ត្រាស់ឡើងស្មោះ- ទ្រង់ព្រះនាមថា
ព្រះធម្មរាជឆ្ពោះ ព្រះជន្មអង្គនោះ ប្រាំបីម៉ឺនវស្សា ។

ព្រះកាយព្រះអង្គ ខ្ពង់ខ្ពស់ត្រយង់ ដប់ប្រាំមួយហត្ថា ដើមខ្លឹងជាពោ-
ធិព្រឹក្សសាខា ស្លោមស្លឹកបុប្ផ ក្រអូបអប់អង្គ ។
ផុសវ័ត្តបល្ល័ង្ក ភ្លឺផ្លេកបិតបាំង ព្រះសែងសុរិយង្គ ស្ដេចគង់ក្បៀមក្បាន្ត
ឥតព្រួយព្រះអង្គ ដរាបដល់ទ្រង់ ជាមហាមុនី ។
ទី៤មារាធិរាជ បានត្រាស់អង់អាច ជាព្រះសាមី ព្រះជន្មមួយសែន
ព្រះកាយជិនស្រី ខ្ពង់ខ្ពស់បារមី ដល់ប៉ែតសិបហត្ថ ។
ដើមសាលព្រឹក្ស ពោធិព្រឹក្សមហា ស្វេតច្ឆ័ត្រមានផ្កា រុះរោយថ្វាយថ្វាត់
ព្រះមហាសត្វ បល្ល័ង្កល្អក្ដាត់ ផុសក្រោមរុក្ខជាតិ ។
ថ្វាយព្រះអរហំ ជាព្រះទីនាំង ទែនទិព្វស្អាងស្អាត ដូចកែវព្រោងព្រាយ
ពណ្ណរាយលើសខ្ចាត ព្រះត្រៃលោកនាថ ទ្រង់ត្រាស់ទេសនា ។
ទី៥រាហូអសុរិន្ទ ជាវង្សទេវិន្ទ មានឫទ្ធិចេស្ដា បានត្រាស់រួចស្រេច
ទ្រង់ព្រះនាមថា នារទសាស្ដា មានបុណ្យបារមី ។
ព្រះជន្មព្រះអង្គ មួយម៉ឺនឆ្នាំទ្រង់ កាយកបវង្សី ខ្ពស់ម្ភៃហត្ថា
នៃព្រះជិនស្រី · ដើមចន្ទន៍ល្អក្រៃ ជាពោធិព្រឹក្ស ។
ផុសវ័ត្តបល្ល័ង្ក ឡើងជាទីនាំង ស្ដេចគង់ឥតភ្លឹក ទេវតាណាន់ណែន
ម៉ឺនសែនបីអធិក ព្រះអង្គរំលឹក បុព្វេវាសនា ។
ទី៦សោណព្រាហ្មណ៍ ទ្រង់ប្រសើរខ្ពស់ខ្ពង់ បានត្រាស់ឡើងជា ព្រះវង្សមុនី
មានព្រះជន្មា ប្រាំពាន់វស្សា ហុកសិបហត្ថគត់ ។
ដើមល្បៀបជាពោ- ធិព្រឹក្សសេដ្ឋា ថ្វាយអង្គពុទ្ធវ័ត្ត ផុសវ័ត្តបល្ល័ង្ក
ទីនាំងពែនព័ទ្ធ ភ្លឺផ្លេកច្រវាត់ ដូចកែវចរណៃ ។
ទី៧សុភព្រាហ្មណ៍អង្គ កសាងយូរលង់ ច្រើនអសង្ខេយ្យ ទ្រង់ត្រាស់ព្រះនាម
ទេវទេពថ្កើងក្រៃ ព្រះជន្មចមត្រៃ ប្រាំម៉ឺនវស្សា ។
ព្រះកាយព្រះអង្គ ខ្ពង់ខ្ពស់ឧត្តុង្គ ប៉ែតសិបហត្ថា ដើមចម្ប៉ាស
ផ្កាល្អបុប្ផ . ជាពោធិ៍សាខា ក្រអូបពេកក្រៃ ។

ផុសរ័ត្នបល្ល័ង្ក  ឡើងជាទីនាំង  ដូចកែវចរណៃ  ស្ដេចគង់ខ្ពង់ខ្ពស់
លើសលុបព្រឹក្សព្រៃ  អស់ទេពសួគ៌ថ្លៃ  គង់គាល់គារវៈ ។

ទី៨ព្រះគោតមេយ្យព្រាហ្មណ៍  ទ្រង់ត្រាស់ព្រះនាម  ព្រះនរសីហៈ  ព្រះជន្មព្រះអង្គ
ប៉ែតសិបឆ្នាំជាក់  ទ្រង់ជាពុំនាក់  សព្វសត្វនានា ។

ព្រះកាយព្រះអង្គ  ខ្ពង់ខ្ពស់ត្រចង់  ហុកសិបហត្ថា  ច្រនៀងជាពោ-
ធិព្រឹក្សថ្លៃថ្លា  ផ្សាយក្លិនបុប្ផ  អប់អង្គព្រះកាយ ។

ផុសរ័ត្នបល្ល័ង្ក  ឡើងជាទីនាំង  ស្ដេចគង់ឆើតឆាយ  ឥតមានអំពល់
ក្នុងព្រះអង្គកាយ  ទេវតាទាំងឡាយ  គាល់ព្រះចមត្រៃ ។

ទី៩នាឡាគីរី  ពូជពង្សពោធិ  សាងមកយូរក្រៃ  ប្រាថ្នានាំសត្វ
ឆ្លងកាត់ជលស័យ  ពោលគឺភពត្រៃ  ដល់ត្រើយអមតៈ ។

ត្រាស់ស្រេចព្រះអង្គ  ព្រះនាមចមពង្ស  ជាព្រះតិស្សៈ  ព្រះជន្មព្រះអង្គ
ប្រាំម៉ឺនឆ្នាំជាក់  ជាទីពំនាក់  សព្វមនុស្សទេព្តា ។

ព្រះកាយព្រះអង្គ  ប៉ែតសិបហត្ថទ្រង់  គួរទស្សនា  ដើមជ្រៃជាពោ-
ធិព្រឹក្សថ្លៃថ្លា  ស្លោមស្លឹកសាខា  ថ្វាយព្រះទ្រង់ញាណ ។

កើតរ័ត្នបល្ល័ង្ក  ថ្វាយជាទីនាំង  ស្ដេចគង់ក្សេមក្សាន្ត  រំលឹកធម៌ថ្លៃ
ញាណញេយ្យកល្យាណ  ទេវតាប្រមាណ  ច្រើនអសង្ខេយ្យា ។

គង់គាល់ព្រះអង្គ  ស្ដាប់ធម៌ស្ដេចទ្រង់  សំដែងទេសនា  ឱ្យបានជាផ្លូវ
ទៅកាន់ព្រះមហា  និព្វានសុខា  ឥតកើតស្លាប់ផង ។

ទី១០ដីវបាលិលេយ្យ  ស្ដេចមានញាណញេយ្យ  សាងច្រើនកប្បហោង  ប្រាថ្នាបានត្រាស់
ទេសនាចំឡង  នាំអស់សត្វផង  អនេកអនន្ត ។

ស្ដេចត្រាស់ឡើងថ្កល់  នាមព្រះសុមង្គល  ជាអង្គឯកអគ្គ  ព្រះជន្មព្រះអង្គ
មួយសែនឆ្នាំជាក់  ព្រះកាយកបល័ក្ខណ៍  ល្អឥតផ្ទឹមបាន ។

ខ្ពស់ហុកសិបហត្ថ  ប្រសើរពេកក្ដាត់  ព្រះអនាវរណញ្ញាណ  ដើមខ្ទឹងជាពោ-
ធិព្រឹក្សយោនយាន  ស្លឹកផ្កាជាឋាន  ចាំងសែងសុរិយា ។

ផ្កាវីកនៅនិត្យ ថ្វាយព្រះបពិត្រ អប់ព្រះកាយា ផុសវ័ត្ថបល្ល័ង្គ
ទីនាំងពេជ្រថ្លា ថ្វាយព្រះសាស្តា ជាគ្រួចម្បង ។ 
វីជនឯណា មានចិត្តជ្រះថ្លា ក្រែពេកកន្លង បានថ្វាយបង្គំ
នូវព្រះពុទ្ធផង ទាំងដប់នេះហោង ដូចបានរៀបរាប់ ។
ជននោះបានផល ច្រើនឥតផ្ទឹមដល់ ប្រសើរគួរគាប់ មិនធ្លាក់នរក
អស់សែននៃកប្ប ជាមនុស្សមានភ័ព្វ វាសនាខ្ពង់ខ្ពស់ ។
ខ្ញុំសូមនមស្ការ ព្រះសាស្តាចារ្យ ទាំងដប់ព្រះអង្គ សូមឱ្យខ្ញុំបាន
ឋានធំឧត្តុង្គ បានសុខឃូរលង់ គឺនិព្វានហោង ។

# ភាសិតោវាទសង្ខេប

ឧកាស ខ្ញុំសូមគោរព !

យោ បន[១] ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ

អ្នកឯណាមួយ ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ជាប្រក្រតី អ្នកនោះ ឈ្មោះថាធ្វើសក្ការៈ ធ្វើសេចក្តីគោរពរាប់អាន បូជានូវព្រះតថាគត ដោយបដិបត្តិបូជា ជាបូជាដ៏ឧត្តម ។

សព្វបាបស្ស អករណំ　　កុសលស្សូបសម្បទា
សចិត្តបរិយោទបនំ　　ឯតំ ពុទ្ធាន សាសនំ

កិរិយាមិនធ្វើនូវបាបទាំងពួង កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ ទាំងនេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

ខន្តិ បរមំ តបោ តីតិក្ខា
និព្វានំ បរមំ វទន្តិ ពុទ្ធា
ន ហិ បព្វជិតោ បរូបឃាតី
សមណោ ហោតិ បរំ វិហេឋយន្តោ

អំណត់គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់ថា ព្រះនិព្វានជាគុណជាតដ៏ឧត្តម អ្នកបួស ដែលបៀតបៀនសត្វដទៃ សម្លាប់សត្វដទៃ មិនមែនជាបព្វជិត មិនមែនជាសមណៈឡើយ ។

---

១- ច្បាប់ភាណវារៈខ្លះ យោ បន ភិក្ខុ ច្បាប់ខ្លះមានត្រឹមតែប៉ុណ្ណេះ ។

**អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ**

**មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ**

**អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ**

កិរិយាមិនតិះដៀល (អ្នកដទៃ) ១ កិរិយាមិនបៀតបៀន (អ្នកដទៃ) ១ កិរិយាសង្រួមក្នុងបាដិមោក្ខ ១ ភាវៈដឹងប្រមាណក្នុងភត្តាហារ ១ ទីដេក និងទីអង្គុយដ៏ស្ងាត់ ១ កិរិយាបំពេញព្យាយាមក្នុងអធិចិត្ត ១ ទាំងនេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

**សីលសមាធិគុណានំ ខន្តិ បធានការណំ**

**សព្វេបិ កុសលា ធម្មា ខន្ត្យាយត្តា វឌ្ឍន្តិ តេ**

សេចក្តីអត់ធន់ ជាហេតុជាទីតាំង នៃគុណគឺសីលនិងសមាធិទាំងឡាយ ធម៌ទាំងឡាយជាកុសលទាំងអស់នោះ តែងចម្រើនដោយសេចក្តីអត់ធន់មែនពិត ។

**កេវលានំបិ បាបានំ ខន្តិ មូលំ និកន្តតិ**

**គរហកលហាទីនំ មូលំ ខណតិ ខន្តិកោ**

សេចក្តីអត់ធន់ តែងកាត់បង់នូវឫសនៃបាបទាំងឡាយទាំងអស់ បុគ្គលអ្នកអត់ធន់ ឈ្មោះថាជីករំលើងនូវឫសនៃទោសទាំងឡាយ មានពាក្យតិះដៀលនិងការឈ្លោះប្រកែកជាដើម ។

**ខន្តិ ធីរស្សលង្ការោ ខន្តិ តបោ តបស្សិនោ**

**ខន្តិ ពលំ ច យតីនំ ខន្តិ ហិតសុខាវហា**

សេចក្តីអត់ធន់ ជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ សេចក្តីអត់ធន់ ជាគ្រឿងដុតបង់នូវបាបរបស់អ្នកដែលមានតបធម៌ សេចក្តីអត់ធន់ ជាកម្លាំងរបស់អ្នកប្រព្រឹត្តធម៌ សេចក្តីអត់ធន់ ជាគុណជាតិនាំមកនូវប្រយោជន៍ និងសេចក្តីសុខ ។

**ខន្តិកោ មេត្តវា លាភី យសស្សី សុខសីលវា**

**បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ**

អ្នកអត់ធន់ ជាអ្នកមានមិត្រសម្លាញ់ ជាអ្នកមានលាភ ជាអ្នកមានយស ជាអ្នកមានសេចក្ដីសុខជាប្រក្រតី អ្នកអត់ធន់ រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត នៃទេវតានិងមនុស្សទាំងឡាយ ។

អត្តនោបិ បរេសញ្ច អត្ថាវហោ ច ខន្តិកោ

សគ្គមោក្ខគមំ មគ្គំ អារុឡ្ហោ ហោតិ ខន្តិកោ

អ្នកអត់ធន់ ជាអ្នកនាំមកនូវប្រយោជន៍ដល់ខ្លួនឯងផង ដល់ជនទាំងឡាយឯទៀតផង អ្នកអត់ធន់ ជាអ្នកឡើងកាន់ផ្លូវជាទីទៅឋានសួគ៌ និងព្រះនិព្វាន ។

សត្ថុនោ វចនោវាទំ ករោតិយេវ ខន្តិកោ

បរមាយ ច បូជាយ ជិនំ បូជេតិ ខន្តិកោ

អ្នកអត់ធន់ ឈ្មោះថាធ្វើតាម នូវព្រះពុទ្ធដីកាជាឱវាទ នៃព្រះសាស្ដាមែនពិត អ្នកអត់ធន់ ឈ្មោះថាបូជានូវព្រះវិជិតមារ ដោយការបូជាដ៏ឧត្តម ។

ទុល្លភញ្ច មនុស្សត្តំ ពុទ្ធុប្បាទោ ច ទុល្លភោ

ទុល្លភា ខណសម្បត្តិ សទ្ធម្មោ បរមទុល្លភោ

ភាវៈកើតជាមនុស្ស គឺសត្វទាំងឡាយបានដោយកម្រ កិរិយាត្រាស់ជាព្រះពុទ្ធ គឺសត្វទាំងឡាយបានដោយកម្រ កិរិយាដល់ព្រមដោយខណៈ គឺបានកើតជួបនឹងព្រះពុទ្ធ ឬនឹងព្រះពុទ្ធសាសនា គឺសត្វទាំងឡាយបានដោយកម្រ ធម៌របស់សប្បុរស គឺសត្វទាំងឡាយបានដោយកម្រក្រៃលែង ។

សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា

សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ

កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្ដីសុខ កិរិយាសម្ដែងនូវធម៌របស់សប្បុរស នាំមកនូវសេចក្ដីសុខ សេចក្ដីព្រមព្រៀងគ្នារបស់សង្ឃ ឬពួកក្រុម

នាំមកនូវសេចក្ដីសុខ សេចក្ដីព្យាយាម របស់អ្នកដែលព្រមព្រៀងគ្នាទាំងឡាយ នាំមកនូវសេចក្ដីសុខ ។

សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ
អព្យាបជ្ឈំ សុខំ លោកេ បាណភូតេសុ សញ្ញមោ

សេចក្ដីស្ងប់ស្ងាត់ របស់អ្នកដែលត្រេកអរ (ក្នុងទីស្ងាត់) ជាអ្នកមានធម៌បានស្ដាប់ហើយ ពិចារណាឃើញ (នូវធម៌) នាំមកនូវសេចក្ដីសុខ កិរិយាមិនបៀតបៀន គឺកិរិយាសង្រួមចំពោះសត្វទាំងឡាយ នាំមកនូវសេចក្ដីសុខក្នុងលោក ។

សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ
អស្មិមានស្ស វិនយោ ឯតំ វេ បរមំ សុខំ

ភាវៈប្រាសចាករាគៈ គឺកិរិយាកន្លងនូវកាមទាំងឡាយ នាំមកនូវសេចក្ដីសុខក្នុងលោក កិរិយាធ្វើឱ្យវិនាសនូវអស្មិមានៈនេះឯង នាំមកនូវសេចក្ដីសុខដ៏ឧត្ដម ។

កិច្ឆោ មនុស្សប្បដិលាភោ កិច្ឆំ មច្ចាន ជីវិតំ
កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ

កិរិយាត្រឡប់បានអត្តភាពជាមនុស្ស ជាការលំបាក សេចក្ដីរស់នៅរបស់សត្វទាំងឡាយ ជាការលំបាក កិរិយាស្ដាប់នូវព្រះសទ្ធម្ម ជាការកម្រ កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ ជាការលំបាក ។

សត្ថុនោ សទ្ធម្មំ សុត្វា សព្វស្មិំ ជិនសាសនេ
កប្បានិ សតសហស្សានិ ទុគ្គតឹ សោ ន គច្ឆតិ

បុគ្គលឯណា បានស្ដាប់នូវព្រះសទ្ធម្មរបស់ព្រះសាស្ដា (ដែលរាប់បញ្ចូល) ក្នុងពាក្យប្រៀនប្រដៅនៃព្រះវិជិតមារទាំងពួង បុគ្គលនោះ រមែងមិនទៅកាន់ទុគ្គតិអស់សែនកប្ប ។

បុព្វណ្ហេ បិណ្ឌបាតញ្ច សាយណ្ហេ ធម្មទេសនំ
បទោសេ ភិក្ខុឱវាទំ អឌ្ឍរត្តេ ទេវបញ្ហនំ
បច្ចូសេវ គតេ កាលេ ភព្វាភព្វេ វិលោកនំ
ឯតេ បញ្ចវិធេ កិច្ចេ វិសោធេតិ មុនិបុង្គវោតិ

ព្រះសម្មាសម្ពុទ្ធ ជាចម្បងជាងអស់អ្នកប្រាជ្ញ ទ្រង់ជម្រះនូវពុទ្ធកិច្ចទាំងឡាយ ៥ ប្រការនេះ គឺក្នុងពេលព្រឹក ទ្រង់ស្ដេចទៅបិណ្ឌបាត ១ ក្នុងពេលល្ងាច ទ្រង់សម្ដែងធម៌ទេសនា ១ ក្នុងពេលព្រលប់ ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុ ១ ក្នុងពេលអាធ្រាត្រ ទ្រង់ដោះប្រស្នានៃទេវតា ១ ក្នុងពេលជិតភ្លឺ[១] ទ្រង់ប្រមើលមើលនូវឧបនិស្ស័យសត្វ ដែលគួរត្រាស់ដឹង និងមិនគួរត្រាស់ដឹង ១ ។

កុក្កុដេ គព្ភវាសោ ច សោណោ ចុតនិក្ខមិ
ឧសភេ រាជសម្បត្តិ សសេ បព្វជិតោ ជិនោ

ព្រះវិជិតមារ ទ្រង់យាងចុះមកអាស្រ័យនៅក្នុងព្រះគភ៌ (នៃព្រះវរមាតា) ក្នុងឆ្នាំរកា ទ្រង់ប្រសូតចាកព្រះគភ៌ក្នុងឆ្នាំច ទ្រង់សោយរាជ្យសម្បត្តិក្នុងឆ្នាំឆ្លូវ ទ្រង់ព្រះផ្នួសក្នុងឆ្នាំថោះ ។

កុក្កុដេ សព្វញ្ញូ ពុទ្ធោ តត្ថ ចក្កំ បវត្តយិ
និព្វានគមនំ សប្បេ សហស្សំ បញ្ច មូសិកេ

ទ្រង់ត្រាស់ដឹងជាព្រះសព្វញ្ញូពុទ្ធក្នុងឆ្នាំរកា ទ្រង់សំដែងព្រះធម្មចក្រក្នុងឆ្នាំនោះ ទ្រង់យាងចូលកាន់បរិនិព្វានក្នុងឆ្នាំម្សាញ់ ព្រះពុទ្ធសាសនានឹងគ្រប់ ៥.០០០ គត់ក្នុងឆ្នាំជូត ។

---

១- ក្នុងអដ្ឋកថាធម្មបទ សម្ដែងថាព្រះអង្គប្រមើលមើល ឧបនិស្ស័យសត្វក្នុង ១ ថ្ងៃ ១ យប់ ពីរដង គឺក្នុងពេលជិតភ្លឺម្ដង ពេលល្ងាចម្ដង ពេលជិតភ្លឺទ្រង់ប្រមើលមើល ពីកណ្ដាប់ចក្រវាឡ រហូតដល់គន្ធកុដិ ពេលល្ងាចទ្រង់ប្រមើលមើល ពីគន្ធកុដិ រហូតទៅកណ្ដាប់ចក្រវាឡ ។

ឱក្កន្តោ ច គរុវារស្មឹ　　សុក្រវារេ ច និក្ខមិ

សម្ពុទ្ធោ. ពុធវារស្មឹ　　អង្គារេ បរិនិព្វុតោ

ព្រះអង្គយាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃព្រហស្បតិ៍ ប្រសូតក្នុងថ្ងៃសុក្រ បានត្រាស់ជាព្រះសម្ពុទ្ធក្នុងថ្ងៃពុធ បរិនិព្វានក្នុងថ្ងៃអង្គារ ។

អាសាឡ្ហបុណ្ណមោក្កន្តោ　　វិសាខេយេវ និក្ខមិ

វិសាខបុណ្ណមី សម្ពុទ្ធោ　　វិសាខេ បរិនិព្វុតោ

ព្រះអង្គយាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃពេញបូណ៌មីខែអាសាឍ ប្រសូតក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បានត្រាស់ជាព្រះសម្ពុទ្ធ ក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បរិនិព្វានក្នុងថ្ងៃពេញបូណ៌មីខែវិសាខ ។

និព្វុតោ លោកនាថម្ហិ　　សម្ពុទ្ធេ អគ្គបុគ្គលេ

បដិមា ពោធិរុក្ខា ច　　ថូបា ច ជិនធាតុយោ

ចតុរាសីតិសហស្ស-　　ធម្មក្ខន្ធា សុទេសិតា

អគ្គបច្ចត្តនដ្ឋានេ　　ឋបិតា ហោន្តិ បាណិនំ

កាលព្រះសម្មាសម្ពុទ្ធ ជាអគ្គបុគ្គល ជាទីពឹងនៃសត្វលោក បរិនិព្វានទៅហើយ ព្រះបដិមាករផង ពោធិព្រឹក្សផង ព្រះស្តូបផង ព្រះជិនធាតុផង ព្រះធម៌ ៨ ហ្មឺន ៤ ពាន់ធម្មក្ខន្ធ ដែលព្រះអង្គទ្រង់សម្តែងហើយដោយប្រពៃផង ជាវត្ថុគឺព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក ក្នុងឋានដ៏ប្រព្រឹត្តទៅ ដើម្បីជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វទាំងឡាយ ។

ឥតិ សម្មាសម្ពុទ្ធេន　　ទេសិតំ ឱវាទំ ចិត្តេ

ឋបេត្វា សម្មាសម្ពុទ្ធេន　　ឧត្តប្បការេន បដិបត្តិ

បូជាយ បូជំ ករោន្តេន　　លោកិយលោកុត្តរ-

សម្បត្តិសិទ្ធំ ភាតព្វំ　　ឧកាស អារាធនំ ករោមិ

បុគ្គលគួរដំកល់នូវឱវាទ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្ដែងហើយទុកក្នុងចិត្ត ហើយធ្វើការបូជា ដោយបដិបត្តិបូជា ដោយនូវប្រការដែលព្រះសម្មាសម្ពុទ្ធត្រាស់សម្ដែងហើយ គួរធ្វើឱ្យសម្រេច នូវសម្បត្តិជាលោកិយៈនិងលោកុត្តរៈ ខ្ញុំសូមគោរពអារាធនាទុកដោយប្រការដូច្នេះ ។

## វិធីបកពុទ្ធសករាជ

ឱកាស សិរីសក្យមុនីសព្វញ្ញុពុទ្ធស្ស ពលចប្បច្ចុសសមយេ កុសិនារាយ យមកសាលានមន្តរេ អម្ហិ សប្បសំវច្ឆរេ គិម្ហឧតុម្ហិ វិសាខមាសេ សុក្កបក្ខេ បុណ្ណមសិយា តិថិយំ ភុម្មវារេ ភុម្មយាមេ អនុរាធនក្ខត្តទិវសេ បរិនិព្វានំ អហោសិ អនុបាទិសេសាយ និព្វានធាតុយា ។

ខ្ញុំសូមគោរព សម្ដេចព្រះសិរីសក្យមុនីសព្វញ្ញុពុទ្ធជាម្ចាស់ទ្រង់បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ក្នុងចន្លោះដើមសាលព្រឹក្សទាំងគូជិតក្រុងកុសិនារា ក្នុងសម័យដ៏មានកំលាំង ក្នុងថ្ងៃនៃនក្ខត្តឫក្ស ឈ្មោះអនុរាធា ក្នុងថ្ងៃអង្គារ យាមអង្គារ ជាតិថីពេញបូណ៌មី ខាងខ្នើត ខែវិសាខ ក្នុងគិម្ហរដូវ ឆ្នាំម្សាញ់ឯណោះហោង ។

តស្ស ភគវតោ សម្មាសម្ពុទ្ធស្ស បរិនិព្វុតទិវសតោ បដ្ឋាយ យាវជ្ជតនា ចតុទ្ទសទិវសុត្តរទសមាសាធិកា អដ្ឋ សត្តតិសំវច្ឆរុត្តរ-ចតុស្សតាធិកានិ ទ្វេ សំវច្ឆរសហស្សានិ អតិក្កន្តានិ អហេសុំ ។

ឥមស្មឹ បច្ចុប្បន្នកាលេ សូករសំវច្ឆរេ គិម្ហឧតុម្ហិ ផល្គុណមាសេ កាឡបក្ខេ បណ្ណរសិយា តិថិយំ រវិវារេ អនាគតេ កាលេ បណ្ណរសទិវសុត្តរឯកមាសាធិកឯកវីសតិសំវច្ឆរុត្តរបញ្ចសតាធិកានិ ទ្វេ សំវច្ឆរសហស្សានិ ភវិស្សន្តិ ។

សូមគោរពរំលឹក ដល់កាលដែលព្រះសក្យមុនីសព្វញ្ញុពុទ្ធទ្រង់មានសិរី ព្រះអង្គចូលនិព្វានហើយដោយអនុបាទិសេសនិព្វានធាតុ ក្នុងថ្ងៃប្រកបដោយនក្ខត្តឫក្ស ក្នុងថ្ងៃអង្គារ យាមអង្គារ នៅថ្ងៃ ១៥ កើត ខែពិសាខ ក្នុងគិម្ហរដូវ ឆ្នាំម្សាញ់ឯណោះ ក្រោមចន្លោះមែកសាលព្រឹក្សទាំងគូ ទោសាលវ័នឧទ្យាន ជិតក្រុងកុសិនារាក្នុងសម័យជិតភ្លឺ ។

រាប់ចាប់ដើមតាំងអំពីថ្ងៃ ដែលព្រះសម្មាសម្ពុទ្ធមានព្រះភាគអង្គនោះ ទ្រង់ចូលបរិនិព្វានទៅហើយ ដរាបមកដល់សព្វថ្ងៃនេះ ព្រះពុទ្ធសាសនាអតិក្កន្តនិកន្លងទៅបាន ២៤៧៨ ឆ្នាំ ១០ ខែ និង ១៤ ថ្ងៃ ។

បច្ចុប្បន្នឥឡូវនេះ នៅក្នុងឆ្នាំកុរសប្តស័ក គិម្ហរដូវ ខែផល្គុន ១៥ រោច ថ្ងៃអាទិត្យ (ថ្ងៃ ខែ ឆ្នាំ នេះលោកកំណត់ថាជាបច្ចុប្បន្នកាល) ។

**អនាគតេកាលេ** ចំណែកខាងអនាគត ព្រះពុទ្ធសាសនកាល នៅសល់ ២៥២១ ឆ្នាំ ១ ខែ និង ១៥ថ្ងៃ បើរួបរួម ថ្ងៃ ខែ ឆ្នាំ ទាំង ៣ កាល ត្រូវជាព្រះពុទ្ធសាសនកាល គ្រប់ចំនួន ៥០០០ វស្សា ដោយបរិបូណ៌ហោង ។

**<u>កំណត់ចំណាំ</u>**

-ចូលឆ្នាំពុទ្ធសករាជ ថ្ងៃ១៤, ១៥កើត និង ១រោជ ខែ វិសាខ ជារៀងរាល់ឆ្នាំ ។

-ចូលឆ្នាំមហាសករាជ ថ្ងៃ១៤, ១៥កើត និង ១រោជ ខែ កត្តិក ជារៀងរាល់ឆ្នាំ ។

-ចូលឆ្នាំចុល្លសករាជ ថ្ងៃទី១៣ ឬ១៤ និងទី១៥, ទី១៦ ខែមេសា ជារៀងរាល់ឆ្នាំ។

-ចូលឆ្នាំគ្រិស្តសករាជថ្ងៃ ២៩-៣០-៣១ ខែ ធ្នូ ជារៀងរាល់ឆ្នាំ ។

ដោយៈ ឧទ្ទេសាចារ្យ

ប្រាត់ ឃុន

# បរាភវសូត្រ

## បទ បឋ្យាវត្ត

( ទេវតាទូលសួរព្រះសាស្តាថា )

បរាភវន្តំ បុរិសំ　　មយំ បុច្ឆាម គោតមំ
ភគវន្តំ បុដ្ឋុមាគម្ម　　កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយមកសូមទូលសួរ　　នូវហេតុដែលគួរចំរើនវិនាស
ប្រុសស្រីក្នុងលោកសន្និវាស　　ដែលនឹងវិនាសសាបសូន្យចាកគុណ ។
ឆ្ពោះព្រះគោតមព្រះអង្គមានបុណ្យ　　មេត្តានិមន្តសំដែងឱ្យទាន
ធម្មជាតិដូចម្តេចដែលជាប្រធាន　　នាំសត្វឱ្យមានសេចក្តីវិនាស ។

( ព្រះសាស្តា ឆ្លើយតបនឹងទេវតាថា )

សុវិជានោ ភវំ ហោតិ　　សុវិជានោ បរាភវោ
ធម្មកាមោ ភវំ ហោតិ　　ធម្មទេស្សី បរាភវោ ។

អ្នកដែលចំរើនតថាគតស្គាល់ងាយ　　អ្នកដែលអន្តរាយតថាគតស្គាល់ពិត
អ្នកប្រាថ្នាធម៌ល្អិតល្អក្នុងចិត្ត　　ហើយខំប្រព្រឹត្តនឹងបានចំរើន
អ្នកដែលទ្រុស្តធម៌ស្អប់ធម៌ឥតកើន　　ឥតកើតចំរើនវិនាសទៅមុខ ។

ឥតិ ហេតំ វិជានាម　　បឋមោ សោ បរាភវោ
ទុតិយំ ភគវា ព្រូហិ　　កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង　　វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ　　វិនាសនោះឈ្មោះ ទី ១ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត　　សូមទ្រង់និមន្តសំដែងឱ្យទាន
វិនាសទី ២ អ្វីជាប្រធាន　　នាំសត្វឱ្យមានសេចក្តីវិនាស ។

អសន្តស្ស បិយា ហោន្តិ　　សន្តេ ន កុរុតេ បិយំ
អសតំ ធម្មំ រោចេតិ　　តំ បរាភវតោ មុខំ ។

អ្នកដែលស្រឡាញ់ពេញចិត្តស្នេហា រតែនឹងមនុស្សណោអសប្បុរស
តែងមិនស្រឡាញ់ពេញចិត្តទាំងអស់ នឹងអ្នកសប្បុរសមកធ្វើជាមិត្រ ។
សេចក្តីស្រឡាញ់ពេញចិត្តគំនិត ហើយទៅគប់មិត្រអសប្បុរស
គាប់ចិត្តក្នុងធម៌ឬមួយរបស់ ហេតុនោះទាំងអស់នាំឱ្យវិនាស ។

ឥតិ ហេតំ វិជានាម ទុតិយោ សោ បរាភវោ
តតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ៗ

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្រ្គោះ វិនាសនោះឈ្មោះ ទី ២ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន
វិនាសទី ៣ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

និទ្ទាសីលី សភាសីលី អនុដ្ឋាតា ច យោ នរោ
អលសោ កោធបញ្ញាណោ តំ បរាភវតោ មុខំ ៗ

អ្នកដេកច្រើនមួយនិយាយច្រើនមួយ នឹងអ្នកឥតព្រួយឥតគិតប្រឹងប្រែង
អ្នកខ្ជិលច្រអូសមិនមានខ្នះខ្នែង ១ ខឹងច្រើនសំដែងឱ្យគេឃើញបាន ។
ហេតុធម៌ទាំងនោះមិនជាកល្យាណ ៤ នាំឱ្យខកខានខាតខូចប្រយោជន៏
មានជាប្រធានតិចច្រើនដោយហោច នាំបង់ប្រយោជន៍ហើយឱ្យវិនាស ។

ឥតិ ហេតំ វិជានាម តតិយោ សោ បរាភវោ
ចតុត្ថំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ៗ

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្រ្គោះ វិនាសនោះឈ្មោះ ទី ៣ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន
វិនាសទី ៤ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

យោ មាតរំ វា បិតរំ វា ជិណ្ណកំ គតយោព្វនំ

បហុសន្តោ ន ភរតិ តំ បរាភវតោ មុខំ ។

នរជនណាមានទ្រព្យធនធាន ហើយខ្លួនមិនបានចិញ្ចឹមរក្សា

មាតាបិតាដែលចាស់ជរា ហេតុនោះទៅជានាំឱ្យវិនាស ។

ឥតិហេតំ វិជានាម ចតុត្ថោ សោ បរាភវោ

បញ្ចមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ

ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ៤ ទាន់ហន់ ។

បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន

វិនាសទី ៥ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

យោ សមណំ ព្រាហ្មណំ វា អញ្ញំ វាបិ វនិព្វកំ

មុសាវាទេន វញ្ចេតិ តំ បរាភវតោ មុខំ ។

ជនបញ្ឆោតព្រាហ្មណ៍ឬពួកសមណៈ ពួកស្មូមឬអ្នកដទៃៗ

ដោយមុសាវាទឃ្លាតពាក្យប្រពៃ នោះប្រធាននៃសេចក្តីវិនាស ។

ឥតិហេតំ វិជានាម បញ្ចមោ សោ បរាភវោ

ឆដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ

ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ៥ ទាន់ហន់ ។

បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន

វិនាសទី ៦ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

បហុតវិត្តោ បុរិសោ សហិរញ្ញោ សភោជនោ

ឯកោ ភុញ្ជតិ សាទូនិ តំ បរាភវតោ មុខំ ។

បុរសអ្នកមានទ្រព្យធនធានច្រើន មាសប្រាក់ចំរើននឹងគ្រឿងអាហារ
លបលាក់របស់ដែលឆ្ងាញ់ពិសា ស៊ីម្នាក់ឯងជាប្រធានវិនាស ។

ឥតិហេតំ វិជានាម ឆដ្ឋមោ សោ បរាភវោ
សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើកាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ៦ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន
វិនាសទី ៧ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ច យោ នរោ
សញ្ញាតឹ អតិមញ្ញេតិ តំ បរាភវតោ មុខំ ។

អ្នកដែលប្រកាន់ទ្រព្យជាតិត្រកូល ហើយមិនប្រមូលសាច់ញាតិសន្តាន
មើលងាយញាតិខ្លួនដោយអាងខ្លួនមាន នោះជាប្រធានសេចក្តីវិនាស ។

ឥតិហេតំ វិជានាម សត្តមោ សោ បរាភវោ
សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើកាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ៧ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន
វិនាសទី ៨ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ
លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ ។

ជនអ្នកប្រព្រឹត្តល្បែង ៣ ប្រការ ល្បែងស្រីល្បែងស្រាល្បែងភ្នាល់ទាំងឡាយ
ធ្វើទ្រព្យខ្លួនមានឱ្យអន្តរាយ ការល្បែងទាំងឡាយនោះនាំវិនាស ។

ឥតិហេតំ វិជានាម អដ្ឋមោ សោ បរាភវោ

សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ

ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ៨ ទាន់ហន់ ។

បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន

វិនាសទី ៩ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

សេហិ ទារេហិ អសន្តុដ្ឋោ វេសិយាសុ បទុស្សតិ

ទុស្សតិ បរទារេសុ តំ បរាភវតោ មុខំ ។

ប្រុសមិនត្រេកអរនឹងប្រពន្ធខ្លួន ហើយទៅជាប់ជូននឹងស្រីពេស្យា

ទ្រុស្តនឹងប្រពន្ធកូនជននានា ហេតុនោះទៅជានាំឱ្យវិនាស ។

ឥតិហេតំ វិជានាម នវមោ សោ បរាភវោ

សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ

ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ៩ ទាន់ហន់ ។

បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន

វិនាសទី ១០ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

អតីតយោព្វនោ បោសោ អានេតិ តិម្ពរុត្ថនឹ

តស្សា ឥស្សា ន សុបតិ តំ បរាភវតោ មុខំ ។

បុរសដែនមានវ័យចាស់ហួសពេក ហើយមានតម្រេកដោយក្តីតណ្ហា

នាំយកស្រីក្មេងមកធ្វើភរិយា ហេតុនោះទៅជានាំឱ្យវិនាស ។

ឥតិហេតំ វិជានាម ទសមោ សោ បរាភវោ

សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ
គឺវិនាសនេះបើរាប់សង្រ្គោះ វិនាសនោះឈ្មោះ ទី ១០ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន
វិនាសទី ១១ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

ឥត្ថឹ សោណ្ឌឹ វិកិរណឹ បុរិសំ វាបិ តាទិសំ
ឥស្សរិយស្មឹ ឋបេតិ តំ បរាភវតោ មុខំ ។

បុរសតាំងស្រីអ្នកលេងខ្ជះខ្ជាយ ឬស្រីទាំងឡាយតាំងបុរសនោះ
ដែលជាអ្នកលេងខ្ជះខ្ជាយដូច្នោះ អំពើទាំងនោះនាំឱ្យវិនាស ។

ឥតិហេតំ វិជានាម ឯកាទសមោ សោ បរាភវោ
សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ
គឺវិនាសនេះបើរាប់សង្រ្គោះ វិនាសនោះឈ្មោះ ទី ១១ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន
វិនាសទី ១២ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

អប្បភោគោ មហាតណ្ហោ ខត្តិយេ ជាយតេ កុលេ
សោ ច រជ្ជំ បត្ថយតិ ! តំ បរាភវតោ មុខំ ។

ជនណាកើតក្នុងត្រកូលជាក្សត្រ អ្នកក្រសម្បត្តិហើយប្រាថ្នាធំ
ចង់បានជាស្តេចសោយរាជស្តុកស្តម្ភ ហេតុនោះនឹងនាំឱ្យដល់វិនាស ។

ឯតេ បរាភវេ លោកេ បណ្ឌិតោ សមវេក្ខិយ
អរិយោ ទស្សនសម្បន្នោ ស លោកំ ភជតេ សិវំ ។

ជនជាបណ្ឌិតគំនិតប្រសើរ បានឃើញដំណើរនៃហេតុវិនាស
ដល់សត្វក្នុងលោកសន្និវាស គេចពីវិនាសគប់រកចំរើន ។

(បរាភវសុត្តំ និដ្ឋិតំ)

# នាមពុទ្ធបរិស័ទចូលបច្ច័យបោះពុម្ពសៀវភៅធម៌

| | |
|---|---|
| ឧបាសិកា ខាំ ផៃ ព្រមទាំងកូនចៅ | $3000 |
| អ្នកស្រី អ៊ូច ច័ន្ទសុក ព្រមទាំងបុត្រាបុត្រី | $3000 |
| ឧបាសិកា កែវ និត ព្រមទាំងកូនចៅ | $1000 |
| លោក ត្រាន លីន្ទ | $1000 |
| លោក ង៉ូវ ហុក និងភរិយា ព្រមទាំងបុត្រ | $1000 |
| ឧបាសិកា ជុំ សាគុណ ព្រមទាំងកូនចៅ | $550 |
| ឧបាសិកា ជា ស៊ុនអ៊ី ព្រមទាំងកូនចៅ | $350 |
| ឧបាសិកា ស៊ីវ ឡៃហ៊ាង និងគ្រួសារ ព្រមទាំងកូនចៅ | $250 |
| ឧបាសិកា សួស ជួន ព្រមទាំងកូនចៅ | $100 |
| អ្នកស្រី ទុំ សារឿន | $20 |
| អ្នកស្រី ម៉ម សេរី និងគ្រួសារ ព្រមទាំងកូនចៅ | $20 |
| ឧបាសិកា ព្រហ្ម ថុង ព្រមទាំងកូនចៅ | $50 |
| ឧបាសិកា ប៊ុល ភាង ព្រមទាំងកូនចៅ | $50 |
| ឧបាសិកា ហេង ហៀង ព្រមទាំងកូនចៅ | $50 |
| ឧបាសិកា កែវ សារ៉េត ព្រមទាំងកូនចៅ | $50 |
| ឧបាសិកា គីម ត្រី ព្រមទាំងកូនចៅ | $50 |
| ឧបាសិកា អ៊ូ សារី ឧបាសក គង់ សាធ ព្រមទាំងកូនចៅ | $100 |
| ឧបាសិកា ទៀ ថៅហ៊ាង ព្រមទាំងកូនចៅ | $50 |
| ឧបាសិកា យីម សុខឿន ព្រមទាំងកូនចៅ | $50 |
| លោក សុត ស៊ុន្ទី អ្នកស្រី យីម សម្បត្តិ ព្រមទាំងបុត្រ | $50 |
| ឧបាសិកា ស៊ូ អេម ព្រមទាំងកូនចៅ | $30 |
| ឧបាសិកា ធម្ម នីរុន ព្រមទាំងកូនចៅ | $50 |
| ឧបាសិកា ប៊ុល ណាត ព្រមទាំងកូនចៅ | $30 |

| | |
|---|---|
| ឧបាសិកា បែន យាន ព្រមទាំងកូនចៅ | $220 |
| ឧបាសិកា ឆុម ស៊ុម ព្រមទាំងកូនចៅ | $200 |
| ឧបាសិកា សួស សារឿន ឧបាសក ឃឹម យុន ព្រមទាំងកូនចៅ | $50 |
| ឧបាសិកា ស្វ ផេង ព្រមទាំងកូនចៅ | $100 |
| ឧបាសិកា នួន សុខុម ព្រមទាំងកូនចៅ | $125 |
| ឧបាសិកា អ៊ុក ណាភ និងគ្រួសារ ព្រមទាំងកូនចៅ | $50 |
| ឧបាសិកា ជា តឹម ព្រមទាំងកូនចៅ | $40 |
| ឧបាសិភា ឃិន សង ព្រមទាំងកូនចៅ | $50 |
| លោក កែវ ប៊ុនឆាយ | $40 |
| ឧបាសិកា មោក មី ព្រមទាំងកូនចៅ | $60 |
| ឧបាសិកា ឡុង សារុន ព្រមទាំងកូនចៅ | $150 |
| ឧបាសិកា តឹក សារឿន ព្រមទាំងកូនចៅ | $100 |
| លោក ហុង សាហ៊ូ និងគ្រួសារ ព្រមទាំងកូនចៅ | $100 |
| ឧបាសិកា ប៉ុក សុគន្ធា ព្រមទាំងកូនចៅ | $216 |
| លោក តន់ អឿន អ្នកស្រី ស្វាយ ទីម ព្រមទាំងកូនចៅ | $50 |
| វ័ត្ត ចន្ទដារា, សាំង ឡេង និង សាយ សុគន្ធី, សាយ សុជន និងអ៊ូ សារិន, អ៊ុង ប៊ុនអេង និង លីម សុះង៉ែត | $50 |
| ឧបាសិកា ព្រាប វិម ព្រមទាំងកូនចៅ | $200 |
| បង សុភាព និងគ្រួសារ | $20 |
| អ្នកស្រី សុខ ប៊ុនឆេន | $20 |
| លោក លឹម ប៊ុនផាត និងគ្រួសារ ព្រមទាំងបុត្រ | $50 |
| អ្នកស្រី ឃឹម គី | $10 |
| អ្នកស្រី ហ៊ុ អូន | $20 |
| បង ពេជ្រ ពៅ | $15 |
| អ្នកស្រី ហាង ស៊ីវជាវ និងគ្រួសារ ព្រមទាំងបុត្រ | $50 |

| | |
|---|---|
| អ្នកស្រី ទូច អៀវ | $10 |
| លោក ឌី ចាបសាយ និងគ្រួសារ ព្រមទាំងបុត្រ | $50 |
| លោក឵ ឆាយ លី | $10 |
| ឧបាសិកា អៀ សៃវ៉ូច ព្រមទាំងកូនចៅ | $20 |
| ឧបាសិកា អៀ សៃស៊ុំ ព្រមទាំងកូនចៅ | $20 |
| ឧបាសិកា គាត ជាវ ព្រមទាំងកូនចៅ | $50 |
| ឧបាសក សូវ អេងឡុង និងគ្រួសារ ព្រមទាំងបុត្រ | $50 |
| ឧបាសក ជួន សំ និងគ្រួសារ ព្រមទាំងបុត្រ | $10 |
| លោក លឿម សឿ និងគ្រួសារ ព្រមទាំងបុត្រ | $20 |
| អ្នកស្រី លីម វ៉ូចឡាំង និងគ្រួសារ ព្រមទាំងបុត្រ | $50 |
| ព្រះតេជគុណ នូ សុធា | $50 |
| ព្រះតេជគុណ ឆាយ ឆាយ | $100 |
| ឧបាសក ញ៉ិក ឈួម និងគ្រួសារ ព្រមទាំងបុត្រ | $50 |
| ឧបាសិកា លីម ឈីវយី | $100 |
| លោក សោ ស៊ីណេត អ្នកស្រី សោ ផារ៉ែន ព្រមទាំងបុត្រ | $20 |
| ឧបាសិកា ផេង ជឹង | $20 |
| ស សារី និងកូនចៅ | $50 |
| ឧបាសក តឿ ព្រិម ឧបាសិកា សួន ចាន់ និងកូនចៅ | $50 |
| ឧបាសក ជា ជួន និងគ្រួសារ | $50 |
| ឧបាសិកា យន ណៃគាវ | $50 |
| លោក ហឿង យ៉ា និងគ្រួសារ | $50 |
| ជា សាវឿន | $50 |
| ហ្វង់ ជី | $60 |
| សូ ផលាមុនី | $10 |
| ភ៉ាន់ លីនដា, មួន + ស ថានី ព្រមទាំងកូនចៅ | $50 |

| | |
|---|---|
| ហែម សារ៉េន | $50 |
| ឧបាសក ម៉ម អុន ឧបាសិកា សុខ ហឿន ព្រមទាំងកូនចៅ | $115 |
| សារិន ជាវ | $50 |
| ហេង ទ្រីតា និងភរិយា, លី ហួយហ្គិច | $50 |
| លោក ជា តិចហុង និងភរិយា | $25 |
| ខា ណារ៉េត និងភរិយា | $10 |
| អឿន ង៉ិម | $50 |
| លោកអាចារ្យ ពេជ្រ ម៉ុន និងគ្រួសារ ព្រមទាំងកូនចៅ | $50 |
| អ៊ីប រីន, សំអាន, សំអាត និង មៀត សាខឿម | $50 |
| ង៉ូវ អៀងចេង | $10 |
| ង៉ូវ អៀងមួយ | $10 |
| លោក វ៉ែក អង អ្នកស្រី ប៉ាន សាមុត ព្រមទាំងបុត្រ | $200 |
| ឧបាសក សំ ហំ និងគ្រួសារ | $20 |
| ង៉ែត | $20 |
| ឧបាសិកា គូ សុខា ព្រមកូនចៅ | $50 |
| ញ៉ែម រឿន, ម៉ាឡែន, ចន្ទឡុយ, ញ៉ែម សាវេទ, ដេវីត, សាវ៉ន, សារិន, | $70 |
| យាយ ឡេង | $10 |
| លោកយាយ៉ិ អៀន ណយ ព្រមទាំងកូនចៅ | $75 |
| យាយ រិន, ស៊ុនទី | $20 |
| សួង សាខន | $20 |
| សួង ផេង | $20 |
| យ៉ត ធូ | $10 |
| ហឿង គៀន | $5 |
| លោក ង៉ូវ ឡេង និងគ្រួសារ | $200 |

ការផ្សាយសៀវភៅ នេះជា eBook បាន បង្កើតឡើងដោយ

មូលនិធិខ្មែរសម្រាប់ការសិក្សា **និង** ករុណាខ្មែរ

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ សៀង ស៊ីវ៉ាន់

សីហា ឆ្នាំ ២០១៥

គាំទ្រដោយ កូនប្រុស ស្រី

លោក ស៊ី ដារា និងលោកស្រី សុន ដារី ព្រមទាំងលោកស្រី បុប្ផា ដឹឡូប៉ែស

ដើម្បី ឧទិសកុសល ដល់វិញ្ញាណក្ខន្ធ

លោកឪពុក សង្វារ ដឺ ឡូប៊ីស និងលោកម្ដាយ ឌិន សៅខុន

សូមអរគុណ

ខៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org